# អដ្ឋកថា ព្រះសុត្តន្តបិដក

## សុមង្គលវិលាសិនី

## បញ្ចមភាគ

## ភាគ ១៨

ពុទ្ធសករាជ ២៥៥៣

# អដ្ឋកថា ទីឃនិកាយ

## នៃព្រះសុត្តន្តបិដក

## បាដិកវគ្គវណ្ណនា បញ្ចមភាគ

## ភាគ ១៨

ឈ្មោះ

# សុមង្គលវិលាសិនី

ពុទ្ធសករាជ ២៥៥៣

អធិប្បាយ

**បាដិកសូត្រ-ឧទុម្ពរិកសូត្រ-ចក្កវត្តិសូត្រ-អគ្គញ្ញសូត្រ-សម្បសាទនីយសូត្រ-បាសាទិកសូត្រ**

A

# Signes et accents:



# ស្រះពេញតួ

## Voyelles:

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| ឡូប Romain | a | . ā | i | i | u | ū | e | o |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ
# *Consonnes.*

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| រូប Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ກ | ຂ | ຄ | ຆ | ງ |
| សង្ហ Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

# D

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຊ | ຍ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

E


Cambodgien
Romain
ṭ ṭh ḍ ḍh ṇ
Siamois
Laotien
Cinghalais
Birman

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ត្ត | ថ្ថ | ទ្ទ | ធ្ធ | ន្ន |
| Romain | *t* | *th* | *d* | *dh* | *n* |
| សៀម Siamois | ต | ถ | ท | ธ | น |
| លាវ Laotien | ຕ | ຖ | ທ | ດ | ນ |
| Cinghalais | ත | ථ | ද | ධ | න |
| ភូមា Birman | တ | ထ | ဒ | ဓ | န |

G

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ប | ផ | ព | ភ | ម |
| [illegible] Romain | *p* | *ph* | *b* | *bh* | *m* |
| សៀម Siamois | ป | ผ | พ | ภ | ม |
| លាវ Laotien | ປ | ຜ | ພ | ຠ | ມ |
| [illegible] Cinghalais | ප | ඵ | බ | භ | ම |
| ភូមា Birman | ပ | ဖ | ဗ | ဘ | မ |

H


CAMBODGIEN
Romain
y r l v s h ḷ ṃ
Siamois
Laotien
Cinghalais
Birman

# ពាក្យផ្តើម

*ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖*

***សុត្ត*** *បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។*

***គេយ្យ*** *បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។*

***វេយ្យាករណ*** *គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមាន គាថា និងពុទ្ធវចនៈ ដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។*

***គាថា*** *គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។*

***ឧទាន*** *គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្តែងដោយសោមនស្សញ្ញាណ ។*

*ឥតិវុត្តក គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្តើមឡើងដោយពាក្យថា សេចក្តីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។*

***ជាតក*** *គឺ ជាការសម្តែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។*

***អព្ភូតធម៌*** *គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។*

*វេទល្ល* គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស់ ព្រមទាំងបាននូវសេចក្ដីរីករាយ និង*សួរជាបន្ត ៗ ទៅ* ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្ដែងថា ៖

**ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម**
**ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត**
**មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល**
**បណ្ឌិតគប្បីដឹងបាន ។**

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្ដីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទឹកដីផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្ដែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគ មាន ៣ ប្រការ គឺ ៖

**១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង** ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

**២ ទ្រង់សម្ដែងធម៌មានហេតុផល** ដែលអ្នកស្ដាប់អាចពិចារណាឃើញតាម

សេចក្តីពិតបាន ។

៣ **ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ** គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់ បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថាការបានស្តាប់នូវពុទ្ធោវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដកនូវសេចក្តីដែលលំបាកយល់ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ **ព្រះសូត្រ** គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-

បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

**២ សុត្តានុលោម** គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយសេចក្តីដែលលំបាកក្នុងព្រះត្រៃបិដក ។

**៣ អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និងបុព្វាចារ្យជំនាន់ក្រោយ ៗ ។

**៤ អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្តែងធម៌ក្នុងព្រះពុទ្ធសាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយច្រើន ទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹងក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដក ប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនីងជំទាស់

ដល់ច្បាប់វដ្តធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថា ធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ  ប្រតិស្ឋានក្នុងហឫទ័យ
របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្តីចម្រើនក្នុងព្រះធម៌  ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្តីសង្ខេបថា ក្នុងទីបំផុតនៃការសម្តែងយមកប្បាដិហារ្យ ព្រះមានព្រះភាគជាម្ចាស់ ស្តេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្មកថាដល់ទេវបរិស័ទ លុះទ្រង់សម្តែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្តែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះ ធម៌-វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្ចាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមកត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់កត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណាប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមកត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្ដាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្ពាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គ ក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញ៉ាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយវាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បាន

បានជាប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិសាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្ដាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូលអាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយ-សង្កន្តិកៈទាំងឡាយបែកគ្នាហើយ និកាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះ កើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទយ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយវាទ ១១ និកាយនេះ រួមនឹងថេរវាទដើមក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្ដី ត្រកូលអាចារ្យ ១៨ ក្ដី ជាឈ្មោះរបស់និកាយ ដែលពោលមកហើយទាំងនោះឯង ។ ម្យ៉ាងទៀត បណ្ដានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទបណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្តែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្តេញចេញហើយ បានពួកដទៃទៀត ទើបផ្តើមតាំងជាគណាចារ្យថ្មី ៗ

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា **ព្រះពុទ្ធឃោសាចារ្យ** បានប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាននាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរអដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការកសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធឃោសាចារ្យជាអ្នកស្រុកជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ពុទ្ធគយាដែនមគធៈ ជិតស្ពានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធ-សាសនា បានសិក្សាសិល្បសាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅកាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បានឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហាព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហាដែលសមណព្រាហ្មណ៍ និង

បណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះបោះសំឡេងខ្ទរខ្ទារ គ្រប់សង្កាត់រហូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទី ពុទ្ធគយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេច បដិសម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាង ត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍ នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍ នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរ ត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយ អធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះ ឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុង ព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនា បករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះ អដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថា

ដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កា-ទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយមានព្រះ សារីបុត្ត (ឈ្មោះដូចអគ្គសាវក) ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡ: សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះហើយ ព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធ-ទត្តត្ថេរៈ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថាមហានាម មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្លះ ( សិរិកុឋ: ) ខ្លះ ( សិរិកូដ្ឋ: ) ខ្លះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្តាប់អដ្ឋកថាជាភាសាសីហឡ: និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថាជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិ អំពីសង្ឃ

ដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធ: ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនាសិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបានរចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្ដីយ៉ាងល្អប្រសើរ រហូតដល់ព្រះសង្ឃលង្កាទទួលស្គាល់នូវសេចក្ដីជំនាញរបស់លោក តាមប្រវត្តិបាននិយាយថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតាបានបណ្ដាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បានរចនាជាថ្មីម្ដងទៀត ទេវតាក៏បណ្ដាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្ដងទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញវេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរប្រៀបធៀបគ្នាហើយ មិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុងឬ ដោយថេរវាទ ឬដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណានីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បីសម្ដែងសេចក្ដីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្ដីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គនេះជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិ

ឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡៈមកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្តាប់កិត្តិគុណរបស់លោក ស្តេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃហើយនមស្ការព្រះពុទ្ធឃោសៈនិមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធានឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរីយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា

ព្រះមហិន្ទត្ថេរៈនាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡៈឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរីយៈ ឈ្មោះថា **បច្ចរីយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋ-

កថាព្រះត្រៃបិដកជាភាសាមគធៈ  មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តបាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលទៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្ដីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។

## រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុផាត

ឧបាសក ក្អាត ហ៊ន | ឧបាសក នាក់ ម៉ៅ

ឧបាសក ទុំ ទូន | ឧបាសក កុយ សាម៉ន

ឧបាសក ហុក សឹងហួត | ឧបាសក ជឹម ជំនិត

ឧបាសក កើត ទិត្យ | ឧបាសក សន ម៉ារឌី

ឧបាសក ហាយ ចំរើន | ឧបាសក អ៊ឹម រ៉ៃយ៉ា

ឧបាសក សុក្រ ហ៊ត | ឧបាសក សំ ឆាយ

ឧបាសិកា ថាប់ លឿម | ឧបាសិកា ហាយ សារ៉ាត់

ឧបាសិកា ប៊ុត សុម៉ាលី | ឧបាសិកា យស សម្បត្តិ

ឧបាសិកា ពូ ហ៊ាង | ឧបាសិកា ប៊ុត សេដ្ឋាដួង

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

ព្រះភិក្ខុអគ្គទិន្នោ នូវ បូរ៉ា ប្រធានអាស្រម

ព្រះភិក្ខុចិត្តរក្ខិតោ សំ សម្បត្តិ ធម្មាចារ្យ

ព្រះភិក្ខុវរធម្មោ ផុត តៅ ធម្មាចារ្យ

ព្រះភិក្ខុសារញ្ញាណោ ស សត្ថា ធម្មាចារ្យ

ព្រះភិក្ខុកល្យាណធម្មោ យឿន កល្យាណ វិនយាចារ្យ

ព្រះភិក្ខុបវរធម្មោ អ៊ុល សុធា សមណសិស្ស សាលាសតិប្បដ្ឋាន

សាមណេរ កោវិនោ ឡោះ សូវៀត សមណសិស្ស សាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

ឧបាសក ក្អាត ហ៊ន ឧបាសក ហាយ ចំរើន

ឧបាសក សន ម៉ារឌី ឧបាសក អ៊ឹម រ៉ៃយ៉ា

ឧបាសក ទុំ ទូន ឧបាសក ហុក សឹងហួត

ឧបាសក រីម សុមេធ ឧបាសក សន ឃៀត

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.000 ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ ៖-

ឧទ្ទិសថ្វាយ និងគោរពជូន ៖

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុផាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រៃភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះបានស្មើ ៗ គ្នា

សូមអនុមោទនា !.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌

ឈ្មោះធម៌ ទំព័រ


## អដ្ឋកថា ទាជិកសូត្រ ទី ១

ពោលអំពី ឥទ្ធិបាដិហារិយ៍ ៦
ពោលអំពី ច្បាប់ទម្លាប់ ៧
រឿងអាចេលកបាជិកបុត្រ ២២
ព្រះមានព្រះភាគចូលទៅកាន់...... ២៧
ការប្រៀបធៀបសីហមិគរាជ និងចចកចាស់ ៣០
ពោលអំពី ច្បាប់ម្រាប់ជាដើម ៣៧
ពោលអំពី សុភវិមោក្ខ ៤០

## អដ្ឋកថា ឧទុម្ពរិកសូត្រ ទី ២

............................................... ៤៣
រឿងនិគ្រោធបរិព្វាជក ៤៦
ពោលអំពី ឧបក្កិលេស ........ ៥៥
ពោលអំពី តបោជិគុច្ឆវាទ ៦៤
ពោលអំពី ការសាកសួរបែសន្ធានគហបតី ៦៨
ពោលអំពី គុណនៃព្រះសម្មាសម្ពុទ្ធ ៦៩
ពោលអំពី អានិសង្សដ៏ឧត្តមនៃការបដិបត្តិ ... ៧០

## អដ្ឋកថា ចក្កវត្តិសូត្រ ទី ៣

............................................... ៧៧
រឿងស្តេចចក្រពត្តិព្រះនាម ទល្ហនេមិ ៨៤

ចក្ករតន៍ជាទិព្វ បាត់ទៅ ៨៧
អានុភាពនៃចក្ករតន៍ ៨៧
ចក្ករតន៍ប្បតបាកទី ៨៨
វត្តរបស់ព្រះចៅចក្រពត្តិ ៩២
ទ្រង់មិនព្រះរាជទានទ្រព្យ ............... ៩៧
សេចក្តីប្រៀបធៀបដោយស្មៅ ....... ១០០
និយាយពីគំនុំដ៏ក្បៀវក្លា ១០៣
ការកើតរបស់ព្រះបាទសង្ខរាជ ១០៦
អំពីគុណកថានៃព្រះសម្ពុទ្ធមេតេយ្យ ១១១

## អដ្ឋកថា អគ្គញ្ញសូត្រ ទី ៤

............................................. ១១៥
ពោលអំពី វណ្ណៈ ៤ ១២៥
ពោលអំពី ធម៌ស ធម៌ខ្មៅ ១២៦
ពោលអំពី ជាតិផ្សេង ៗ ១៣៤
ពោលអំពី ការប្រកាជ ១៣៧
ពោលអំពី ប្រមាណទំហំ ១៣៨
ពោលអំពី កម្ពស់ - ការវិល ១៣៩
ពោលអំពី ផែនដីមានរសជាដើម ១៤៣
ពោលអំពី ក្រមរផែនដីជាដើម ១៤៤
ពោលអំពី នាំយកស្រូវសាលីជាដើម ១៤៦
ការសន្ទត់សត្វម្នាក់ ................. ១៤៧
ពោលអំពី បាបធម៌មានអទិន្នាទានជាដើម ១៤៨
ការប្រព្រឹត្តអាក្រក់ និងផល ............ ១៥១

ការប្រព្រឹត្តល្អ និងផល .................. ១៥១
គាថារបស់សនង្កុមារព្រហ្ម ១៥៤

## អដ្ឋកថា សម្បសាទនីយសូត្រ ទី ៥

.......................................... ១៥៥
ពោធិបក្ខិយធម៌ញុំាងបុគ្គលឲ្យស្គាល់អាយតនៈ ១៨២
អាទេសនាវិធី ១៩១
ទស្សនសមាបត្តិ ៤ ១៩៦
បុគ្គល ៧ ពួក ១៩៩
បដិបទា ៤ យ៉ាង ២០៦
អនុសាសនវិធា ៤ យ៉ាង ២១៣
សស្សតវាទ ៣ ប្រការ ២១៤
បុព្វេនិវាសានុស្សតិញ្ញាណ ២១៦
ឥទ្ធិវិធា ២ យ៉ាង ២១៧
ព្រះសារីបុត្រទូលសួរ ព្រះមានព្រះភាគព្យាករ ២២០

## អដ្ឋកថា ចាសាទិកសូត្រ ទី ៦

.................................................. ២៤៤
ធម្មវិន័យដែលសាស្ដាពោលទុកមិនល្អ ២៥៣
ពួកសាវ័កមិនបានដឹង .............. ២៥៦
ភាសិតរបស់សង្ឃជាសព្រហ្មចារី ២៦១
ការឈប់ប្រព្រឹត្តកន្លងហេតុទាំង ៩ យ៉ាង ២៦៥
ប្រស្នាដែលព្រះតថាគតទ្រង់ព្យាករ ..... ២៦៨

អធិប្បញ្ញត្តិនៃសមណព្រាហ្មណ៍ទាំងឡាយ ២៧៤
សតិប្បដ្ឋាន ៤ ២៧៦

# អដ្ឋកថា ទីឃនិកាយ ចាដិកវគ្គវណ្ណនា
# ឈ្មោះ សុមង្គលវិលាសិនី
## នៃព្រះសុត្តន្តបិដក
## ភាគ ១៨

## ចាដិកសូត្រ ទី ១

[១] បាដិកសូត្រមានពាក្យបាលីថា ឯវំមេ្ម សុតំ ។ល។ មល្លេសុ វិហរតិ ។ ក្នុងបាដិកសូត្រនោះ នឹងបានអធិប្បាយសេចក្តីតាមលំដាប់បទ ដូចតទៅនេះ ៖

ពាក្យថា មល្លេសុ វិហរតិ មានពាក្យអធិប្បាយដូច្នេះ សូម្បីជនបទមួយកន្លែង ដែលជាទីស្នាក់អាស្រ័យរបស់បណ្តាមល្លរាជកុមារ អ្នកមាននិវាសដ្ឋាននៅក្នុងជនបទ ក៏ហៅថា មល្ល: ព្រោះបន្ថែមស័ព្ទចូលមក ( ព្រះមានព្រះភាគប្រថាប់នៅ ) ក្នុងជនបទមួយកន្លែងនោះ ក្នុងបណ្តាមល្លជនបទទាំងឡាយ ។ ពាក្យថា អនុប្បិយំ នាម មល្លានំ និគមោ មានពាក្យអធិប្បាយដូច្នេះ មាននិគមជនបទរបស់អ្នកមល្ល:មួយកន្លែង ឈ្មោះថា

**អនុបិយ** ព្រះមានព្រះភាគ ប្រថាប់នៅក្នុងដងព្រៃមួយកន្លែង ដល់ព្រម ដោយម្លប់ និងទឹក អាស្រ័យអនុបិយនិគមជនបទនោះ ជាគោចរគ្រាម ។ បាលីកន្លែងខ្លះជា " **អនោបិយ** " ក៏មាន ។ បទថា ចារិសិ គឺ ស្តេចបាន ចូលទៅហើយ ។ មួយទៀត នឹងពោលថា ព្រះមានព្រះភាគស្តេចយាងចូល ទៅស្រេចហើយ មិនត្រូវពោលថា ត្រូវស្តេចយាងចូលទៅម្តងទៀត ព្រោះ ហេតុថា សូម្បីស្តេចយាងចេញមកហើយ ក៏ទ្រង់នៅមានព្រះបំណងនឹង ស្តេចយាងចូលទៅទៀត ។ មានឧបមាដូច្នេះ ។ ដូចបុរសម្នាក់ចេញពី ស្រុកបំណងនឹងទៅកាន់ស្រុកមួយទៀត សូម្បីដើរផ្លូវមិនទាន់ដល់ស្រុកនោះ កាលមានពាក្យសួរថា បុរសម្នាក់នេះនៅទីណា ក៏ត្រូវឆ្លើយថា គេទៅស្រុក នោះហើយ សេចក្តីនេះមានឧបមាយ៉ាងណា ក៏មានឧបមេយ្យដូច្នោះដែរ ។

ពាក្យថា ឯតទហោសិ គឺ ព្រះរាជតម្រិះនេះបានកើតឡើងហើយ កាលព្រះមានព្រះភាគប្រថាប់ឈរជិតស្រុកនិងទតព្រះនេត្រមើលព្រះអាទិត្យ ។ ពាក្យថា អតិប្បគោ ខោ ប្រែថា ដូចជានៅព្រឹកពេក មនុស្សក្នុងត្រកូលទាំង ឡាយដាំបាយ យាគូ មិនទាន់ឆ្អិន ។ មានពាក្យសួរថា ក៏ព្រះមានព្រះភាគ ទ្រង់មិនជ្រាបវេលាឬ ទើបស្តេចចេញទៅ ។

មានពាក្យឆ្លើយថា ព្រះអង្គទ្រង់មិនជ្រាបវេលាស្តេចចេញទៅ ក៏មិនមែនដែរ ។ ព្រោះក្នុងវេលាព្រឹកព្រលឹម ព្រះមានព្រះភាគ ទ្រង់ផ្សាយសំណាញ់ញាណពិចារណាមើលសត្វលោក ទតព្រះនេត្រឃើញឆន្នបរិព្វាជកកក្កវគោត្រ ចូលទៅប្រាកដក្នុងសំណាញ់ព្រះញាណ ទ្រង់ជ្រាបច្បាស់ថា ក្នុងថ្ងៃនេះ តថាគតនឹងនាំហេតុ ដែលតថាគតបានបំពេញទុកក្នុងកាលមុនមក សម្តែងធម៌ដល់បរិព្វាជកនេះ ធម្មកថានោះនឹងមានផល ព្រោះបរិព្វាជកនោះ បាននូវសេចក្តីជ្រះថ្លាក្នុងតថាគត ទ្រង់មានព្រះបំណងនឹងស្តេចយាងចូលទៅកាន់អាពាមរបស់បរិព្វាជក ទើបបានស្តេចយាងចេញទៅពីព្រឹកព្រលឹម ព្រោះដូច្នោះ ទើបទ្រង់កើតមានព្រះតម្រិះយ៉ាងនេះ ព្រោះមានព្រះរាជបំណងនឹងស្តេចយាងចូលទៅក្នុងអាពាមរបស់ឆន្នបរិព្វាជកនោះ ។

ពាក្យថា ឯតុ ខោ ច មានពាក្យអធិប្បាយដូច្នេះ ឆន្នបរិព្វាជកឃើញព្រះមានព្រះភាគហើយ មិនបានសម្តែងអាការរឹងរូស ព្រោះមានមានះបានថ្វាយបង្គំទទួលព្រះសាស្តា ក្រាបទូលពាក្យថា សូមព្រះអង្គទ្រង់ស្តេចយាងចូលមកចុះព្រះអង្គ ជាដើម ។ ពាក្យថា ឥមំ បរិយាយំ បានដល់វារៈនេះ អធិប្បាយថា វារៈដែលស្តេចមកក្នុងថ្ងៃនេះ ។ សូម្បីកាលមុន

ព្រះមានព្រះភាគ ស្តេចធ្លាប់បានទៅក្នុងអារាមរបស់ឆន្នបរិព្វាជកនោះខ្លះឬ ។ ស្តេចមិនធ្លាប់ទៅ ។ តែបរិព្វាជកបានក្រាបទូលយ៉ាងនោះ ព្រោះបណ្តោយតាមសំនួនពាក្យរបស់មនុស្សលោកទាំងឡាយ ។ ព្រោះមនុស្សលោកទាំងឡាយបានឃើញអ្នកដែលខ្លួនពេញចិត្ត មិនថា នឹងធ្លាប់មកយូរហើយក្តី ឬមិនធ្លាប់មកក្តី រមែងពោលពាក្យជាដើមថា លោកដ៏ចម្រើន លោកមកពីណាអស់វេលាយូរណាស់ហើយ ដែលលោកដ៏ចម្រើនបានមកទីនេះទៀត លោកដឹងផ្លូវមកទីនេះបានយ៉ាងណា លោកវង្វេងផ្លូវមកឬ ជាដើម ព្រោះដូច្នោះគប្បីជ្រាបថា ឆន្នបរិព្វាជកនេះ បានពោលយ៉ាងនេះ ព្រោះបណ្តោយតាមសំនួនពាក្យរបស់មនុស្សលោក ។ ប្រយោគថា ឥទមាសនំ មានន័យថា បរិព្វាជកបានពោលយ៉ាងនោះ ព្រមទាំងចង្អុលប្រាប់អាសនៈដែលខ្លួនអង្គុយ ។

ពាក្យថា សុនក្ខត្តោ លិច្ឆវិបុត្តោ បានដល់ ព្រះរាជឱរសរបស់ក្សត្រលិច្ឆវី ទ្រង់ព្រះនាមថា **សុនក្ខត្ត** ។ បានឮថា ព្រះរាជឱរសអង្គនោះកាលនៅជាគ្រហស្ថ ជាសម្លាញ់របស់ឆន្នបរិព្វាជកនោះ ស្តេចចូលមកកាន់សម្នាក់របស់បរិព្វាជកនោះក្នុងគ្រាខ្លះ ។

ពាក្យថា បច្ចក្ខាតោ បានដល់ ពោលលា គឺ លះ លះបង់ចោល

ដោយពោលពាក្យយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ឥឡូវនេះខ្ញុំសូមបោះបង់ព្រះមានព្រះភាគ ឥឡូវនេះ ខ្ញុំនឹងមិនសូមឧទ្ទិសដល់ព្រះមានព្រះភាគ ។

ពាក្យថា ភគវន្តំ ឧទ្ទិស្ស បានដល់ សម្តែងអាងយ៉ាងនេះថា ព្រះមាន-ព្រះភាគជាសាស្តារបស់យើង យើងនឹងបដិបត្តិតាមឱវាទរបស់ព្រះមាន-ព្រះភាគ ។

ពាក្យថា កោសន្តោ កំ សេចក្តីថា ព្រះមានព្រះភាគ ទ្រង់សម្តែងថា អ្នកសូមគប្បីពោលលាដល់អ្នកត្រូវសូម ឬថា អ្នកត្រូវសូមគប្បីពោលលាដល់អ្នកសូម ប៉ុន្តែថា អ្នកមិនមែនជាអ្នកសូម និងអ្នកត្រូវសូម ម្នាលមោឃបុរស កាលបើដូច្នេះ អ្នកឯងជាអ្នកណា ពោលលាដល់អ្នកណា ។

ពាក្យថា បស្ស មោឃបុរិស ប្រែថា ម្នាលមោឃបុរស អ្នកចូរមើល ។ ពាក្យថា យាវញ្ច តេ ឥទំ អបរទ្ធំ ប្រែថា រឿងនេះជាកំហុសរបស់អ្នកច្រើនត្រឹមណា ។ ព្រះមានព្រះភាគទ្រង់សម្តែងថា តថាគតសូមលើកទោសដែលមានហើយយ៉ាងនេះថា អ្នកមានកំហុសត្រឹមណា ក៏មានទោសត្រឹមនោះ ដែរ ។

# ពោលអំពី ឥទ្ធិប្បាដិហារិយ៍

[២] បទថា ឧត្តរិមនុស្សធម្មា គឺ ធម៌ដ៏ប្រសើរក្រៃលែងបំផុត ជាងធម៌របស់មនុស្ស បានដល់ សីល ៥ និងសីល ១០ ។ បទថា ឥទ្ធិចាដិហារិយំ បានដល់ បាដិហារ្យ ជាឫទ្ធិ ។ បទថា កតេ វា ប្រែថា បានធ្វើហើយក៏ដោយ ។ បទថា យស្សត្ថាយ បានដល់ ដើម្បីប្រយោជន៍ នៃការអស់ទុក្ខណា ។ ដោយពាក្យថា សោ និយ្យាតិ តក្ករស្ស ព្រះមាន-ព្រះភាគត្រាស់សួរថា ធម៌នោះរមែងទៅ គឺ ប្រព្រឹត្តទៅដើម្បីការអស់ទុក្ខ ក្នុងវដ្ដៈទាំងពួង បានដល់ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអមតនិព្វាន ដល់អ្នកធ្វើតាមធម៌នោះ គឺ អ្នកធ្វើតាមធម៌ដែលតថាគតសម្ដែងទុក បានដល់ បុគ្គលដែលបដិបត្តិត្រូវ ។ ឬដោយពាក្យថា តត្រ សុនក្ខត្ត ជាដើម ព្រះមានព្រះភាគ ទ្រង់សម្ដែងការគ្មានប្រយោជន៍នៃបាដិហារ្យថា ម្នាលសុនក្ខត្ត: កាលបើធម៌ដែលតថាគតបានសម្ដែងហើយនោះ ប្រព្រឹត្តទៅដើម្បីការអស់ទៅនៃទុក្ខដោយប្រពៃ ដល់អ្នកបដិបត្តិធម៌នោះ ឥទ្ធិបាដិហារ្យដែលក្រៃលែងជាងធម៌របស់មនុស្ស ដែលតថាគតធ្វើហើយ នឹងធ្វើអ្វីបាន គឺ មានប្រយោជន៍អ្វី ដោយការធ្វើបាដិហារ្យនោះ ព្រោះសូម្បីតថាគតនឹងធ្វើបាដិហារ្យនោះ

ឬមិនធ្វើក៏ដោយ ការសោបសូន្យនៃពាក្យទូន្មានរបស់តថាគត រមែងមិនមានសេចក្តីពិត តថាគតបំពេញបារមីមកដើម្បីប្រាថ្នាឲ្យទេវតា និងមនុស្សទាំងឡាយសម្រេចអមតនិព្វាន មិនបានប្រាថ្នាឲ្យធ្វើបាដិហារ្យ ហើយទ្រង់បានលើកទោសទីពីរថា ម្នាលមោឃបុរស អ្នកចូរឃើញ ។

## ពោលអំពី ច្បាប់ឧទ្ទាហរណ៍

[៣] ពាក្យថា អគ្គញ្ញំ គឺ បញ្ញត្តិនៃលោក ដែលគប្បីដឹងយ៉ាងនេះថា វត្ថុនេះជាកំពូលក្នុងលោក បានដល់ ការប្រព្រឹត្តដ៏ប្រសើរ ព្រះរាជកុមារត្រាស់ថា ព្រះមានព្រះភាគមិនបញ្ញត្តិវត្ថុដែលលោកសម្មតិថា ដ៏កំពូលនោះ ។ ពាក្យដ៏សេសក្នុងព្រះសូត្រនេះ គប្បីជ្រាប តាមទំនងវារៈដែលនៅបន្ទាប់ទៅនោះឯង ។ ពាក្យថា អនេកបរិយាយេន ខោ នេះ ព្រះមានព្រះភាគទ្រង់ប្រារព្ធឡើង ព្រោះហេតុអ្វី ។ បានឮថា សុនក្ខត្តរាជកុមារទ្រង់បានរអ៊ូរទាំដោយពាក្យដូច្នេះថា យើងនឹងលុបលាងគុណរបស់ព្រះមានព្រះភាគ បញ្ញត្តិទោសឡើង កាលបានស្តាប់ព្រះតម្រាស់របស់ព្រះមានព្រះភាគ តាំងនៅមិនបានមិនហ៊ានថ្លែងព្រះសូរសៀង ។ គ្រានោះ ព្រះមានព្រះភាគបានត្រាស់ពាក្យថា

អនេកបរិយាយេន ជាដើម ដើម្បីទ្រង់សម្តែងទោសក្នុងភាពជាអ្នកលុបគុណថា ម្នាលសុនក្ខត្តៈ អ្នកតាំងនៅក្នុងភាពជាអ្នកលុបគុណយ៉ាងនេះ នឹងបានទទួលពាក្យតិះដៀលខ្លួនឯងតែម្យ៉ាង ។

បទថា អនេកបរិយាយេន ក្នុងព្រះសូត្រនោះ ប្រែថា ដោយមិនមែនមួយ ។

បទថា វជ្ជិគាមេ បានដល់ វេសាលីនគរ ដែលជាស្រុករបស់មេគណៈអ្នកវជ្ជី ។ បទថា នោ វិសហិ បានដល់ មិនអាច ។ បទថា សោ អវិសហន្តោ បានដល់ សុនក្ខត្តរាជកុមារអង្គនោះ ។ ក្នុងគ្រាមុន ព្រះរាជកុមារអង្គណា កាលត្រាស់សរសើរព្រះរតនត្រ័យ ព្រះឱសដែលត្រាស់ទុកមិនត្រឹមល្មម ឥឡូវនេះ ព្រះរាជកុមារអង្គនោះ ទ្រង់បានប្រើព្រះឱសនោះដូចគ្នា មកត្រាស់តិះដៀលព្រះរតនត្រ័យ ។

បទថា អវិសហន្តោ បានដល់ មិនអាចប្រព្រឹត្តព្រហ្មចរិយៈ បានត្រាស់តិះដៀល ព្រោះភាពដែលព្រះអង្គជាបុគ្គលពាល ហើយវិលមកដើម្បីជាបុគ្គលអាក្រក់ ចំណែកពួកបុគ្គលអ្នកសរសើរព្រះរតនត្រ័យ យ៉ាងនេះថា ព្រះពុទ្ធត្រាស់ដឹងពិត ព្រះធម៌ដែលព្រះមានព្រះភាគត្រាស់ពិត ព្រះសង្ឃ

បដិបត្តិពិត រមែងសម្តែងទោសរបស់អ្នកដោយចំពោះ ។ ពាក្យថា ឥតិ ខោ តេ សេចក្តីថា ព្រះមានព្រះភាគទ្រង់សម្តែងថា ម្នាលសុនក្ខត្តៈ ពួកមនុស្ស នឹងពោលតិះដៀលយ៉ាងនេះឯង ។ ព្រោះដូច្នោះ កាលទោសកើតឡើង យ៉ាងនេះ អ្នកមិនអាចនឹងពោលបានថា ព្រះសាស្តាដែលមានព្រះញាណមិន មានអ្វីរាំងក្នុងអតីត និងអនាគត សូម្បីទ្រង់ជ្រាបថា ទោសនឹងកើតដល់ យើងយ៉ាងនេះ ក៏មិនត្រាស់ដាស់តឿនយើងអំពីកាលមុន ។

បទថា អបក្កមេវ បានដល់ បានចៀសចេញទៅហើយ ។ ឬបាន ចៀសចេញទៅ អធិប្បាយថា ឃ្លាតចេញទៅ ។ ពាក្យថា យថា តំ អាចា-យិកោ អធិប្បាយថា សត្វអ្នកគួរទៅកើតក្នុងអបាយ សត្វអ្នកគួរទៅកើត ក្នុងនរក គប្បីគេចចេញទៅកើត យ៉ាងណា អ្នកក៏បានចៀសចេញទៅដូច្នោះ ។

[៤] ដោយពាក្យថា ឯកមិទាហំ នេះ ព្រះមានព្រះភាគទ្រង់សម្តែង អ្វី ។ ព្រះអង្គទ្រង់ផ្តើមសូត្រនេះ ដោយពីរបទថា ទ្រង់មិនដែលធ្វើឥទ្ធិ-បាដិហារ្យ និងមិនបញ្ញត្តិវត្ថុដែលមនុស្សលោកសម្មតិថា កំពូល ។ ក្នុងពីរ បទនោះ ពាក្យថា **ទ្រង់មិនបញ្ញត្តិវត្ថុដែលមនុស្សលោកសម្មតិថា កំពូល** នេះ ទ្រង់នឹងសម្តែងក្នុងផ្នែកខាងចុងសូត្រ ។ ចំណែកបទថា **ទ្រង់មិនធ្វើ**

**ឥទ្ធិបាដិហារ្យ** នេះ ទ្រង់បានផ្ដើមទេសនានេះ ដោយអំណាចដែលទ្រង់សម្ដែងបន្ត ។

ពាក្យថា ឯកមិទាហំ ក្នុងបាលីនោះ ចែកបទជា ឯកស្មឹ អហំ ។

បទថា សមយំ បានដល់ ក្នុងសម័យ ។ អធិប្បាយថា ក្នុងកាលមួយតថាគត ។ បទថា ថូលូសុ អធិប្បាយថា មានជនបទមួយកន្លែងឈ្មោះថា **ថូលូ** តថាគតនៅក្នុងជនបទនោះ ។ បទថា ឧត្តរកា នាម អធិប្បាយថា មាននិគមថូលូជនបទ មានឈ្មោះជាភេទស្រីថា ឧត្តរកា ទ្រង់អាស្រ័យនិគមនោះ ជាគោចរគ្រាម ។ បទថា អចេលោ បានដល់ អ្នកអាក្រាតកាយ ។ បទថា កោរក្ខត្តិយោ បានដល់ ក្សត្រអ្នកមានព្រះបាទងខុប ។ បទថា កុក្កុរវត្តិកោ បានដល់ សមាទានសុនខវត្ត ហិតក្លិនស៊ីអាហារ ដេកក្នុងបរិវេណផេះចង្ក្រានដូចសុនខ ធ្វើកិរិយារបស់សុនខសូម្បីយ៉ាងដទៃទៀត ។ បទថា ចតុកោណ្ឌិកោ គឺ វារដើងបួន បានដល់ជង្គង់ពីរ និងដៃពីរច្រត់លើផែនដី ដើរទៅ ។ បទថា ឆមានិក្កិណ្ណំ បានដល់ ដែលរាត់រាយ ចាក់ទុក ដាក់ទុកលើផែនដី ។ បទថា ភក្ខសំ បានដល់ អាហារ គឺ របស់ទំពារ របស់បរិភោគណាមួយ ។ បទថា មុខេនេវ គឺ មិន

បានប្រើដៃចាប់អាហារ ប្រើមាត់តែម្យ៉ាងទំពារអាហារ ដែលគប្បីទំពារ សូម្បីអាហារដែលគប្បីបរិភោគ ។ ក៏ប្រើមាត់តែម្យ៉ាងបរិភោគ ។ បទថា សាធុរូបោ បានដល់ មានរូបស្អាត ។ បទថា អរហាំ សមណោ បានដល់ សមណៈដែលជាព្រះអរហន្តមួយអង្គ ។

សព្ទថា វត ក្នុងបាលីនោះ ជានិបាតចុះក្នុងអត្ថនៃសេចក្តីប្រាថ្នា ។ បានឮថា ព្រះរាជកុមារនោះ មានសេចក្តីប្រាថ្នាយ៉ាងនេះថា អ្នកបួសដទៃ ដែលនឹងចាត់ថា ជាសមណៈ ដូចសមណៈរូបនេះមិនមាន ព្រោះសមណៈ រូបនេះមិនស្លៀកសំពត់ ព្រោះជាអ្នកមានសេចក្តីប្រាថ្នាតិច មានសេចក្តី សម្គាល់ថា វត្ថុនេះ ជាហេតុឲ្យកើតសេចក្តីយឺតយូរ ទើបមិនប្រើសូម្បី ភាជនៈសម្រាប់ដាក់អាហារ ស៊ីអាហារដែលទុកនៅលើផែនដីប៉ុណ្ណោះ អ្នក បួសរូបនេះចាត់ថា ជាសមណៈ ចំណែកពួកយើងនឹងជាសមណៈបានយ៉ាង ណា ។ សាវកអ្នកដើរតាមក្រោយព្រះពុទ្ធជាសព្វញ្ញូ យ៉ាងនេះ ក៏មានការ នឹកគិតអាក្រក់ ដូច្នេះ ។

ពាក្យថា ឯតទវោចំ អធិប្បាយថា បានឮថា ព្រះមានព្រះភាគ ទ្រង់ត្រិះរិះថា សុនក្ខត្តៈ អ្នកមានអធ្យាស្រ័យថោកទាបនេះ ជាអ្នកបួសនេះ

គិតយ៉ាងណាហ្ន៎ គ្រាទ្រង់ត្រិះរិះយ៉ាងនេះ ទ្រង់ជ្រាបអធ្យាស្រ័យរបស់គេ ទ្រង់ពិចារណាឃើញថា មោឃបុរសនេះ ដើរតាមក្រោយព្រះសព្វញ្ញូដូចតថាគត ទៅសម្គាល់អ្នកបួសដែលអាក្រាតកាយថា ជាព្រះអរហន្ត ឥឡូវនេះ ជនពាលនេះ គួរត្រូវតិះដៀលទោសក្នុងទីនេះឯង ដោយទ្រង់មិនទាន់ត្រឡប់ឡើយ បានត្រាស់ពាក្យថា ត្វំបិ ឆាម ជាដើមនេះ ។ បិ ស័ព្ទ ក្នុងពាក្យថា ត្វំបិ ឆាម នោះ ចុះក្នុងអត្ថថា តិះដៀល ។ ព្រោះព្រះមានព្រះភាគ កាលទ្រង់តិះដៀលសុនក្ខត្តៈ បានត្រាស់ពាក្យថា " ត្វំបិ ឆាម " ។ ក្នុងពាក្យនេះ មានពាក្យអធិប្បាយដូច្នេះថា សូម្បីខ្លួនអ្នក មានអធ្យាស្រ័យថោកទាបថ្នាក់នេះ នៅតែប្តេជ្ញាយ៉ាងនេះថា យើងជាសមណៈ ជាសក្យបុត្រទៀតឬ ។ ដោយពាក្យថា កឹ បន មេ ភន្តេ សុនក្ខត្តៈបានក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ឃើញវត្ថុដែលគួរតិះដៀលអ្វី ក្នុងខ្លួនរបស់ខ្ញុំព្រះអង្គ ទើបបានត្រាស់យ៉ាងនេះ ។ គ្រានោះ ព្រះមានព្រះភាគ កាលត្រាស់ប្រាប់ដល់គេ បានត្រាស់ពាក្យថា ឆន្ទុ តេ ជាដើម ។ ដោយពាក្យថា មច្ឆរាយតិ នេះ សុនក្ខត្តៈ បានក្រាបទូលសួរថា ព្រះមានព្រះភាគ ទ្រង់ហួងហែងព្រះអរហត្ត ព្រោះទ្រង់ត្រិះរិះយ៉ាងនេះថា អ្នកដទៃចូរកុំបាន

ជាព្រះអរហន្ត ឬ ។ ពាក្យថា ឆ ខោ អហំ អធិប្បាយថា ម្នាលមោឃបុរស តថាគតប្រាថ្នាឲ្យមនុស្សលោក ព្រមទាំងទេវលោកបានព្រះអរហន្តទាំងអស់គ្នា តថាគតធ្វើកម្មដែលធ្វើបានលំបាកច្រើនណាស់ បំពេញបារមីមក ក៏ដើម្បីប្រយោជន៍យ៉ាងនេះប៉ុណ្ណោះ តថាគតមិនបានហួងហែងព្រះអរហត្តឡើយ ។ ពាក្យថា ចាបកំ ទិដ្ឋិគតំ អធិប្បាយថា គេកើតមានការឃើញក្នុងបុគ្គលដែលមិនមែនព្រះអរហន្តថា ជាព្រះអរហន្ត និងក្នុងបុគ្គលដែលជាព្រះអរហន្តថា មិនមែនព្រះអរហន្ត ។ ព្រះមានព្រះភាគត្រាស់ថា ចាបកំ ទិដ្ឋិគតំ សំដៅដល់ ការឃើញខុសដូចពោលមកនោះ ។ ពាក្យថា យំ ខោ បឆ បានដល់ អ្នកសម្គាល់អ្នកបួសដែលអាក្រាតកាយរូបនោះ យ៉ាងនេះ ។

ពាក្យថា សត្តមំ ទិវសំ ប្រែថា ក្នុងថ្ងៃទី ៧ ។ បទថា អលសកេឆ បានដល់ ដោយព្យាធិឈ្មោះ **អលសកៈ** ។ ពាក្យថា កាលំ ករិស្សតិ ប្រែថា ស្លាប់ ព្រោះមានពោះហើមប៉ោង ។

ពាក្យថា កាលកញ្ជិកា ជាឈ្មោះរបស់អសុរទាំងនោះ ។ បានឮថា អសុរទាំងនោះ មានអត្តភាពកម្ពស់បីគាវុត មានសាច់ និងលោហិតតិច ដូចស្លឹកឈើចាស់ មានភ្នែកលៀនចេញមកជាប់នៅលើក្បាលដូចក្តាម

មានមាត់ប៉ុនវន្ទម្ពុលជាប់នៅលើក្បាលដូចគ្នា ឱនខ្លួនចុះយកមាត់ស៊ីអាហារ ។

បទថា វីរណាត្ថម្ភកេ អធិប្បាយថា ក្នុងព្រៃជាទីចោលសាកសព នោះ មានស្បូវរណ្ដាស់ ព្រោះដូច្នោះ ទើបហៅព្រៃជាទីចោលសាកសព នោះថា វីរណត្ថម្ភកេ ។ ពាក្យថា តេនុបសង្កមិ អធិប្បាយថា កាល ព្រះមានព្រះភាគត្រាស់ ដូច្នោះ ស្ដេចទៅបិណ្ឌបាតក្នុងស្រុកនោះ ហើយស្ដេច ទៅកាន់វិហារ សុនក្ខត្ត:បានចេញពីវិហារ ចូលទៅរកអ្នកបួសស្រោតនោះ ។ ពាក្យថា យេន ត្វំ សេចក្ដីថា អ្នកត្រូវព្រះមានព្រះភាគទ្រង់ព្យាករណ៍ទុក ព្រោះហេតុអ្វី ។ អធិប្បាយថា ព្រោះហេតុដែលលោកត្រូវព្រះមានព្រះភាគ ទ្រង់ព្យាករណ៍ទុក ។ ពាក្យថា មត្តំ មត្តំ បានដល់ ល្មមគួរដល់ ប្រមាណៗ ។ បាលីកន្លែងខ្លះថា មន្តា មន្តា ក៏មានអធិប្បាយថា ប្រើ បញ្ញាពិចារណា ។ ពាក្យថា យថា សមណស្ស សេចក្ដីថា សុនក្ខត្ត: បានពោលថា លោកគប្បីធ្វើឲ្យពាក្យពោល របស់ព្រះសមណគោតមខុស ទៅ ។ កាលសុនក្ខត្ត:ពោលយ៉ាងនេះហើយ អ្នកបួសអាក្រាតដេកក្នុង បរិវេណផេះចង្រ្កានដូចសុនខ បានអើតក្បាល បើកភ្នែកក្រឡេកមើល ពោល ថា ព្រះសមណគោតម ជាអ្នកចងពៀរ ជាសត្រូវនឹងពួកយើង បាននិយាយ

អ្វី ចាប់តាំងពីព្រះសមណគោតមឧប្បត្តិឡើងមក ពួកយើងមានសភាពដូចជាហ្វូងអំពិលអំពែក ក្នុងយាមព្រះអាទិត្យឧទ័យ ព្រះសមណគោតម គប្បីពោលវាចាយ៉ាងនេះនឹងពួកយើង ឬពោលយ៉ាងដទៃ តែជាធម្មតាថា ពាក្យរបស់អ្នកដែលជាសត្រូវនិងគ្នា រមែងមិនពិត លោកចូរចេញទៅចុះ យើងនឹងដឹងក្នុងរឿងនេះឯង ហើយដេកទៀតទៅ ។

បទថា ឯកទ្វីហិកាយ បានដល់ ពោលរាប់ថា មួយ ពីរ ។ បទថា យថា តំ អធិប្បាយថា រាប់ដូចអ្នកខ្លះដែលមិនជឿ គប្បីរាប់ និងក្នុងមួយថ្ងៃ បានចូលទៅរកបីដង ប្រាប់ថា មួយថ្ងៃកន្លងទៅហើយ ពីរថ្ងៃកន្លងទៅហើយ ។ ពាក្យថា សត្តមំ ទិវសំ អធិប្បាយថា បានឮថា អ្នកបួសស្រាតនោះ បានស្តាប់ពាក្យរបស់សុនក្ខត្តៈហើយ មិនបរិភោគអាហារឡើយរហូតដល់អស់ ៧ ថ្ងៃ ។ លុះដល់ថ្ងៃទី ៧ ឧបដ្ឋាកម្នាក់របស់គេគិតថា ថ្ងៃនេះ ជាថ្ងៃទី ៧ ដែលសមណៈប្រចាំត្រកូលរបស់ពួកយើងមិនមក សម្គាល់ថា នឹងកើតសេចក្តីមិនសប្បាយ ហើយឲ្យអាំងសាច់ជ្រូក នាំអាហារទៅគរទុកលើផែនដីខាងមុខ ។ អ្នកបួសអាក្រាត ក្រឡេកមើលហើយ គិតថា ពាក្យរបស់ព្រះសមណគោតមមុខជាពិត ឬកុហកក៏ដោយ តែកាលយើង

បរិភោគឆ្អែតហើយ សុម្បីយើងនឹងស្លាប់ក៏សម្គាល់ថា ស្លាប់ដោយល្អ ហើយក៏ក្រាបចុះ លូនស៊ីអាហារដេកឆ្អែត ៗ ក្នុងវេលាកណ្តាលយប់ គេមិនអាចនឹងឲ្យអាហាររលួយបាន ទើបអស់ជីវិតដោយរោគឈ្មោះ **អលសកៈ** ។ សុម្បីគេមិនទាន់គិតថា នឹងបរិភោគដូច្នោះ គេនឹងត្រូវបរិភោគ ក្នុងថ្ងៃនោះហើយ អស់ជីវិតដោយរោគឈ្មោះ **អលសកៈ** ។ ព្រោះព្រះតថាគតទាំងឡាយរមែងមិនមានវាចាដោយពាក្យពីរ ។

ពាក្យថា វីរណត្ថម្ភកេ អធិប្បាយថា បានឮថា ពួកតិរ្ថិយជ្រាបដំណឹងថា **កោរក្ខត្តិយៈអស់ជីវិតហើយ រាប់ថ្ងៃហើយពោលថា** ពាក្យព្យាករណ៍របស់ព្រះសមណគោតម ក៏ជាពាក្យពិតហើយ ឥឡូវនេះពួកយើងនឹងនាំសាកសពគេទៅចោលក្នុងទីដទៃ នឹងគ្របសង្កត់ព្រះសមណគោតមដោយមុសាវាទ បាននាំគ្នាទៅនាំយកវល្លិ៍មកចងសាកសព ហើយទាញទៅព្រមនឹងពោលថា ចោលសាកសពទុកត្រង់នេះៗ ។ ទីកន្លែងដែលទាញសាកសពទៅនោះ ជាទីទួលទាំងអស់ ។ ពួកគេទើបទាញសាកសពទៅកាន់ព្រៃជាទីចោលសាកសពឈ្មោះ **វីរណត្ថម្ភកៈ** ជ្រាបថា ជាស្មសាន ក៏បានទាញសាកសពទៅ តាំងចិត្តថា នឹងនាំទៅចោលក្នុងទីដទៃ ។ ក្លាមនោះ

វល្លិ៍ទាញសាកសពក៏ដាច់ ។ ពួកគេមិនអាចនឹងឲ្យសាកសពកម្រើកបាន ទើបនាំគ្នាចៀសចេញពីទីនោះទៅ ។ ព្រោះដូច្នោះ ។ ព្រះមានព្រះភាគ ទើបត្រាស់ថា **បានចោលក្នុងព្រៃស្មសានឈ្មោះ វីរណត្ថម្ភកៈ** ។

ពាក្យថា តេនុបសង្កមិ មានពាក្យអធិប្បាយដូច្នេះ ព្រោះហេតុអ្វី ឱរសរបស់ស្តេចលិច្ឆវី ឈ្មោះសុនក្ខត្តៈ ទើបចូលទៅរក បានជ្រាបថា សុនក្ខត្តៈ ឱរសរបស់ស្តេចលិច្ឆវីនោះ គិតថា ពាក្យពោលរបស់ព្រះសមណ-គោតម រមែងពិតប្រាកដ ក៏ធម្មតាថា អ្នកស្លាប់នឹងក្រោកឡើងនិយាយ នឹងអ្នកដទៃ រមែងមិនមាន ណ្ហើយចុះ យើងនឹងទៅសួរ បើព្រះសមណ-គោតមត្រាស់ប្រាប់ក្តី បើមិនប្រាប់ក្តី យើងនឹងគ្របសង្កត់ព្រះសមណគោតម ដោយមុសាវាទ ។ សុនក្ខត្តៈ ចូលទៅគាល់ព្រោះហេតុនេះ ។ បទថា អាកោដេត្វសិ ប្រែថា គោះ (ដោយបាតដៃ) ។ មានពាក្យសួរថា សាកសព របស់អ្នកដែលស្លាប់ហើយ រមែងមិនអាចនឹងក្រោកឡើងមកនិយាយបាន អ្នកបួសអាក្រាតរូបនោះ បានពោលពាក្យថា “**ម្នាលអ្នកមានអាយុ យើងដឹង**” បានយ៉ាងណា ។ មានពាក្យឆ្លើយថា គេនិយាយបានដោយពុទ្ធានុភាព ។ បានជ្រាបថា ព្រះមានព្រះភាគ បាននាំកោរក្ខត្តិយៈ ពីកំណើតអសុរ ឲ្យ

ចូលស្ថិតក្នុងសាកសព ហើយឲ្យនិយាយ ។ ន័យមួយទៀត ព្រះអង្គទ្រង់បាន ឲ្យសាកសពនោះនិយាយ ។ ព្រោះវិស័យព្រះពុទ្ធ ជាអចិន្តេយ្យ ( អ្នកដទៃមិនគួរគិត ) ពាក្យថា តថេវ តំ វិចាកំ បានដល់ ផលរបស់ពាក្យនិយាយនោះ កើតហើយយ៉ាងនោះ ស័ព្ទថា វិចាកំ នោះ ចាត់ជាលិង្គវិបល្លាស ។ អត្ថន័យដ៏ត្រឹមត្រូវ ក៏គឺ តថេវ សោ វិចាកោ ។ ចំណែកអាចារ្យពួកខ្លះពោលថា វិបក្កំ ក៏មាន ។ អត្ថន័យ គឺ កើតហើយ ។ សូម្បីគ្រានេះគួរនឹងបានប្រមូលបាដិហារ្យមក ក៏ហេតុការណ៍ទាំងអស់នេះ ជាបាដិហារ្យ ៥ យ៉ាង គឺ ព្រះតម្រាស់ថា អ្នកបួសស្រោតនោះ នឹងស្លាប់ក្នុងថ្ងៃទី ៧ គេក៏ស្លាប់តាមព្រះតម្រាស់នោះ នេះជាបាដិហារ្យប្រការទី ១ , ព្រះតម្រាស់ថា គេនឹងស្លាប់ដោយរោគ " **អលសក:** " គេក៏ស្លាប់ដោយរោគអលសក: ពិត នេះជាបាដិហារ្យប្រការទី ២ , ព្រះតម្រាស់ថា អ្នកបួសស្រោតនោះ នឹងទៅកើតក្នុងពួកអសុរឈ្មោះ **កាលកញ្ជិកា** គេក៏កើតក្នុងកពអសុរពិត នេះជាបាដិហារ្យប្រការទី ៣ , ព្រះតម្រាស់ថា ពួកតិរ្ថិយនឹងចោលសាកសពទុកក្នុងព្រៃស្មសានឈ្មោះ វីរណត្ថម្ភក: គេក៏ត្រូវបោលក្នុងព្រៃស្មសាននោះពិត នេះជាបាដិហារ្យប្រការទី ៤ , ព្រះតម្រាស់ថា គេនឹងមកអំពីទី

ដែលខ្លួនកើតហើយ ពោលនឹងសុនក្ខត្តៈ ឱរសស្តេចលិច្ឆវី គេក៏ពោលពិត នេះជាបាដិហារ្យប្រការទី ៥ ។

## វត្តរបស់អចេល ៧ យ៉ាង

[៥] ពាក្យថា កឡារមដ្ឋកោ គឺ អ្នកបួសស្រោត អ្នកមានធ្មេញនិងពុកមាត់ដុះចេញមក ឬពាក្យថា កឡារមដ្ឋកោ នេះ ជាឈ្មោះរបស់អ្នកបួសស្រោតនោះប៉ុណ្ណោះ ។ បទថា លាភគ្គប្បត្តោ គឺ អ្នកដល់ភាពជាកំពូលដោយលាភ អធិប្បាយថា អ្នកប្រសព្វលាភដ៏ល្អកំពូល បទថា យសគ្គប្បត្តោ គឺ ប្រសព្វភាពដ៏កំពូលដោយយស គឺ មានបរិវារដ៏ច្រើន ។ បទថា វត្តបទានិ គឺ វត្តបដិបត្តិទាំងអស់ ឬវត្តបដិបត្តិចំណែកខ្លះ បទថា សមត្តានិ បានដល់ កាន់យក ។ បទថា សមាទិន្នានិ ជាវេវចនៈរបស់បទថា សមត្តានិ នុ៎ះឯង ។ ពាក្យថា បុរត្ថិមេន វេសាលឹ បានដល់ ក្នុងទិសបូព៌ាជិតក្រុងវេសាលី ។ បទថា ចេតិយំ គឺ ជាចេតិយស្ថានរបស់យក្ខ ។ គ្រប់ៗ បទ ក៏មានន័យដូច្នេះ ។

ពាក្យថា យេន អចេលោ មានអធិប្បាយថា សុនក្ខត្តៈ ជាឱរស

ស្ដេចលិច្ឆវី ធ្វើវត្តព្រះមានព្រះភាគហើយ បានទៅកាន់ទិសដែលអចេល-បរិព្វាជកឈ្មោះថា **កឡារមដ្ឋកៈ** នៅ ។ បទថា បញ្ហំ បុច្ឆិ គឺ សួរបញ្ហាដែលប្រកបដោយត្រៃលក្ខណ៍យ៉ាងជ្រាលជ្រៅ ។ បទថា ន សម្បាយាសិ អធិប្បាយថា កឡារមដ្ឋកបរិព្វាជក មិនបានប្រព្រឹត្តទៅដោយញាណគតិដែលត្រូវផ្លូវ គេឆ្លើយខុសផ្ទាតសូម្បីតែមួយបញ្ហានោះៗ ដូចបុគ្គលខ្វាក់ភ្នែកដើរអើលដួលក្នុងទីរដិបរដុប គេមើលមិនឃើញខាងដើម ខាងចុងរបស់បញ្ហា ។ម្យ៉ាងទៀត បទថា ន សម្បាយាសិ សេចក្ដីថា មិនឲ្យដល់ព្រម ( ដោយ ) បញ្ហា គឺ មិនអាចនឹងឲ្យបញ្ញាកើតឡើងពោល ( ឆ្លើយ ) បាន កឡារមដ្ឋក-បរិព្វាជក កាលមិនអាចនឹងឆ្លើយបាន ក៏ឈរដាក់គ្រាប់ភ្នែកទៅមក និយាយថា លោកនៅក្នុងសម្នាក់របស់អ្នកដែលមិនបានទទួលការសិក្សា បួសក្នុងទីមិនមែនឱកាស ដើរសួរបញ្ហាទូទៅ ចូរចៀសទៅ កុំមកឈរក្នុងទីនេះ ។

ពាក្យថា កោបញ្ច ទោសញ្ច អបច្ចយញ្ច បាត្វាកាសិ មានអធិប្បាយដូច្នេះ កឡារមដ្ឋកបរិព្វាជក បានសម្ដែងសេចក្ដីក្រោធ គឺ អាការកម្រើកទោសៈ មានអាការប្រទូសរ៉ាយ និងការមិនរីករាយ គឺ ទោមនស្សដែលជាអាការនៃការមិនត្រេកអរ ។ បទថា អាសាទិយិដ្ឋាសេ បានដល់

បានរកពាន គឺ បៀតបៀន ។ ពាក្យថា មា វត នោ អហោសិ ប្រែថា ឱហ្ន៎ ប្រការនោះមិនគប្បីមានដល់យើង ។ បាលីថា មំ វត នោ អហោសិ ដូច្នេះក៏មាន ។ បណ្តាបទទាំងនោះ បទថា មំ ជាទុតិយាវិភត្តិ ប្រើក្នុងអត្ថឆដ្ឋីវិភត្តិ ។ សេចក្តីថា ប្រការនោះ បានមានដល់យើងហើយហ្ន៎ ក៏ឯសុនក្ខត្តៈ គ្រាគិតយ៉ាងនោះហើយ ទើបអង្គុយប្រហោងសូមខមាទោស **កឡារមដ្ឋកបរិព្វាជក** នោះថា បពិត្រលោកដ៏ចម្រើន សូមលោកមេត្តាអត់ទោសដល់ខ្ញុំផងចុះ សូម្បីបរិព្វាជកនោះ ក៏ពោលថា តាំងពីឥឡូវនេះជាដើមទៅ អ្នកនឹងមិនត្រូវសួរបញ្ហាដទៃណា ។ សុនក្ខត្តៈឱរសស្តេចលិច្ឆវីពោលថា ខ្ញុំសូមធានាថា នឹងមិនសួរបញ្ហាទៀត បរិព្វាជកនោះពោលថា បើដូច្នោះ លោកចូរទៅ យើងអត់ទោសឲ្យដល់លោក ហើយបង្គាប់សុនក្ខត្តៈ ឱរសស្តេចលិច្ឆវីត្រឡប់ទៅ ។

បទថា បរិហិតោ ប្រែថា ស្លៀកដណ្តប់ សេចក្តីថា ត្រឡប់ស្លៀកដណ្តប់សំពត់វិញ ។ បទថា សានុចារិកោ សេចក្តីថា កិរិយាលោកហៅ **អនុចារិកា** ។ បុគ្គលដែលមានកិរិយា លោកហៅ **សានុចារិក** អធិប្បាយថា អចេលឈ្មោះ កឡារមដ្ឋកៈ លះការប្រព្រឹត្តព្រហ្មចរិយៈនោះៗ ហើយ

មានកិរិយា ។ បទថា ឱឡារិកំ បានដល់ ស៊ីបាយខ្លះ ស៊ីនំខ្លះ ក្រៃលែងជាង គឺ ផឹកសុរា និងស៊ីសាច់សត្វ ។ បទថា យសា និហីនោ សេចក្តីថា គេប្រសព្វនូវភាពខ្ពង់ខ្ពស់ដោយលាភ ភាពខ្ពង់ខ្ពស់ដោយយសណា ក៏វិនាសចាកលាភ និងយសយ៉ាងនោះ ឥទ្ធិបាដិហារ្យដែលខ្ពស់ក្រៃលែងជាងប្រក្រតីធម្មតារបស់មនុស្ស ឈ្មោះថា ជាគុណ ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ព្រោះហេតុនោះ ក្នុងប្រការនេះ គប្បីជ្រាបបាដិហារ្យ ៧ យ៉ាង គឺ ការឈានព្រះបាទទៅបាន ៧ ជំហាន ។

## រឿងអចេលកចាដិកបុត្រ

[៦] បទថា ចាដិកបុត្តោ គឺ ជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះបាដិកៈ ។ បទថា ញាណវាទេន គឺ ជាមួយញាណវាទៈ ។ បទថា ឧបឌ្ឍបថំ សេចក្តីថា បើក្នុងរវាងពួកយើងគប្បីមាន (ផ្លូវឆ្ងាយ) មួយយោជន៍ ព្រះសមណគោតម គប្បីស្តេចយាងទៅពាក់កណ្តាលផ្លូវ យើងក៏គប្បីទៅក្នុងពាក់កណ្តាលផ្លូវ ។ ក្នុងផ្លូវ មានពាក់កណ្តាលផ្លូវជាដើម ក៏ន័យនេះ ។ បុគ្គលដែលដើរទៅបាន ១ ជំហាន នឹងឈ្នះអ្នកមិនបានដើរទៅ ។ បទថា

តេ តត្ថ សេចក្ដីថា ក្នុងទីជួបគ្នានោះ យើងទាំងពីរ ( នឹងធ្វើឥទ្ធិបាដិហារ្យ ដ៏ប្រសើរក្រៃលែងជាងប្រក្រតីធម៌របស់មនុស្ស ) ។ បទថា ឥទ្ធិគុណាំ ឥទ្ធិគុណាហាំ សេចក្ដីថា យើងនឹងធ្វើឲ្យច្រើនជាងនោះ ជាទ្វេគុណៗ ។ **អចេលឈ្មោះ បាដិកបុត្រ** សូម្បីជ្រាបសេចក្ដីដែលខ្លួនមិនអាចធ្វើបាដិហារ្យ ប្រកួតនឹងព្រះមានព្រះភាគ តែក៏ជ្រាបថា អ្នកដែលផ្ដើមធ្វើបាដិហារ្យប្រកួត នឹងបុរសដ៏កំពូល សូម្បីមិនអាចយកឈ្នះបាន ក៏បានទទួលពាក្យសរសើរខ្លះ ទើបពោលយ៉ាងនេះ ។ សូម្បីមនុស្សអ្នកព្រះនគរ ស្ដាប់ពាក្យនោះហើយ ក៏នាំគ្នាគិតថា ធម្មតាបុគ្គលដែលមិនអាច រមែងមិនប្រកាសយ៉ាងនេះ **អចេលកបាដិកបុត្រ** នេះ នឹងជាព្រះអរហន្តពិត ទើបបាននាំគ្នាធ្វើសក្ការៈ ជាច្រើនដល់គេ ។

ពាក្យថា យេនាហាន្តេនុបសង្កមិ សេចក្ដីថា បានឮថា សុនក្ខត្តៈ បានស្ដាប់ថា **អចេលបាដិកបុត្រ** រមែងពោលយ៉ាងនេះ ។ ពេលនោះ **អចេលឈ្មោះថា បាដិកបុត្រ** បានកើតការគិត ( យ៉ាងនេះ ) ព្រោះមាន អធ្យាស្រ័យអាក្រក់ ព្រោះមានការគិតឃើញថោកទាប ។ សុនក្ខត្តៈ ធ្វើវត្ត ព្រះមានព្រះភាគហើយ កាលព្រះមានព្រះភាគស្ដេចចូលព្រះគន្ធកុដិ ទើប

ទៅកាន់សម្នាក់ **អចេលឈ្មោះ បាដិកបុត្រ** ហើយសួរថា បានឮថា លោកពោលពាក្យដូច្នេះឬ ។ គេឆ្លើយថា មែន យើងពោល ។ សុនក្ខត្តៈពោលថា កាលបើដូច្នោះ លោកកុំគិត កុំខ្លាចឡើយ លោកជាអ្នកដែលជិតជិត ចូរនិយាយយ៉ាងនេះទៅ ខ្ញុំជាឧបដ្ឋាករបស់ព្រះសមណគោតម រមែងជ្រាបវិស័យរបស់ព្រះអង្គ ព្រះសមណគោតម នឹងមិនអាចធ្វើបាដិហារ្យនឹងលោកបាន យើងនឹងប្រាប់ដល់ព្រះសមណគោតម ឲ្យកើតសេចក្តីខ្លាច នឹងនាំព្រះអង្គទៅទីដទៃ លោកកុំខ្លាចឡើយ បានលួងលោមអចេលបាដិកបុត្រដរាបធូរស្រាលចិត្ត ទើបទៅកាន់សម្នាក់ព្រះមានព្រះភាគ ដោយហេតុនោះទើបទ្រង់ត្រាស់ថា យេនាហំ តេនុបសង្កមិ ។

ក្នុងពាក្យថា តំ វាចំ ជាដើមនោះ ពាក្យថា **អចេលបាដិកបុត្រ** កាលពោលថា ខ្ញុំមិនមែនជាព្រះពុទ្ធឡើយ បានដើរនិយាយថា ខ្ញុំជាព្រះពុទ្ធ បានពោលពាក្យមិនពិតឡើយ ខ្ញុំមិនមែនជាព្រះពុទ្ធឡើយ ឈ្មោះថា លះបង់វាចានោះ **អចេលឈ្មោះថាបាដិកបុត្រ** អង្គុយគិតក្នុងទីកំបាំងភ្នែក គេគិតថា ខ្ញុំមិនមែនជាព្រះពុទ្ធឡើយរហូត ដល់អស់កាលនោះ បានដើរនិយាយថា ខ្ញុំជាព្រះពុទ្ធ ចាប់ផ្តើមតាំងពីពេលនេះជាដើមទៅ ខ្ញុំមិនមែនជាព្រះពុទ្ធ

ឈ្មោះថា លះបង់សេចក្តីគិតនោះ **បាដិកបុត្រ** កាលលះបង់សេចក្តីគិតថា ខ្ញុំមិនមែនជាព្រះពុទ្ធ តែបានប្រកាន់ទិដ្ឋិអាក្រក់ថា ខ្ញុំជាព្រះពុទ្ធ អ្នកឯងដើរទៅវេហូតដល់អស់កាលប៉ុណ្ណេះ ខ្ញុំលះទិដ្ឋិនេះ ចាប់ផ្តើមពីពេលនេះជាដើមទៅ ឈ្មោះថា លះបង់ទិដ្ឋិនោះ តែបាដិកបុត្រមិនធ្វើយ៉ាងនេះ លោកទើបពោលថា មិនលះបង់វាចានោះ មិនលះបង់សេចក្តីគិតនោះ មិនលះបង់ទិដ្ឋិនោះ ។ បទថា វិបតេយ្យ គឺ សីសៈរបស់គេ គប្បីរបូតចាក.កដូចផ្លែត្នោតទុំរបូតចាកទង ឬគប្បីបែកជា ៧ ចំរៀក ។

បទថា រក្ខតេតំ ។ បទថា ឯកំសេន បានដល់ ចូរទ្រង់រក្សាព្រះវាចានោះ ដោយនិប្បរិយាយ ។ បទថា ឱធារិតា គឺ ពោលហើយ ។ ពាក្យថា អចេលោ ច ភន្តេ ចាដិកបុត្តោ សេចក្តីថា បើ **អចេលកបាដិកបុត្រ** ពោលហើយដោយវាចា ដល់ព្រះមានព្រះភាគដោយចំណែកមួយ ដោយប្រការដូច្នេះ ។

បទថា ទិរូបរូបេន បានដល់ ក្លែងរូប ។ អធិប្បាយថា **អចេលក-ឈ្មោះបាដិកបុត្រ** មកដោយរូប ដែលក្លែងពីសភាពពីដើម គឺ លះបង់រូបរបស់មនុស្សមកនៅចំពោះព្រះភក្ត្រព្រះមានព្រះភាគ ដោយការធ្វើមិនប្រាកដ

ឬដោយរូបផ្សេង ៗ ដូចរាជសីហ៍ និងខ្លាជាដើម ។ ពាក្យថា តុច្ឆស្ស ភគវតោ មុសា សេចក្តីថា កាលបើដូច្នោះ ព្រះតម្រាស់នោះ របស់ព្រះមានព្រះភាគ គប្បីជាពាក្យកុហក គឺ ( **អចេលកបាដិកបុត្រ** ) គ្រប សង្កត់ដោយមុសាវាទ ។ បានឮថា ព្រះមានព្រះភាគ មិនគប្បីត្រូវគ្រប សង្កត់ដោយមុសាវាទដទៃ វៀរតែមុសាវាទប្រការនោះ ។ បទថា ទ្វយ- គាមិនី សេចក្តីថា មានព្រះវាចាមិនមានពីរ គឺ មានដោយសង្ខេប តែ មិនមានខ្លឹមសារដែលជាប្រយោជន៍ ។ ពាក្យថា **មានដំណើរបែកជាពីរ** នោះ ជាឈ្មោះវាចាដែលសូន្យទទេចាកប្រយោជន៍ និងមិនមានផល ។

ពាក្យថា អជិតោបិ នាម លិច្ឆវីនំ សេនាបតិ សេចក្តីថា បានជ្រាប ថា អជិតៈនោះ ជាឧបដ្ឋាករបស់ព្រះមានព្រះភាគ គេបានស្លាប់ហើយ ។ គ្រានោះ ពួកមនុស្សបានធ្វើឈាបនកិច្ចសពគេ ហើយសួរបាដិកបុត្រថា សេនាបតីកើតទីណា បាដិកបុត្រឆ្លើយថា កើតក្នុងមហានរក ។ ក៏ឯបាដិ- កបុត្រ លុះពោលយ៉ាងនេះហើយ និយាយទៀតថា សេនាបតីរបស់ពួក លោក មកកាន់សម្នាក់របស់យើង ហើយស្រែកយំថា យើងមិនធ្វើតាម ពាក្យរបស់លោក ជឿក្នុងវាទៈរបស់សមណគោតម ក៏បានទៅកើតក្នុង

នរកហើយ ។

## ព្រះមានព្រះភាគស្តេចចូលទៅកាន់ អារាមរបស់អចេលចាជិកបុត្រ

[៧-៨] ក្នុងពាក្យថា តេនុបសង្កមឹ ទិវា វិហារាយ នេះ សួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគ ទើបមិនត្រាស់ថា ដើម្បីធ្វើបាដិហារ្យ ។ ឆ្លើយថា ព្រោះមិនមានហេតុ សូម្បីការប្រឈមមុខដាក់គ្នារវាងបាដិកបុត្រ នឹងព្រះមានព្រះភាគមិនមាន ការធ្វើបាដិហារ្យនឹងមានអំពីណា ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបមិនត្រាស់យ៉ាងនោះ ត្រាស់ថា ទិវា វិហារាយ ។

បទថា គហបតិនេចយិកា បានដល់ គហបតីមហាសាល ។ ពិតហើយ គហបតីទាំងនោះបានសន្សំទ្រព្យ និងស្រូវអង្ករជាច្រើនទុក ព្រោះដូច្នោះ គហបតីទាំងនោះ លោកទើបហៅថា នេចយិកា ។ បទថា អនេកសហស្សា បានដល់ គណនាមិនបាន សូម្បីដោយចំនួនពាន់ ។ បានឮថា បុគ្គលដទៃវៀរសុនក្ខត្តៈ រមែងមិនអាចឲ្យបរិស័ទធំប្រជុំគ្នាបាន យ៉ាងនេះ ព្រោះហេតុនោះឯង ព្រះមានព្រះភាគបាននាំសុនក្ខត្តៈត្រាច់ទៅ រហូតដល់

អស់កាលប្រមាណប៉ុណ្ណោះ ។ សេចក្តីតក់ស្លុតនៃចិត្ត ឈ្មោះថា **ភ័យ** , សេចក្តីញាប់ញ័រនៃសរីរៈគ្រប់ចំណែក ឈ្មោះថា ឆម្ភិតត្តំ , ការដែលទាំងឡាយបះឡើង ឈ្មោះថា លោមហំសោ ។ បានឮថា **អចេលកឈ្មោះ-បាដិកបុត្រ** គិតថា យើងបានពោលពាក្យធំក្រៃលែង ធ្វើខុសជាមួយបុគ្គលដ៏ខ្ពង់ខ្ពស់ក្នុងលោក ព្រមទាំងទេវលោក ភាពជាព្រះអរហន្ត ឬហេតុនៃការធ្វើបាដិហារ្យមិនមានខាងក្នុងយើងឡើយ ចំណែកព្រះសមណគោតម នឹងធ្វើបាដិហារ្យ កាលបើដូច្នោះ មហាជនឃើញបាដិហារ្យរបស់ព្រះសមណគោតមនោះហើយ នឹងបៀតបៀនដោយគ្រឿងប្រហារ មានកំណាត់ឈើ ដុំដីនិងអាជ្ញាជាដើម ដោយពោលថា ឥឡូវនេះ លោកមិនអាចធ្វើបាដិហារ្យបាន ព្រោះហេតុអ្វីទើបមិនដឹងប្រមាណខ្លួនឯង មកតាំងខ្លួនជាគូចំពោះនឹងបុគ្គលដ៏ខ្ពង់ខ្ពស់ក្នុងលោក សម្តែងកិរិយារុករាន ។ ព្រោះដូច្នោះសេចក្តីខ្លាច សេចក្តីភ័យខ្លាច ឬការព្រឺព្រួចរោម ទើបបានកើតឡើងដល់គេ ព្រោះស្តាប់ដំណឹងការប្រជុំគ្នារបស់មហាជន និងប្រការដែលស្តេចមករបស់ព្រះ-មានព្រះភាគ ។ អចេលកបាដិកបុត្រនោះ ប្រាថ្នានឹងផុតចាកទុក្ខនោះ ទើបបានទៅអារាមរបស់បរិព្វាជក ឈ្មោះថា តិណ្ឌុកខាណុ ។ ដើម្បីនឹងសម្តែង

អត្ថន័យនោះ ព្រះធម្មសង្គាហកាចារ្យ ទើបពោលថា អថ ខោ ភគ្គវ ជាដើម ។

បណ្តាបទទាំងនោះ បទថា ឧបសង្កមិ សេចក្តីថា **អចេលកឈ្មោះបាដិកបុត្រ** មិនបានចូលទៅរកតែម្យ៉ាង ក៏កាលចូលទៅហើយ ក៏ចូលទៅកាន់អារាមរបស់បរិព្វាជកឈ្មោះឆ្ងាយបានកន្ទុះយោជន៍ មិនទាន់បានការសប្បាយចិត្ត ទើបចូលទៅផ្លូវផ្នែកខាងចុងបំផុតរបស់អារាម ជ្រើសរើសបានស្ថានទីជាព្រៃមួយកន្លែងខាងចុងអារាម អង្គុយលើផ្ទាំងថ្ម ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រិះរិះថា បើអចេលកបាដិកបុត្រនេះជាជនពាល ជឿពាក្យរបស់បុគ្គលខ្លះ គប្បីមកក្នុងស្ថានទីនេះសោត បុគ្គលពាលចូរកុំវិនាសឡើយ ទើបទ្រង់អធិដ្ឋានថា សូមផ្ទាំងថ្មដែលអង្គុយ ចូរជាប់នឹងសរីរៈរបស់គេ ព្រមនឹងចិត្តដែលអធិដ្ឋាន ទីអង្គុយនោះ បានជាប់នឹងសរីរៈរបស់គេ ។ អចេលកបាដិកបុត្រនោះ ដូចជាត្រូវចងដោយគ្រឿងចង គឺ ច្រវាក់ធំ និង ដូចត្រូវកាត់ជើង ដូច្នោះ ។ បទថា អស្សោសិ សេចក្តីថា ពួកបរិស័ទនាំគ្នាស្វែងរក **អចេលកឈ្មោះបាដិកបុត្រ** ខាងនេះ និងខាងនោះ កាលត្រូវបុរសណាម្នាក់ចងជាប់តាមស្នាមជើងរបស់អចេលកឈ្មោះបាដិកបុត្រ ដឹង

ទីអន្ធយ មកហើយ សួរថា ពួកលោកស្វែងរកអ្នកណា ម្នាក់ៗ នាំគ្នាឆ្លើយថា **អចេលកឈ្មោះបាដិកបុត្រ** បានស្តាប់វាចាដែលបុរសនោះឆ្លើយថា **អចេ-លកឈ្មោះបាដិកបុត្រ** នោះ អន្ធយនៅក្នុងអាពាមបរិព្វាជកឈ្មោះថា តិណ្ឌុ-កខាណុ ។ បទថា សំសប្បតិ បានដល់ ជ្រប់សិរសៈ គឺ នៅក្នុងអាពាម នោះឯង ។ គូថ លោកហៅថា ចាវឡ ។ បទថា បរាភូតរូបោ បានដល់ ជាអ្នកបរាជ័យហើយ គឺ វិនាសហើយ ។

បទថា គោយុគេហិ សេចក្តីថា ទឹមហើយដោយគូគោ ចំនួនរយ ឬចំនួនពាន់ ។ បទថា អាវិញ្ឆេយ្យាម ប្រែថា គប្បីទាញមក ។ បទថា ឆិជ្ជេរុំ បានដល់ គប្បីដាច់ចេញឬ **អចេលកឈ្មោះបាដិកបុត្រ** គប្បីដាច់ចេញក្នុងទីចង ។

## ការប្រៀបធៀបដោយសីហាមិគរាជ និងចចកចាស់

**[៩]** បទថា ធារុបត្តិកន្តេវាសី បានដល់ ជាសិស្សនៃជាងក្រឡឹងឈើ ។

បានស្តាប់ថា សិស្សនៃជាងក្រឡឹងឈើនោះ មានការគិតថា ចូរ

លើកបាដិហារ្យទុកចុះ ព្រះសមណគោតមពោលថា **អចេលកឈ្មោះបាដិកបុត្រ** នឹងមិនក្រោកឡើងចាកអាសនៈ ណ្ហើយចុះ យើងនឹងទៅឲ្យបាដិកបុត្រនោះក្រោកឡើងចាកអាសនៈដោយឧបាយណាមួយ ដោយហេតុត្រឹមតែប៉ុណ្ណោះ ព្រះសមណគោតមក៏នឹងបរាជ័យ ព្រោះដូច្នោះ សិស្សនៃជាងក្រឡឹងឈើទើបពោលយ៉ាងនេះ ។ បទថា សីហស្ស សេចក្ដីថា ស្ដេចសីហមិគរាជមាន ៤ ប្រភេទ គឺ ស្ដេចសីហតិណរាជ ស្ដេចសីហកាឡរាជ ស្ដេចសីហបណ្ឌុរាជ និងស្ដេចសីហកេសររាជ ។ បណ្ដាស្ដេចសីហរាជទាំងនោះ ស្ដេចសីហកេសររាជ បានដល់ ជាសត្វដ៏ប្រសើរ ។ ក្នុងទីនេះ លោកបំណងយកស្ដេចសីហកេសររាជ ។ បទថា មិគរញ្ញោ បានដល់ ជារាជានៃសត្វជើងបួនគ្រប់ប្រភេទ បទថា អាសយំ បានដល់ ស្ថានទីនៅ ។ បទថា សីហនាទំ គឺ បន្លឺ បែបមិនខ្លាច ។ បទថា គោចរាយ បក្កមេយ្យំ សេចក្ដីថា គប្បីត្រាច់ទៅដើម្បីរកអាហារ ។ ពាក្យថា វរំ វរំ បានដល់ ហ្វូងម្រឹគដែលធាត់ៗ ប្រសើរៗ ។ បទថា មុទុមំសានិ បានដល់ សាច់ដែលទន់ល្មៃ ។ បាលីថា មធុមំសានិ ក៏មាន ។ អធិប្បាយថា សាច់ដែលមានរសផ្អែម ។ បទថា អជ្ឈុបេយ្យំ បានដល់ គប្បីចូលទៅ បទថា

សីហានាទំ ននិត្វា សេចក្តីថា បន្លឺហើយដោយសេចក្តីករុណា ដែលអាស្រ័យភាពជាអ្នកខ្លាំងក្លារបស់ខ្លួនថា សត្វពួកណាមានកំលាំងតិច សត្វពួកនោះចូរចៀសចេញទៅ ។ បទថា វិឃាសសំវឌ្ឍោ សេចក្តីថា ចម្រើនដោយសាច់ដែលជាសំណល់ គឺ ស៊ីសាច់ដែលជាសំណល់ពីសត្វដទៃស៊ីហើយក៏ធំធាត់ឡើង ។ បទថា ទិត្តោ គឺ ធំធាត់ បានដល់ មានរាងកាយធាត់ ។ បទថា ពលវា គឺ សម្បូរណ៍ដោយកម្លាំង ។ បទថា ឯតទហោសិ បានដល់ មានហើយ ព្រោះហេតុអ្វី ។ ព្រោះទោសនៃអស្មិមានះ ។

ក្នុងសេចក្តីនោះ មានអនុបុព្វិកថា ដូចតទៅនេះ ៖

បានឮថា ថ្ងៃមួយ សីហរាជនោះ ត្រឡប់ពីទីស្វែងរកអាហារ បានឃើញចចកនោះកំពុងរត់គេច ព្រោះសេចក្តីខ្លាច កើតសេចក្តីករុណា ទើបនិយាយថា សម្លាញ់កុំខ្លាចឡើយ ឈប់សិន លោកឈ្មោះអ្វី ។ ចចកឆ្លើយថា ខ្ញុំឈ្មោះ ជម្ពុកៈ លោក ។ សីហរាជ ទើបនិយាយថា ជម្ពុកៈ អ្នកមានវ័យស្មើគ្នា តាំងអំពីនេះទៅ អ្នកអាចឧបដ្ឋាកយើងបានឬ ។ ចចកតបថា ខ្ញុំនឹងឧបដ្ឋាកលោក ។ តាំងពីនោះមក ចចកនោះ ក៏ឧបដ្ឋាក ( សីហរាជ ) ។ សីហរាជ កាលត្រឡប់ពីទីស្វែងរកអាហារ ក៏នាំសាច់

ចំណិតធំមកឲ្យ ។ ចចកនោះទំពារស៊ីសាច់ចំណិតធំនោះហើយ ក៏នៅលើផែនថ្មក្នុងទីមិនឆ្ងាយ ។ លុះវេលាកន្លងទៅពីរបីថ្ងៃប៉ុណ្ណោះ ចចកនោះក៏ធំធាត់ មានដើម.កធំ ។ គ្រានោះ សីហរាជនោះ បានពោលនឹងចចកនោះថា អើ! ជម្ពុកៈ អ្នកនឹងអាចនិយាយថា ក្នុងវេលាដែលយើងពត់កាយ អ្នកអាចនឹងឈរក្នុងទីមិនឆ្ងាយ ហើយនិយាយថា បពិត្រលោកម្ចាស់ លោកចូរក្រោធបានឬទេ ។ ចចកឆ្លើយថា អាចលោកម្ចាស់ ។ ក្នុងវេលាដែលសីហរាជពត់កាយ ចចកបានធ្វើតាមដែលបង្គាប់ ព្រោះការធ្វើតាមនោះ ។ សីហរាជ ទើបមានអស្មិមានះយ៉ាងក្រៃលែង ។ តមកថ្ងៃមួយ ចចក ដល់កាលផឹកទឹកក្នុងស្រះ បានឃើញស្រមោលរបស់ខ្លួន ឃើញរាងខ្លួនធំធាត់និងដើមក.ធំ មិនធ្វើទុកក្នុងចិត្តថា យើងជាចចកដែលចម្រើនហើយ តែសម្គាល់ថា សូម្បីយើងក៏ជាសីហរាជ ទើបបាននិយាយពាក្យនេះនឹងខ្លួនថា អើ! ជម្ពុកៈ ការដែលអត្តភាពនេះ របស់អ្នកឯង បរិភោគសាច់ដែលជាសំណល់អ្នកដទៃគួរហើយឬ អ្នកឯងមិនមែនកូនប្រុសឬ សូម្បីសីហរាជក៏មានជើងបួន ចង្កូមពីរ ត្រចៀកពីរ និងមានកន្ទុយមួយ សូម្បីអវយវៈទាំងអស់របស់អ្នកឯងក៏មានដូចសីហរាជ អ្នកឯង មិនមែនមានកំលាំងត្រឹម

តែកេសរផ្កាឈើតែម្យ៉ាងប៉ុណ្ណោះ ។ កាលចចកបានគិតយ៉ាងនេះ អស្មិមានះក៏កម្រើកឡើង ។ គ្រានោះ ចចកនោះ បានកើតការសម្គាល់ថា យើង គឺនរណាជាដើម ព្រោះទោសនៃអស្មិមានះនោះ ។

បណ្ដាបទទាំងនោះ បទថា កោ ចាហំ សេចក្ដីថា យើង គឺនរណា សីហមិគរាជ គឺ មិនមែនញាតិ មិនមែនជាចៅហ្វាយរបស់យើង អធិប្បាយថា យើងនឹងធ្វើការឱនលំទោនដល់សត្វដំធ្វើអ្វី ។ បទថា សិគាលកំយេវ បានដល់ ស្រែកដូចចចកនុ៎ះឯង ។ បទថា កេរណ្ឌកំយេវ បានដល់សម្លេងមិនគួរស្រឡាញ់ និងមិនគួរពេញ ចិត្ត ។ ពាក្យថា កេ ច ឆេវ សិគាលេ សេចក្ដីថា ចចកដែលទន់ខ្សោយ នឹងដូចម្ដេច ។ ពាក្យថា កេ បន សីហនាទេ បានដល់ ការបន្លឺបែបសីហៈនឹងដូចម្ដេច ។ អធិប្បាយថា ក៏ការបន្លឺរបស់ចចក និងរបស់សីហរាជ មានអ្វីជាប់ទាក់ទងគ្នា ។

បទថា សុគតាបទានេសុ បានដល់ តាមសិក្ខា ៣ យ៉ាង ដែលជាលក្ខណៈរបស់ព្រះសុគត គឺ ជាសាសនារបស់ព្រះសុគត ។ ក៏ព្រះសុគតនោះ ញុំាំងជីវិតតាមបែបសិក្ខា ៣ យ៉ាងនោះ យ៉ាងណា ។ ពិតហើយ ពុទ្ធសាសនិកជន កាលថ្វាយបច្ច័យ ៤ ចំពោះព្រះសុគតនោះ រមែងថ្វាយ

ដោយគិតថា យើងនឹងថ្វាយ ( បច្ច័យ ៤ ) ចំពោះព្រះសម្មាសម្ពុទ្ធ ដែលសម្បូរណ៍ដោយគុណ មានសីលជាដើម ( ចំណែក ) អចេលកបាជិកបុត្រនោះ មិនមែនជាព្រះពុទ្ធ កាលបរិភោគបច្ច័យដែលជនកំណត់ថ្វាយព្រះពុទ្ធឈ្មោះថា មានជីវិតប្រព្រឹត្តទៅក្នុងសាសនារបស់ព្រះសុគត ។ បទថា សុគតាតិរិត្តានិ អធិប្បាយថា បានឮថា ប្រជាជនកាលនឹងថ្វាយភោជនដល់ព្រះពុទ្ធ ពួកទាំងនោះ បានថ្វាយដល់ព្រះពុទ្ធ និងសាវករបស់ព្រះពុទ្ធពួកទាំងនោះ ខាងក្រោយ ទើបឲ្យអាហារដែលនៅសល់ក្នុងវេលាល្ងាច ដល់ **អចេលកឈ្មោះបាជិកបុត្រ** នេះឈ្មោះថា បរិភោគអាហារដែលជាសំណល់ព្រះសុគត ដោយប្រការដូច្នេះ ។ បទថា តថាគតេ សេចក្តីថា លោកសម្គាល់ថា ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ជាបុគ្គលដែលគប្បីបៀតបៀនគឺ គប្បីរុករាន ។ មយ៉ាងទៀត បទថា តថាគតេ ជាដើម ជាទុតិយាវិភត្តិពហុវចនៈ ។ សូម្បីបទថា អាសាទេតុំ នេះ ក៏ជាពហុវចនៈដូចគ្នា លោកពោលថា ដូចជាឯកវចនៈ ។ បទថា អាសាទនា បានដល់ ការបៀតបៀនថា " យើងនឹងធ្វើបាដិហារ្យជាមួយព្រះពុទ្ធ " ។

បទថា សមេក្ខិយាន ប្រែថា ពិចារណាហើយ គឺ សម្គាល់ហើយ ។

បទថា អមញ្ញិ ប្រែថា បានប្រកាន់ខ្លួន ។

បទថា កោត្ថុ សំដៅយកឆ្កែចចក ។

[១០] ពាក្យថា អត្តានំ វិឃាសេ សមេក្ខិយ បានដល់ បានឃើញអត្តភាពធាត់ជំក្នុងទឹកដែលថ្លា ក្នុងស្រះទឹក ។ បទថា យាវត្តានំ ន បស្សតិ សេចក្តីថា រមែងមិនឃើញខ្លួនតាមសេចក្តីពិត យ៉ាងនេះថា យើងជាចចក ដល់កាលធំធាត់ឡើង ព្រោះសាច់ដែលជាសំណល់របស់ស្តេចសីហមិគរាជ ។ បទថា ព្យគ្ឃោតិ មញ្ញតិ បានដល់ រមែងសម្គាល់ថា យើងជាស្តេចសីហមិគរាជ ឬប្រកាន់ខ្លួនថា យើងមានកម្លាំងស្មើនឹងសីហៈជាខ្លាធំពិត ។

[១១] បទថា ភុត្វាន ភេណ្ឌេ បានដល់ ស៊ីកង្កែបតាមអណ្តូង ។ បទថា ខលមូសិកាយោ សេចក្តីថា ស៊ីកណ្តុរក្នុងលានស្រូវ ។ បាទគាថាថា កដសីសុ ខិត្តានិ ច កូណបានិ សេចក្តីថា ស៊ីសាកសពដែលគេបោលក្នុងព្រៃស្មសាន ។ បទថា មហាវនេ គឺ ក្នុងព្រៃធំ ។ បទថា សុញ្ញវនេ គឺ ក្នុងព្រៃស្ងាត់ ។

បទថា វិវឌ្ឍោ គឺ ធំធាត់ហើយ ។

*ពាក្យថា តថេវ សោ សិគាលកំ អនធិ សេចក្តីថា ចចកនោះសូម្បីធំធាត់បានយ៉ាងនេះ ក៏នៅសម្គាល់ថា យើងជាមិគរាជ ក៏ស្រែកដូចសុនខចាស់ ដូចជាចចកដែលមិនមានកម្លាំងក្នុងកាលមុន ដូច្នោះ ។ សិស្សរបស់ជាងក្រឡឹងឈើ ឈ្មោះជាលិយៈ បានរុករានបាដិកបុត្រនោះហើយថា លោកបរិភោគអាហារដែលជាសំណល់ ហើយជាប់នៅក្នុងលាភសក្ការៈ ដូចខ្មែចចកដែលស៊ីសត្វ មានកន្អែបជាដើម ហើយធំធាត់ឡើង ដូច្នោះដោយគាថាសូម្បីនេះ ។*

**[១២]** *បទថា* ឆាគេហិ *គឺ ដោយពួកដំរី ។ បទថា* មហាពន្ធនា *គឺ ឲ្យផុតពីគ្រឿងចង គឺ កិលេសធំ ។ បទថា* មហាវិទុគ្គា *សេចក្តីថា ឱឃៈ ៤ យ៉ាង ឈ្មោះថា អន្លង់ធំ ឡើងពីអន្លង់ធំនោះហើយ ឲ្យតាំងនៅលើគោក គឺ ព្រះនិព្វាន ។*

## ពោលអំពីច្បាប់ធម្មាប់ជាដើម

**[១៣]** *ព្រះអដ្ឋកថាចារ្យ លុះសម្តែងបទអនុសន្ធិថា ព្រះមានព្រះភាគទ្រង់មិនធ្វើឥទ្ធិបាដិហារ្យ ដោយកថាមគ្គប្រមាណប៉ុណ្ណោះហើយ ឥឡូវនេះ*

កាលទ្រង់សម្តែងអនុសន្ធិនៃបទនេះថា ឆ អត្តញ្ញំ បញ្ញបេតិ ទើបផ្តើមទេសនាថា អត្តញ្ញញាហំ ជាដើម ។

បណ្តាបទទាំងនោះ បទថា អត្តញ្ញញាហំ សេចក្តីថា ម្នាលភគ្គវៈ តថាគត រមែងដឹងច្បាស់នូវវត្ថុដែលលោកសម្មតិថា ខ្ពង់ខ្ពស់ និងចរិយាវត្តដែលកើតឡើងរបស់លោក ។ បទថា តញ្ច បជានាមិ សេចក្តីថា តថាគតមិនមែនមិនជ្រាបច្បាស់វត្ថុដែលលោកសម្មតិថា ខ្ពង់ខ្ពស់តែម្យ៉ាងប៉ុណ្ណោះ រមែងដឹងច្បាស់វត្ថុដែលលោកសម្មតិថា ខ្ពង់ខ្ពស់នោះផង ហើយដឹងច្បាស់ជាងនោះ គឺ ជ្រាបច្បាស់តាំងអំពីសីល សមាធិ រហូតដល់ព្រះសព្វញ្ញុ-តញ្ញាណ ។ ពាក្យថា តញ្ច បជានំ ឆ បរាមសាមិ សេចក្តីថា តថាគតសូម្បីកាលជ្រាបច្បាស់នូវវត្ថុនោះ ក៏មិនប្រកាន់មាំដោយអំណាចនៃតណ្ហាទិដ្ឋិ និងមានះថា យើងរមែងដឹងច្បាស់ដល់វត្ថុឈ្មោះនេះ ព្រះមានព្រះភាគទ្រង់សម្តែងថា ព្រះតថាគតមិនមានការប្រកាន់មាំ ។ ពាក្យថា បច្ចត្តញ្ញេវ និព្វុតិ វិទិតា បានដល់ ទ្រង់ជ្រាបការរលត់កិលេសក្នុងព្រះអង្គ ដោយព្រះអង្គតែម្យ៉ាង ។

ពាក្យថា យទភិជានំ តថាគតោ គឺ ព្រះតថាគតទ្រង់ដឹង គឺ ទ្រង់

ជ្រាបការរលត់កិលេស ។

ពាក្យថា នោ អនយំ អាបជ្ជតិ មានអធិប្បាយថា ព្រះតថាគត រមែងមិនដល់ **អនយៈ** គឺ ទុក្ខ បានដល់ សេចក្តីវិនាស ដូចតិរ្ថិយដែលមិនជ្រាបព្រះនិព្វាន ដូច្នោះ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលសម្តែងដល់វត្ថុដែលពួកតិរ្ថិយបញ្ញត្តិថា ខ្ពង់ខ្ពស់ ទើបត្រាស់ថា សន្តិ ភគ្គវ ជាដើម ។ បណ្តាបទទាំងនោះ បទថា ឥស្សរកុត្តំ ព្រហ្មកុត្តំ បានដល់ ព្រះឥសូរធ្វើឲ្យ ព្រះព្រហ្មធ្វើឲ្យ ។ អធិប្បាយថា ព្រះឥសូរនិម្មិតឲ្យ ព្រះព្រហ្មនិម្មិតឲ្យ ។ ពិតហើយ គប្បីជ្រាបថា ព្រះព្រហ្មប៉ុណ្ណោះ ឈ្មោះថា ជាធំ ដោយភាពជាអធិបតីក្នុងពាក្យថា ឥស្សរកុត្តំ ព្រហ្មកុត្តំ នេះ ។ បទថា អាចរិយកំ គឺ ភាវៈជាអាចារ្យ បានដល់ លទ្ធិរបស់អាចារ្យ ។ ក្នុងពាក្យថា អាចរិយកំ នោះ អាចរិយវាទ ឈ្មោះថា វត្ថុដែលលោកសន្មតិគ្នាថា ខ្ពង់ខ្ពស់ ។ ក៏អាចរិយវាទនោះ ដែលព្រះមានព្រះភាគទ្រង់អធិប្បាយថា វត្ថុដែលលោកសម្មតិថា ខ្ពង់ខ្ពស់ យើងសម្តែងទុកក្នុងពាក្យថា អាចរិយវាទនេះ ទើបត្រាស់ថា អគ្គញ្ញំ ដូច្នេះ ។ បទថា កថំវិហិតកំ គឺ នរណាចាត់ទុក

ចាត់ទុកយ៉ាងណា ៗ ពាក្យដ៏សេស គប្បីជ្រាបតាមន័យដែលអធិប្បាយពិស្តារហើយក្នុងព្រហ្មជាលសូត្រ ។

**[១៤-១៦]** បទថា ខិឌ្ឌាបទោសិកំ បានដល់ មានមូលមកពីទេវតាពួកខិឌ្ឌាបទោសិកៈ ។

## ពោលអំពីសុភវិមោក្ខ

**[១៧]** បទថា អសតា គឺ មិនមាន ។ អធិប្បាយថា ព្រោះអត្ថថាមិនមាន ។ បទថា តុច្ឆា បានដល់ ដោយពាក្យទទេ គឺ វៀរចាកខ្លឹមខាងក្នុង ។ បទថា មុសា គឺ ដោយមុសាវាទ ។ បទថា អភូតេន គឺ វៀរចាកពាក្យដែលពិត ។ បទថា អព្ភាចិក្ខន្តិ គឺ ពោលមួលបង្កាច់ ( យើង ) ។ បទថា វិបរីតោ គឺ មានសញ្ញាវិបរិត បានដល់ មានចិត្តវិបរិត ។ បទថា ភិក្ខវោ ច សេចក្តីថា មិនមែនព្រះសមណគោតមតែម្យ៉ាងដែលវិបរិត ពួកភិក្ខុដែលធ្វើតាមពាក្យទូន្មានព្រះសមណគោតមនោះក៏វិបរិតផងដែរ ។ គ្រានោះ ដើម្បីនឹងសម្តែងពាក្យពោល ដែលពួកតិរ្ថិយពោលសំដៅយកថា ព្រះសមណគោតមជាអ្នកវិបរិត ព្រះមានព្រះភាគទើប

ត្រាស់ពាក្យថា សមណោ គោតមោ ជាដើម ។ បទថា សុភវិមោក្ខំ បានដល់ **វណ្ណកសិណ** ។

បទថា អសុភន្តេវ បានដល់ ដឹងច្បាស់យ៉ាងនេះថា វត្ថុដែលស្អាត និងវត្ថុដែលមិនស្អាតទាំងអស់ ចាត់ជាអសុភៈ ។ ពាក្យថា សុភន្តេន តស្មឹ សមយេ សេចក្តីថា រមែងដឹងច្បាស់ក្នុងសម័យនោះថា វត្ថុនេះស្អាត រមែងមិនដឹងវត្ថុដែលមិនស្អាត ។

បទថា ភិក្ខវោ ៩ សេចក្តីថា ពួកភិក្ខុ និងសមណៈអន្តេវាសិក របស់ពួកជនដែលនិយាយយ៉ាងនេះ ( នុ៎ះឯង ) **វិបរិត** ។ បទថា បហោតិ បានដល់ មានសមត្ថភាព គឺ អាច ។ បទថា ទុក្ករំ ខោ បានដល់ បរិព្វាជកនេះ ជ្រះថ្លាយ៉ាងនេះហើយ ទើបនិយាយថា អហំ ភន្តេ ជាដើម ។ ( សេចក្តីពិត ) បរិព្វាជកពោលពាក្យនោះ ដោយការអួតអាង គឺ ដោយការបញ្ឆោតបន្លំ ។ បានជ្រាបថា បរិព្វាជកនោះមានការគិតថា ព្រះសមណ-គោតមសម្តែងធម្មកថា ប្រមាណប៉ុណ្ណេះដល់យើង យើងសូម្បីស្តាប់ធម្ម-កថានោះហើយ ក៏មិនអាចបួសបាន យើងគួរធ្វើខ្លួន ឲ្យដូចនឹងការបដិបត្តិ តាមពាក្យទូន្មានព្រះសមណគោតមនោះ ។ ព្រោះហេតុនោះ បរិព្វាជកនោះ

ទើបពោលយ៉ាងនេះ ដោយការអួតអាង គឺ ដោយការបញ្ឆោតបន្ទំ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ដូចជាទីងកាត់ដាច់សេចក្តីហួងហែង ដល់បរិព្វាជកនោះ ទើបត្រាស់ថា ឧក្កាំ ខោ ឯតំ ភគ្គវា តយា អញ្ញ- ធិដ្ឋិកេន ជាដើម ។ ពាក្យនោះ មានខ្លឹមសារតាមដែលពោលទុកក្នុង បោដ្ឋបាទសូត្រ ។ បទថា សាធុកមនុរក្ខ បានដល់ ចូររក្សាឲ្យល្អ ។ ព្រះមានព្រះភាគ ទ្រង់បបួលបរិព្វាជកឲ្យរក្សាសេចក្តីជ្រះថ្លា (ត្រឹមតែដែល មាននៅឲ្យល្អ) ដោយប្រការដូច្នេះ ។ បរិព្វាជកឈ្មោះ ភគ្គវគោត្រនោះ សូម្បីស្តាប់ព្រះសូត្រយ៉ាងច្រើនយ៉ាងនេះ ក៏មិនអាចធ្វើកិលេសឲ្យអស់ទៅ បាន ។ ក៏ការទេសនា (ព្រះសូត្រនេះ) បានជាបច្ច័យ ដើម្បីវាសនាក្នុង ភពតទៅរបស់គេ ។ ពាក្យដ៏សេសគ្រប់ ៗ បទ មានខ្លឹមសារច្បាស់លាស់ ហើយទាំងនោះឯង ។

" ចប់ អដ្ឋកថា ចាដិកសូត្រ ទី ១ "

# អដ្ឋកថា ឧត្តុម្ពារិកាសូត្រ ទី ២

[១៨] ឧទុម្ពរិកសូត្រ ចាប់ផ្ដើមថា ឯវម្មេ សុតំ ដូច្នេះ ។

ក្នុងឧទុម្ពរិកសូត្រនោះ មានការពណ៌នាតាមលំដាប់បទ ដូចតទៅនេះ ៖

បទថា បរិព្វាជកោ សំដៅយកឆន្នបរិព្វាជក បទថា ឧទុម្ពរិកាយ បរិព្វាជការាមេ បានដល់ ក្នុងអារាមបរិព្វាជក ក្នុងសម្នាក់របស់នាងឧទុម្ពរិកាទេវី ។

ពាក្យថា សន្ធានោ ជាឈ្មោះរបស់គហបតីនោះ ។ គហបតីនេះ មានអានុភាពច្រើន ជាកំពូលបុរសក្នុងចំនួនឧបាសក ៥០០ នាក់ ហែហមត្រាច់ទៅ ជាព្រះអនាគាមី ( ផង ) ។ ព្រះមានព្រះភាគ បានសរសើរគេត្រង់កណ្ដាលមហាបរិស័ទថា ម្នាលភិក្ខុទាំងឡាយ សន្ធានគហបតី ប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកមានសេចក្ដីជ្រះថ្លាមុតមាំក្នុងព្រះតថាគត តម្កល់ខ្លួននៅក្នុងព្រះសទ្ធម្ម អង្គ ៦ ប្រការដូចម្ដេច ។ គឺ ៖

-សេចក្ដីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះពុទ្ធ

-ក្នុងព្រះធម៌

-ក្នុងព្រះសង្ឃ

-ក្នុងអរិយសីល

-ក្នុងអរិយញាណ

-ក្នុងអរិយវិមុត្តិ ។

ម្នាលភិក្ខុទាំងឡាយ សន្ធានគហបតីប្រកបដោយអង្គ ៦ ប្រការ យ៉ាងនេះឯង ទើបឈ្មោះថា មានសេចក្តីជ្រះថ្លាមុតមាំ តម្កល់ខ្លួននៅក្នុងព្រះសទ្ធម្ម ។ សន្ធានគហបតីនោះ អធិដ្ឋានអង្គឧបោសថពីព្រឹកព្រលឹមហើយ ក្នុងវេលាព្រឹក ក៏ថ្វាយទានចំពោះព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ។ កាលពួកភិក្ខុ ទៅវិហារហើយ កើតសេចក្តីរំខាន ព្រោះសំឡេងរុកកួនរបស់ក្មេងតូច និងក្មេងធំក្នុងស្រុក ទើបចេញទៅដោយគិតថា នឹងស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តា ។ ដោយហេតុនោះ លោកទើបពោលថា ព្រះ-មានព្រះភាគ ស្តេចយាងចេញចាកក្រុងរាជគ្រឹះពេលរសៀល ។

បណ្តាបទទាំងនោះ បទថា ទិវាទិវស្សេវ បានដល់ វេលាហួសត្រង់ ឈ្មោះថា វេលារសៀល ។ អធិប្បាយថា សន្ធានគហបតីនោះ បាន

ចេញទៅក្នុងវេលារសៀល គឺ ត្រាច់ទៅវេលាត្រជាក់ ។

បទថា បដិសល្លីនោ បានដល់ ប្រមូលចិត្តចាកអារម្មណ៍ មានរូបជាដើមនោះៗ ពួនសម្ងំ គឺ ជាអ្នកមានចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃការសោយ ការត្រេកអរក្នុងឈាន ។

បទថា មនោភាវនីយានំ គឺ អ្នកញុំាងចិត្តឲ្យចម្រើន បានដល់ចិត្តរបស់អ្នករលឹកដល់ ធ្វើទុកក្នុងចិត្ត រមែងជាចិត្តដែលប្រាសចាកនីវរណៈ គឺ ចិត្តខ្ពស់ឡើង ចម្រើនឡើង ។

# រឿងនិគ្រោធបរិព្វាជក

[១៩] បទទាំងឡាយមានបទថា ឧទុម្ពរិកាយំ ជាដើម គប្បីជ្រាបតាមន័យដោយពិស្តារក្នុងបោដ្ឋបាទសូត្រនុ៎ះឯង ។

បទថា យាវតា គឺ មានចំនួនប៉ុនណា ។ បទថា អយមេតេសំ អញ្ញតរោ សេចក្តីថា បណ្តាសាវកទាំងនោះ សន្ធានគហបតីនេះ រាប់បញ្ចូលនៅខាងក្នុងសាវកទាំងនោះ ឬជាសាវកម្នាក់ ។ បានស្តាប់ថា ពួកសាវករបស់ព្រះមានព្រះភាគ ចំពោះគ្រហស្ថដែលជាព្រះអនាគាមី មានចំនួន ៥០០ នាក់ អាស្រ័យនៅក្នុងក្រុងរាជគ្រឹះ ។ និគ្រោធបរិព្វាជកពោលថា អយំ តេសំ អញ្ញតរោ ដូច្នេះជាដើម សំដៅដល់ ពួកឧបាសកតែម្នាក់ៗមានបរិវារ ៥០០ នាក់ ។ និគ្រោធបរិព្វាជកប្រាថ្នាការចូលមករបស់គហបតីនោះ ពោលថា អប្បេវនាម ដូច្នេះ ។ ក៏ហេតុនៃសេចក្តីប្រាថ្នា បានពោលទុកហើយក្នុងបោដ្ឋបាទសូត្រនុ៎ះឯង ។

[២០] បទថា ឯតទវោច បានដល់ សន្ធានគហបតី កំពុងដើរមកបានពោលពាក្យនេះថា អញ្ញថា ខោ ឥមេ ជាដើម ព្រោះខ្លួនបានស្តាប់ពាក្យរបស់បរិព្វាជកទាំងនោះ ក្នុងចន្លោះផ្លូវនុ៎ះឯង ។ ក្នុងបទទាំងនោះ

បទថា អញ្ញតិត្ថិយា សេចក្ដីថា ដែលឈ្មោះថា អន្យតិរ្ថិយ៍ ព្រោះជាតិរ្ថិយពួកដទៃ ដោយការឃើញខ្លះ មារយាទខ្លះ កិរិយាខ្លះ អាចារៈខ្លះ ការនៅខ្លះ ឥរិយាបថខ្លះ ។ បទថា សង្គម្ម សមាគម្មា បានដល់ ក្នុងស្ថានទី ( ពួកបរិព្វាជក ) ទៅមករួមគ្នា អង្គុយជាក្រុម ។ បទថា អរញ្ញ វនបត្ថានិ បានដល់ ដងព្រៃក្នុងព្រៃ គឺ សេនាសនៈដែលឆ្ងាយផុតអំពីព្រំដែនស្រុក ។ បន្តានិ សេនាសនៈស្ងាត់ គឺ ស្ថានទីនៅឆ្ងាយផ្លូវអំពីដែនរបស់មនុស្ស ។

បទថា អប្បសទ្ទានិ គឺ មានសំឡេងតិចខ្លះ សូម្បីតែសំឡេងអ្នកធ្វើដំណើរ ដែលដើរហួសទៅជិតទីនៅ ។ បទថា អប្បនិគ្ឃោសានិ គឺ មានសំឡេងតិចៗ ដោយមិនមានសំឡេងគឹកកង ។ បទថា វីជនវាតានិ គឺ ប្រាសចាកវាទៈរបស់អ្នកដែលសញ្ចរទៅក្នុងខាងក្នុង ។ បទថា មនុស្សរាហាសេយ្យកានិ បានដល់ សមគួរ គឺ សមគួរដល់ការធ្វើកម្មដែលពួនសម្ងំកំបាំងពីមនុស្ស ។ បទថា បដិសល្លានសារុប្បានិ បានដល់ សមគួរដល់ការនៅម្នាក់ឯង ។ ព្រោះដូច្នោះ សន្ធានគហបតី ទើបគិតថា ឱព្រះសាស្ដារបស់យើង សេពសេនាសនៈបែបនេះ ទើបផ្គងអញ្ជលីទុក

លើសិរសៈហើយ អង្គុយថ្វាយទានទេះ ។

ពាក្យថា ឯវំ វុត្តេ សេចក្តីថា កាលសន្ធានគហបតីថ្វាយទាន យ៉ាងនេះ និគ្រោធបរិព្វាជក ទើបគិតថា គហបតីនេះ សូម្បីអង្គុយក្នុងសម្នាក់យើង ក៏នៅសរសើរ លើកតម្កើងព្រះសាស្តារបស់ខ្លួនតែមួយអង្គ ដោយមិនសម្គាល់យើងថា មាននៅ យើងនឹងឲ្យការកម្រើក ដែលកើតឡើងក្នុងគហបតីនោះ ធ្លាក់ទៅក្នុងខាងលើព្រះសមណគោតម ទើបពោលពាក្យនេះជាមួយសន្ធានគហបតី ។ ពាក្យថា យគ្ឃេ ជានិបាតប្រើក្នុងអត្ថថា ជំទាស់ ។ បទថា ជានេយ្យាសិ ប្រែថា គួរដឹង គួរឃើញ ។

បទថា កេន សមណោ គោតមោ សល្លបតិ សេចក្តីថា ព្រះសមណគោតម រមែងចរចា និយាយ ពោលជាមួយនរណា ដោយហេតុអ្វី ។ មានពាក្យអធិប្បាយយ៉ាងណា ? មានពាក្យអធិប្បាយថា ប្រសិនបើថា ហេតុនៃការចរចាអ្វីៗ នឹងគប្បីមាន ឬប្រសិនបើថា នរណាៗ មានសេចក្តីត្រូវការចរចា គប្បីទៅសម្នាក់ព្រះសមណគោតម គប្បីចរចា តែមិនមានហេតុ នរណាៗ ក៏មិនទៅរកព្រះអង្គ ។ ព្រះសមណគោតមនោះ នឹងចរចាជាមួយនរណាហ្ន៎ កាលមិនបានចរចា ក៏នឹងបន្លឺព្រះសីហនាទ យ៉ាង

ណាបាន ។ បទថា សាកច្ចំ គឺ សន្ទនារួមគ្នា ។ បទថា បញ្ញាវេយ្យត្តិយំ បានដល់ ភាពជាអ្នកច្លាតក្នុងញាណដោយឧត្តរន័យ និងបច្ចុត្តរន័យ ។

បទថា សុញ្ញាគារគតា គឺ វិនាសទៅហើយក្នុងសុញ្ញាគារ ។ និគ្រោធបរិព្វាជក ពោលថា ព្រោះព្រះសមណគោតម បានសម្រេចព្រះបញ្ញា ត្រឹមតែបន្តិចបន្តួចត្រង់គល់ពោធិ កាលព្រះសមណគោតមតែមួយព្រះអង្គ អង្គុយក្នុងសុញ្ញាគារ ព្រះបញ្ញានោះក៏វិនាសទៅ តែព្រះសមណគោតម នោះ គប្បីអង្គុយប្រឲបូកប្រឲបល់ដោយពួកគណៈដូចយើង ព្រះបញ្ញារបស់ ព្រះអង្គ ក៏នឹងមិនគប្បីវិនាសទៅ ។ បទថា អបរិសាវចរោ បានដល់ មិនអាចចូលកាន់ទីប្រជុំបាន ព្រោះមិនក្លៀវក្លា ។ បទថា ឆាលំ សល្លាចាយ គឺ មិនអាចចរចាប្រាស្រ័យបាន ។ បទថា អន្តមន្តានេវ សេចក្តីថា ព្រះសមណគោតមខ្លាចចំពោះបញ្ហាថា នរណាៗ គប្បីសួរបញ្ហាចំពោះយើង ដូច្នេះ ទើបសេពទីដ៏ស្ងាត់ត្រង់កន្លែងមួយ គឺ សេនាសនៈដែលស្ងាត់ ។ បទថា គោកាណា បានដល់ មេគោមានភ្នែកខ្វាក់ម្ខាង បានឮថា មេគោ ខ្វាក់នោះ ដើរវិលវល់ក្នុងទីដែលស្ងាត់ប៉ុណ្ណោះ បានស្តាប់មកថា មេគោ ខ្វាក់នោះ សូម្បីប្រាថ្នានឹងទៅកាន់ដងព្រៃ ក៏មិនអាចទៅបាន ព្រោះជាគោ

ភ្នែកខ្វាក់ ។ សួរថា ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះមេគោនោះខ្វាក់ រមែងខ្លាចចំពោះស្លឹកឈើ មែកឈើ ឬបន្លាប៉ះពាល់ត្រូវ ។ រមែងមិនអាចនឹងទៅនៅចំពោះមុខហ្វូងគោបាន ។ សួរថា ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះមេគោខ្វាក់នោះ រមែងខ្លាចស្នែងគោ ត្រចៀកគោ ឬកន្ទុយប៉ះពាល់ត្រូវ ។

សព្ទថា ឥង្ឃ ជានិបាត ប្រើក្នុងអត្ថថា ជំទាស់ ។ បទថា សំសាទេយ្យាម បានដល់ យើងគប្បីធ្វើសេចក្តីប្រមាថមើលងាយ គឺ ឲ្យដល់សេចក្តីមិនដាច់ស្រេចប៉ុណ្ណោះ ដោយការសួរបញ្ហាប្រការមួយ ។ បទថា តុច្ឆកុម្ភីវ នំ បានដល់ (គប្បីបង្វិលព្រះសមណគោតម) នោះ ដូច (បុគ្គលបង្វិល) ឆ្នាំងទទេ ដូច្នោះ ។ បទថា ឱរោធេយ្យាម គឺ គប្បីចាប់បង្វិល ។ ពិតហើយ ឆ្នាំងដែលពេញហើយ ប្រមៀលទៅខាងនោះខាងនេះ បុគ្គលចាប់បង្វិលមិនបាន ចំណែកឆ្នាំងទទេ បុគ្គលនឹងអាចត្រឡប់ចាប់បង្វិលតាមសេចក្តីពេញចិត្តបាន យ៉ាងណា និគ្រោធបរិព្វាជកនេះ រមែងពោលថា យើងនឹងបង្វិលព្រះសមណគោតម ដូចគ្នានឹងបង្វិលឆ្នាំងដែលទទេដោយជុំវិញបាន ដោយការបៀតបៀនដោយវាទៈ ព្រោះព្រះអង្គ មានបញ្ញាត្រូវ

កម្ចាត់ចេញហើយ ។ បរិព្វាជក កាលមិនឃើញវង់ព្រះនលាដពណ៌មាស របស់ព្រះសាស្តា ទើបសម្តែងកម្លាំងរបស់ខ្លួនក្នុងទីកំបាំងព្រះភក្ត្រព្រះទសពល គម្រាមទទេៗ មានប្រការផ្សេងៗ ដូចជាកូនមនុស្សចណ្ឌាល បំបែកបំបាក់ ខត្តិយកុមារ ដែលមិនបានលាយឡំដោយជាតិ និងដូចឆ្កែចចក បំបែក បំបាក់កេសរសីហរាជពិតៗ ដោយកម្លាំង ដូច្នោះ ។ សូម្បីឧបាសក ក៏ គិតថា បរិព្វាជកនេះសំឡុត គម្រាមហួសពេក ព្យាយាមដោយមិនមាន ប្រយោជន៍ ដូចលូកជើងទៅដើម្បីប៉ះអវិចី ដូចលូកដៃទៅដើម្បីចាប់ ភវគ្គព្រហ្ម ដូច្នោះ បើព្រះសាស្តារបស់យើងគប្បីមកកាន់ទីនេះ ព្រះអង្គ គប្បីទម្លាក់ទង់ គឺ មានះ ដែលបរិព្វាជកនេះ លើកឡើងដរាបដល់ភវគ្គ-ព្រហ្ម ដោយឋានៈតែមួយ ។ សូម្បីព្រះមានព្រះភាគ ទ្រង់ក៏បានស្តាប់ការ សន្ទនាប្រាស្រ័យនោះ ។ ដោយហេតុនោះ លោកទើបពោលថា អស្សោសិ ខោ ឥមំ កថា សល្លាបំ ដូច្នេះ ។

[២១] បទថា សុមាគធាយ សេចក្តីថា បុរសណាម្នាក់អង្គុយ ត្រង់មាត់ស្រះបោក្ខរណី ឈ្មោះសុមាគធា បានឃើញពួកអសុរ កំពុងចូល ទៅកាន់ភពអសុរ តាមទងផ្កាឈូក ។ **អាហារ** លោកហៅថា និវាបៈ

ក្នុងពាក្យថា មោរនិវាបេ នេះ អធិប្បាយថា បានដល់ ស្ថានទីដែលបុគ្គល ឲ្យចំណីព្រមទាំងឲ្យអភ័យដល់សត្វក្ងោក ។ បទថា អព្ភោកាសេ គឺ ក្នុង ស្ថានទីទួល ។ បទថា អស្សសប្បត្តា បានដល់ ប្រសព្វសេចក្ដីត្រេកអរ គឺ ប្រសព្វសេចក្ដីសោមនស្ស ។ ពាក្យថា អជ្ឈាសយំ គឺ ជានិស្ស័យ នៃមគ្គជាន់ខ្ពស់ ។ ពាក្យថា អាទិព្រហ្មចរិយំ បានដល់ អរិយមគ្គ ពោលគឺ ព្រហ្មចរិយខាងដើម ។ និគ្រោធបរិព្វាជក បានពោលដូច្នេះថា បពិត្រ ព្រះអង្គដ៏ចម្រើន ពួកសាវកដែលព្រះមានព្រះភាគទ្រង់ណែនាំហើយ បំពេញ អរិយមគ្គដែលជាអាទិព្រហ្មចរិយ ដោយអធ្យាស្រ័យហើយ ដល់កាពអស់ ទៅ រមែងដឹងចំពោះ ដោយការសម្រេចព្រះអរហត្តដោយធម៌ឈ្មោះអ្វី ។

[២២] បទថា វិប្បកតា បានដល់ ដែលឈប់បង្អង់នៅមិនទាន់ចប់ ព្រោះការមករបស់តថាគតជាបច្ច័យ ។ ព្រះមានព្រះភាគ ទ្រង់បើកឱកាស ឲ្យនិយាយបែបព្រះសព្វញ្ញូថា អ្នកចូរពោលទៅចុះ តថាគតនឹងសម្ដែង ធម៌នោះឲ្យចប់ដល់ទីបំផុត ។ បទថា ឧដ្ឋានំ ខោ សេចក្ដីថា ព្រះមាន-ព្រះភាគ ទ្រង់ស្ដាប់ពាក្យរបស់បរិព្វាជក ហើយទ្រង់ត្រិះរិះថា បរិព្វាជក នេះ រមែងសួរដល់ធម៌ ដែលតថាគតសម្ដែងដល់ព្រះសាវក ដែលនាំការ

បដិបត្តិ ដែលព្រះសាវកទាំងនោះគប្បីបំពេញ បើតថាគតនឹងពោលធម៌នោះ តាំងពីដើមដល់គេ គេនឹងមិនអាចដឹងធម៌សូម្បីដែលតថាគតពោលហើយ ក៏បរិព្វាជកនេះ ជាអ្នកមានវាទៈខ្ពើមបាប ដោយសេចក្តីព្យាយាមណ្ហើយចុះ តថាគតនឹងឲ្យគេសួរបញ្ហាក្នុងវិស័យនៃវាទៈនោះ ប៉ុណ្ណោះ ហើយនឹងសម្តែងសេចក្តីមិនមានប្រយោជន៍ នៃលទ្ធិរបស់សមណព្រាហ្មណ៍ដ៏ច្រើន នឹងព្យាករណ៍បញ្ហានេះក្នុងខាងក្រោយ ទើបត្រាស់ថា ឧដ្ឋានំ ខោ ឯតំ ជាដើម ។

បណ្តាបទទាំងនោះ បទថា សកេ អាចរិយកេ គឺ ក្នុងលទ្ធិអាចារ្យរបស់ខ្លួន ។ បទថា អធិជេគុច្ឆេ គឺ ក្នុងការខ្ពើមបាប ដោយសេចក្តីព្យាយាម ។ បទថា កថំ សន្តា គឺ យ៉ាងណា ។ បទថា តបោជិគុច្ឆា បានដល់ ការខ្ពើមបាប គឺ ការនឿយណាយចំពោះបាប ដោយសេចក្តីព្យាយាម ។ បទថា បរិបុណ្ណា គឺ បរិសុទ្ធិហើយ ។ ពាក្យថា កថំ អបរិបុណ្ណា បានដល់ អ្នកចូរសួរយ៉ាងនេះថា មិនបរិសុទ្ធិយ៉ាងណា ។ បទថា យត្រ ហិ នាម គឺ យោ នាម ។

[២៣] បទថា អប្បសទ្ទេ កត្វា បានដល់ ឲ្យមិនមានសំឡេងខ្លាំង

គឺ ឲ្យមានសំឡេងតិច ។ បានស្តាប់ថា បរិព្វាជកនោះគិតថា ព្រះសមណ-គោតម រមែងនឹងមិនប្រាប់ត្រឹមតែបញ្ហាមួយ.ខ សូម្បីការសន្ទនាប្រាស្រ័យរបស់ព្រះសមណគោតមនោះ មិនច្រើនពេក ក៏ជនទាំងនេះរមែងបណ្តោយតាម និងសរសើរព្រះសមណគោតមតាំងពីដើម ណ្ហើយចុះ យើងនឹងធ្វើជនទាំងនេះ ឲ្យស្ងាត់សំឡេង ។ បរិព្វាជក បានធ្វើតាមនោះហើយ ។ ដោយហេតុនោះ លោកទើបពោលថា អប្បសទ្ទេ កត្វា ជាដើម ។

ក្នុងពាក្យជាដើមថា តបោជិគុច្ឆវាទា សេចក្តីថា យើងពោលការខ្ពើមបាបដោយតបៈ រមែងកាន់យកការខ្ពើមបាបដោយតបៈនោះ ថាជាសារៈដោយចិត្តខ្លះ រមែងតម្កល់មាំ ការខ្ពើមបាបដោយតបៈនោះ ប្រកបសេចក្តីព្យាយាមក្នុងការទូន្មានខ្លួនឯង ដែលមានប្រការផ្សេងៗ ហើយនៅដោយកាយខ្លះ ។

បទថា តបស្សី គឺ អាស្រ័យតបៈ ។ ពាក្យថា អចេលកោ ជាដើម គប្បីជ្រាបដោយន័យពិស្តារ ក្នុងសីហនាទសូត្រ ។

## ពោលអំពីឧបកិលេសនៃការខ្ពើមចាប ដោយព្យាយាម...

[២៤] បទថា តបំ សមាទិយតិ បានដល់ ប្រកាន់តបៈ ដូចជា អចេលកៈជាដើម គឺ ប្រកាន់យ៉ាងមុតមាំ ។ បទថា អត្តមនោ ហោតិ សេចក្តីថា បរិព្វាជកសប្បាយចិត្តថា គឺ នរណាដទៃក្នុងតបៈនេះ ដូចជាយើង ។ បទថា បរិបុណ្ណសង្កប្បោ បានដល់ មានសេចក្តីត្រិះរិះដល់ទីបំផុតយ៉ាងនេះថា ត្រឹមនេះក៏ល្មម ។ ក៏ពាក្យនេះមក ដោយអំណាចនៃពួកតិរ្ថិយ គប្បីសម្តែង សូម្បីដោយអំណាចការទាក់ទងក្នុងផ្លូវសាសនា ។ ពិតណាស់ បុគ្គលខ្លះសមាទានធុតង្គ គេរមែងត្រេកអរដោយធុតង្គនោះថា បុគ្គលដទៃណាហ្ន៎ទឹងទ្រទ្រង់ធុតង្គដូចយើង ឈ្មោះថា មានសេចក្តីត្រិះរិះបរិបូណ៌ហើយ ។ ពាក្យថា តបស្សិនោ ឧបក្កិលេសោ ហោតិ បានដល់ នេះគឺ ឧបក្កិលេសរបស់អ្នកមានតបៈទាំងពីរប្រការនោះ ។ យើងរមែងពោលថា តបៈជាឧបក្កិលេសដល់បុគ្គលនោះ ដោយហេតុត្រឹមតែប៉ុណ្ណេះ ។

បទថា អត្តានុក្កំសេតិ បានដល់ លើកខ្លួន គឺ តម្កើងខ្លួនថា នរណាទឹងមានដូចយើង ។ បទថា បរំ វម្ភេតិ បានដល់ តម្កើង គឺ មើលងាយអ្នកដទៃថា អ្នកនេះមិនដូចយើង ។ បទថា មជ្ជតិ គឺ ស្រវឹង

ដោយការស្រវឹង គឺ មានះ ។

បទថា មុច្ឆតិ បានដល់ គ្មានសតិ គឺ ដាប់នៅ បានដល់ ជំពាក់នៅ ។ បទថា មទមាបជ្ជតិ បានដល់ ដល់សេចក្តីស្រវឹងថា វត្តនេះប៉ុណ្ណោះជាសារៈ ។ បរិព្វាជកនេះ សូម្បីបួសក្នុងសាសនាហើយ ជាអ្នកមានធុតង្គបរិសុទ្ធ មិនមែនមានកម្មដ្ឋានបរិសុទ្ធ ។ រមែងប្រកាន់ធុតង្គប៉ុណ្ណោះ ថាជាសារៈ ដូចប្រកាន់ព្រះអរហត្ត ។ ក្នុងពាក្យថា លាភសក្ការសិលោកំ នេះ មានវិនិច្ឆ័យដូចតទៅនេះ ៖

ដែលឈ្មោះថា **លាភ** ព្រោះអត្ថថា បានបច្ច័យ ៤ ។ បច្ច័យទាំងនោះឯង ដែលគាត់តែងធ្វើទុកយ៉ាងល្អបានមក ឈ្មោះថា **សក្ការៈ** ។ ការពោលសរសើរ ឈ្មោះថា សិលោក ។ បទថា និព្វត្តេតិ សេចក្តីថា លាភជាច្រើន រមែងកើតឡើង ព្រោះអាស្រ័យការៈជាអាចេលកៈជាដើម ឬការសមាទានធុតង្គរបស់គេ ព្រោះដូច្នោះ បរិព្វាជក ទើបពោលថា និព្វត្តេតិ ដូច្នេះ ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបដោយអំណាចនៃអ្នកមានតបៈទាំងពីរប្រភេទ ដោយន័យដែលពោលទុកកាលមុនទុ៎ះឯង ។

បទថា វោទាសំ អាបជ្ជតិ បានដល់ ដល់ ២ ចំណែក គឺ ធ្វើឲ្យ

ជា ២ ចំណែក ។ បទថា ឲមតិ គឺ ពេញចិត្ត ។

បទថា ន ឲមតិ គឺ មិនពេញចិត្ត ។

បទថា សាបេក្ខោ បជហាតិ បានដល់ អ្នកមានសេចក្ដីប្រាថ្នា រមែងលះ ។

សួរថា តើយ៉ាងណា ។

ឆ្លើយថា ពេលព្រឹក គេបរិភោគនំ ។ ពេលនោះ ទាយកបាននាំសាច់ទៅឲ្យគេទៀត ។ គេមានការគិតយ៉ាងនេះថា ឥឡូវនេះ កាលណាយើងនឹងបានយ៉ាងនេះទៀត ។ បើដឹងយ៉ាងនេះ យើងនឹងមិនគួរបរិភោគនំពេលព្រឹក យើងអាចធ្វើអ្វីបាន ទើបបំណាងលះបង់ដូចការលះបង់ជីវិតដោយការពោលថា ទៅចុះ លោកដ៏ចម្រើន លោកទុំះឯងចូរបរិភោគ ។

បទថា គធិតោ គឺ កើតត្រេកត្រអាលហើយ ។ បទថា មុច្ឆិតោ បានដល់ វង្វេងភ្លេចហើយ ព្រោះសេចក្ដីប្រាថ្នាមានកម្លាំង គឺ ជាអ្នកមិនមានសតិ ។ បទថា អជ្ឈាបន្នោ គឺ ជាប់ជំពាក់នៅក្នុងអាមិសៈ ។ មិនធ្វើសូម្បីត្រឹមតែការអញ្ជើញដោយធម៌ថា ម្នាលលោកដ៏មានអាយុ លោកនឹងបរិភោគ ធ្វើឲ្យជាពំនូតធំៗ ។ បទថា អនាទីនវទស្សាវី គឺ មិនឃើញ

សូម្បីត្រឹមតែទោស ។ ការស្គាល់ប្រមាណ ឈ្មោះថា **និស្សរណៈ** ក្នុងពាក្យថា អនិស្សរណប្បញ្ញោ នេះ ។ គេមិនធ្វើសូម្បីត្រឹមតែការពិចារណានិងការបរិភោគ ។ បទថា លាភសក្ការសិលោកនិក្កន្តិហេតុ គឺ ព្រោះហេតុនៃសេចក្តីប្រាថ្នាក្នុងលាភជាដើម ។ បទថា សំភក្ខេត្តិ ប្រែថាទំពារស៊ី ។ បទថា អសនីវិចក្កំ គឺ មានសណ្ឋានមុតដូចកាំរន្ទះ ។ មានពាក្យអធិប្បាយថា ចុងធ្មេញរបស់បុគ្គលនេះ មុតដូចកាំរន្ទះ មិនមែននឹងមិនបរិភោគពូជអ្វី ក្នុងបណ្តាពូជដែលកើតពីឫសជាដើម ក៏កាលដូច្នោះជនទាំងឡាយ រមែងស្គាល់គេថា ជាសមណៈ ដោយការពោលបន្តាច់ថាជាសមណៈ ។ គេរមែងរុកកួន គឺ មើលងាយ ដោយអាការយ៉ាងនេះ ។ប្រការនេះ មកដោយអំណាចពួកតិរ្ថិយ ។ តែដោយអំណាចភិក្ខុ ក្នុងសេចក្តីនេះ មានពាក្យអធិប្បាយប្រកបដូចតទៅនេះថា ភិក្ខុនេះ ខ្ជួនឯងបានទ្រទ្រង់ធុតង្គ គេរមែងរុកកួនអ្នកដទៃយ៉ាងនេះថា ជនទាំងនេះ នឹងឈ្មោះថាជាសមណៈបានយ៉ាងណា តែពោលថា ពួកយើងជាសមណៈ ដូច្នេះ សូម្បីគុណត្រឹមតែធុតង្គក៏មិនមាន អ្នកទាំងនេះកាល ស្វែងរកអាហារមានឱទ្ទេស-កកត្តជាដើម ឈ្មោះថា ប្រាថ្នាច្រើនដោយបច្ច័យត្រាច់ទៅ ។

បទថា លូខជីវី បានដល់ អ្នកមានការចិញ្ចឹមជីវិតសៅហ្មង ដោយភាពជាអចេលកៈជាដើម ឬដោយអំណាចធុតង្គ ។ បទថា ឥស្សាមច្ឆរិយំ បានដល់ សេចក្តីឫស្យា មានការប្រណែនដល់សម្បត្តិ មានសក្ការៈជាដើមរបស់អ្នកដទៃជាលក្ខណៈ និងសេចក្តីកំណាញ់ មានការមិនព្រមធ្វើសក្ការៈជាដើម ជាលក្ខណៈ ។ បទថា អាធាវកនិសាទី ហោតិ បានដល់ អង្គុយនៅក្នុងផ្លូវដើរ គឺ ក្នុងទីដែលឃើញមនុស្សទាំងឡាយ ។ បុគ្គលដែលមានតបៈឈរក្នុងស្ថានទីជនទាំងឡាយនឹងឃើញបាន រមែងទូន្មានវគ្គុលិវត្ត ( ការបដិបត្តិដូចសត្វប្រចៀវ ) បំពេញតបៈ ៥ យ៉ាង ឈរដោយជើងតែម្ខាង សំពះព្រះអាទិត្យ ។ សូម្បីភិក្ខុដែលបួសក្នុងសាសនាហើយ បានសមាទានធុតង្គ ដេកលក់រហូតដល់អស់មួយយប់ហើយ បំពេញតបៈក្នុងផ្លូវដែលមនុស្សមើលឃើញ វេលាល្ងាច ធ្វើចីវរកុដីលើទីដេកធំ កាលព្រះអាទិត្យឡើងក៏រក្សា ពេលជ្រាបថា ពួកមនុស្សមករក ក៏គោះរគាំងដាក់ចីវរទុកលើសីរសៈ ដើរចង្រ្កម ( តមក ) ក៏ចាប់អំបោស បោសលានវិហារ ។ បទថា អត្តានំ បានដល់ នូវគុណរបស់ខ្លួន ។ អ អក្សរក្នុងពាក្យថា អឧស្សូយមានោ ត្រឹមតែនិបាត ។ សេចក្តីថា សម្តែង ។ បទថា

ឥធម្បិ មេ តបស្មឹ បានដល់ កម្មសូម្បីនេះ នៅក្នុងតបៈរបស់យើង ។
ន័យមួយទៀត បទថា តបស្មឹ នេះ ជាសត្តមីវិភត្តិ ប្រើក្នុងអត្ថបឋមា-
វិភត្តិ ។ អធិប្បាយថា កម្មសូម្បីនេះ ជាតបៈរបស់យើង ។ ពិតហើយ
អ្នកមានតបៈនោះ បានឮថា អ្នកបួសអចេលកៈដែលលះបង់អាចារៈ មាន
នៅទីឯណោះ ជាដើម ក៏និយាយថា នេះជាតបៈរបស់យើង អចេលកៈ
នោះជាអន្តេវាសិករបស់យើងជាដើមថា បានស្តាប់ថា ភិក្ខុអ្នកទ្រទ្រង់សំពត់
បង្សុកូលនៅក្នុងទីឯណោះជាដើម ក៏និយាយថា នេះជាតបៈរបស់យើង
ភិក្ខុនោះជាអន្តេវាសិករបស់យើងជាដើម ។ បទថា កិញ្ចិទេវ បានដល់
ទោស ឬទិដ្ឋិអ្វីៗ ។ បទថា បដិច្ឆន្នំ សេវតិ បានដល់ រមែងសេព
ដោយប្រការដែលជនពួកដទៃមិនដឹង ។ បទថា អក្ខមមានំ អាហ ខមតិ
បានដល់ រមែងពោលដល់វត្ថុដែលខ្លួនមិនពេញចិត្តថា យើងពេញចិត្ត ។
បុគ្គលមានតបៈ រមែងបញ្ញត្តិទោសដែលខ្លួនធ្វើច្រើនហើយថា មានចំនួន
តិច តែសម្តែងទោស ដែលអ្នកដទៃធ្វើហើយត្រឹមតែអាបត្តិទុក្កដថា ដូច
ជាត្រូវអាបត្តិបារាជិក ។ បទថា អនុញ្ញេយ្យំ បានដល់ គួរជ្រាប គឺ
គប្បីអនុមោទនា ។ បទថា កោធនោ ហោតិ ឧបនាហិ បានដល់ អ្នក

ប្រកបដោយកោធៈ មានការថ្នាំងថ្នាក់ចិត្តជាលក្ខណៈ និងដោយឧបនាហៈ មានការមិនលះបង់ពៀរវេរាជាលក្ខណៈ ។ បទថា មក្ខី ហោតិ បឡាសី បានដល់ ប្រកបដោយមក្ខៈ មានការលុបបំបាត់គុណអ្នកដទៃជាលក្ខណៈ និងដោយបឡាសៈ មានការវាយឫកស្មើជាលក្ខណៈ ។ បទថា ឥស្សុកី ហោតិ មច្ឆរី បានដល់ ប្រកបដោយសេចក្តីឫស្យាក្នុងសក្ការៈរបស់អ្នកដទៃជាដើមជាលក្ខណៈ និងដោយសេចក្តីកំណាញ់ ៥ យ៉ាង មានសេចក្តីកំណាញ់ក្នុងអាវាស ត្រកូល លាភ វណ្ណៈ និងធម៌ ជាលក្ខណៈ ។ បទថា សឋោ ហោតិ មាយាវី បានដល់ ប្រកបដោយសាឋេយ្យៈ មានការអួតអាងជាលក្ខណៈ និងមាយា មានការបិទបាំងកម្មដែលធ្វើហើយ ជាលក្ខណៈ ។

បទថា ថទ្ធោ ហោតិ អតិមានី បានដល់ ប្រកបដោយថម្ភៈ មានការរឹងចចេសដែលគ្មានមេត្តា និងករុណា ជាលក្ខណៈ និងអតិមានះ មានការមើលងាយកន្លងហួសអ្នកដទៃ ជាលក្ខណៈ ។ បទថា ឆាបិច្ឆោ ហោតិ បានដល់ ប្រកបដោយការប្រាថ្នាលាមក មានការលើកតម្កើង និងប្រាថ្នាអសប្បុរស ជាលក្ខណៈ ។ បទថា ឆាបិកានំ គឺ លុះក្នុងអំណាចសេចក្តីប្រាថ្នាដ៏លាមកទាំងនោះឯង ។ បទថា មិច្ឆាទិដ្ឋិកោ គឺ ប្រកប

ដោយទិដ្ឋិដែលមិនត្រឹមត្រូវ ដែលប្រព្រឹត្តទៅតាមន័យថា ទានដែលបុគ្គលឲ្យហើយមិនមានផល ជាដើម ។ បទថា អន្តគ្គាហិកាយ បានដល់ ទិដ្ឋិនោះឯង លោកហៅថា អន្តគ្គាហិកា ព្រោះគេប្រកាន់ការដាច់សូន្យ អធិប្បាយថា អ្នកប្រកបដោយអន្តគ្គាហិកទិដ្ឋិនោះ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា សន្ទិដ្ឋិបរាមាសី ជាដើម ដូចតទៅនេះ ៖

ការឃើញដោយខ្លួនឯង ឈ្មោះថា សន្ទិដ្ឋិ អ្នកណាស្ទាបអង្អែលប្រកាន់សន្ទិដ្ឋិនោះឯងត្រាច់ទៅ ហេតុនោះ អ្នកនោះឈ្មោះថា **សន្ទិដ្ឋិបរា-មាសី** ។ ការតាំងទុកដោយល្អ តាំងមាំល្អ ហៅថា **អាធាន:** ។ អ្នកណាប្រកាន់ទុកយ៉ាងមុតមាំ អ្នកនោះឈ្មោះថា **អាធានគ្គាហី** ។ អ្នកណាមិនអាចលះបង់ការប្រកាន់មាំនោះ ដូចអរិដ្ឋ:សាមណេរ ហេតុនោះ អ្នកនោះឈ្មោះថា **ទុប្បដិនិស្សគ្គី** ។ ស័ព្ទថា យទិមេ កាត់ជា យទិ ឥមេ ។

បទថា ឥធ និគ្រោធ តបស្សី សេចក្តីថា ព្រះមានព្រះភាគទ្រង់សម្តែងព្រះបាលីចំណែកដែលសៅហ្មង គឺ ទ្រង់សម្តែងលទ្ធិដែលពួកអន្យ-តិរ្ថិយ៍កាន់យកតប: ដែលពួកតិរ្ថិយទាំងនោះរក្សាថា ជាវត្ថុសៅហ្មងទាំងអស់ហើយ ឥឡូវនេះ ដើម្បីសម្តែងបាលីចំណែកបរិសុទ្ធិ កាលផ្តើមទេសនា

ទើបត្រាស់ថា ឥធ និគ្រោធ ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា ឆ អត្តមនោ ជាដើម គប្បីជ្រាបដោយអំណាចបទដែលផ្ទុយគ្នាពីដែលពោលហើយ ។ ក្នុងវារៈបទគ្រប់ៗ បទគប្បីប្រកបសេចក្ដី ដោយអំណាចអ្នកមានតបៈសៅហ្មង និងអ្នកទ្រទ្រង់ធុតង្គ ។ បទថា ឯវំ សោ តស្មឹ ឋានេ បរិសុទ្ធោ ហោតិ សេចក្ដីថា អ្នកមានតបៈនោះ ជាអ្នកបរិសុទ្ធិ គឺ គ្មានឧបក្កិលេស ព្រោះមានសេចក្ដីពេញចិត្តដោយតបៈនោះក៏ទេ ព្រោះហេតុពោលគឺ សេចក្ដីត្រិះរិះបរិបូណ៌ក៏ទេ ។ អ្នកមានតបៈនេះ កាលព្យាយាមក្រៃលែងឡើងទៅ ក៏ជាអ្នកមានកម្មដ្ឋានបរិសុទ្ធិ រមែងសម្រេចព្រះអរហត្តបាន ។

**[២៥]** គប្បីជ្រាបសេចក្ដីក្នុងវារៈគ្រប់ ៗ បទ ដោយន័យនេះ ។ បទថា អទ្ធា ខោ ភន្តេ សេចក្ដីថា បរិព្វាជករមែងដឹងតាមថា បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នេះ វាទៈដែលខ្ពើមបាបដោយសេចក្ដីព្យាយាម រមែងបរិសុទ្ធិដោយចំណែកតែមួយ ។ ម្យ៉ាងទៀត បរិព្វាជកនោះ កាលមិនដឹងនូវកំពូល និងខ្លឹមសារដទៃអំពីនេះ ទើបពោលថា អគ្គប្បត្តា សារប្បត្តា ច ដូច្នេះ ។ ពេលនោះ ព្រះមានព្រះភាគ កាលទ្រង់បដិសេធវាទៈនោះ

ជាខ្លឹមសារ ដល់បរិព្វាជកនោះ ទើបត្រាស់ថា ន ខោ និគ្រោធ ជាដើម ។

បទថា បបដិកមត្តា ហោតិ សេចក្តីថា ព្រះមានព្រះភាគ ទ្រង់រមែងសម្តែងថា ការខ្ពើមបាបដោយតបៈបែបនេះ ដូចជាក្រមរខាងក្រៅផុតពីខ្លឹម ស្រាយ សំបក របស់ដើមឈើមានខ្លឹម ។

## ពោលអំពីតបោជិគុច្ឆវាទ

## ដែលដល់នូវកំពូលធម៌ និងខ្លឹមធម៌

[២៦] បទថា អគ្គំ ចាបេតុ សេចក្តីថា រមែងទូលសូមចំពោះព្រះទសពលថា សូមព្រះមានព្រះភាគមេត្តាសម្តែងឲ្យដល់កំពូល គឺ មេត្តាសម្តែងឲ្យដល់ខ្លឹម ដោយអំណាចនៃទេសនា ។

បទថា ចាតុយាមសំវរសំវុតោ គឺ បិទហើយ ដោយការសង្រួម ៤ យ៉ាង ។

បទថា ន ចាណាមតិចាបេតិ គឺ មិនបៀតបៀនសត្វ ។ បទថា ន ភាវិតមាសីសតិ សេចក្តីថា កាមគុណ ៥ យ៉ាង ឈ្មោះថា ជាវត្ថុដែលនាំគ្នាបដិបត្តិមក ព្រោះកំណត់ចាំទុក មិនប្រាថ្នា គឺ មិនសេពកាមគុណ

ទាំងនោះ ។ បទថា អនុញ្ញាស្ស ហោតិ សេចក្តីថា ប្រការដែលនឹងពោល ក្នុងឥឡូវនេះជាដើមថា សោ អភិហរតិ ទើបជាលក្ខណៈរបស់គេ ។

បទថា តបស្សិតាយ គឺ ព្រោះភាពជាអ្នកមានតបៈ ។ បណ្តាបទទាំងនោះ បទថា សោ អភិហរតិ សេចក្តីថា គេរមែងរក្សាសីលនោះឲ្យក្រៃលែង គឺ បំពេញឲ្យខ្ពស់ក្រៃលែងឡើងទៅ បានដល់ មិនលះសេចក្តីព្យាយាមថា សីលយើងបរិបូណ៌ហើយ តបៈយើងផ្តើមឡើងហើយ ល្មមលះបង់ដោយហេតុត្រឹមតែប៉ុណ្ណេះ ។ បទថា ឆោ ហិនាយាវត្តតិ សេចក្តីថា មិនវិលមកដើម្បីភាពជាបុគ្គលអាក្រក់ គឺ ដើម្បីភាពជាគ្រហស្ថ បានដល់ធ្វើសេចក្តីព្យាយាម ដើម្បីត្រូវការសម្រេចគុណវិសេសក្រៃលែងជាងសីល ។ គេកាលធ្វើបានយ៉ាងនេះ រមែងសេពសេនាសនៈដែលស្ងាត់ ។

បទថា អរញ្ញំ ជាដើម មានពិស្តារហើយក្នុងសាមញ្ញផលសូត្រ ។ បទថា មេត្តាសហគតេន ជាដើម លោកពណ៌នាទុកហើយក្នុងវិសុទ្ធិមគ្គ ។

បទថា តចប្បត្តា គឺ ដល់សំបកខាងក្នុង តែក្រមរ ។

[២៧] បទថា ផេគ្គុប្បត្តា គឺ ដល់ស្រាយខាងក្នុងសំបក អធិប្បាយថា ដូចជាស្រាយ ។

[២៨] ព្រះមានព្រះភាគ ទ្រង់ត្រាស់ពាក្យថា ឯត្តាវតា និគ្រោធ តបោជិគុច្ឆា អគ្គប្បត្តា ច ហោតិ សារប្បត្តា ច នេះ ដោយអំណាចពួកតិរ្ថិយ ។

ពិតហើយ លាភ និងសក្ការៈរបស់ពួកតិរ្ថិយ ដូចគ្នានឹងមែកឈើ និងស្លឹកឈើ ។ ត្រឹមតែសីល ៥ ដូចក្រមរឈើ ។ ត្រឹមតែសមាបត្តិ ៨ ដូចសំបកឈើ ។ បុព្វេនិវាសញ្ញាណ និងអភិញ្ញាក្នុងទីបំផុត ដូចស្រាយ ។ ក៏ពួកតិរ្ថិយទាំងនោះ រមែងកាន់យកទិព្វចក្ខុថា ជាព្រះអរហត្ត ។ ព្រោះហេតុនោះ សេចក្តីប្រកាន់នោះរបស់ពួកគេ ដូចខ្លឹមឈើ ។ ចំណែកលាភ និងសក្ការៈក្នុងព្រះសាសនា ដូចជាមែកឈើ និងស្លឹកឈើ ។ ការដល់ព្រមដោយសីល ដូចជាក្រមរ , ឈាន និងសមាបត្តិ ដូចជាសំបក ។ លោកិយអភិញ្ញា ដូចជាស្រាយ ។ មគ្គ និងផលជាខ្លឹម ។ ព្រះមានព្រះភាគទ្រង់ប្រៀបធៀបសាសនារបស់ព្រះអង្គ ដោយដើមឈើ មានផលរហូតដល់មែកដែលបន្ទោនចុះ និងផ្សាយចេញ ដោយប្រការដូច្នេះ ។

ព្រោះព្រះអង្គឈ្លាសក្នុងការសម្តែងទេសនា ព្រះមានព្រះភាគ ព្រះអង្គនោះ ទ្រង់ផ្តើមសម្តែងថា ឥតិ ខោ និគ្រោធ ជាដើម ដើម្បីសម្តែង

សេចក្តីប្លែកគ្នានៃទេសនារបស់ព្រះអង្គថា សាសនារបស់តថាគតក្រៃលែងជាង ប្រណីតជាង ការដល់ព្រមដោយខ្លឹមរបស់អ្នកនោះ អ្នកនឹងដឹងសាសនានោះក្នុងកាលណា ។

បទថា តេ បរិព្វាជកា បានដល់ បរិព្វាជកចំនួន ៣.០០០ នាក់ពួកនោះ ជាបរិវាររបស់គេ ។ បទថា ឯត្ថ មយំ ន បស្សាម បានដល់ក្នុងបាលីមានបែបផែនអចេលកៈជាដើមនេះ ។ លោកពោលថា សូម្បីបែបផែនអចេលកៈ ក៏មិនមានដល់យើង បែបផែនដែលបរិសុទ្ធិនឹងមានពីទីណា សូម្បីបែបផែនដែលបរិសុទ្ធិរបស់ពួកយើង ក៏មិនមានក្នុងទីនោះ ។ ការសង្រួម ៤ យ៉ាង ជាដើម នឹងមានអំពីទីណា សូម្បីការសង្រួម ៤ យ៉ាង ក៏មិនមាន ការនៅព្រៃជាដើម នឹងមានពីទីណា សូម្បីការនៅព្រៃមិនមាន ការលះនីវរណៈជាដើម នឹងមានពីទីណា សូម្បីការលះនីវរណៈមិនមាន សូម្បីព្រហ្មវិហារជាដើម នឹងមានពីទីណា សូម្បីព្រហ្មវិហារមិនមាន បុព្វេនិវាសញ្ញាណជាដើម នឹងមានពីទីណា សូម្បីបុព្វេនិវាសញ្ញាណមិនមាន ទិព្វចក្ខុរបស់ពួកយើង នឹងមានពីទីណា ពួកយើងព្រមទាំងអាចារ្យវិនាសក្នុងទីនេះ ។ បទថា ឥតោ ភិយ្យោ ឧត្តរិតរំ សេចក្តីថា

បរិព្វាជកទាំងនោះរមែងពោលថា ពួកយើងមិនទាន់ដឹងច្បាស់ ការសម្រេចគុណវិសេសដទៃ ដែលក្រៃលែងជាងការសម្រេចទិព្វចក្ខុញ្ញាណនេះ សូម្បីដោយអំណាចការស្តាប់ ។

## ពោលអំពីការសាកសួរនៃសន្ធានគហបតី

**[២៩]** បទថា អថ ខោ និគ្រោធំ បរិព្វាជកំ សេចក្តីថា សន្ធានគហបតីនោះ មានសេចក្តីគិតយ៉ាងនេះថា បរិព្វាជកទាំងនេះ តាំងចិត្តស្តាប់ភាសិតរបស់ព្រះមានព្រះភាគក្នុងឥឡូវនេះ ក៏និគ្រោធបរិព្វាជកនេះបានពោលពាក្យជំទាស់អំពីក្រោយខ្នងព្រះមានព្រះភាគ ឥឡូវនេះ បរិព្វាជកនេះបានកើតការចង់ស្តាប់ ឥឡូវនេះ ជាកាលដែលនឹងទម្លាក់ទង់ គឺ មានះរបស់បរិព្វាជកនេះចុះហើយ លើកព្រះសាសនារបស់ព្រះមានព្រះភាគឡើងលំដាប់នោះ គេទើបបានពោលពាក្យនោះ ចំពោះនិគ្រោធបរិព្វាជក និងសូម្បីសន្ធានគហបតីនោះក៏មានការគិតដទៃទៀតថា បរិព្វាជកនេះ កាលយើងមិននិយាយ ក៏នឹងមិនសូមខមាព្រះសាស្តា និងការមិនសូមទោសនោះនឹងប្រព្រឹត្តទៅដើម្បីមិនមែនប្រយោជន៍ ដើម្បីទុក្ខដល់គេក្នុងអនាគត តែ

*កាលយើងនិយាយហើយ គេនឹងសូមខមាទោស ការសូមខមាទោសនោះនឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់គេ រហូតដល់អស់កាលយូរ ដូច្នេះ ពេលនោះ គេទើបបានពោលពាក្យនោះ ចំពោះនិគ្រោធបរិព្វាជក ។ សំពុថា បន ក្នុង ពាក្យថា អបរិសាវចរំ បន នំ ករោថ នេះជានិបាត ។ សេចក្តីថា ក៏ពួកលោកចូរធ្វើព្រះអង្គកុំឲ្យហ៊ាន ត្រាច់ទៅក្នុងទីប្រជុំ ។ បាលីថា អបរិសាវចរេតំ ដូច្នេះ ក៏មាន ។ម្យ៉ាងទៀត អធិប្បាយថា ពួកលោកចូរធ្វើព្រះសមណគោតមនោះ មិនឲ្យហ៊ានត្រាច់ទៅក្នុងទីប្រជុំ ឬចូរធ្វើឲ្យដូចជាមេគោខ្វាក់ភ្នែកជាដើម ណាមួយ ។ សូម្បីក្នុងពាក្យថា* គោកាណំ នេះ *មានអធិប្បាយថា ពួកលោកចូរធ្វើព្រះសមណ-គោតម ឲ្យដូចជាគោខ្វាក់ភ្នែក ត្រាច់វិលវល់ទៅ ដូច្នោះ ។ បទថា* តុណ្ហីភូតោ *គឺ ចូលដល់ភាពជាអ្នកស្ងៀម ។ បទថា* មង្កុភូតោ *គឺ អស់អំណាច ។ បទថា* បត្តក្ខន្ធោ *គឺ ឱន.ក ។ បទថា* អធោមុខោ *គឺ ដាក់មុខ ។*

## ពោលអំពីគុណនៃព្រះសម្មាសម្ពុទ្ធ

[៣០] *បទថា* ពុទ្ធោ សោ ភគវា សម្ពោធាយ *សេចក្តីថា*

ព្រះមានព្រះភាគ ត្រាស់ដឹងដោយព្រះអង្គឯង ហើយទ្រង់សម្តែងធម៌ដើម្បីឲ្យសត្វទាំងឡាយដឹងអរិយសច្ច ៤ ផង ។

បទថា ឧន្តោ គឺ ទូន្មានផ្លូវចក្ខុះ ។ល។ ទូន្មានផ្លូវចិត្តខ្ទះ ។ បទថា ឧមថាយ បានដល់ ដើម្បីត្រូវការទូន្មានសត្វពួកដទៃ មិនមែនដើម្បីវាទះ ។

បទថា សន្តោ បានដល់ ទ្រង់ស្ងប់ហើយ ព្រោះមានរាគៈស្ងប់រំងាប់ គឺ ទ្រង់ស្ងប់ ព្រោះមានទោសៈ និងមោហៈស្ងប់ ព្រោះមានអកុ-សលធម៌ទាំងពួង និងអភិសង្ខារទាំងពួងស្ងប់ ។ បទថា សមថាយ គឺ ទ្រង់សម្តែងធម៌ដើម្បីឲ្យមហាជនមានរាគៈជាដើម ស្ងប់ ។ បទថា តិណ្ណោ គឺ ឆ្លងផុតឱឃៈ ៤ យ៉ាងបាន ។ បទថា តរណាយ គឺ ដើម្បីត្រូវការនឹងឲ្យមហាជនឆ្លងផុតឱឃៈ ។ បទថា បរិនិព្វុតោ បានដល់ ជាអ្នករលត់ហើយដោយកិលេសនិព្វាន ។ បទថា បរិនិព្វានាយ បានដល់ ទ្រង់សម្តែងធម៌ ដើម្បីត្រូវការឲ្យមហាជនរលត់ កិលេសគ្រប់យ៉ាង ។

## ពោលអំពីអានិសង្សដ៏ឧត្តមនៃការបដិបត្តិក្នុងធម្មវិន័យ

[៣១] បទថា អច្ចយោ ជាដើម បានពោលទុកហើយក្នុងសាមញ្ញ-

ផលសូត្រ ។

បទថា ឧជុជាតិកោ បានដល់ វៀរចាក ការកោងផ្លូវកាយជាដើម មានសេចក្តីទៀងត្រង់ជាសភាព ។ បទថា អហាមនុសាសាមិ សេចក្តីថា តថាគតនឹងប្រៀនប្រដៅបុគ្គលដូចលោក និងនឹងសម្តែងធម៌ដល់បុគ្គល ដូចលោកនោះ ។

បទថា សត្តាហំ គឺ រហូតដល់អស់ប្រាំពីរថ្ងៃ ។ ក៏ព្រះមានព្រះភាគទ្រង់ប្រាថ្នាដល់បុគ្គលដែលមានបញ្ញាក្រាស់ ទើបត្រាស់ពាក្យនេះទាំងអស់ ។ ក៏បុគ្គលដែលមិនអួតអាង មិនមានមាយា ជាបុគ្គលត្រង់ នឹងអាចសម្រេចព្រះអរហត្តបាន ដោយត្រឹមតែមួយរំពេចប៉ុណ្ណោះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់សម្តែងថា មនុស្សអួតអាង មនុស្សកោងកាចតថាគតមិនអាចទូន្មានបាន ដូច្នេះ ដោយពាក្យជាដើមថា អសឋំ ដូច្នេះ ដូចជាទ្រង់ចាប់បរិព្វាជកត្រង់ជើង គ្រវែងទៅត្រង់ជើងភ្នំព្រះសុមេរុ ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះបរិព្វាជកអ្នកនេះ អួតអាងហួសប្រមាណ មានសន្តានចិត្តកោងកាច ។ សូម្បីកាលព្រះសាស្តា ត្រាស់ហើយយ៉ាងនេះ បរិព្វាជកក៏មិនបង្អោនចិត្តទៅក្នុងព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ

មិនផ្ទៀងសោតៈទៅដើម្បីភាពជាអ្នកបង្អោនចិត្តទៅ តាំងនៅក្នុងសេចក្តីបញ្ចោតបន្ទំ សូមខមាទោសព្រះសាស្តា ព្រោះដូច្នោះ ព្រះមានព្រះភាគទ្រង់ជ្រាបអធ្យាស្រ័យរបស់គេ ទើបត្រាស់ថា តថាគតក៏មិនអាចទូន្មានមនុស្សអួតអាងបាន ។

បទថា អន្តេវាសិកម្យតា បានដល់ ចង់បានអន្តេវាសិក គឺ ប្រាថ្នាពួកយើងជាអន្តេវាសិក ។ បទថា ឯវមាហ បានដល់ ព្រះមានព្រះភាគត្រាស់ពាក្យថា បុរសអ្នកដឹង មិនអួតអាង ចូរមកជាដើម ។ បទថា យោ ឯវ វោ អាចរិយោ សេចក្តីថា អ្នកណាតាមប្រក្រតីជាអាចារ្យរបស់អ្នក ។ បទថា ឧទ្ទេសា នោ ចាវេតុកាមោ សេចក្តីថា ព្រះសមណគោតមប្រាថ្នានឹងឲ្យយើងកាន់យកពាក្យទូន្មានរបស់ព្រះអង្គ ហើយឲ្យពួកយើងឃ្លាតចាកឧទ្ទេសរបស់ពួកយើង ។ បទថា សោយេវ វោ ឧទ្ទេសោ ហោតុ សេចក្តីថា តាមប្រក្រតី ឧទ្ទេសណាជាឧទ្ទេសរបស់អ្នក ឧទ្ទេសនោះ ក៏ជាឧទ្ទេសរបស់អ្នកទាំងឯង យើងមិនមានសេចក្តីត្រូវការដោយឧទ្ទេសរបស់អ្នក បទថា អាជីវា គឺ ចាកសេចក្តីរស់នៅ ។ បទថា អកុសលសង្ខាតា គឺ ដល់ចំណែកថា អកុសល ។ បទថា អកុសលា ធម្មា បានដល់ ធម៌ គឺ

ការកើតនៃអកុសលចិត្ត ១២ ដួង ម្យ៉ាងទៀត ដោយវិសេស ក៏បានដល់តណ្ហានុ៎ះឯង ។ ពិតហើយ តណ្ហានោះ ព្រះមានព្រះភាគត្រាស់ហៅថា ចោនោព្ភវិកា ព្រោះធ្វើឲ្យកើតទៀត ។ បទថា សទរថា គឺ ប្រកបដោយសេចក្តីខ្វល់ខ្វាយ ដោយកិលេស ។ បទថា ជាតិជរាមរណិយា គឺ ជាបច្ច័យនៃជាតិ ជរា និងមរណៈ ។ បទថា សង្កិលេសិកា ធម្មា គឺ ប្រកាន់ការកើតនៃអកុសលចិត្ត ១២ ដួង ។ បទថា វោទានិយា បានដល់ធម៌ គឺ សមថៈ និងវិបស្សនា ។ ព្រោះធម៌ គឺ សមថៈ និងវិបស្សនាទាំងនោះ រមែងធ្វើឲ្យសត្វបរិសុទ្ធិបាន ព្រោះហេតុនោះ ធម៌ទាំងនោះព្រះមានព្រះភាគទើប ត្រាស់ថា វោទានិយា ។ បទថា បញ្ញាចារិបូរី គឺ ការបរិបូណ៌ដោយមគ្គប្បញ្ញា ។ បទថា វេបុល្លត្តញ្ច បានដល់ ការបរិបូណ៌ដោយផលប្បញ្ញា ។

ន័យមួយទៀត ទាំងពីរបទនេះ ជាវេវចនៈនៃគ្នានិងគ្នា ។ លោកអធិប្បាយទុកថា ព្រោះហេតុនោះពួកលោកនឹងធ្វើឲ្យច្បាស់មគ្គប្បញ្ញា និងផលប្បញ្ញា ដោយបញ្ញាដ៏ក្រៃលែងរបស់ខ្លួន ក្នុងបច្ចុប្បន្ននុ៎ះឯង ចូលដល់ហើយ ដូច្នេះ ។ ព្រះមានព្រះភាគទ្រង់ប្រារព្ធបរិព្វាជកទាំងឡាយ កាល

ទ្រង់នឹងសម្ដែងកម្មាំងនៃព្រះឱវាទានុសាសនីរបស់ព្រះអង្គ ទើបញ៉ាំងព្រះធម៌ទេសនាឲ្យចប់ស្រេចដល់កំពូល គឺ ព្រះអរហត្ត ដោយប្រការដូច្នេះ ។ បទថា យថា តំ មារេន បានដល់ ពួកបរិព្វាជកទាំងនោះ ជាអ្នកអង្គុយស្ងៀម ។លៗ មិនមានបដិភាណ ដូចត្រូវមារបណ្ដាលចិត្ត ដូច្នោះ ។

បានឮថា មារគិតថា ព្រះសាស្ដាសម្ដែងកម្លាំងព្រះពុទ្ធគំពមកំហែងហួសប្រមាណ សម្ដែងធម៌ដល់បរិព្វាជកទាំងនេះ គួរនឹងមានការត្រាស់ដឹងធម៌ខ្លះក្នុងពេលខ្លះ ណ្ហើយចុះ យើងនឹងបណ្ដាលចិត្ត ដូច្នេះ ។ មារទើបបណ្ដាលចិត្តរបស់បរិព្វាជកទាំងនោះ ។ ពិតហើយ ចិត្តដែលនៅលះវិបល្លាសមិនទាន់បាន ទើបត្រូវមារធ្វើតាមសេចក្ដីប្រាថ្នា ។

**[៣២]** សូម្បីបរិព្វាជកទាំងនោះ ត្រូវមារបណ្ដាលចិត្តហើយ ក៏អង្គុយស្ងៀមមិនមានបដិភាណ ដូចមានអវយវៈគ្រប់ចំណែករឹងគាំង ដូច្នោះ ។ លំដាប់នោះ ព្រះសាស្ដាទ្រង់រំពឹងថា បរិព្វាជកទាំងនោះអង្គុយស្ងៀមស្ងាត់មានហេតុអ្វីហ្ន៎ ដូច្នេះទើបបានជ្រាបថា ពួកបរិព្វាជកត្រូវ មារបណ្ដាលចិត្ត ។ ក៏បើហេតុនៃការសម្រេចមគ្គ និងផលរបស់បរិព្វាជក ទាំងនោះគប្បីមាន ព្រះមានព្រះភាគ ក៏គប្បីហាមមារហើយសម្ដែងធម៌ តែព្រះមាន-

ព្រះភាគនោះ ទ្រង់ជ្រាបហើយថា ហេតុនៃមគ្គផលមិនមានដល់បរិព្វាជក ទាំងនោះ បរិព្វាជកទាំងអស់នេះជាមោឃបុរស ព្រោះដូច្នោះលោកទើប ពោលពាក្យជាដើមថា គ្រានោះឯង ព្រះមានព្រះភាគទ្រង់មានព្រះតម្រិះថា បរិព្វាជកទាំងអស់ទាំងនេះ ជាមោឃបុរស ។

ក្នុងបណ្តាបទទាំងនោះ បទថា ផុដ្ឋា ចាបិមតា បានដល់ ត្រូវ មារមានបាបបណ្តាលចិត្តហើយ ។ បទថា យត្រ ហិ នាម ប្រែថា ក្នុង បរិព្វាជកពួកណា ។ បទថា អញ្ញាណត្ថម្បិ គឺ ដើម្បីសេចក្តីដឹង ។ បទថា កឹ ករិស្សតិ សត្តាហោ បានដល់ ប្រាំពីរថ្ងៃ ដែលព្រះសមណ-គោតមកំណត់ទុកហើយ នឹងធ្វើអ្វីដល់ពួកយើងបាន ។ ពួកបរិព្វាជកបាន ពោលថា ព្រះសមណគោតមត្រាស់ថា និគ្រោធបរិព្វាជក នឹងធ្វើឲ្យច្បាស់ ដោយបញ្ញាដ៏ក្រៃលែងរបស់ខ្លួនរហូតដល់អស់មួយសប្តាហ៍ មួយសប្តាហ៍ នោះ នឹងធ្វើសេចក្តីមិនសុខស្រួលអ្វីដល់ពួកយើង ណ្ហើយចុះ ពួកយើង នឹងប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីសេចក្តីដឹងថា ក្នុងខាងក្នុងមួយសប្តាហ៍ ពួក យើងនឹងអាចធ្វើឲ្យច្បាស់ធម៌នោះបានឬទេ ។ ន័យមួយទៀត ក្នុងសេចក្តី នេះ មានអធិប្បាយថា បរិព្វាជកទាំងនោះ មិនបានកើតសេចក្តីគិត ដើម្បី

នឹងជីងត្រឹមតែមួយជងថា ក្នុងថ្ងៃមួយ ពួកយើងនឹងជីងធម៌របស់ព្រះអង្គបាន ក៏មួយសប្តាហ៍នឹងធ្វើអ្វីដល់បរិព្វាជក អ្នកខ្ជិលប្រអូសទាំងនោះបាន បរិព្វាជកទាំងនោះ នឹងបំពេញរបូតដល់អស់សប្តាហ៍បានយ៉ាងណា ។

បទថា សីហនាទំ គឺ បន្លឺហើយ បន្លឺបែបមិនខ្លាចអ្នកណា ជាការទម្លាយវាទៈអ្នកដទៃ និងជាការប្រកាសវាទៈរបស់ខ្លួន ។ បទថា បច្ចុដ្ឋាសិ គឺ តាំងនៅហើយ ។ បទថា តាវទេវ ប្រែថា ក្នុងខណៈនោះទុំះឯង ។ បទថា រាជគហំ ឧាវិសិ បានដល់ ស្តេចចូលទៅកាន់ក្រុងរាជគ្រឹះទុំះឯង ។ ក៏បរិព្វាជកទាំងនោះ មិនបានកើតគុណវិសេស ព្រោះស្តាប់ព្រះសូត្រនេះ ក៏ពិត សូម្បីដូច្នោះ នឹងជាបច្ច័យ ដើម្បីជាវាសនាដល់បរិព្វាជកទាំងនោះតទៅ ។ ពាក្យដ៏សេសគ្រប់ៗ បទ ច្បាស់លាស់ហើយទាំងនោះ ។

( ចប់ អដ្ឋកថា ឧទុម្ពរិកសូត្រទី ២ )

# អដ្ឋកថា ចក្កវត្តិសូត្រ ទី ៣

[៣៣] ចក្កវត្តិសូត្រមានពាក្យផ្តើមថា ខ្ញុំបានស្តាប់ហើយយ៉ាងនេះ ។ ក្នុងព្រះសូត្រនោះ មានការពណ៌នាបទដែលលំបាកដូចតទៅនេះ ៖

បទថា មាតុលាយំ បានដល់ ក្នុងព្រះនគរដែលមានឈ្មោះយ៉ាងនោះ ។ ព្រះមានព្រះភាគ ទ្រង់ធ្វើព្រះនគរនោះឲ្យជាគោចរគ្រាម ប្រថាប់នៅក្នុងព្រៃស្រោងមិនឆ្ងាយ ។ ក្នុងពាក្យថា តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ នេះ មានអនុបុព្វីកថា ដូចតទៅនេះ ៖

បានឮមកថា ក្នុងសម័យដែលព្រះសូត្រនេះកើតឡើង ព្រះមានព្រះភាគ ចេញចាកមហាករុណាសមាបត្តិក្នុងពេលទៀបភ្លឺ ទ្រង់ប្រមើលមើលសត្វលោក ទតឃើញការត្រាស់ដឹងធម៌របស់ពួកសត្វ ៨៤.០០០ អ្នកនៅក្នុងមាតុលនគរ ដោយការសម្តែងព្រះសូត្រ ដែលសម្តែងដល់អនាគតវង្សនេះ ។ ព្រះមានព្រះភាគ ព្រមដោយភិក្ខុ ២០.០០០ រូប ស្តេចយាងទៅកាន់មាតុលនគរពីព្រឹកព្រលឹម ។ ស្តេចមាតុលនគរ ឮដំណឹងថា ព្រះមាន-ព្រះភាគទ្រង់យាងមក ទើបទូលអារាធនាព្រះទសពល ឲ្យស្តេចចូលកាន់

ព្រះនគរដោយគ្រឿងសក្ការៈជាច្រើន ទ្រង់រៀបចំទឹកន្ទែងប្រថាប់គន្ធ អារាធនាឲ្យព្រះមានព្រះភាគប្រថាប់គង់លើបល្ល័ង្ក ដ៏មានតម្លៃ បានថ្វាយមហាទានចំពោះភិក្ខុសង្ឃដែលមានព្រះពុទ្ធជាប្រធាន ។ ព្រះមានព្រះភាគ ទ្រង់ធ្វើភត្តកិច្ចស្រេចហើយ ទ្រង់ត្រិះរិះថា បើតថាគតនឹងសម្តែងធម៌ដល់ពួកមនុស្សទាំងនេះ ក្នុងទីនេះសោត ទីនេះបង្អៀត ពួកមនុស្សនឹងមិនមានឱកាសនឹងឈរ នឹងអង្គុយ តែសមាគមធំគប្បីមាន ។ លំដាប់នោះព្រះមានព្រះភាគ ទ្រង់មិនធ្វើភត្តានុមោទនា ដល់ពួករាជត្រកូលឡើយ ព្រះអង្គទ្រង់កាន់បាត្រ ស្តេចចេញចាកព្រះនគរទៅ ។ ពួកមនុស្សគិតថាព្រះសាស្តាទ្រង់មិនធ្វើអនុមោទនាដល់ពួកយើង ស្តេចចេញទៅ អាហារមានរសដ៏ប្រសើរ គង់មិនសព្វព្រះទ័យ ឈ្មោះថា ព្រះពុទ្ធទាំងឡាយនរណាៗ មិនអាចផ្គាប់ព្រះទ័យត្រូវបាន ធម្មតាថា ការធ្វើសេចក្តីស្និទ្ធ-ស្នាលនឹងព្រះពុទ្ធទាំងឡាយ ក៏ដូចជាការចាប់.កអាសិរពិស ដែលកំពុងបើកពពារ មកចុះលោកដ៏ចម្រើនទាំងឡាយ ពួកយើងនឹងសូមខមាទោសព្រះតថាគត ។ ពួកអ្នកព្រះនគរទាំងអស់ ម្នាក់ៗ នាំគ្នាចេញទៅតាមព្រះមានព្រះភាគ ។

ព្រះមានព្រះភាគ ខណៈស្តេចយាងទៅនៅទុះឯង ទ្រង់ទតឃើញដើមមាតុលៈ (ដើមស្វាក់) មួយដើមដុះនៅក្នុងស្រែរបស់អ្នកនគរមគធៈ បរិបូណ៌ដោយម្លប់ត្រឈឹងត្រឈៃ តាំងនៅក្នុងភូមិភាគប្រមាណមួយករីសៈ ទ្រង់ត្រិះរិះថា តថាគតនឹងអង្គុយត្រង់គល់ឈើនេះ កាលតថាគតសម្តែងធម៌ មហាជននឹងមានឱកាសឈរ និងអង្គុយបាន ព្រះអង្គទើបស្តេចចៀសចេញពីផ្លូវ ចូលរកគល់ឈើ ទតឆ្មៀងព្រះនេត្រមើលព្រះអានន្ទ ដែលជាធម្មភណ្ឌាគារិក (ឃ្លាំងព្រះធម៌) ព្រះថេរៈជ្រាបថា ព្រះសាស្តាបំណងនឹងប្រថាប់គង់ ដោយន័យដែលព្រះអង្គទ្រង់ឆ្មៀងព្រះនេត្រប៉ុណ្ណោះ ទើបក្រាលចីវរធំថ្វាយព្រះសុគត ។ ព្រះមានព្រះភាគ ប្រថាប់លើអាសនៈដែលព្រះអានន្ទក្រាលថ្វាយ ។ លំដាប់នោះ ពួកមនុស្សនាំគ្នាអង្គុយខាងមុខព្រះភ័ក្ត្រព្រះតថាគត ។ ពួកភិក្ខុអង្គុយសងខាង និងផ្នែកខាងក្រោយ ពួកទេវតាឈរក្នុងអាកាស ។ ព្រះមានព្រះភាគ ប្រថាប់ត្រង់កណ្តាលបរិស័ទធំនោះឯង ដោយអាការយ៉ាងនេះ ទើបបានត្រាស់ហៅភិក្ខុទាំងឡាយ ។ ពីរបទថា តេ ភិក្ខូ សេចក្តីថា ភិក្ខុជាធម្មបដិគ្គាហក ទទួលធម៌ចូលទៅក្នុងសមាគមនោះ ។ បទថា អត្តទីបា សេចក្តីថា ពួកអ្នកចូរធ្វើ

ខ្លួនឲ្យជាកោះ ជាទីពំនាក់ ជាទីពួន ជាគតិ ជាទីទៅខាងមុខ ជាទីពឹងចុះ ។ ពាក្យថា អត្តសរណា នេះ ជាវេវចនៈរបស់ពាក្យថា អត្តទីបា នុ៎ះឯង ។ ពាក្យថា អនញ្ញសរណា ជាពាក្យបដិសេធទីពឹងយ៉ាងដទៃ ។ សេចក្តីពិត បុគ្គលដទៃនឹងជាទីពឹងដល់បុគ្គលដទៃមិនបាន ព្រោះបុគ្គលដទៃនឹងបរិសុទ្ធិ ដោយសេចក្តីព្យាយាមរបស់បុគ្គលដទៃមិនបាន ។

សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា ខ្លួនជាទីពឹងរបស់ខ្លួន អ្នកដទៃជាទីពឹងដូចម្តេចបាន ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា អនញ្ញសរណា ។ សួរថា ក៏ក្នុងពាក្យថា អត្តទីបា នេះ អ្វីហ្ន៎ ឈ្មោះថា ខ្លួន ។ ឆ្លើយថា លោកិយធម៌ និងលោកុត្តរធម៌ ។ ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ធម្មទីបា ធម្មសរណា អនញ្ញសរណា មានធម៌ជាកោះ មានធម៌ជាទីពឹង មិនមានវត្ថុដទៃជាទីពឹង ដូច្នេះ ។

ពាក្យថា កាយេ កាយានុបស្សី ជាដើម បានពោលពិស្តារទុកហើយក្នុងមហាសតិប្បដ្ឋានសូត្រ ។ បទថា គោចរេ បានដល់ ក្នុងស្ថានទីគួរត្រាច់ទៅ ។ បទថា សកេ គឺ កន្លែងដែលជារបស់មាននៅនៃខ្លួន ។

បទថា បេត្តិកេ វិសយេ គឺ ក្នុងទីដែលមកពីវិស័យរបស់បិតា ។ បទថា ចរតំ គឺ ត្រាច់ទៅហើយ បាលីថា ចរន្តំ ដូច្នេះក៏មាន ។ សេចក្តីក៏ដូច្នេះឯង ។ បទថា ន លច្ឆតិ សេចក្តីថា នឹងមិនបាន គឺ នឹងមិនឃើញ ។

បទថា មារោ បានដល់ ទេវបុត្តមារខ្លះ កិលេសមារខ្លះ ។ បទថា ឱតារំ បានដល់ ស្នាម គឺ ចន្លោះផ្លូវបើក ។ ក៏សេចក្តីនេះ បណ្ឌិតគប្បីសម្តែងដោយរឿងសត្វខ្លែង ដែលឆាបយកសត្វប្រចៀច ហើរចេញពីដីអាចម៍បំណះ ហើរឡើងទៅទំនៅលើសសរខឿន (សសរបន្ទាយ) នៅក្រោមកំដៅថ្ងៃស្រទន់ ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា ៖

ម្នាលភិក្ខុទាំងឡាយ ធ្លាប់មានរឿងពីដើមមកថា មានសត្វខ្លែងបានឆាបសត្វប្រចៀចដោយរហ័ស ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង សត្វប្រចៀច កាលដែលសត្វខ្លែងកំពុងនាំទៅ ក៏ស្រែកបម្រះនទៀលយ៉ាងនេះថា ពួកយើងនុ៎ះឯង ត្រាច់ទៅក្នុងទីអគោចរ ដែលជាដែនរបស់បរបក្ខរាប់ថា មិនមានបុណ្យ មានបុណ្យតិច ។ ប្រសិនបើថ្ងៃនេះ យើងត្រាច់ទៅក្នុងទីគោចរ ជាដែនរបស់បិតាសោត សត្វខ្លែងនឹងមិនអាចចាប់យើងបាន ។ សត្វខ្លែងសួរថា នែ៎! ប្រចៀច ចុះទីណាជាទីគោចររបស់ឯង

ដែលជាដែននៃបិតារបស់ឯង ? សត្វប្រចៀច ឆ្លើយថា គឺ ទីមានដីអាចម៍បំណះដែលគេទើបនឹងភ្ជួរដោយនង្គ័ល ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង សត្វខ្លែងមិនប្រមាណក្នុងកម្លាំងរបស់ខ្លួន ជឿជាក់ក្នុងកម្លាំងរបស់ខ្លួន ក៏លែងសត្វប្រចៀចទៅ ដោយពោលថា នែ ! ប្រចៀច ឯងចូរទៅចុះ ទោះជាឯងទៅក្នុងទីនោះ ក៏មិនរួចអំពីអញដែរ ។ គ្រានោះឯងសត្វប្រចៀច ក៏ហើរទៅកាន់ទីដីអាចម៍បំណះ ហើយទំលើដីអាចម៍បំណះនិយាយនឹងសត្វខ្លែងថា នែ ! ខ្លែង ឯងចូរមករកយើងក្នុងកាលឥឡូវនេះចុះ នែ ! ខ្លែង ឯងចូរមករកយើងក្នុងកាលឥឡូវនេះចុះ ។

ម្នាលភិក្ខុទាំងឡាយ គ្រានោះ សត្វខ្លែងមិនប្រមាណក្នុងកម្លាំងខ្លួនជឿជាក់ក្នុងកម្លាំងរបស់ខ្លួន ហើយសម្របស្លាបទាំងពីរ បោះពួយតម្រង់សត្វប្រចៀច ។ ម្នាលភិក្ខុទាំងឡាយ សត្វប្រចៀចបានដឹងខ្លួនថា សត្វខ្លែងនេះ បោះពួយចុះមកហើយ គ្រានោះឯង សត្វប្រចៀចក៏ចូលពួនត្រង់ចន្លោះដីអាចម៍បំណះនោះឯង ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង សត្វខ្លែងក៏ទង្គិចទ្រូងនឹងដីអាចម៍បំណះនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ប្រការនោះ ក៏ដូចគ្នានឹងភិក្ខុដែលត្រាច់ទៅក្នុងទីមែនជាគោចរ ដែលជាដែនរបស់

បរបក្ខ ។

ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ពួកអ្នកចូរកុំត្រាច់ទៅក្នុងទីមិនមែនជាគោចរ ដែលជាដែនរបស់បរបក្ខ ។ កាលបើអ្នកត្រាច់ទៅក្នុងទីមិនមែនជាគោចរ ដែលជាដែនរបស់បរបក្ខ មារតែងបាននូវចន្លោះ មារតែងបាននូវអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ ក៏អ្វី គឺ អគោចរ ដែលជាដែនរបស់បរបក្ខចំពោះភិក្ខុ គឺ កាមគុណ ៥ ។ កាមគុណ ៥ ដូចម្តេច បានដល់ រូប ដែលគប្បីដឹងបានដោយចក្ខុ ដែលគួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត ប្រកបដោយសេចក្តីស្រឡាញ់ ជាទីតាំងនៃតម្រេក ។ល។ ផោដ្ឋព្វៈ ដែលគប្បីដឹងដោយកាយ ។ល។ ដែលជាតាំងនៃតម្រេក ។ ម្នាលភិក្ខុទាំងឡាយ នេះគឺ អគោចរ ដែលជាដែនរបស់បរបក្ខសម្រាប់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ពួកអ្នកទាំងឡាយចូរត្រាច់ទៅក្នុងទីជាគោចរ ។ល។ មាររមែងមិនបាននូវអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ អ្វីគឺ ជាគោចរៈរបស់ភិក្ខុ ដែលជាដែននៃបិតារបស់ខ្លួន គឺ សតិប្បដ្ឋានទាំង ៤ ។ សតិប្បដ្ឋាន ៤ តើដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ពិចារណាឃើញនូវកាយក្នុងកាយ ។ល។ ធម៌ដែលជាដែននៃបិតាខ្លួន ។

បទថា កុសលានំ គឺ ធម៌ដែលមិនមានទោស ជាលក្ខណៈ ។ បទថា សមាទានហេតុ គឺ ព្រោះហេតុសមាទានហើយប្រព្រឹត្ត ។ បទថា ឯវមិទំ បុញ្ញំ បវឌ្ឍតិ សេចក្តីថា ផលបុណ្យដែលជាលោកិយៈ និង លោកុត្តរៈនេះ រមែងចម្រើនយ៉ាងនេះ ។ មួយទៀត ពាក្យថា ផលបុណ្យ នោះ គប្បីជ្រាបថា បានដល់ ទាំងបុណ្យ ទាំងផលរបស់បុណ្យជាន់ខ្ពស់ៗ ។

## រឿងស្តេចចក្រពត្តិព្រះនាមទល្ហនេមិ រតនៈ ៧ ប្រការ

[៣៤] ក្នុងពាក្យថា បុញ្ញផលំ នោះ កុសលមាន ២ យ៉ាង គឺ វដ្តគាមីកុសល កុសលជាផ្លូវទៅកាន់វដ្តៈ ១ , វិវដ្តគាមីកុសល កុសល ជាផ្លូវទៅកាន់វិវដ្តៈ ១ ។ ក្នុងកុសល ២ យ៉ាងនោះ ចិត្តដែលបង្អោនទៅ របស់មាតាបិតា ដោយអំណាចនៃសេចក្តីស្រឡាញ់ក្នុងបុត្រធីតា និងចិត្ត ដែលបង្អោនទៅរបស់បុត្តធីតា ដោយអំណាចនៃសេចក្តីស្រឡាញ់ ក្នុង មាតាបិតា ឈ្មោះថា វដ្តគាមីកុសល ។ ពោធិបក្ខិយធម៌ ៣៧ ប្រការ មានប្រភេទជាដើមថា សតិប្បដ្ឋាន ៤ ឈ្មោះថា វិវដ្តគាមីកុសល ។ ក្នុង កុសលទាំងនោះ ចំពោះកុសលដែលជាវដ្តគាមី មានទីបំផុតត្រឹមសិរិ-

សម្បត្តិរបស់ស្តេចចក្រពត្តិ ក្នុងមនុស្សលោក ។ ចំពោះកុសលដែលជាវិវដ្តគាមី មានទីបំផុត គឺ មគ្គផល និងនិព្វានសម្បត្តិ ។ ក្នុងកុសលពីរយ៉ាងនោះ ព្រះមានព្រះភាគ ទ្រង់សម្តែងវិបាករបស់វដ្តគាមីកុសលទុកក្នុងខាងចុងរបស់សូត្រ ។ តែក្នុងទីនេះ ដើម្បីសម្តែងវិបាកនៃវដ្តគាមីកុសលព្រះអង្គទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលណាបុត្រធីតា មិនតាំងនៅក្នុងឱវាទរបស់មាតាបិតា កាលនោះ ពួកគេសាបសូន្យអាយុខ្លះ ពណ៌សម្បុរខ្លះ ភាពជាធំខ្លះ ប៉ុន្តែថា កាលណាគេតាំងនៅក្នុងឱវាទ កាលនោះទើបចម្រើន ដូច្នេះហើយ ទើបផ្តើមព្រះធម៌ទេសនា ដោយអំណាចការបន្តវដ្តគាមីកុសល ទើបព្រះអង្គត្រាស់ថា ភូតបុព្វំ ភិក្ខវេ ជាដើមទៅ ។

ក្នុងពាក្យទាំងនោះ ពាក្យជាដើមថា ចក្កវត្តិ បានពោលពិស្តារហើយក្នុង **មហាបទានសូត្រ** នោះឯង បទថា ឱសក្កិតំ ប្រែថា ឃ្លាតចេញទៅបន្តិចបន្តួច ។

បទថា ឋានា ចុតំ ប្រែថា ឃ្លាតទៅចាកឋានៈ ដោយប្រការទាំងពួង ។ បានឮមកថា ចក្រកែវនោះ បានអណ្តែតឡើងទៅតាំងនៅក្នុងអាកាស ដូចនាំទៅដោយកង់នៅលើទ្វារព្រះរាជវាំងជាន់ខាងក្នុង ។ គ្រា

នោះ ព្រះរាជាត្រាស់បង្គាប់ឲ្យកប់សសរគគីរពីរដើម ទុកត្រង់ទីខាងទាំងពីរនៃចក្រនោះ ទីខាងលើបំផុតរបស់ចក្រកែវ ចងខ្សែអំបោះទុកមួយសរសៃឲ្យនៅត្រង់កង់ ។ សូម្បីក្នុងផ្នែកខាងក្រោម ក៏ចងខ្សែអំបោះមួយសរសៃឲ្យនៅត្រង់កង់ ។ ចក្រកែវខាងក្រោម ក៏ស្រុតចុះបន្តិច ពីខ្សែសរសៃខាងលើ ក្នុងបណ្ដាខ្សែពីរសរសៃនោះ ក៏ពោលបានថា ឃ្លាតចុះ ។ ទីបំផុតនៃចក្រកែវនោះ ក៏ឃ្លាតចាកឋានហើយ ។ កាលមានទោសខ្វាំងក្លាចក្រកែវនោះ នឹងជាយ៉ាងនេះ គឺ ឃ្លៀងឃ្លាតចាកឋាន សូម្បីប្រមាណប៉ុនសរសៃអំបោះ ឬប្រមាណមួយអង្គុលី ពីរអង្គុលី ។

លោកសំដៅយកហេតុនោះ ទើបពោលថា ឱសក្កិតំ ឋានា ចុតំ ឃ្លៀងឃ្លាតចាកទី ដូច្នេះ ។ ពាក្យថា អថ មេ អារោចេយ្យាសិ សេចក្តីថា ព្រះរាជាត្រាស់បង្គាប់ថា បាអើយ រាប់ពីថ្ងៃនេះជាដើមទៅ អ្នកចូរទៅកាន់ទីរក្សាចក្រកែវមួយថ្ងៃ ៣ ដង អ្នកកាលទៅយ៉ាងនោះ ឃើញចក្រកែវឃ្លាតចាកទីសូម្បីតែបន្តិចណា គប្បីប្រាប់ដល់យើងកាលនោះ ព្រោះថាជីវិតរបស់យើងផ្ញើទុកក្នុងដៃរបស់អ្នក ។

បទថា អទ្ទស សេចក្តីថា បុរសនោះមិនប្រមាទឡើយ ទៅមើល

មួយថ្ងៃ ៣ ដង ថ្ងៃមួយក៏បានឃើញ ។

## ចក្ករតន៍ជាទិព្វចាត់នៅ

[៣៥] ប្រការថា អជ្ឈោ ភិក្ខវេ សេចក្តីថា ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ គ្រានោះព្រះបាទទឡ្ហនេមិ ទ្រង់ព្រះសណ្តាប់ថា ចក្រកែវ ឃ្លាតចាកទីហើយ ក៏កើតសេចក្តីទោមនស្សយ៉ាងខ្លាំង ត្រិះរិះថា យើងនឹងមានជីវិតមិនយឺនយូរ អាយុរបស់យើងនៅសល់តិចណាស់ឥឡូវនេះ យើងនឹងមិនមានពេលបរិភោគកាមទៀតឡើយ វេលានៃការបព្វជ្ជារមែងមានដល់យើងក្នុងកាលឥឡូវនេះ ដូច្នេះហើយ ទ្រង់ព្រះកន្សែងទួញយំត្រាស់បង្គាប់ឲ្យហៅព្រះរាជកុមារ ជាឱរសច្បងមក ហើយត្រាស់ពាក្យនេះ ។

## អានុភាពនៃចក្ករតន៍

[៣៦] ពាក្យថា សមុទ្ទបរិយន្តំ គឺ មានសមុទ្រមួយដែលឡោមព័ទ្ធជុំវិញជាព្រំដែនទុំះឯង ។ ដែលពិត ទ្រព្យ គឺ ផែនដីនេះ ជារបស់ប្រចាំរាជត្រកូលរបស់ព្រះរាជាអង្គនោះ ។ មួយទៀត ចក្រកែវនោះ មានចក្រវាឡ

ជាព្រំដែន កើតឡើងបានដោយអំណាចបុញ្ញឫទ្ធិ នរណាៗ ក៏មិនអាចនឹងលើកឲ្យគ្នាបាន ។ ក៏ព្រះរាជា កាលនឹងប្រគល់ចក្រកែវ ដែលជាវត្ថុប្រចាំរាជត្រកូល ទើបត្រាស់ថា សមុទ្ទបរិយន្តំ ដូច្នេះ ។ បទថា កេសមស្សុំ សេចក្តីថា ការពិតបុគ្គលទាំងឡាយ សូម្បីកាលនឹងបួសជាតាបស ក៏កោរសក់ និងពុកមាត់ចេញជាមុន អំពីនោះទៅ ទើបបានបួងសក់ដែលដុះឡើងមក ត្រាច់ទៅ ព្រោះហេតុនោះ លោកទើបពោលថា កេសមស្សុំ ឱហារេត្វា ។ បទថា កាសាយានិ បានដល់ សំពត់ដែលជ្រលក់ដោយទឹកអម្ចត់ ។ អធិប្បាយថា ខាងដើមបានធ្វើយ៉ាងនោះ ខាងក្រោយ ទើបទ្រទ្រង់សូម្បីសំពត់សំបកឈើ ។

## ចក្ករតន៍ជាទិព្វចប្បតបាកទី

**[៣៧]** បទថា បព្វជិ ប្រែថា បួសហើយ ។ អធិប្បាយថា ក៏គ្រាបួសហើយ បានប្រថាប់នៅក្នុងព្រះរាជឧទ្យាន ដែលជាសួនមង្គលរបស់ព្រះអង្គ នុ៎ះឯង ។

បទថា រាជីសិម្ហិ គឺ រាជឥសី ។ ពិតហើយ អ្នកបួសចេញចាក

វណ្ណៈព្រាហ្មណ៍ លោកហៅថា ព្រាហ្មណឥសី ។ ចំណែកអ្នកលះបង់ស្វេតឆ័ត្រ បួសពីវណ្ណៈក្សត្រិយ៍ ហៅថា រាជឥសី ។ បទថា អន្តរធាយិ ប្រែថា បាត់ទៅហើយ គឺ ដល់ការមិនមាន ដូចអណ្តាតប្រទីបដែលរលត់ហើយ ។

បទថា បដិសំវេទេសិ សេចក្តីថា ( ព្រះរាជឱរស ) ទ្រង់ព្រះកន្សែងរៀបរាប់ ទូលឲ្យជ្រាបហើយ ។ បទថា បេត្តិកំ គឺ លោកសម្តែងថា មិនមែនទ្រព្យមត៌ក ដែលមកពីខាងរាជបិតា ដែលនរណាៗ មានការខ្ជិលច្រអូស មានការព្យាយាមធូរថយ សមាទានប្រព្រឹត្តអកុសលកម្មបថ ១០ ប្រការ មិនអាចលះបង់បាន ប៉ុន្តែថា បុគ្គលដែលអាស្រ័យកម្ម ដែលធ្វើទុកល្អរបស់ខ្លួន បំពេញវត្តរបស់ស្តេចចក្រពត្តិ ១០ យ៉ាង ឬ ១២ យ៉ាង ប៉ុណ្ណោះ ទើបនឹងបានចក្រកែវនោះ ។ គ្រានោះ រាជឥសី កាលដាស់តឿនរាជបុត្រនោះ ទុកក្នុងវត្តបដិបត្តិ ទើបត្រាស់ពាក្យជាដើមថា តេនហិ ត្វំ ស្តេចយាងចុះព្រះអង្គ ។

ក្នុងវត្តបដិបត្តិនោះ ពាក្យថា អរិយេ គឺ អស់ទោស ។ ពាក្យថា ចក្កវត្តិវត្តេ បានដល់ ក្នុងវត្តរបស់ស្តេចចក្រពត្តិ ។

បទថា ធម្មំ បានដល់ ធម៌ គឺ កុសលកម្មបថ ១០ ។ បទថា និស្សាយ គឺ ធ្វើធម៌នោះប៉ុណ្ណោះ ឲ្យជាទីអាស្រ័យ ដោយព្រះទ័យដែលអធិដ្ឋានធម៌នោះទុកហើយ ។ បទថា ធម្មំ សក្ករោន្តោ សេចក្តីថា ធម៌នោះដែលគេបំពេញហើយ គឺ បំពេញដោយល្អយ៉ាងណា លោកក៏បំពេញធម៌យ៉ាងនោះដូចគ្នា ។ ពីរបទថា ធម្មំ គរុករោន្តោ គឺ ធ្វើធម៌នោះឲ្យក្រៃលែង ដោយការចូលដល់សេចក្តីគោរពក្នុងធម៌នោះ ។ បទថា ធម្មំ មានេន្តោ គឺ ធ្វើធម៌នោះប៉ុណ្ណោះឲ្យជាទីស្រឡាញ់ និងឲ្យគួរដល់ការលើកតម្កើង ។ បទថា ធម្មំ បូជេន្តោ គឺ សំអាងធម៌នោះហើយ ធ្វើការបូជាចំពោះធម៌នោះដោយការបូជា ដោយវត្ថុមានគ្រឿងក្រអូប និងផ្កាឈើជាដើម ។ បទថា ធម្មំ អបចាយមានោ សេចក្តីថា ធ្វើការប្រព្រឹត្តបន្ទោរចំពោះធម៌នោះនុ៎ះឯង ដោយសាមីចិកម្ម មានការលើកដៃប្រណម្យជាដើម ។

បទថា ធម្មទ្ធជោ ធម្មកេតុ អធិប្បាយថា ឈ្មោះថា មានធម៌ដូចជាទង់ជ័យ និងឈ្មោះថា មានធម៌ជាវត្ថុខ្ពស់បំផុត ព្រោះលើកស្ទួយធម៌នោះទុកខាងមុខ ដូចទង់ជ័យ និងលើកធម៌នោះឡើង ធ្វើឲ្យដូចកំពូល

ហើយប្រព្រឹត្ត ។

បទថា ធម្មាធិបតេយ្យោ គឺ មានធម៌ជាធំ បានដល់ ជាធម្មាធិបតេយ្យ ព្រោះភាវៈនៃធម៌ដែលមានមកហើយ និងព្រោះធ្វើកិរិយាទាំងអស់ ដោយអំណាចធម៌ប៉ុណ្ណោះ ។

បទថា ធម្មិកំ រក្ខាវរណគុត្តឹ សំវិទហស្សុ មានវិគ្រោះដូច្នេះ ធម៌នៃការរក្សាមាន ហេតុនោះ ការរក្សានោះ ឈ្មោះថា មានធម៌ការពារ និងការឃុំគ្រង ឈ្មោះថា រក្ខវរណគុត្តិ ។ បណ្ដាធម៌ ជាគ្រឿងរក្សាទាំងនោះ ធម៌ទាំងឡាយមានខន្តីជាដើម ឈ្មោះថា ការរក្សា ព្រោះព្រះបាលីថា បុគ្គលកាលរក្សាអ្នកដទៃ ឈ្មោះថា រក្សាខ្លួន ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ក៏បុគ្គលកាលរក្សាអ្នកដទៃ ឈ្មោះថា រក្សាខ្លួន តើដូចម្ដេច ។ បុគ្គលកាល រក្សាអ្នកដទៃ ឈ្មោះថា រក្សាខ្លួនទុកបានដោយខន្តី ដោយការមិនបៀតបៀន ដោយការមានមេត្តាចិត្ត និងដោយមានសេចក្ដីអាណិត ។ ការការពារវត្ថុ មានសំពត់ស្លៀក សំពត់ដណ្ដប់ និងផ្ទះជាដើម ឈ្មោះថា **អាវរណ** ការការពារ ។ ការឃុំគ្រងដើម្បីហាមឧបទ្រវន្តរាយ មានចោរជាដើម ឈ្មោះ

ថា គុត្តិ ការឃុំគ្រង ។ អធិប្បាយថា លោកចូរចាត់ចែងកិច្ចការទាំងអស់ នោះ គឺ ឲ្យប្រព្រឹត្តទៅ ឲ្យតាំងនៅដោយល្អ ។ ឥឡូវនេះ កាលទ្រង់ សម្ដែងវត្តដែលគប្បីចាត់ការរក្សាការពារ ឃុំគ្រង ឥសីទើបពោលថា អន្តោជនស្មឹ សេចក្ដីសង្ខេបក្នុងពាក្យនោះ មានដូចតទៅនេះ ។

## វត្តរបស់ព្រះចៅចក្រពត្តិ

អ្នកឯងចូរញុំាងបុត្រ និងភរិយា ពោលគឺ ជនខាងក្នុងរបស់អ្នក ឲ្យតាំងនៅក្នុងសីលសំវរៈ ចូរឲ្យវត្ថុមានសំពត់ ផ្កាឈើ និងគ្រឿងក្រអូប ជាដើម ដល់ពួកបុត្រ និងភរិយានោះ និងចូរការពារឧបទ្រវៈទាំងអស់ ឲ្យដល់គេ ។ សូម្បីក្នុងពួកទាហានជាដើម ក៏ន័យនេះដូចគ្នា ។ តែមាន ប្រការផ្សេងគ្នាដូច្នេះ ។ ពួកទាហានដែលព្រះរាជាគួរសង្គ្រោះ ដោយការ បន្ថែមប្រាក់បំណាច់រង្វាន់ឲ្យ មិនឲ្យកន្លងហួសកាលវេលា ។ ក្សត្រអ្នក បានទទួលការអភិសេក គួរសង្គ្រោះដោយការឲ្យរតនៈ មានសេះអាជានេយ្យ ដ៏ស្អាតសង្ហាជាដើម ។ ក្សត្រដែលជាប្រទេសរាជ គួរឲ្យត្រេកអរ សូម្បី ដោយការប្រគល់ឲ្យនូវយានពាហនៈ ដែលសមគួរដល់ភាពជាក្សត្រនោះ ។

ព្រាហ្មណ៍ទាំងឡាយ គួរឲ្យត្រេកអរដោយទេយ្យធម៌ មានបាយ ទឹក និង សំពត់ជាដើម ។

ពួកគហបតីគួរសង្គ្រោះ ដោយការឲ្យពូជស្រូវ នង្គ័ល ផាល និង គោល្អជាដើម ។ អ្នកនៅក្នុងនិគម ឈ្មោះនេគមៈ ( អ្នកនិគម ) និងអ្នក នៅក្នុងជនបទ ឈ្មោះថា ជនបទា ( ពួកអ្នកជនបទ ) ក៏ដូចគ្នា ( គឺគួរ សង្គ្រោះដោយការឲ្យពូជស្រូវ នង្គ័ល ផាល និងគោល្អជាដើម ) ។

ពួកសមណព្រាហ្មណ៍ អ្នកមានបាបស្ងប់ហើយ មានបាបអណ្តែត ចេញហើយ គួរសក្ការៈ ដោយការថ្វាយបរិក្ខារសម្រាប់សមណព្រាហ្មណ៍ ។ ម្រឹគីម្រឹគា និបបក្សាបក្សី គួរឲ្យរីករាយចិត្ត ដោយការឲ្យអភ័យ ។ បទថា វិជិតេ គឺ ក្នុងស្ថានទី ដែលនៅក្នុងអំណាចឃុំគ្រងរបស់ខ្លួន ។ បទថា អធម្មការោ គឺ ការធ្វើដែលមិនប្រកបដោយធម៌ ។ បទថា មា បវត្តិត្ថ អធិប្បាយថា ចូរញុំាងការធ្វើដែលជាអធម៌នោះ មិនឲ្យប្រព្រឹត្តទៅ ។

បទថា សមណព្រាហ្មណា បានដល់ អ្នកមានបាបស្ងប់រំងាប់ គឺ មានបាបបណ្តែតចេញហើយ ។ បទថា មទប្បមាទា បដិវិរតា គឺ វៀរចាក សេចក្តីស្រវឹងដោយអំណាចមានះ ៩ យ៉ាង និងចាកសេចក្តីប្រមាទ ពោល

គឺ ការបណ្តោយចិត្តទៅក្នុងកាមគុណ ៥ ។ បទថា ១ន្តិសោរច្ចេ និវិដ្ឋា សេចក្តីថា តាំងនៅក្នុងអធិវាសនខន្តី និងក្នុងភាពជាអ្នកស្ងប់ស្ងៀម ។ បទថា ឯកមត្តានំ សេចក្តីថា សមណព្រាហ្មណ៍ទាំងឡាយ លោកពោលថា រមែងទូន្មានខ្លួន ស្ងប់រំងាប់ រំលត់ម្នាក់ឯង ដោយការគ្រប់សង្កត់កិលេស មានរាគៈជាដើម របស់ខ្លួន ។ បទថា កាលេន កាលំ គឺ គ្រប់វេលា ។

បទថា អភិនិវជ្ជេយ្យាសិ សេចក្តីថា គប្បីវៀរចេញនូវអកុសលដែលប្រៀបដូចលាមក ដូចថ្នាំពិស និងដូចភ្លើងកំពុងឆេះ ។ បទថា សមាទាយ គឺ គប្បីកាន់យកនូវកុសល ដែលប្រៀបដូចជាកម្រងផ្កាឈើដែលមានក្លិនក្រអូប និងប្រៀបដូចទឹកអម្រឹត ហើយបដិបត្តិដោយប្រពៃ ។ បណ្ឌិតតាំងនៅក្នុងកុសលធម៌នេះ ហើយគប្បីនាំវត្តមកបដិបត្តិដោយល្អ ។

វត្តនោះ មាន ១០ ប្រការ យ៉ាងនេះគឺ វត្តដែលគប្បីបដិបត្តិក្នុងពួកទាហានដែលជាជនខាងក្នុង ១ ក្នុងពួកក្សត្រ ១ ក្នុងក្សត្រប្រទេសរាជ ១ ក្នុងព្រាហ្មណ៍ និងគហបតី ១ ក្នុងអ្នកនិគម និងអ្នកជនបទ ១ ក្នុងសមណព្រាហ្មណ៍ ១ ក្នុងពួកម្រឹគ និងពួកបក្សា ១ ការហាមការធ្វើ

ដែលមិនមែនជាធម៌ ១ ការប្រគល់ទ្រព្យឲ្យដល់អ្នកមិនមានទ្រព្យ ១ ការចូលទៅរកសមណព្រាហ្មណ៍ហើយសួរបញ្ហា ១ តែកាលកាន់យកគហបតីនិងពួកបក្សាជាតិជាផ្នែកមួយហើយ ក៏នឹងមាន ១២ យ៉ាង ។ បណ្ឌិតអ្នកកាន់យកពាក្យដែលមិនបានពោលទុកក្នុងគ្រាមុន គប្បីជ្រាបថា វត្តមាន ១២ យ៉ាង ដោយអាស្រ័យការលះបង់រាគៈដែលមិនមែនជាធម៌ និងវិសម-លោភៈ លោភៈដែលមិនស្មើជាដើម ។

ប្រការថា ឥទំ ខោ តាត តំ ដូច្នេះ សេចក្តីថា វត្តទាំង ១០ យ៉ាង និង ១២ យ៉ាងនេះ ឈ្មោះថា វត្តបដិបត្តិរបស់ស្តេចចក្រពត្តិដ៏ប្រសើរ ។

បទថា វត្តមានស្ស គឺ បំពេញឲ្យបរិបូរណ៍ ។ ពាក្យជាដើមថា តទហុបោសថេ បានពោលទុកហើយក្នុងមហាសុទស្សនសូត្រ ។

[៣៨] បទថា សមតេន គឺ តាមមតិរបស់ខ្លួន ។

ពាក្យថា សុទំ ត្រឹមតែជានិបាត ។ បទថា បសាសតិ គឺ ឃុំគ្រង ។ មានពាក្យពោលអធិប្បាយទុកថា ព្រះរាជាទ្រង់លះបង់រាជវង្សពីអតីត បានដល់រាជធម៌ ដែលជារាជប្រពៃណីចេញហើយ តាំងនៅក្នុងធម៌ត្រឹមតែជាមតិ

របស់ខ្លួនគ្រប់គ្រងប្រទេស កាលបើដូច្នោះ ព្រះរាជាអង្គនោះ ទើបជាព្រះរាជាអង្គចុងក្រោយ ដែលជាអ្នកផ្តាច់វង្សរបស់ព្រះបាទទឡ្ហនេមិ ដូចអ្នកឲ្យកើតសេចក្តីសៅហ្មងដល់វង្សមេឃទេព ដូច្នោះ ។ បទថា បុព្វេនាបរំ គឺ ក្នុងកាលតមក ប្រជារាស្ត្រមិនរុងរឿង គឺ មិនចម្រើន ដូចកាលមុន ។ សេចក្តីថា យថា តំ បុព្វកានំ សេចក្តីថា ប្រជារាស្ត្រចម្រើនហើយដូចគ្នាទាំងក្នុងរជ្ជកាលមុន និងរជ្ជកាលក្រោយ របស់ព្រះរាជាអង្គមុនៗ យ៉ាងណានឹងចម្រើនរុងរឿង ដូច្នោះមិនបាន គឺ ក្នុងទីណាក៏ទេ ត្រូវបោរប្ញទ់អធិប្បាយថា សូម្បីឱជាក្នុងប្រេង ទឹកឃ្មុំ ទឹកអំពៅជាដើម និងក្នុងយាគូកត្តជាដើម ក៏សាបសូន្យទៅ ។ ពីរបទថា អមច្ចា ចារិសជ្ជា គឺ ពួកអាមាត្យនិងអ្នកត្រាច់ទៅក្នុងបរិស័ទ ។ បទថា គណាកមហាមត្តា បានដល់ ពួកហោរអ្នកជំនាញក្នុងបាឋៈ មានអច្ឆិទ្ទិកៈ ទាយសំពត់ដាច់ជាដើម និងពួកអាមាត្យថ្នាក់ធំ ។ បទថា អនីកដ្ឋា គឺ ពួកអាចារ្យទាំងឡាយ មានហត្ថាចារ្យជាដើម ។ បទថា ទោវារិកា គឺ ពួកអ្នករក្សាទ្វារ ។ បញ្ញាហៅថា មន្តក្នុងបទថា មន្តស្សាជីវិនោ ។ អាមាត្យថ្នាក់ធំពួកណា ធ្វើបញ្ញានោះឲ្យជាគ្រឿងចិញ្ចឹមជីវិត អាមាត្យថ្នាក់ធំពួកនោះ ឈ្មោះថា **បណ្ឌិត** ពាក្យថា

មនុស្សាធិបតិនោ នោះ ជាឈ្មោះនៃមហាមាត្យទាំងនោះ ។

## ទ្រង់មិនព្រះរាជទានទ្រព្យដល់ពួកមនុស្សដែលឥតទ្រព្យ

**[៣៩]** *បទថា នោ ច ខោ អធនានំ សេចក្តីថា ដល់មនុស្សអ្នកគ្មានទ្រព្យ គឺ អ្នកក្រលំបាក ព្រោះខ្លួនមានសេចក្តីលោភខ្លាំងក្លា ។ បទថា ធនេ នានុប្បទិយមានេ សេចក្តីថា ដែលគេមិនប្រគល់ទ្រព្យឲ្យ ។ មង្យ៉ាងទៀតបាលីក៏ជាដូច្នេះដូចគ្នា ។ បទថា ធាលិទ្ទិយំ ប្រែថា ទ័លក្រ ។ បទថា អត្តនា ច ជីវាហិ សេចក្តីថា ចូររស់នៅ គឺ ចូរញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅឯង ។ បទថា ឧទ្ធគ្គិកំ មានវិគ្គហៈថា ផលរបស់ទក្ខិណានោះទៅក្នុងខាងលើដោយអំណាចឲ្យផលក្នុងភូមិខ្ពស់ៗ ឡើងទៅ ហេតុនោះទក្ខិណានោះ ទើបឈ្មោះថា មានផលទៅក្នុងខាងលើ ។ ទក្ខិណាឈ្មោះថា សោវគ្គិកា ព្រោះជាប្រយោជន៍ដល់សួគ៌ ព្រោះឲ្យកើតក្នុងសួគ៌នោះ ។ ទក្ខិណា ឈ្មោះថា* ***មានវិបាកជាសុខ*** *ព្រោះមានវិបាកជាសុខ ក្នុងទីដែលខ្លួនកើតហើយ ។ ទក្ខិណាឈ្មោះថា* ***ប្រព្រឹត្តទៅដើម្បីសួគ៌*** *ព្រោះឲ្យកើតផលវិសេស ១០ យ៉ាង មានវណ្ណៈដែលជាទិព្វជាដើម ដែលប្រសើរក្រៃ*

លែង ។ អធិប្បាយថា អ្នកចូរញ៉ាំងទក្ខិណាទាន ឃើញបែបនេះ ឲ្យតាំង
នៅ ។

[៤០] បទថា បវឌ្ឍិស្សតិ គឺ នឹងចម្រើន គឺ នឹងមានច្រើន ។
បទថា សុនិសេធំ និសេធេយ្យំ សេចក្តីថា យើងនឹងធ្វើការហាម គឺ គប្បី
បដិសេធដាច់ខាត ។

បទថា មូលឃច្ចំ គឺ ដកឫស ។ បទថា ខុរស្សរេន គឺ មាន
សម្លេងគ្រោតគ្រាត ។

បទថា បណវេន គឺ ស្គរពិឃាត ។

[៤១-៤២] បទថា សិសានិ នេសំ ជិន្ទិស្សាមិ សេចក្តីថា ដោយ
ទីបំផុត ពួកយើងនាំសូម្បីត្រាវ-ជំឡូង ត្រឹមតែមួយក្តាប់របស់អ្នកណាទៅ
យើងនឹងកាត់សីសៈរបស់អ្នកនោះ ដោយប្រការដែលនរណាៗ នឹងមិនដឹង
សូម្បីរឿងដែលយើងសម្លាប់ ឥឡូវនេះក្នុងទីនេះ នឹងមានប្រយោជន៍អ្វី
ដល់ពួកយើង សូម្បីព្រះរាជា ស្តេចក្រោកឡើងយ៉ាងនោះហើយ ត្រាស់
បង្គាប់ឲ្យសម្លាប់បុគ្គលដទៃ ។ គប្បីជ្រាបអធិប្បាយនៃពាក្យទាំងនោះ ដូច
ពោលមកនេះ ។

បទថា ឧបក្កមីសុ គឺ ផ្តើមហើយ ។ បទថា បន្ធនុហានំ សេចក្តីថា ការបូន់អ្នកដើរផ្លូវ ។ ពាក្យថា ន ហិ ទេវ សេចក្តីថា បានឮមកថា បុរសនោះគិតថា ព្រះរាជានេះ ត្រាស់បង្គាប់ឲ្យប្រហារតាមដែលឲ្យការសារភាពថា ពិតហើយព្រះអង្គ ណ្ហើយចុះ យើងនឹងឲ្យការកុហក ដូច្នេះហើយ ព្រោះខ្លាចស្លាប់ ទើបទូលថា មិនពិតទេព្រះអង្គ ។

[៤៣] ពាក្យថា ឥធំ ក្នុងពាក្យថា ឯកឹធំ នេះ ត្រឹមតែជានិបាត ។ អធិប្បាយថា សត្វពួកមួយ ។

[៤៤] បទថា ចារិត្តំ បានដល់ ការប្រព្រឹត្តខុស ។ បទថា អភិជ្ឈាព្យាបាទា បានដល់ អភិជ្ឈា និងព្យាបាទ ។

បទថា មិច្ឆាទិដ្ឋិ បានដល់ ទិដ្ឋិដែលជាសត្រូវ មានអន្តគាហិកទិដ្ឋិ មានជាអាទិ៍ថា " ទានដែលបុគ្គលឲ្យហើយមិនមានផល " ដូច្នេះ ។ បទថា អធម្មរាគោ បានដល់ តម្រេកក្នុងឋានៈដែលមិនសមគួរ ជាដើមថា មាតា ១ ម្តាយមីង ១ បិតា ១ បងស្រី ១ អ៊ំស្រី ១ ។ បទថា វិសមលោភោ បានដល់ សេចក្តីលោភដ៏ខ្លាំងក្លា ក្នុងឋានៈសូម្បីមិនគួរបរិភោគ ។ បទថា មិច្ឆាធម្មោ សេចក្តីថា តម្រេកដោយអំណាចសេចក្តីពេញចិត្ត រវាងប្រុស

និងប្រុស ស្រ្តីនិងស្ត្រី ។ ក្នុងបទថា អមត្តេយ្យតា ជាដើម មានវិគ្គហៈថា អ្នកជួយសង្គ្រោះមាតា ឈ្មោះ មត្តេយ្យ ភាវៈនៃមត្តេយ្យៈនោះ ឈ្មោះ មត្តេយ្យតា ។

[៤៥] ពាក្យថា មត្តេយ្យតា នោះ ជាឈ្មោះនៃការបដិបត្តិប្រពៃក្នុងមាតា ការមិនមាននៃមត្តេយ្យតានោះ និងភាពជាបដិបក្ខចំពោះមត្តេយ្យតានោះ ឈ្មោះថា អមត្តេយ្យតា ។ សូម្បីក្នុង អបេត្តេយ្យតា ជាដើម ក៏ន័យនេះឯង ។

បទថា ន កុលេជេដ្ឋាបចាយិតា សេចក្ដីថា ភាវៈ គឺ ការមិនធ្វើសេចក្ដីកោតក្រែង គឺ ការប្រព្រឹត្តទន់ភ្លន់ចំពោះរៀមច្បង ក្នុងត្រកូល ។

## សេចក្ដីប្រៀបដោយស្មៅគែលលកជាភោជនដ៏ប្រសើរ

[៤៦] បទថា យំ ឥមេសំ គឺ ក្នុងសម័យណា នៃមនុស្សទាំងនេះ ។ បទថា អលំបតេយ្យ សេចក្ដីថា គួរឲ្យសំពត់ ។ បទថា ឥមានិ រសានិ សេចក្ដីថា រសទាំងនេះ ជារសដ៏ប្រសើរក្នុងលោក ។ បទថា អតិព្យា-ធីបិស្សន្តិ បានដល់ នឹងរុងរឿងយ៉ាងក្រៃលែង ។ មួយ៉ាងទៀត បាលី

ក៏យ៉ាងនេះដូចគ្នា ។ បទថា កុសលន្តិបិ ន ភវិស្សតិ សេចក្តីថា សូម្បីឈ្មោះថា " **កុសល** " ដូច្នេះ ក៏នឹងមិនមាន ។

អធិប្បាយថា សូម្បីត្រឹមតែបញ្ញត្តិនឹងមិនប្រាកដ ។ បទថា បុជ្ជា ច ភវិស្សន្តិ ចាសំសា សេចក្តីថា នឹងជាអ្នកគួរបូជា និងគួរសរសើរ ។ បានឮថា ក្នុងសម័យនោះ ពួកមនុស្សគិតគ្នាថា បុគ្គលឈ្មោះឯណោះ សម្លាប់មាតា សម្លាប់បិតា ផ្តាច់ជីវិតសមណព្រាហ្មណ៍ គួរសេង្វៀគហ្ន៍ បុរសមែនមិនដឹង សូម្បីជារៀមច្បងក្នុងត្រកូលមាន ដូច្នេះហើយ នឹងបូជា និងនឹងសរសើរបុរសនោះនុ៎ះឯង ។ ប្រការថា ន ភវិស្សតិ មាតាតិវា សេចក្តីថា ចិត្តដែលប្រកបដោយសេចក្តីគោរព ថា អ្នកនេះជាមាតារបស់យើងនឹងមិនមានឡើយ ។ មនុស្សទាំងឡាយ កាលពោលពាក្យអសប្បុរសប្រការផ្សេងៗ ដូចពោលនឹងមាតុគ្រាមក្នុងផ្ទះ ក៏នឹងចូលទៅរកដោយអាការមិនគោរព ។ សូម្បីក្នុងញាតិទាំងឡាយ មានម្តាយមីងជាដើម ក៏ន័យនេះដូចគ្នា ។ ក៏ក្នុងពាក្យថា មាតុច្ឆា ជាដើមនេះ គឺ ប្អូន ឈ្មោះថា មាតុច្ឆា បានដល់ ប្អូនស្រីរបស់ម្តាយ ឈ្មោះថា មាតុលានី បានដល់ ភរិយារបស់អ៊ំ ។ ឈ្មោះថា អាចរិយភរិយា បានដល់ ភរិយារបស់

អាចារ្យអ្នកឲ្យសិក្សាសិល្បវិជ្ជា ។ បទថា គរូនំ ធារា បានដល់ កិរិយារបស់ញាតិ មានឪពុកមា និងឪពុកធំជាដើម ។ បទថា សម្ពេធំ សេចក្តីថា ការៈដែលឡាយលំ ឬថា ការទម្លាយប្រពៃណី ។ បទថា តិព្វោ អាឃាតោ បច្ចុប្បដ្ឋិតោ ភវិស្សតិ សេចក្តីថា សេចក្តីក្រោធដែលខ្លាំងក្លានឹងកើតឡើងចំពោះ ដោយកើតឡើងញយៗ ។ ពីរបទក្រោយ ក៏ជាវេវចនៈរបស់សេចក្តីក្រោធទាំងនោះ ។ ពិតណាស់ សេចក្តីក្រោធ រមែងធ្វើចិត្តឲ្យចងអាឃាត ហេតុនោះ ទើបឈ្មោះថា **អាឃាត** ។ សេចក្តីក្រោធ រមែងធ្វើប្រយោជន៍ និងសេចក្តីសុខរបស់ខ្លួន និងអ្នកដទៃឲ្យវិនាស ហេតុនោះទើបឈ្មោះថា **ព្យាបាទ** នឹងពោលថា ការប្រទូសរ៉ាយនៃចិត្តក៏បាន ព្រោះប្រទូសរ៉ាយចិត្ត ។ បទថា តិព្វំ វធកចិត្តំ សេចក្តីថា ចិត្តគិតនឹងសម្លាប់ដើម្បីឲ្យអ្នកដទៃស្លាប់ រមែងមានបានសូម្បីដល់អ្នកដែលមានចិត្តស្រឡាញ់គ្នា ។ ដើម្បីនឹងសម្តែងរឿងនៃចិត្តគិតនឹងសម្លាប់គ្នានោះ ទើបពោលពាក្យជាដើមថា មាតុបិ បុត្តម្ហិ ដូច្នេះ ។ បទថា មាគវិកស្ស បានដល់ព្រានព្រៃ ។

## និយាយអំពីគំនុំដ៏ក្លៀវក្លាជាដើម

**[៤៧]** បទថា សត្ថន្តរកប្បោ សេចក្តីថា កប្បដែលវិនាសក្នុងចន្លោះដោយសស្ត្រា គឺ នៅមិនទាន់ដល់សំវដ្តកប្ប លោកក៏វិនាសក្នុងចន្លោះ ។ ក៏ឈ្មោះថា **អន្តរកប្ប** នេះ មាន ៣ យ៉ាង គឺ ទុព្ភិក្ខន្តរកប្ប កប្បដែលលោកវិនាសក្នុងចន្លោះដោយទុព្ភិក្ខភ័យ ១ រោគន្តរកប្ប កប្បដែលលោកវិនាសក្នុងចន្លោះដោយរោគ ១ សត្ថន្តរកប្ប កប្បដែលលោកវិនាសក្នុងចន្លោះដោយសស្ត្រា ១ ។ ក្នុងកប្បទាំងនោះ ទុព្ភិក្ខន្តរកប្ប កើតឡើង មានឡើង បានដល់ ពួកសត្វដែលក្រាស់ដោយសេចក្តីលោភ ។ រោគន្តរកប្ប កើតឡើង មានឡើង បានដល់ ពួកសត្វដែលក្រាស់ដោយមោហៈ ។ សត្ថន្តរកប្ប កើតឡើង មានឡើង បានដល់ ពួកសត្វដែលក្រាស់ដោយទោសៈ ។

ក្នុងកប្បទាំងនោះ ពួកសត្វដែលវិនាស ព្រោះទុព្ភិក្ខន្តរកប្ប រមែងកើតឡើងក្នុងបិត្តិវិស័យនៃប្រេតដោយច្រើន ។ ព្រោះអ្វី ? ព្រោះមានសេចក្តីប្រាថ្នាក្នុងអាហារជាកម្លាំង ។ ពួកសត្វដែលវិនាសព្រោះរោគន្តរ-កប្ប កើតក្នុងសួគ៌ដោយច្រើន ។ ព្រោះអ្វី ? ព្រោះសត្វទាំងនោះ កើត

មេត្តាចិត្តឡើងថា ឱហ្ន៎ ពេគបែបនេះ មិនគប្បីមានដល់សត្វពួកដទៃ ។ ពួកសត្វដែលវិនាសព្រោះសត្ថន្តរកប្ប រមែងកើតក្នុងនរកដោយច្រើន ។ ព្រោះអ្វី ? ព្រោះមានការអាឃាតចំពោះគ្នានិងគ្នាយ៉ាងខ្លាំងក្លា ។ បទថា មិគសញ្ញំ សេចក្តីថា មនុស្សកើត សេចក្តីសម្គាល់ឡើងថា អ្នកនេះជាម្រឹគ អ្នកនេះជាម្រឹគ ។ បទថា តិណ្ហានិ សត្ថានិ ហត្ថេសុ ចាតុភ-វិស្សន្តិ សេចក្តីថា បានពួមកថា សម្រាប់មនុស្សទាំងនោះ វត្ថុអ្វីៗ ល្មមនឹងយកដៃចាប់បាន ដោយហោចទៅ សូម្បីតែស្លឹកស្មៅ ក៏នឹងក្លាយជាអាវុធទៅទាំងអស់ ។ មាតិកាថា មា ច មយំ កញ្ចិ សេចក្តីថា ពួកយើងកុំសម្លាប់សូម្បីបុរសណាម្នាក់ឲ្យស្លាប់ឡើយ ។ មាតិលាថា មា ច អម្ហេ កោចិ សេចក្តីថា បុរសដទៃណាៗ កុំសម្លាប់ពួកយើងឡើយ ។ ពាក្យថា យន្នូន មយំ សេចក្តីថា ពួកសត្វនឹងសម្គាល់គិតយ៉ាងនេះថា សេចក្តីវិនាសនៃលោកនេះប្រាកដចំពោះហើយ ដែលយើងទាំងឡាយពីរនាក់នៅក្នុងទីជាមួយគ្នា មិនអាចមានជីវិតរស់នៅបាន ។ បទថា វនគហានំ សេចក្តីថា ទីព្រៃក្រាស់ដាយព្រឹក្សាជាតិ មានគុម្ពស្មៅ និងវល្លិ៍ជាដើម ដែលរាប់ថា ព្រៃ ។ បទថា រុក្ខគហានំ គឺ ដោយដើមឈើ គឺ ព្រៃ

ក្រាស់ដោយដើមឈើ គឺ ដែលចូលទៅបានលំបាក ។ បទថា នទីវិទុគ្គំ គឺ ទឹកន្លែងដែលទៅបានដោយលំបាក ក្នុងទីដែលមានកោះ នៅចន្លោះជាដើម នៃទន្លេទាំងឡាយ ។ បទថា បព្វតវិសមំ គឺ កន្លែងដែលមិនរាបស្មើ ដោយភ្នំទាំងឡាយ ។ ឬថា កន្លែងដែលក្រហេងក្រហូងក្នុងភ្នំទាំងឡាយ ។ បទថា សភាគាយិស្សន្តិ សេចក្តីថា ពួកសត្វនឹងធ្វើមនុស្សទាំងនោះ ឲ្យស្មើនឹងខ្លួនដោយពាក្យដែលណែនាំឲ្យរីករាយយ៉ាងនេះថា លោកដ៏ចម្រើនទាំងឡាយ យើងរស់នៅដោយប្រការណា សត្វទាំងឡាយ លោកក៏ជួបឃើញហើយ សូម្បីលោកក៏រស់នៅដោយប្រការនោះ ។ បទថា អាយតំ គឺ ច្រើន ។ បទថា ធាណាតិធាតា វិរមេយ្យាម សេចក្តីថា ពួកយើងគួរវៀរបាណាតិបាតចេញ ។ អាចារ្យពួកខ្លះសូត្រថា ធាណាតិធាតំ វិរ-មេយ្យាម ក៏មាន ។ ក្នុងពាក្យនោះ មានអធិប្បាយថា ពួកយើងគួរវៀរបាណាតិបាត ។ បទថា វីសតិវស្សាយុកា សេចក្តីថា មាតាបិតាវៀរចាកបាណាតិបាត ព្រោះហេតុអ្វី បុត្រទាំងឡាយ ទើបមានអាយុត្រឹមតែ ២០ ឆ្នាំ ។ ព្រោះមានខេត្តបរិសុទ្ធិ ។ ពិតហើយ មាតាបិតា នៃបុត្រទាំងនោះជាអ្នកមានសីល ដូច្នោះ ពួកគេទើបមានអាយុវែង ព្រោះខេត្តបរិសុទ្ធិនេះ

ហេតុដែលពួកបុត្រចម្រើនក្នុងគភ៌របស់អ្នកមានសីល ។ ក៏សត្វពួកណាស្លាប់ក្នុងទីនេះ ហើយកើតក្នុងទីនោះនុ៎ះឯង សត្វទាំងនោះមានអាយុវែងដោយសម្បត្តិ គឺ សីលរបស់ខ្លួន ។ បទថា អសប្ពាម ប្រែថា គប្បីមាន ។ បទថា ចត្តាឡីសវស្សាយុកា សេចក្តីថា ចំណែកដែលជាខាងដើម បណ្ឌិតគប្បីជ្រាបដោយអំណាចបុគ្គលដែលវៀរដាច់ខាតចាកអទិន្នាទានជាដើម ។

## ការកើតឡើងនៃព្រះចានសង្ឃរាជ

[៤៨] បទថា ឥច្ឆា សេចក្តីថា តណ្ហាដែលកើតឡើងយ៉ាងនេះថា ពួកលោកចូរឲ្យអាហារដល់យើង ។ បទថា អនសនំ សេចក្តីថា មិនមានការស៊ី គឺ ការៈដែលមិនរីកពាយសប្បាយ បានដល់ សេចក្តីខ្ជិលប្រអូសផ្លូវកាយ គឺ ការប្រាថ្នានឹងដេក ព្រោះបច្ច័យ គឺ សេចក្តីស្រវឹងក្នុងអាហាររបស់អ្នកបរិភោគអាហារ ។ អធិប្បាយថា ការៈនៃកាយមានកម្លាំងទន់ខ្សោយ ព្រោះការបរិភោគ ។ បទថា ជរា បានដល់ ជរាប្រាកដ ។ បទថា កុក្កុដសម្បាតិកា មានវិគ្រោះថា ការចុះព្រមនៃមាន់ ពោលគឺ ប្រការដែលមាន់ហើរឡើងពីដំបូលផ្ទះមួយ ហើយចុះលើដំបូលផ្ទះមួយទៀត មាន

នៅក្នុងគាមនិគម និងរាជធានីទាំងនេះ ហេតុនោះ គាមនិគម និងរាជធានីទាំងនេះ ឈ្មោះថា មានចម្ងាយមាន់ហើរធ្លាក់ ។ បាលីថា សម្បាធិកា ដូច្នេះ ក៏មាន ។ អធិប្បាយថា ការដល់ព្រមនៃមាន់ ពោលគឺ ការដើរទៅដោយជើងនៃមាន់ពីចន្លោះផ្ទះមួយ ទៅកាន់ចន្លោះផ្ទះមួយទៀត មាននៅក្នុងគាមនិគម និងរាជធានីទាំងនេះ ។ លោកសម្តែងប្រការដែលសត្វនៅរួមគ្នាជាក្រុមនោះឯង សូម្បីទាំងពីរនោះ ។ បទថា អវីចិ មញ្ញេ ផុដោ ភវិស្សតិ សេចក្តីថា នឹងពេញណែនតាន់តាប់ ដូចអវិចីមហានរក ។

ព្រះមានព្រះភាគ មិនត្រាស់ទុកដោយអំណាចនៃអាយុសត្វ ដែលច្រើនថា ម្នាលភិក្ខុទាំងឡាយ ក្នុងវេលាមនុស្សមានអាយុ ៨០,០០០ ឆ្នាំ ព្រះមានព្រះភាគនាមថា **មេត្តេយ្យ** នឹងឧប្បត្តិឡើងក្នុងលោក ។ ព្រោះព្រះពុទ្ធទាំងឡាយ រមែងមិនកើតក្នុងវេលាសត្វដែលមានអាយុកំពុងចម្រើនឡើង តែរមែងកើតក្នុងវេលាសត្វមានអាយុថយចុះ ។ អធិប្បាយថា ព្រោះហេតុនោះ វេលាណាអាយុនោះចម្រើនដល់អសង្ខេយ្យហើយ ត្រឡប់ថយចុះទៀត នឹងតាំងនៅក្នុងកាលដែលសត្វមានអាយុ ៨០,០០០ ឆ្នាំ ក្នុងកាលនោះ ព្រះពុទ្ធនឹងឧប្បត្តិឡើង ។ ក៏បទថា បរិហរិស្សតិ នេះ លោក

ពោលទុកដោយអំណាចនៃសត្វដែលត្រាច់ទៅជុំវិញ ។ បទថា យូបោ បានដល់ ប្រាសាទ ។ បទថា រញ្ញា មហាបនាទេន ការាបិតោ សេចក្តីថា មានព្រះរាជាអ្នកជាដើមហេតុ ស្តេចសក្កទេវរាជ ទើបបញ្ជូនវិស្សុកម្មទេវបុត្រ ឲ្យទៅសាងប្រាសាទ ដើម្បីប្រយោជន៍ដល់ព្រះរាជាអង្គនោះ ។

បានឮមកថា កាលមុន បិតា និងបុត្រពីរនាក់ ជាជាងតម្បាញជាមួយគ្នា យកឈើបបុស និងឈើល្វា សាងបណ្ណសាលាថ្វាយចំពោះព្រះបច្ចេកពុទ្ធ ហើយនិមន្តឲ្យលោកគង់ក្នុងទីនោះ ទំនុកបម្រុងដោយបច្ច័យ ៤ ។ លុះធ្វើកាលកិរិយាហើយ ក៏កើតក្នុងទេវលោក ។ បិតា និងបុត្រទាំងពីរនាក់នោះ បិតាក៏នៅក្នុងទេវលោកនុ៎ះឯង ។ បុត្រចុតិចាកទេវលោកហើយ កើតក្នុងព្រះគភ៌របស់ព្រះនាងសុមេធាជាទេវីរបស់ព្រះបាទសុរុចិត្តជាព្រះរាជកុមារព្រះនាមថា **មហាបនាទ** ។ លុះក្រោយមក ព្រះអង្គក៏បានទទួលការអភិសេក បានជាព្រះរាជាព្រះនាមថា **មហាបនាទ** ។ លំដាប់នោះដោយបុញ្ញានុភាពរបស់ព្រះអង្គ ស្តេចសក្កទេវរាជ ទើបបញ្ជូនវិស្សុកម្មទេវបុត្ត ឲ្យទៅសាងប្រាសាទថ្វាយ ។ វិស្សុកម្មទេវបុត្តនោះ និម្មិតប្រាសាទ

មួយថ្វាយព្រះអង្គ មានកម្ពស់ដល់ ២៥ យោជន៍ ៧ ជាន់ សុទ្ធតែប្រកប ដោយរតនៈទាំង ៧ ប្រការ ដែលលោកពោលទុកក្នុងជាតកថា ៖

*ព្រះរាជាព្រះនាមថា បនាទ មានប្រាសាទសុទ្ធតែប្រកប ដោយមាសសុទ្ធ ទទឹង ១៦ ជួរធ្នូ ជនទាំងឡាយពោល ចំណែកកម្ពស់ដល់ពាន់ជួរធ្នូ ប្រាសាទនោះ ៧ ជាន់ កម្ពស់ ១,០០០ ជួរធ្នូព្រោងព្រាត ទៅដោយទង់ភ្លឺផ្លេក ដោយកែវពណ៌ខៀវ អ្នករបាំ ៦ ពាន់ បែងចែកជា ៧ ពួក បានរាំនៅក្នុងប្រាសាទនោះ ម្នាលភទ្ទជិសេដ្ឋី លោក ពោលទុកដោយប្រការណា ហេតុនោះ បានមានក្នុងកាល នោះ ដោយប្រការនោះ គ្រានោះ តថាគត ដូច្នេះ ។*

ព្រះរាជានោះ ប្រថាប់នៅត្រង់ប្រាសាទនោះ រហូតអស់ព្រះជន្មាយុ ចូលទីវង្គត់ហើយ ទៅកើតក្នុងទេវលោក ។ កាលព្រះអង្គកើតក្នុងទេវ-លោក ប្រាសាទនោះ ក៏លិចចុះក្នុងក្រសែទឹកទន្លេមហាគង្គា ។ ព្រះនគរ ឈ្មោះ **បយាគៈ** ដែលទេវតានិម្មិតហើយក្នុងទីជិតក្បាលជណ្តើរ របស់ ប្រាសាទនោះ ។ ស្រុកឈ្មោះ **កោដិគ្រាម** មានក្នុងទីត្រង់កំពូលប្រាសាទ ។

ក្រោយមក កាលព្រះមានព្រះភាគរបស់យើង ទេវបុត្រជាងតម្បាញនោះ ចុតិចាកទេវលោក បានជាសេដ្ឋីឈ្មោះ **ភទ្ទជិ** ក្នុងមនុស្សលោក បួសក្នុងសម្នាក់ព្រះសាស្តា បានសម្រេចព្រះអរហត្ត ។ គប្បីឲ្យរឿងពិស្តារដោយពាក្យថា " លោកនោះ សម្តែងប្រាសាទនោះ ដល់ពួកភិក្ខុក្នុងថ្ងៃដែលយកទូកឆ្លងទន្លេគង្គា " ។ សួរថា ក៏ព្រោះហេតុអ្វីប្រាសាទនេះ ទើបមិនអន្តរធានទៅ ។ ឆ្លើយថា ព្រោះអានុភាពបុណ្យទេវបុត្រក្រៅពីនេះ ។ កុលបុត្រអ្នកធ្វើបុណ្យរួមជាមួយលោក កើតក្នុងទេវលោក ក្នុងអនាគតនឹងជាព្រះរាជាព្រះនាមថា **សង្ខ:** ប្រាសាទនោះ នឹងតាំងឡើងសម្រាប់ឲ្យព្រះរាជានោះប្រើប្រាស់ ព្រោះហេតុនោះ ប្រាសាទទើបមិនអន្តរធាន ។

បទថា ឧស្សាបេត្វា សេចក្តីថា ឲ្យប្រាសាទនោះតាំងឡើង ។ បទថា អជ្ឈាវសិត្វា បានដល់ ប្រថាប់នៅក្នុងទីនោះ ។ បទថា វិសជ្ជិត្វា សេចក្តីថា ឲ្យប្រាសាទនោះ ដោយអំណាចទាន និងលះបង់ដោយអំណាចការបរិច្ចាគ ដោយមិនសម្ងឹង ( ផលតបស្នង ) ។ សួរថា ថ្វាយប្រាសាទយ៉ាងនោះ ដល់អ្នកណា ។ ឆ្លើយថា ដល់ពួកសមណ:ជាដើម ។ ព្រោះហេតុនោះ លោកទើបបានពោលទុកថា " ឲ្យទានដល់សមណព្រាហ្មណ៍

មនុស្សកំព្រា អ្នកដើរផ្លូវ វណិពកយាចក " ។ សួរថា ក៏ព្រះរាជា ( ព្រះកទូជិ ) នោះ នឹងសម្តែងប្រាសាទមួយខ្នង ដល់ភិក្ខុជាច្រើនយ៉ាងណា ? ឆ្លើយថា ន័យថា ចិត្តរបស់លោកនឹងកើតឡើងយ៉ាងនេះថា ប្រាសាទនេះ ចូរខ្ទាត់ខ្ទាយទៅ ។ ប្រាសាទនោះ ក៏ខ្ទាត់ខ្ទាយជាបំណែកតូច ៗ ព្រះអង្គ មិនមានចិត្តជាប់ជំពាក់នឹងប្រាសាទនោះឡើយ នឹងលះបង់ដោយអំណាចទាន ដោយព្រះតម្រាស់ថា អ្នកណាប្រាថ្នាចំនួនប៉ុនណា អ្នកនោះចូរកាន់យកចំនួនប៉ុណ្ណោះចុះ ដោយហេតុនោះ លោកទើបពោលថា ឆានំ ឥត្វា មេត្តេយ្យស្ស ភគវតោ ។បេ។ វិហរិស្សតិ ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងអនុសន្ធិបន្តនៃវដ្តគាមីកុសល ដោយព្រះតម្រាស់មានប្រមាណប៉ុណ្ណោះ ។

## អំពីគុណកថានៃព្រះមានព្រះភាគព្រះនាមមេត្តេយ្យ

**[៤៩-៥០]** ឥឡូវនេះ កាលនឹងទ្រង់សម្តែងសេចក្តីបន្តនៃវដ្តគាមីកុសល ទើបត្រាស់ពាក្យថា អត្តទីចា ភិក្ខវេ វិហរថ ជាដើមទុកទៀត ។ ប្រការថា ឥធំ ខោ ភិក្ខវេ ភិក្ខុនោ អាយុស្មិំ សេចក្តីថា ព្រះមានព្រះភាគ

ទ្រង់សម្ដែងថា ម្នាលភិក្ខុទាំងឡាយ តថាគតបានពោលពាក្យណាទុកនឹង អ្នកថា "អ្នកទាំងឡាយនឹងចម្រើនដោយអាយុខ្លះ" ពាក្យនេះ រមែងមានក្នុង អាយុរបស់ភិក្ខុនោះ គឺ ពាក្យនេះ ជាហេតុនៃអាយុ ។ ព្រោះដូច្នោះ ពួកអ្នក កាលត្រូវការឲ្យអាយុចម្រើន ត្រូវចម្រើនឥទ្ធិបាទ ៤ យ៉ាង ទាំង នេះ ។ បទថា វណ្ណស្មឹ សេចក្ដីថា ព្រះមានព្រះភាគ ទ្រង់សម្ដែងថា តថាគតបានពោលពាក្យណាទុកនឹងអ្នកថា ពួកអ្នកនឹងចម្រើនដោយវណ្ណៈ ខ្លះ នេះជាហេតុ ( ចម្រើន ) វណ្ណៈក្នុងវណ្ណៈនោះ ដោយថា វណ្ណៈ នៃ សរីរៈរបស់អ្នកមានសីល រមែងចម្រើនដោយអំណាចសេចក្ដីមិនក្ដៅក្រហាយ ជាដើម សុម្បីវណ្ណៈ គឺ គុណ ក៏ចម្រើនដោយអំណាចកេរ្ដិ៍ឈ្មោះ ព្រោះ ដូច្នោះ ពួកអ្នកកាលត្រូវការឲ្យវណ្ណៈចម្រើន ត្រូវមានសីលបរិបូរណ៌ ។

បទថា សុខស្មឹ សេចក្ដីថា ព្រះមានព្រះភាគ ទ្រង់សម្ដែងថា តថាគត បានពោលពាក្យណាទុកនឹងពួកអ្នកថា ពួកអ្នកនឹងចម្រើនដោយសេចក្ដីសុខ ខ្លះដូច្នេះ ពាក្យនេះ រមែងមានសេចក្ដីសុខដែលកើតពីឈាន មានប្រការ ផ្សេងៗ មានបីតិ និងសុខកើតអំពីវិវេក ក្នុងសេចក្ដីសុខនោះ គឺ ព្រោះ ហេតុនោះ ពួកអ្នកកាលត្រូវការឲ្យចម្រើនដោយសេចក្ដីសុខ ត្រូវចម្រើន

ឈាន ៤ យ៉ាង ទាំងនេះ ។ បទថា ភោគស្មឹ សេចក្តីថា ព្រះមានព្រះភាគ ទ្រង់សម្តែងថា តថាគតបានពោលពាក្យណាទុកនឹងពួកអ្នកថា ពួកអ្នកនឹងចម្រើនដោយភោគៈខ្លះ ដូច្នេះនេះ គឺ ភោគៈ បានដល់ ព្រហ្មវិហារ ដែលគប្បីផ្សាយបានទូទៅគ្រប់ទិស ដែលនាំភាពជាអ្នកមិនស្អប់ខ្ពើមពួកសត្វដែលរកប្រមាណមិនបាន មានអានិសង្ស ១១ ប្រការ ដូចដេកជាសុខជាដើម ព្រោះដូច្នោះ ពួកអ្នកកាលត្រូវការឲ្យភោគៈចម្រើន ត្រូវចម្រើនព្រហ្មវិហារទាំងនេះ ។ បទថា ពលស្មឹ សេចក្តីថា ព្រះមានព្រះភាគ ទ្រង់សម្តែងថា តថាគតបានពោលពាក្យណាទុកនឹងពួកអ្នកថា ពួកអ្នកនឹងចម្រើនដោយកម្លាំងខ្លះ ដូច្នេះ ពាក្យនេះ គឺ កម្លាំង ពោលគឺ អរហត្តផលដែលកើតឡើងក្នុងទីបំផុតក្នុងការអស់ទៅនៃអាសវៈ ព្រោះហេតុនោះ ពួកអ្នកកាលត្រូវការនឹងឲ្យកម្លាំងចម្រើន ត្រូវប្រារព្ធសេចក្តីព្យាយាម ដើម្បីការសម្រេចដល់ព្រះអរហត្ត ។ បទថា យថយិទំ ភិក្ខវេ មារពលំ សេចក្តីថា ព្រះមានព្រះភាគទ្រង់សម្តែងថា តថាគត រមែងពិចារណាមិនឃើញសូម្បីកម្លាំងដែលជាឯកក្នុងលោកដទៃ ដែលគ្របសង្កត់បានដោយលំបាក កម្ចាត់បានដោយលំបាក ដូចកម្លាំងរបស់ទេវបុត្តមារ មច្ចុមារ

កិលេសមារនេះឡើយ អរហត្តផលនេះប៉ុណ្ណោះ រមែងគ្របសង្កត់កម្លាំង នោះបាន ព្រោះហេតុនោះ ពួកអ្នកគួរប្រារព្ធសេចក្ដីព្យាយាមក្នុងព្រះអរហត្ត នេះ ប៉ុណ្ណោះ ។

ប្រការថា ឯវមិទំ បុញ្ញំ សេចក្ដីថា សូម្បីបុណ្យដែលជាលោកុត្តរៈ នេះ រមែងចម្រើនរហូតអស់អាសវៈ ។ ព្រះមានព្រះភាគ កាលញ៉ាំងអនុសន្ធិ បន្តនៃវិវដ្តគាមីកុសលឲ្យចប់ស្រេច ទើបញ៉ាំងទេសនាឲ្យចប់សព្វគ្រប់ដល់ កំពូល គឺ ព្រះអរហត្ត ។ ក្នុងវេលាចប់ព្រះសូត្រ ភិក្ខុ ២០,០០០ រូប បានសម្រេចព្រះអរហត្ត សត្វ ៨៤,០០០ បានផឹកនូវទឹកអម្រឹត ដូច្នេះឯង ។

( ចប់ អដ្ឋកថាចក្កវត្តិសូត្រ ទី ៣ )

# អដ្ឋកថា អគ្គញ្ញសូត្រ ទី ៤

[៥១] អគ្គញ្ញសូត្រ មានពាក្យផ្ដើមថា ឯវម្មេ សុតំ ដូច្នេះ ។

ក្នុងអគ្គញ្ញសូត្រនោះ មានការពណ៌នាបទដែលនៅមានសេចក្ដីមិនទាន់ជាក់ច្បាស់ដូចតទៅនេះ ៖

ក្នុងពាក្យថា បុព្វារាមេ មិគារមាតុបាសាទេ នេះ មានអនុបុព្វីកថា ដូចតទៅនេះ ៖

បានឮថា ក្នុងអតីតកាល ក្នុងទីបំផុតសែនកប្ប ឧបាសិកាម្នាក់អារាធនាព្រះមានព្រះភាគ ព្រះនាមថា បទុមុត្តរ ហើយថ្វាយទានដល់ភិក្ខុសង្ឃមួយសែន មានព្រះពុទ្ធជាប្រធាន បានក្រាបចុះទៀបបាទមូលរបស់ព្រះមានព្រះភាគហើយ បានតាំងសេចក្ដីប្រាថ្នាថា ក្នុងអនាគតកាលខ្ញុំម្ចាស់ សូមបានជាឧបដ្ឋាកយិកាដ៏ប្រសើររបស់ព្រះពុទ្ធ ដូចជាព្រះអង្គ ។ ឧបាសិកានោះ អន្ទោលទៅក្នុងទេវលោក និងមនុស្សលោករហូតដល់អស់សែនកប្ប ហើយបានបដិសន្ធិក្នុងគភ៌របស់នាងសុមនាទេវី ក្នុងផ្ទះរបស់ធនញ្ជយសេដ្ឋី ដែលជាបុត្ររបស់មេណ្ឌកសេដ្ឋី ក្នុងភទ្ទិយនគរ ក្នុងកាល

នៃព្រះមានព្រះភាគរបស់យើងទាំងឡាយ ។ ក្នុងវេលាដែលនាងកើតហើយ ពួកញាតិបានតាំងឈ្មោះឲ្យនាងថា **វិសាខា** ។ នាងវិសាខានោះ កាលដែលព្រះមានព្រះភាគ ស្ដេចយាងទៅកាន់ក្រុងភទ្ទិយនគរ នាងក៏បានទៅធ្វើការទទួលព្រះមានព្រះភាគ ព្រមដោយក្មេងស្រីឯទៀត ៥០០ នាក់ ក្នុងការបានឃើញព្រះមានព្រះភាគ ត្រឹមតែគ្រាដំបូងប៉ុណ្ណោះ នាងក៏បានជាព្រះសោតាបន្ន ក្នុងកាលតមក នាងបានទៅកាន់ផ្ទះរបស់បុណ្ណវឌ្ឍនកុមារបុត្ររបស់មិគារសេដ្ឋីក្នុងក្រុងសាវត្ថី ។ មិគារសេដ្ឋី តាំងនាងទុកក្នុងតំណែងជាមាតាក្នុងផ្ទះនោះ ។ ដូច្នោះ គេទើបហៅនាងថា **មិគារមាតា** ។ ក៏កាលនាងទៅកាន់ត្រកូលស្វាមី បិតាឲ្យជាងធ្វើគ្រឿងប្រដាប់ ឈ្មោះថា **មហាលតាបសាធន៍** ។ ពេជ្រ ៣ នាឡិ កែវមុក្តា ១១ នាឡិ កែវប្រវាឡ ២២ នាឡិ កែវមណី ៣៣ នាឡិ បានដល់ ការប្រកបចូលក្នុងគ្រឿងប្រដាប់នោះ ។ គ្រឿងប្រដាប់នោះ បានសម្រេចដោយរតនៈទាំងឡាយនេះ ដូចពោលមកនេះ និងដោយរតនៈ ៧ ពណ៌ ដទៃទៀត ។ គ្រឿងប្រដាប់នោះ ពាក់លើសីសៈ រមែងគ្របដរាបដល់ខ្នងជើង ។ ស្ត្រីដែលមានកម្លាំងស្មើដំរីសារ ៥ បានប៉ុណ្ណោះ ទើបនឹងអាចទ្រទ្រង់គ្រឿងប្រដាប់នោះបាន ។

ក្នុងកាលតមក នាងវិសាខានោះ បានជាឧបដ្ឋាយិកាដ៏ប្រសើររបស់ព្រះទសពល នាងបានលះបង់គ្រឿងប្រដាប់នោះ ហើយឲ្យសាងវិហារថ្វាយព្រះមានព្រះភាគ ដោយទ្រព្យ **៩ កោដិ** ហើយឲ្យសាងប្រាសាទលើភូមិភាគមួយប្រមាណមួយករីសៈ ។ ប្រាសាទនោះ ប្រដាប់ដោយបន្ទប់ ១.០០០ បន្ទប់ យ៉ាងនេះគឺ ទីជាន់ខាងលើមាន ៥០០ បន្ទប់ ទីជាន់ក្រោមក៏មាន ៥០០ បន្ទប់ ។ នាងគិតថា មានប្រាសាទតែម្យ៉ាង រមែងមិនល្អដូច្នេះ ទើបឲ្យសាងផ្ទះ ២ ជាន់ ៥០០ ខ្នង ប្រាសាទតូច ៥០០ ខ្នង សាលាវែង ៥០០ ខ្នង ហែហមប្រាសាទនោះ ។ ធ្វើការឆ្លងវិហារអស់ ៤ ខែ ។ ដែលឈ្មោះថា ការបរិច្ចាគទ្រព្យ ទុកក្នុងព្រះពុទ្ធសាសនារបស់ស្ត្រីដទៃ ដូចការបរិច្ចាគរបស់នាងវិសាខា អ្នកតាំងនៅក្នុងភាពជាមាតុគ្រាមមិនមានទេ ។ ការបរិច្ចាគទ្រព្យ ទុកក្នុងព្រះពុទ្ធសាសនារបស់បុរសដទៃ ដូចជាការបរិច្ចាគរបស់អនាថបិណ្ឌិកសេដ្ឋី អ្នកតាំងនៅក្នុងភាពជាបុរសក៏មិនមានទេ ។ ព្រោះអនាថបិណ្ឌិកសេដ្ឋីនោះ លះបង់ទ្រព្យ **៥៤ កោដិ** ឲ្យសាងមហាវិហារ ឈ្មោះថា **ជេតវ័ន** ក្នុងទីដូចជាមហាវិហាររបស់ក្រុងអនុរាធបុរី ក្នុងទិសទក្សិណ នាក្រុងសាវត្ថី ។ នាងវិសាខាឲ្យសាងវិហារ

ឈ្មោះថា **បុព្វារាម** ក្នុងទីដូចជាវិហាររបស់នាងឧត្តមទេវី ក្នុងទិសបស្ចិម នៃក្រុងសាវត្ថី ។ ព្រះមានព្រះភាគ ទ្រង់ប្រថាប់នៅក្នុងក្រុងសាវត្ថីជាប្រចាំ ក្នុងវិហារទាំង ២ នេះ ដោយសេចក្តីអនុគ្រោះ ត្រកូលទាំង ២ នេះ ។ ខាងក្នុងវស្សាមួយ ប្រថាប់នៅព្រះជេតវ័នវិហារ ។ ខាងក្នុងវស្សាមួយ ប្រថាប់នៅក្នុងបុព្វារាមវិហារ ។ ក៏ក្នុងសម័យនោះ ព្រះមានព្រះភាគ ប្រថាប់នៅត្រង់បុព្វារាម ។ ដោយហេតុនោះ លោកទើបពោលថា បុព្វា-រាមេ មិគារមាតុចាសាទេ ដូច្នេះ ។

បទថា វាសេដ្ឋភារទ្វាជា បានដល់ វាសេដ្ឋសាមណេរ និងភារទ្វាជ-សាមណេរ ។ ដោយពីរបទថា ភិក្ខូសុ បរិវសន្តិ សេចក្តីថា សាមណេរទាំងពីរនៅបរិវាសដូចតិត្ថិយ មិននៅបរិវាសដើម្បីផុតអាបត្តិក៏ទេ ។ តែសាមណេរទាំងនោះ ព្រោះមានអាយុមិនទាន់បរិបូរណ៍ ទើបប្រាថ្នាភាពជាភិក្ខុ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ថា ភិក្ខុភាវំ អាកង្ខមានា ។ ពិតហើយ សាមណេរស្មូបីទាំងពីរនោះ កើតក្នុងត្រកូលព្រាហ្មណ៍មហាសាលឈ្មោះ **ឧទិច្ច** នីងមានទ្រព្យសម្បត្តិមួយចំណែកៗ ៤០ កោដិ សម្រេចដល់ត្រើយនៃត្រៃវេទ បានស្តាប់វាសេដ្ឋសូត្រ ក្នុងមជ្ឈិម-

និកាយ បានដល់ សរណៈ ស្តាប់គេវិជ្ជសូត្រ ហើយបានបព្វជ្ជាក្នុងវេលានេះ ប្រាថ្នាភាពជាភិក្ខុ ទើបនៅបរិវាស ។ បទថា អព្ភោកាសេ ចង្កមតិ សេចក្តីថា ព្រះមានព្រះភាគ ទ្រង់រុងរោចន៍ដោយព្រះរស្មី ដែលមានពណ៌ ៦ ដែល ផ្សាយចេញទៅក្នុងកណ្តាលវេហាស៍ ប្រៀបដូចមាសដែលមានតម្លៃ កម្ពស់ ១១ ហត្ថ ដែលបុគ្គលទាញមកដោយខ្សែយន្តដូច្នោះ ស្តេចចង្ក្រមទៅមកៗ នៅត្រង់ម្លប់របស់ប្រាសាទ ក្នុងទិសបូព៌ារបស់ប្រាសាទ ដែលជាប់ តគ្នានឹងផ្លូវទិសឧត្តរ និងទិសទក្សិណ ។

បទថា អនុចង្កមឹសុ សេចក្តីថា សាមណេរទាំងពីរ ផ្គងអញ្ជលី បង្អោនសរីរៈចុះ ហើយចង្ក្រមតាមព្រះមានព្រះភាគ ។

បទថា វាសេដ្ឋំ អាមន្តេសិ សេចក្តីថា វាសេដ្ឋៈ និងភារទ្វាជៈ សាមណេរទាំងនោះ វាសេដ្ឋៈសាមណេរឆ្លាតជាង តែងដឹងដល់វត្ថុដែលគួរកាន់យក និងវត្ថុដែលគួរលះបង់ ដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ហៅវាសេដ្ឋៈសាមណេរនោះមក ។ បទថា តុម្ហេ ខ្វត្ថ កាត់បទជា តុម្ហេ ខោ អត្ថ ។ បទថា ព្រាហ្មណជច្ចា សេចក្តីថា ជាព្រាហ្មណ៍ដោយជាតិ ។ បទថា ព្រាហ្មណកុលីនា សេចក្តីថា មានត្រកូល គឺ សម្បូរណ៍ដោយ

ត្រកូលក្នុងពួកព្រាហ្មណ៍ ។

បទថា ព្រាហ្មណកុលា សេចក្ដីថា ចាកត្រកូលព្រាហ្មណ៍ អធិ-ប្បាយថា លះត្រកូលព្រាហ្មណ៍ ដែលសម្បូរណ៍ដោយភោគៈជាដើម ។ បទថា ន អក្កោសន្តិ សេចក្ដីថា រមែងមិនជេរ ដោយអក្កោសវត្ថុ ១០ ។ បទថា ន បរិភាសន្តិ សេចក្ដីថា រមែងមិនប្រទេចដោយការពោលដល់ការលះបង់ ដែលមានវិធីផ្សេងៗ ។ ព្រះមានព្រះភាគទ្រង់ជ្រាបថា ព្រាហ្មណ៍ទាំងឡាយ រមែងជេរ រមែងប្រទេចសាមណេរទាំងនេះ ដូច្នេះ ទើបបានត្រាស់សួរដោយប្រការដូច្នេះ ។ សួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបត្រាស់សួរ ? ឆ្លើយថា ព្រះអង្គទ្រង់ត្រិះរិះថា សាមណេរទាំងនេះ បើតថាគតមិនសួរ នឹងមិននិយាយឡើងមុន កាលតថាគតមិនពោលពាក្យក៏នឹងមិនកើតឡើង ដូច្នេះ ដូច្នោះ ព្រះអង្គទើបត្រាស់សួរ ដើម្បីឲ្យពាក្យផ្ដើមឡើង ។

បទថា តគ្ឃ ជានិបាតប្រើក្នុងពាក្យតែម្យ៉ាង ។ អធិប្បាយថា បពិត្រព្រះអង្គដ៏ចម្រើន ព្រាហ្មណ៍ទាំងឡាយ រមែងជេរ រមែងប្រទេចខ្ញុំព្រះអង្គទាំងពីរ ដោយចំណែកតែមួយ ។ បទថា អត្តរូបាយ សេចក្ដី

ថា តាមសមគួរដល់ខ្លួន ។ បទថា បរិបុណ្ណាយ សេចក្តីថា ដែលលើក បទ និងព្យញ្ជនៈមកពោលបរិបូណ៌ តាមសេចក្តីពេញចិត្តរបស់ខ្លួន ។ បទថា នោ អបរិបុណ្ណាយ សេចក្តីថា ដែលមិនឈប់ក្នុងចន្លោះ ពោលជាប់តទៅ រហូតដល់អស់ ។ សួរថា ព្រោះហេតុអ្វី ពួកព្រាហ្មណ៍ទើបជេរសាមណេរ ទាំងនេះ ។ ឆ្លើយថា ព្រោះមិនតាំងនៅ ( ក្នុងឋានៈរបស់ខ្លួន ) ។ សាមណេរ ទាំងនេះ ជាបុត្ររបស់ព្រាហ្មណ៍អ្នកខ្ពង់ខ្ពស់ សម្រេចដល់ត្រើយនៃត្រៃវេទ មានឈ្មោះបោះសំឡេង ប្រាកដបានទទួលការលើកតម្កើងក្នុងរវាងព្រាហ្មណ៍ ទាំងឡាយ ក្នុងជម្ពូទ្វីប ។ ព្រោះប្រការដែលសាមណេរទាំងពីរនោះបួស បុត្ររបស់ព្រាហ្មណ៍ដទៃជាច្រើនក៏បានបួសតាម ។ លំដាប់នោះ ពួកព្រាហ្មណ៍ ទាំងឡាយគិតថា យើងទាំងឡាយអស់ទីពឹងអាស្រ័យដូច្នេះ ព្រោះប្រការ ដែលខ្លួនឯងមិនមានទីពឹងនេះឯង ជួបសាមណេរទាំងនោះត្រង់ទ្វារស្រុកក្តី ខាងក្នុងស្រុកក្តី ទើបពោលថា ពួកលោកទម្លាយលទ្ធិរបស់ព្រាហ្មណ៍ ពួក លោកជាអ្នកជាប់ក្នុងរស ទើបត្រាច់តាមក្រោយសមណៈត្រងោល ដូច្នេះ ជាដើម និងពោលពាក្យជាដើមថា ព្រាហ្មណ៍ប៉ុណ្ណោះ មានវណ្ណៈប្រសើរ បំផុត ដូច្នេះ ដែលមកក្នុងព្រះបាលីហើយ ទើបជេរ ។ សូម្បីកាលព្រាហ្មណ៍

ទាំងនោះ នឹងនាំគ្នាជេរ សាមណេរទាំងឡាយក៏មិនបានធ្វើសេចក្តីក្រោធ ឬការអាឃាត ព្រោះប្រការដែលត្រូវព្រះមានព្រះភាគត្រាស់សួរ ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកព្រាហ្មណ៍ទាំងឡាយ រមែងនាំគ្នាជេរ នាំគ្នាប្រទេច ពួកខ្ញុំព្រះអង្គ ដូច្នេះ ។ លំដាប់នោះ ព្រះមានព្រះភាគ កាលនឹងត្រាស់សួរអាការ គឺ ការជេរ ទើបត្រាស់សួរថា អ្នកពោលថា យ៉ាងណា ដូច្នេះ ។ សាមណេរទាំងនោះកាលក្រាបទូលអាការ គឺ ការជេរ ទើបក្រាបទូលថា ព្រាហ្មណា ភន្តេ ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា សេដ្ឋោ វណ្ណោ ដូច្នេះ សេចក្តីថា ព្រាហ្មណ៍ទាំងឡាយ រមែងសម្តែងថា ព្រាហ្មណ៍ប៉ុណ្ណោះ ជាវណ្ណៈប្រសើរបំផុត ដូច្នេះ ក្នុងឋានៈជាទីប្រាកដនៃជាតិ និងគោត្រជាដើម ។ បទថា ហីនា អញ្ញេ វណ្ណា សេចក្តីថា ព្រាហ្មណ៍ទាំងឡាយ តែងពោលថា វណ្ណៈបីក្រៅពីនេះ អាក្រក់ អន់ទន់ទាប ដូច្នេះ ។ បទថា សុក្កោ ប្រែថា ស ។ បទថា កណ្ហោ ប្រែថា ខ្មៅ ។ បទថា សុជ្ឈន្តិ សេចក្តីថា ព្រាហ្មណ៍ទាំងឡាយ រមែងបរិសុទ្ធិក្នុងឋានៈមានជាតិ និងគោត្រជាដើមប្រាកដ ។ បទថា ព្រហ្មុនោ បុត្តា សេចក្តីថា ព្រាហ្មណ៍ទាំងឡាយ ជាបុត្ររបស់ស្តេច

មហាព្រហ្ម ។ បទថា ឱរសា មុខតោ ជាតា សេចក្ដីថា នៅក្នុងទ្រូង កើតអំពីមាត់ (របស់ស្ដេចមហាព្រហ្ម) ។ម្យ៉ាងទៀត ឈ្មោះថា ជាឱរស ព្រោះស្ដេចមហាព្រហ្ម ធ្វើទុកក្នុងទ្រូងហើយ ឲ្យចម្រើនហើយ ។

បទថា ព្រហ្មជា សេចក្ដីថា កើតហើយ អំពីស្ដេចមហាព្រហ្ម ។ បទថា ព្រហ្មនិម្មិតា សេចក្ដីថា ដែលស្ដេចមហាព្រហ្មនិម្មិតឡើង ។ បទថា ព្រហ្មទាយាទា សេចក្ដីថា ជាទាយាទរបស់ព្រះព្រហ្ម ។ បទថា ហីនមត្ត-វណ្ណំ អជ្ឈុបគតា សេចក្ដីថា ពួកលោកបានជាអ្នកចូលដល់ វណ្ណៈដែលថោកថយ ។ បទថា មុណ្ឌកេ សមណកេ សេចក្ដីថា ព្រាហ្មណ៍ទាំងឡាយនិន្ទា ស្អប់ខ្ពើម ទើបពោល ។ ក៏ពោលសំដៅយក ភាពជាមនុស្សក្បាលត្រងោល និងភាពជាសមណៈ ។ បទថា ឥព្ភេ បានដល់ គហបតីទាំងឡាយ ។ បទថា កណ្ហេ គឺ ខ្មៅ ។ បទថា ពន្ធុ ប្រែថា ជាផៅពង្សរបស់មារ គឺ ជាបក្សពួករបស់មារ ។ បទថា បាទាបច្ចេ សេចក្ដីថា ជាពួកអ្នកកើតពីជើងរបស់ស្ដេចមហាព្រហ្ម ។ អធិប្បាយថា កើតពីព្រះបាទ ។

ពាក្យថា វោ ក្នុងពាក្យថា តគ្ឃ វោ វាសេដ្ឋ ព្រាហ្មណា បោរាណំ អស្សរន្តា ឯវមាហំសុ នេះ ត្រឹមតែជានិបាត ម្យ៉ាងទៀត ជាឆដ្ឋីវិភត្តិ ។

អធិប្បាយថា ព្រាហ្មណ៍ទាំងឡាយរលឹករឿងចាស់របស់លោកមិនបាន ទើបពោលយ៉ាងនោះ ។

បទថា ចោរាណំ សេចក្តីថា វង្សនៃការប្រព្រឹត្តអ្នកកើតឡើងក្នុងលោកដែលដឹងគ្នាថា ខ្ពង់ខ្ពស់ជារបស់ចាស់ ។ បទថា អស្សរន្តា ប្រែថា ដឹងមិនបាន ។ មានពាក្យអធិប្បាយថា ព្រះមានព្រះភាគត្រាស់ទុកថា វាសេដ្ឋៈ ព្រាហ្មណ៍ទាំងឡាយ រឭកមិនបាន ដឹងមិនបាន នូវការកើតឡើងក្នុងលោក ដែលជារបស់ចាស់របស់លោក ទើបនាំគ្នាពោលយ៉ាងនេះ ។ ពាក្យថា ទិស្សន្តិ ខោ បន ដូច្នេះជាដើម ព្រះមានព្រះភាគ ត្រាស់ទុកដើម្បីប្រយោជន៍ដល់ការទម្លាយ ការឃើញរបស់ព្រាហ្មណ៍ទាំងនោះ ។ បណ្តាបទទាំង នោះ បទថា ព្រាហ្មណិយោ សេចក្តីថា នាងព្រាហ្មណីទាំងឡាយ ដែលពួកព្រាហ្មណ៍នាំមកកាន់ត្រកូល ដោយអំណាចការអាវាហមង្គល និងវិវាហមង្គល ដើម្បីប្រយោជន៍ដល់ការបានបុត្រ ក៏ប្រាកដហើយ ។ សម័យតមក នាងព្រាហ្មណីទាំងឡាយទាំងនោះឯង ក៏ជាស្ត្រីមានរដូវ ។ អធិប្បាយថា មានរដូវកើតឡើង ។ បទថា គព្ភិនិយោ ប្រែថា មានគភ៌ ។ បទថា វិជាយមានា ប្រែថា សម្រាលបុត្រ និងធីតា ។

បទថា ចាយមានា សេចក្តីថា ឲ្យទារកជៅ ។ បទថា យោនិជា វ សមានា សេចក្តីថា ជាអ្នកកើតហើយដោយផ្លូវប្រសូតរបស់នាងព្រាហ្មណី ទាំងឡាយពិត ។ បទថា ឯវមាហំសុ សេចក្តីថា រមែងពោលយ៉ាងនេះ ។

សួរថា ពោលថា យ៉ាងណា ។ ឆ្លើយថា ពោលថា ព្រាហ្មណ៍ ប៉ុណ្ណោះ ជាវណ្ណៈប្រសើរបំផុត ។ល។ ជាទាយាទរបស់ព្រះព្រហ្ម ។ សួរ ថា បើពាក្យនិយាយរបស់ព្រាហ្មណ៍ទាំងនោះ គប្បីជាពាក្យពិតហើយ ដូច្នេះ ផ្ទៃរបស់នាងព្រាហ្មណីគប្បីជាដើមទ្រូងរបស់ស្តេចមហាព្រហ្ម ផ្លូវប្រសូត របស់នាងព្រាហ្មណី ក៏គប្បីជាព្រះឱស្ឋរបស់ស្តេចមហាព្រហ្មដែរ ។ ឆ្លើយ ថា ប្រការនោះ មិនគប្បីយល់ឃើញយ៉ាងនោះ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបមានព្រះតម្រាស់ជាដើមថា តេ ច ព្រហ្មានញ្ចេវ អព្ភាចិក្ខន្តិ ដូច្នេះ ។

## ពោលអំពី វណ្ណៈទាំង ៤

**[៩២]** ព្រះមានព្រះភាគត្រាស់មុខវេច្ចទវាទៈនេះ ដោយព្រះបំណង ថា ចូរព្រាហ្មណ៍ទាំងឡាយកុំគប្បីពោលថា ពួកយើងនៅក្នុងព្រះឧរៈចេញ

មកពីព្រះឱស្ឋរបស់ស្តេចមហាព្រហ្មដូច្នេះ ដោយព្រះតម្រាស់ត្រឹមតែប៉ុណ្ណេះ ទើបទ្រង់សម្តែងថា វណ្ណៈសូម្បីទាំងបួន សមាទានប្រព្រឹត្តកុសលធម៌ពិត ទើបបរិសុទ្ធិបាន ដូច្នេះទៀត ទើបត្រាស់ថា ចត្តារោមេ វាសេដ្ឋ វណ្ណា ជាដើម ។ បទថា អកុសលសំខាតា សេចក្តីថា រាប់ថា ជាអកុសល ដូច្នេះ ឬជាចំណែកនៃអកុសល ។

ក្នុងគ្រប់ៗ បទ ក៏ន័យនេះ ។ បទថា ន អលមរិយា សេចក្តីថា មិនអាចក្នុងភាពជាព្រះអរិយៈបាន ។ បទថា កណ្ហា ប្រែថា មានប្រក្រតីខ្មៅ ។ បទថា កណ្ហវិបាកា សេចក្តីថា វិបាករបស់ធម៌ពួកនោះ ខ្មៅ អធិប្បាយថា ជាទុក្ខ ។ បទថា ខត្តិយេបិ តេ សេចក្តីថា ធម៌ពួកនោះ មាន សូម្បីក្នុងព្រះមហាក្សត្រ ។ បទថា ឯកច្ចេ បានដល់ ឯកស្មឹ ។ ក្នុងគ្រប់ៗ បទ ក៏ន័យនេះ ។

## ពោលអំពីធម៌ស និងធម៌ខ្មៅ

[៥៣] បទថា សុក្កា ប្រែថា ស ដោយភាវៈដែលអស់កិលេស ។ បទថា សុក្កវិបាកា សេចក្តីថា សូម្បីវិបាករបស់ធម៌ទាំងនោះ

ជារបស់ស អធិប្បាយថា ឲ្យផលជាសុខ ។ បទថា ឧភយព្យោកិណ្ណេសុ សេចក្តីថា រួមគ្នា គឺ ច្រឡូកច្រឡំលាយគ្នាក្នុងជន ២ ពួក ។ សួរថា ក្នុងជន ២ ពួកណា ។ ឆ្លើយថា ក្នុងធម៌ចំណែកខ្មៅ ដែលវិញ្ញូជនតិះដៀលមួយពួក និងក្នុងធម៌ចំណែកស ដែលវិញ្ញូជនសរសើរមួយពួក ។ ក្នុងបទថា យទេត្ថ ព្រាហ្មណា ឯវមាហំសុ នេះ មានសេចក្តីវិនិច្ឆ័យថា ព្រាហ្មណ៍ទាំងឡាយ សូម្បីប្រព្រឹត្តក្នុងធម៌ទាំងចំណែកខ្មៅ និងចំណែកសនោះ រមែងពោលយ៉ាងនេះថា ព្រាហ្មណោវ សេដ្ឋោ វណ្ណោ ជាដើម ។ ច្រើនបទថា តន្តេសំ វិញ្ញូ នានុជានន្តិ[១] សេចក្តីថា ជនអ្នកជាបណ្ឌិតក្នុងលោក រមែងមិនត្រេកអរ អធិប្បាយថា រមែងមិនសរសើរ ។ សេចក្តីនោះព្រោះហេតុអ្វី ។ ក្នុងពាក្យថា ឥមេសញ្ហិ វាសេដ្ឋា ជាដើមនេះ មានសេចក្តីសង្ខេបដូច្នេះ ។

បើមានពាក្យសួរថា លោកពោលពាក្យថា នានុជានន្តិ ដូច្នេះទុក ព្រោះហេតុអ្វី ។ គប្បីឆ្លើយថា ៖

ព្រោះបណ្តាវណ្ណៈទាំង ៤ នេះ វណ្ណៈណាជាភិក្ខុ ជា

---

១-អដ្ឋកថា តំ នេសំ វិញ្ញូ នាជានន្តិ , បាលីខាងលើយកតាមបិដក ។

**ព្រះអរហន្ត ។ល។ ផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃ វណ្ណៈនោះ រមែងប្រាកដថា ជាបុគ្គលប្រសើរជាងវណ្ណៈទាំងឡាយ ព្រមទាំងនោះ ពុំជាដូច្នោះឡើយ បណ្ឌិតអ្នកដឹងទាំងឡាយ ទើបមិនទទួលព្រមពាក្យនិយាយរបស់ព្រាហ្មណ៍ទាំងនោះ ។**

គប្បីជ្រាបវិនិច្ឆ័យក្នុងបទ អរហំ ជាដើមតទៅ ដែលឈ្មោះថា **អរហន្ត** ព្រោះហេតុ មានកិលេសទាំងឡាយ នៅឆ្ងាយ ដែលឈ្មោះថា **ខីណាស្រព** ព្រោះអាសវៈទាំងឡាយអស់ទៅ ។ ព្រះសេក្ខៈ ៧ ពួក និងកល្យាណបុថុជ្ជន ឈ្មោះថា **អ្នកនៅប្រព្រឹត្តព្រហ្មចរិយៈ** ។ ក៏ភិក្ខុនេះ អ្នកមានធម៌ជាគ្រឿងនៅចប់ស្រេចហើយ ដូច្នោះ ទើបឈ្មោះថា **អ្នកនៅរួចស្រេចហើយ** ។ កិច្ចដែលនឹងគប្បីធ្វើ មានការកំណត់ដឹងក្នុងសច្ចៈទាំង ៤ ជាដើម ដោយមគ្គ ៤ ដែលភិក្ខុនោះធ្វើហើយ ដូច្នោះ ភិក្ខុនោះ ទើបឈ្មោះថា **មានកិច្ចដែលគួរធ្វើ ធ្វើស្រេចហើយ** ។ កិលេសភារៈ និងខន្ធភារៈ ដែលភិក្ខុនោះដាក់ចុះហើយ ដូច្នោះ លោកទើបឈ្មោះថា **ដាក់ភារៈបានហើយ** ។ បទថា ឱហិតោ ប្រែថា ដាក់ចុះហើយ ។ ប្រយោជន៍

ដ៏ល្អ ឬប្រយោជន៍ដែលជារបស់ខ្លួន ដូច្នោះ ទើបឈ្មោះថា **ប្រយោជន៍ខ្លួន** ។ ប្រយោជន៍របស់ខ្លួន ដែលភិក្ខុនោះតាមសម្រេចបានហើយ ដូច្នោះ លោកទើបឈ្មោះថា តាមសម្រេចប្រយោជន៍ខ្លួនហើយ ។ **តណ្ហា** លោកហៅថា សញ្ញោជនៈគ្រឿងចងសត្វទុកក្នុងភព ។ តណ្ហានោះ របស់ភិក្ខុនោះអស់ហើយ ដូច្នោះ លោកទើបឈ្មោះថា មានសញ្ញោជនៈ គ្រឿងចងសត្វទុកក្នុងភពអស់ហើយ ។ បទថា សម្មទញ្ញា វិមុត្តា សេចក្តីថា ផុតហើយ ព្រោះដឹងដោយប្រពៃ គឺ ដោយហេតុ ដោយការណ៍ ។ បទថា ជនេតស្មឹ កាត់បទជា ជនេ ឯតស្មឹ អធិប្បាយថា ក្នុងលោកនេះ ប្រើនបទថា ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ច សេចក្តីថា ក្នុងអត្តភាពនេះ និងក្នុងអត្តភាពដែលសត្វនឹងគប្បីដល់ ក្នុងលោកខាងមុខ ។

[៩៤] បទថា អនន្តរា សេចក្តីថា វៀរហើយចាកចន្លោះ ។ អធិប្បាយថា ដូចគ្នាដោយត្រកូលរបស់ខ្លួន ។ បទថា អនុយន្តា សេចក្តីថា ប្រព្រឹត្តទៅក្នុងអំណាច ។ បទថា និបច្ចការា សេចក្តីថា ពួកសក្យៈទាំងឡាយដែលចាស់ជាង រមែងសម្តែងការគោរព ដែលក្មេងជាង រមែងធ្វើកិច្ច មានការអភិវាទជាដើម ។ បណ្តាពាក្យទាំងនោះ ពាក្យថា សាមីចិកម្មំ

ដូច្នោះ គឺ កម្មដែលសមគួរ មានការធ្វើវត្តចំពោះព្រះបាទបសេនទិនោះជាដើម ។

[៥៥] បទថា និវិដ្ឋា សេចក្ដីថា តាំងមាំហើយ គឺ តាំងនៅមិនញាប់ញ័រ ។

សួរថា ក៏សទ្ធាបែបនេះ រមែងមានដល់អ្នកណា ។ ឆ្លើយថា រមែងមានដល់ព្រះសោតាបន្ន ។

ក៏ព្រះសោតាបន្ននោះ មានសទ្ធាតាំងមាំ សូម្បីកាលត្រូវគេយកដាវកាត់សិរសា ក៏មិនពោលថា ព្រះពុទ្ធមិនមែនព្រះពុទ្ធដូច្នេះខ្លះ ព្រះធម៌មិនមែនព្រះធម៌ដូច្នេះខ្លះ ព្រះសង្ឃមិនជាព្រះសង្ឃដូច្នេះខ្លះ ។ ព្រះសោ-តាបន្ន រមែងជាអ្នកមានសទ្ធាតាំងមាំដោយពិត ប្រៀបដូចសូរម្ពដ្ឋឧបាសកដូច្នោះ ។ សេចក្ដីថា ឧបាសកនោះ ស្ដាប់ព្រះធម៌ទេសនារបស់ព្រះសាស្ដាហើយ បានជាព្រះសោតាបន្ន ហើយក៏ត្រឡប់ទៅផ្ទះវិញ ។ ពេលនោះមារនិម្មិតព្រះពុទ្ធរូប ដែលប្រដាប់ដោយលក្ខណៈដ៏ប្រសើរ ៣២ ប្រការប្រថាប់នៅត្រង់ទ្វារផ្ទះរបស់ឧបាសកនោះ ហើយលាន់មាត់ថា ព្រះសាស្ដាស្ដេចទ្រង់យាងមក ដូច្នេះ ។ សូរម្ពដ្ឋឧបាសកគិតថា យើងស្ដាប់ព្រះធម៌

ក្នុងសម្នាក់នៃព្រះសាស្តាមកអម្បាញ់មិញនេះឯង អ្វីនឹងមានទៀតហ្ន៎ ដូច្នេះ ហើយ ក៏ចូលទៅរក ក្រាបថ្វាយបង្គំដោយសម្គាល់ថា ជាព្រះសាស្តា ទើបបានឈរស្ងៀម ។ មារពោលថា អម្ពដ្ឋៈ ពាក្យណាដែលយើងពោលដល់អ្នកថា រូបមិនទៀង ។ល។ វិញ្ញាណ មិនទៀង ដូច្នេះ ពាក្យនោះ យើងពោលខុសទេ ព្រោះយើងមិនទាន់ពិចារណា ទើបពោលពាក្យនោះទៅដូច្នោះ អ្នកចូរកាន់យកថា រូបទៀង ។ល។ វិញ្ញាណទៀង ដូច្នេះចុះ ។ សូរម្ពដ្ឋឧបាសកគិតថា សេចក្តីណា ដែលព្រះពុទ្ធទាំងឡាយមិនពិចារណា មិនធ្វើការត្រួតត្រាយ៉ាងប្រចក្ស ហើយត្រាស់អ្វីនោះ មិនជាឋានៈដែលនឹងមានបាន មារនេះ មកដើម្បីប្រាប់ថាទម្លាយយើងយ៉ាងពិតប្រាកដ ។ លំដាប់នោះ សូរម្ពដ្ឋឧបាសក ទើបពោលនឹងមារនោះថា លោកជាមារមែនទេ ដូច្នេះ ។ មារនោះមិនអាចនឹងពោលមុសាវាទបាន ទើបទទួលថាមែនយើងជាមារ ដូច្នេះ ។ ឧបាសកសួរថា ព្រោះហេតុអ្វី លោកទើបមក ។ មារឆ្លើយថា យើងមកដើម្បីធ្វើសទ្ធារបស់លោកឲ្យញាប់ញ័រ ។ ឧបាសកពោលថា ម្នាលមារមានចិត្តបាបឃោរឃៅ លោកតែម្នាក់ចូរបញ្ឈប់ទៅ ពួកមារដូចលោក សូម្បីរយក្តី ពាន់ក្តី សែនក្តី ក៏មិនអាចនឹងញុាំងសទ្ធា

របស់យើងឲ្យញាប់ញ័របាន ឈ្មោះថា សទ្ធា ដែលមកហើយដោយមគ្គ ជារបស់រឹងមាំ មិនញាប់ញ័រ ដូចភ្នំសុមេរុ ដែលតាំងនៅលើផែនដីដែល សុទ្ធតែជាថ្ម លោកនឹងធ្វើអ្វីក្នុងការមកនេះ ដូច្នេះហើយ ក៏ទះដៃឡើង ។ មារនោះ កាលមិនអាចនឹងឋិតនៅបាន ទើបបាត់ទៅក្នុងទីនោះនោះឯង ។ ពាក្យថា និវិដ្ឋា នោះ ព្រះមានព្រះភាគ ត្រាស់សំដៅយកសទ្ធាយ៉ាងនោះ ។

បទថា មូលជាតា បតិដ្ឋិតា សេចក្តីថា តាំងមាំហើយដោយមគ្គ នោះ ដែលជាមូល ព្រោះជាឫសគល់ គឺ មគ្គកើតព្រមហើយ ។ បទថា ទឡ្ហា ប្រែថា រឹងមាំ ។

បទថា អសំហារិយា សេចក្តីថា ដែលនរណាៗ មិនអាចដើម្បី នឹងឲ្យញាប់ញ័របាន ប្រៀបដូចសសរខឿនដែលគេកប់ទុកយ៉ាងមាំ ។ បទថា តស្សេតំ កល្លំ វចនាយ នោះ សេចក្តីថា ពាក្យនោះ គួរនឹងហៅ ព្រះអរិយសាវក ។ លោកពោលថា យ៉ាងណា ។ លោកពោលពាក្យជា ដើមថា យើងជាបុត្រកើតអំពីទ្រូងរបស់ព្រះមានព្រះភាគ ដូច្នេះ ។

សេចក្តីពិត ព្រះអរិយសាវកនោះ អាស្រ័យព្រះមានព្រះភាគ ទើប កើតឡើងក្នុងភូមិរបស់ព្រះអរិយៈ ដូច្នោះ ទើបឈ្មោះថា ជាបុត្ររបស់

ព្រះមានព្រះភាគ និងឈ្មោះថា ជាឱរសកើតអំពីព្រះឱស្ឋ ព្រោះនៅក្នុងទ្រូង ហើយតាំងនៅក្នុងមគ្គ និងផល ដោយអំណាចការពោលធម៌ដែលចេញមកពីព្រះឱស្ឋ ឈ្មោះថា កើតអំពីធម៌ ព្រោះកើតអំពីអរិយធម៌ និងឈ្មោះថា ដែលធម៌និម្មិតឡើង ព្រោះត្រូវអរិយនិម្មិតឡើង ឈ្មោះថា ធម្មទាយាទ ព្រោះគួរទទួលមត៌ក គឺ នវលោកុត្តរធម៌ ។

បទថា តំ កិស្ស ហេតុ សេចក្ដីថា ប្រសិនបើមានពាក្យសួរថា ព្រះមានព្រះភាគត្រាស់ថា ភគវតោម្ហិ បុត្តោ ដូច្នេះហើយ ត្រាស់ទៀតថា ធម្មជោ ធម្មនិម្មិតោ ដូច្នេះទៀត ពាក្យនោះ ព្រះអង្គត្រាស់ព្រោះហេតុអ្វី ។ ឥឡូវនេះ កាលនឹងសម្ដែងសេចក្ដីរបស់ពាក្យនោះ លោកទើបពោលពាក្យជាដើមថា តថាគតស្ស ហេតំ ដូច្នេះជាដើម ។ ក្នុងបាលីនោះ ពាក្យថា ធម្មកាយោ ឥតិបិ សេចក្ដីថា ព្រោះហេតុអ្វី ព្រះតថាគតទើបបានទទួលតាំងនាមថា **ធម្មកាយ** ។ ព្រោះព្រះតថាគត ទ្រង់ព្រះតម្រិះព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដកដោយព្រះហឫទយៈ ហើយទ្រង់នាំចេញសម្ដែងដោយព្រះវាចា ។

ដោយហេតុនោះ ព្រះវរកាយរបស់ព្រះមានព្រះភាគ ទើបចាត់ជា

ធម៌ពិត ព្រោះសម្រេចដោយធម៌ ។ ព្រះធម៌ ជាកាយរបស់ព្រះមានព្រះ-ភាគនោះ ដូចពណ៌នាមកនេះ ដូច្នោះ ព្រះមានព្រះភាគ ទើបឈ្មោះថា **ធម្មកាយ** ។

ឈ្មោះថា **ព្រហ្មកាយ** ព្រោះមានធម៌ជាកាយនោះឯង ពិតណាស់ **ព្រះធម៌** លោកហៅថា ព្រហ្ម ព្រោះជារបស់ប្រសើរ ។ បទថា ធម្មភូតោ បានដល់ សភាវធម៌ ។ ឈ្មោះថា **ព្រហ្មភូត** ព្រោះជាអ្នកកើតពីព្រះធម៌នោះឯង ។

## ពោលអំពីជាតិផ្សេង ៗ

[៥៦] ព្រះមានព្រះភាគ លុះទ្រង់សម្ដែងវាទៈដែលជាគ្រឿងទម្លាយភាពជាអ្នកប្រសើរ ដោយព្រះតម្រាស់មានប្រមាណប៉ុណ្ណេះហើយ ឥឡូវនេះ កាលនឹងទ្រង់សម្ដែងវាទៈ ដែលជាគ្រឿងទម្លាយភាពជាអ្នកប្រសើរដោយន័យដទៃទៀត ទើបត្រាស់ថា ហោតិ ខោ សោ វាសេដ្ឋា សមយោ ដូច្នេះជាដើម បណ្ដាពាក្យទាំងនោះ ពោលដោយសំវដ្ដៈ និងវិវដ្ដៈ បានពណ៌នាដោយពិស្ដារហើយក្នុងព្រហ្មជាលសូត្រ ។

បទថា ឥត្ថត្តំ អាគច្ឆន្តិ សេចក្តីថា រមែងមកកាន់ភាពជាយ៉ាងនេះ គឺ កាន់ភាពជាមនុស្ស ។ បទថា តេ ច ហោន្តិ មនោមយា សេចក្តីថា សត្វទាំងនោះសូម្បីមកកើតក្នុងមនុស្សលោកនេះ ក៏ជាពួកឱបបាតិកកំណើត កើតឡើងដោយចិត្តប៉ុណ្ណោះ ដូច្នោះ ទើបឈ្មោះថា អ្នកមានសេចក្តីសម្រេចផ្លូវចិត្ត ។ បីតិប៉ុណ្ណោះ រមែងឲ្យសម្រេចកិច្ចដោយអាហារដល់សត្វទាំងនោះ សូម្បីក្នុងមនុស្សលោកនេះ ដូចក្នុងព្រហ្មលោក ដូច្នោះ សត្វទាំងនោះ ទើបឈ្មោះថា មានបីតិជាអាហារ ។ គប្បីជ្រាបហេតុមានរស្មីឯងជាដើម ដោយន័យនេះ ។ បទថា ឯកោទកីភូតំ សេចក្តីថា ចក្រវាឡទាំងអស់ ជាទីដែលមានទឹកដូចគ្នា ។ បទថា អន្ធការោ ប្រែថា សេចក្តីងងឹតឈឹង ។ បទថា អន្ធការតិមិសា សេចក្តីថា ញុំាងភាពងងឹត គឺ មានភាពងងឹតឈឹង ដោយការហាមការកើតឡើងនៃចក្ខុវិញ្ញាណ ។

បទថា សមន្តានិ សេចក្តីថា តាំងនៅ គឺ ផ្សាយទៅជុំវិញ ។ បទថា បយតត្តស្ស ប្រែថា ទឹកដោះដែលរំងាស់ឲ្យរីង ។ បទថា វណ្ណសម្បន្នា សេចក្តីថា ដល់ព្រមដោយពណ៌ ។ ក៏ពណ៌របស់រសជីនោះ ដូចជាផ្កាកណិការ ។ បទថា គន្ធសម្បន្នា សេចក្តីថា ដល់ព្រមដោយក្លិន

គឺ ក្លិនដែលជាទិព្វ រមែងសាយទៅ ។ បទថា រសសម្បន្នា សេចក្តីថា ដល់ព្រមដោយរស ដូចដាក់ឱជាទិព្វចុះទៅ ដូច្នោះ ។ បទថា ខុទ្ទកមធុំ សេចក្តីថា ទឹកឃ្មុំដែលសត្វឃ្មុំធ្វើទុក ។ បទថា អនេឡកំ សេចក្តីថា មានទោសទៅប្រាសហើយ គឺ វៀរចាក ពងរុយ ។

បទថា លោលជាតិកោ សេចក្តីថា មានសេចក្តីលោភជាសភាព ។ សូម្បីក្នុងកប្បបន្ទាប់ទៅ ដែលកន្លងទៅហើយ ក៏មានសេចក្តីលោភដូចគ្នា យើងកើតសេចក្តីអស្ចារ្យ ទើបពោលថា អម្ភោ ដូច្នេះ ។ បទថា កិមេវិទំ ភវិស្សតិ សេចក្តីថា ពណ៌ក្តី ក្លិនក្តី នៃរសដីនោះគួរពេញចិត្ត តែរសរបស់រសដីនោះ នឹងជាយ៉ាងណាហ្ន៎ ។ អ្នកដែលកើតសេចក្តីលោភក្នុងរសដីនោះ ក៏យកចង្អុលដៃត្បិះដីនោះ មកលិទ្ធភ្លក្សមើល លុះយកចង្អុលដៃត្បិះមកហើយ ក៏យកមកដាក់ត្រង់អណ្តាត ។ បទថា អច្ឆាទេសិ សេចក្តីថា រសដីនោះ ល្មមគេយកមកដាក់ទុកត្រង់ចុងអណ្តាត ក៏ជ្រួតជ្រាបទៅគ្រប់សរសៃទទួលរសអាហារ ៧,០០០ សរសៃ ជារបស់ គួរពេញចិត្ត ។ បទថា តណ្ហា ចស្ស ឱក្កមិ សេចក្តីថា ការប្រាថ្នាក្នុងរស ក្នុងរសដីនោះ ក៏កើតឡើងដល់សត្វអ្នកមានសេចក្តីលោភនោះ ។ ច្រើនបទថា អាលុម្ប-

កាករំ ឧបក្កមឹសុ បរិភុញ្ជិតុំ សេចក្ដីថា គេពូតជាពំនូត គឺ បែងចែក ចេញជាដុំហើយ ផ្ដើមបរិភោគ ។ ព្រះចន្ទ និងព្រះអាទិត្យ ឈ្មោះថា ចន្ទិមសុរិយា ។ បទថា ធាតុរហេសុំ ប្រែថា ប្រាកដឡើង ។ ក៏បណ្ដា ព្រះចន្ទ និងព្រះអាទិត្យនោះ តើណាមួយប្រាកដមុន តើមួយណានៅក្នុង ទីណា តើប្រមាណរបស់មួយណាមានទំហំប៉ុនណា តើមួយណានៅខ្ពស់ តើមួយណាវិលរហ័ស វិថិរបស់ព្រះចន្ទ និងព្រះអាទិត្យនោះ តើយ៉ាងណា តើត្រាច់ទៅបានយ៉ាងណា តើធ្វើពន្លឺក្នុងទីមានប្រមាណប៉ុនណា ។

## ពោលអំពី ការប្រាកដ

ព្រះចន្ទ និងព្រះអាទិត្យទាំងពីរ មិនប្រាកដព្រមគ្នា ។ ព្រះអាទិត្យ ប្រាកដឡើងមុន ។ កាលរស្មីនៃកាយរបស់សត្វទាំងនោះ បានបាត់ទៅ ភាពងងឹតឈឹង ទើបមានឡើង ។ សត្វទាំងនោះ ក៏ភ័យខ្លាចតក់ស្លុតហើយ គិតគ្នាថា បើពន្លឺប្រាកដឡើងមក គង់នឹងល្អហ្ន៎ ដូច្នេះ បន្ទាប់ពីនោះ ព្រះអាទិត្យក៏កើតឡើងដល់មហាជន ។ ដោយហេតុនោះ ព្រះអាទិត្យនោះ ទើបបាននាមថា សុរិយោ ដូច្នេះ ។ កាលព្រះអាទិត្យនោះ ធ្វើពន្លឺរហូត

ដល់អស់មួយថ្ងៃ ហើយអស្តង្គតទៅ ភាពងងឹតឈឹង ក៏ត្រឡប់មានឡើងទៀត ។ សត្វទាំងនោះ នាំគ្នាគិតថា គង់ទីងជាការល្អហ្ន៎ ប្រសិនបើថាមានពន្លឺយ៉ាងដទៃកើតឡើង ដូច្នេះ ។ ពេលនោះ ព្រះចន្ទដីងនូវសេចក្តីពេញចិត្តរបស់សត្វទាំងនោះ ទើបកើតឡើង ។ ដោយហេតុនោះៗ ឯងព្រះចន្ទ ទើបបាននាមថា ចន្ទោ ដូច្នេះ ។ បណ្តាព្រះចន្ទ និងព្រះអាទិត្យនោះ ព្រះចន្ទនៅក្នុងវិមានខាងក្នុង ប្រកបដោយកែវមណីសុទ្ធ វិមានខាងក្រៅប្រកបដោយប្រាក់សុទ្ធ ទាំងខាងក្នុង និងខាងក្រៅនោះ មានភាពត្រជាក់តែម្យ៉ាង ។ ព្រះអាទិត្យនៅក្នុងវិមានខាងក្នុង ប្រកបដោយមាសសុទ្ធ វិមានខាងក្រៅ ប្រកបដោយកែវផលិកសុទ្ធ ។ ទាំងខាងក្នុង និងខាងក្រៅ ក្តៅទាំងអស់ ។

## ពោលអំពី ប្រមាណធំហាំ

ព្រះចន្ទ មានខ្សែព្រះសូន្យកណ្តាល ៤៩ យោជន៍ វង់ជុំវិញប្រវែង ២៤៩ យោជន៍ ។ ព្រះអាទិត្យ មានខ្សែព្រះសូន្យកណ្តាល ៥០ យោជន៍ ខ្សែវង់ជុំវិញប្រវែង ២៥០ យោជន៍ ។

## ពោលអំពីកម្ពស់

ព្រះចន្ទនៅខាងក្រោម ព្រះអាទិត្យនៅខាងលើ ។ ព្រះចន្ទ និង ព្រះអាទិត្យនោះ នៅឆ្ងាយពីគ្នា ១ យោជន៍ ។ ចំណែកក្រោមរបស់ព្រះចន្ទ ដល់ចំណែកលើរបស់ព្រះអាទិត្យ មានរយៈ ១០០ យោជន៍ ។

## ពោលអំពី ការវិល

ព្រះចន្ទវិលទៅផ្លូវត្រង់យឺត ប៉ុន្តែវិលទៅផ្លូវខាងស្តាំរហ័ស ពួកផ្កាយនក្ខត្តឫក្ស ក៏វិលទៅក្នុងពីរផ្នែក ព្រះចន្ទវិលទៅជិត ពួកផ្កាយនោះៗ ដូចមេគោចូលទៅរកកូនគោ ដូច្នោះ ។ ចំណែកពួកផ្កាយ មិនចោលទីនៅរបស់ខ្លួនឡើយ ។ ការវិលទៅរបស់ព្រះអាទិត្យផ្លូវត្រង់រហ័ស ទៅផ្លូវទទឹងយឺត ។ ព្រះអាទិត្យនេះ គោចរឆ្ងាយពីព្រះចន្ទសែនយោជន៍ ក្នុងថ្ងៃបាដិបទពីថ្ងៃឧបោសថកាឡបក្ខ ។ វេលានោះ ព្រះចន្ទប្រាកដដូចស្នាមគំនូស ដូច្នោះ ។ ព្រះអាទិត្យគោចរឆ្ងាយទៅជារយៈសែនយោជន៍ ក្នុងបក្ខទី ២ ព្រះអាទិត្យបានគោចរឆ្ងាយទៅ ដូចដែលពោលហើយនេះ ជារយៈសែនៗ យោជន៍ ដរាបដល់ថ្ងៃឧបោសថ ។ លំដាប់នោះ ព្រះចន្ទក៏ធំឡើងដោយ

លំដាប់ ហើយពេញដួងក្នុងថ្ងៃឧបោសថ ។ គោចរឆ្ងាយ ចេញទៅសែន យោជន៍ក្នុងថ្ងៃបាដិបទ ( រនោច ) ទៀត ។ គោចរឆ្ងាយចេញទៅជារយៈ សែនយោជន៍ ក្នុងបក្ខទី ២ ព្រះអាទិត្យគោចរឆ្ងាយទៅ ដូចពោលហើយ នេះ ជារយៈសែនៗ យោជន៍ ដរាបដល់ថ្ងៃឧបោសថ ។ ពេលនោះ ព្រះចន្ទថយពន្លឺចុះដោយលំដាប់ ហើយមិនប្រាកដទាំងដួងក្នុងថ្ងៃឧបោសថ ។ ព្រះអាទិត្យ អណ្តែតនៅខាងលើ ឲ្យព្រះចន្ទនៅខាងក្រោម ( ព្រះអាទិត្យ ) រមែងបិទបាំងព្រះចន្ទទុកបាន ដូចភាជន៍តូចត្រូវភាជន៍ធំបិទបាំង ( គ្រប ) ទុក ដូច្នោះ ។ ស្រមោលរបស់ព្រះចន្ទមិនប្រាកដ ដូចស្រមោលផ្ទះមិន ប្រាកដក្នុងវេលាយប់ ។ ព្រះអាទិត្យនោះ កាលស្រមោលមិនប្រាកដ សូម្បី ខ្លួនឯងក៏មិនប្រាកដ ដូចប្រទីបក្នុងពេលថ្ងៃ មិនប្រាកដដល់ពួកជនអ្នកឈរ នៅទីឆ្ងាយ ដូច្នោះ ។

ក៏គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា វិថិរបស់ព្រះអាទិត្យ និងព្រះចន្ទ យ៉ាងណា តទៅនេះវិថិមានដូច្នេះ គឺ វិថិពពែ វិថិដំរី វិថិរបស់គោ ។ បណ្តាវិថិទាំងនោះ ទឹកជារបស់គួរខ្ពើមសម្រាប់ពពែទាំងឡាយ តែទឹក នោះ ជាទីពេញចិត្តរបស់ដំរីទាំងឡាយ ជាទីសប្បាយរបស់ហ្វូងគោ ព្រោះ

មានភាពត្រជាក់ និងភាពក្តៅស្មើគ្នា ។ ដូច្នោះ ក្នុងវេលាណា ព្រះចន្ទ និងព្រះអាទិត្យ ឡើងកាន់វិថិរបស់ពពែ វេលានោះ ភ្លៀងមិនធ្លាក់ឡើយ សូម្បីត្រឹមតែមួយគ្រាប់ កាលណាព្រះចន្ទ និងព្រះអាទិត្យឡើងកាន់វិថិរបស់ដំរី កាលនោះ ភ្លៀងនឹងធ្លាក់ខ្លាំងដូចធ្លាយមេឃ ។ កាលណាព្រះចន្ទ និងព្រះអាទិត្យឡើងកាន់វិថិរបស់គោ កាលនោះ សភាពស្មើរបស់រដូវ ក៏រមែងដល់ព្រម ។

ព្រះចន្ទ និងព្រះអាទិត្យ តែងតែរំកិលនៅខាងក្រៅ ភ្នំសិនេរុអស់វេលា ៦ ខែ និងគោចរនៅខាងក្នុងទៀត ៦ ខែ ។ សេចក្តីពិត ព្រះចន្ទ និងព្រះអាទិត្យនោះ តែងគោចរទៅជិតភ្នំ សិនេរុក្នុងខែ ៨ ។ បន្ទាប់អំពីនោះ រំកិលចេញទៅ គោចរនៅខាងក្រៅ ២ ខែ ហើយរំកិលទៅនៅដោយផ្លូវកណ្តាលក្នុងដើមខែ ១២ ។ តអំពីនោះ រំកិលមានមុខឆ្ពោះចក្រវាឡ ហើយគោចរនៅជិតៗ ចក្រវាឡអស់វេលា ៣ ខែ ហើយរំកិលចេញឆ្ងាយម្តងទៀត ទៅនៅត្រង់កណ្តាលចក្រវាឡក្នុងខែ ៥ តអំពីនោះ ក្នុងខែដទៃក៏រំកិលមុខឆ្ពោះភ្នំសិនេរុ ហើយគោចរនៅជិតៗ ភ្នំសិនេរុ ក្នុងខែ ៨ ទៀត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា ព្រះអាទិត្យ និងព្រះចន្ទធ្វើពន្លឺក្នុងទីនេះប្រមាណប៉ុនណា ដូច្នេះ ព្រះចន្ទ និងព្រះអាទិត្យ រមែងធ្វើពន្លឺក្នុងទ្វីបទាំង ៣ ដោយព្រមគ្នា ។ ធ្វើបានយ៉ាងណា ។ ពេលព្រះអាទិត្យរះឡើងក្នុងទ្វីបនេះ ជាពេលព្រឹកក្នុងបុព្វវិទេហទ្វីប ពេលដែលព្រះអាទិត្យលិចក្នុងឧត្តរកុរុទ្វីប ជាមជ្ឈិមយាមក្នុងអមរគោយានទ្វីប ។ ពេលដែលព្រះអាទិត្យរះឡើងក្នុងបុព្វវិទេហទ្វីប ជាពេលថ្ងៃត្រង់ក្នុងឧត្តរកុរុទ្វីប ពេលដែលព្រះអាទិត្យលិចក្នុងអមរគោយានទ្វីប ជាមជ្ឈិមយាមក្នុងទ្វីបនេះ ។ ពេលដែលព្រះអាទិត្យរះឡើងក្នុងឧត្តរកុរុទ្វីប ជាពេលថ្ងៃត្រង់ក្នុងអមរ-គោយានទ្វីប ពេលដែលព្រះអាទិត្យលិចក្នុងទ្វីបនេះ ជាពេលមជ្ឈិមយាមក្នុងបុព្វវិទេហទ្វីប ។ ពេលដែលព្រះអាទិត្យរះឡើងក្នុងអមរគោយានទ្វីប ជាពេលថ្ងៃត្រង់ក្នុងទ្វីបនេះ ពេលដែលព្រះអាទិត្យលិចក្នុងបុព្វវិទេហទ្វីប ជាវេលាមជ្ឈិមយាមក្នុងឧត្តរកុរុទ្វីប ដូច្នេះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពីរបទថា ឧក្កត្ថានិ តារករូបានិ តទៅ ផ្កាយនក្ខត្ត មានផ្កាយឫក្សជាដើម និងពួកផ្កាយទាំងឡាយដ៏សេស រមែងប្រាកដព្រមនឹងព្រះចន្ទ និងព្រះអាទិត្យ ។ បទថា រត្តិន្ទិវា សេចក្តីថា

តាំងពីព្រះអាទិត្យលិចដរាបដល់រះឡើង ជាវេលាពេលយប់ តាំងពីវេលាព្រះអាទិត្យរះឡើងដរាបដល់ព្រះអាទិត្យលិច ចាត់ជាពេលថ្ងៃ ពេលយប់ និងពេលថ្ងៃ រមែងប្រាកដដូចពោលមកនេះ ។ តអំពីនោះ ១៥ រាត្រី ចាត់ជាកន្លះខែ , ២ កន្លះខែជាមួយខែ កន្លះខែ និងមួយខែ ប្រាកដដូចពោលមកនេះ ។ ដូច្នេះ ៤ ខែ ចាត់ជា ១ រដូវ , ៣ រដូវជា ១ ឆ្នាំ ទាំងរដូវនិងឆ្នាំ ទើបប្រាកដដូចពោលមកនេះ ។

## ពោលអំពីផែនដីមានរសជាដើម

**[៥៧]** ពាក្យថា វណ្ណវេវណ្ណតា ច បានដល់ ការមានពណ៌សម្បុរផ្សេងគ្នា ។ បទថា តេសំ វណ្ណាតិ មានប្បច្ចយា សេចក្តីថា ព្រោះការប្រកាន់ខ្លួនដែលកើតឡើង ព្រោះប្រារព្ធ វណ្ណៈរបស់សត្វទាំងឡាយទាំងនោះជាបច្ច័យ ។ បទថា មានាតិមានជាតិកានំ សេចក្តីថា អ្នកមានមានៈនិងអតិមានៈ កើតឡើងរឿយៗ ជាសភាព ។ បទថា រសបថវិយា សេចក្តីថា ផែនដី ដែលបាននាមថា **រស** ព្រោះសម្បូរណ៍ដោយរស ។

បទថា អនុត្ថុនឹសុ សេចក្តីថា នាំគ្នាត្អូញត្អែរ ។

បទថា អហោ រសំ សេចក្តីថា ឱ ! រសឆ្ងាញ់មានដល់ពួកយើង ។ ពាក្យថា អគ្គញ្ញំ អក្ខរំ នេះ ជាពាក្យពោលដល់វង្សដែលកើតឡើងក្នុងលោក ។ បទថា អនុបតន្តិ សេចក្តីថា រមែងទៅតាម ។

## ពោលអំពីក្រមរដែនដីជាដើម

[៥៨] បទថា ឯវមេវ ចាតុរហោសិ សេចក្តីថា បានជាដូច្នេះតាំងឡើង និងបានតាំងឡើងដូចជាកក់ ដែលស្ងួតកើតឡើង ក្នុងកាលទឹកខាងក្នុងស្រះរីងស្ងួតទៅ ដូច្នោះ ។ ក្រមរមានរសផ្អែមយ៉ាងក៏កើតឡើង ឈ្មោះថា **ក្រមរដី** ។ បទថា កលម្ពកា បានដល់ វល្លិ៍ត្រកួន ។ បទថា អហុ វត នោ សេចក្តីថា ក្រមរផែនដីមានរសផ្អែម បានមានដល់យើងទាំងឡាយហើយហ្ន៎ ។ បទថា អហាយិ វត នោ សេចក្តីថា ក្រមរផែនដីនោះរបស់ពួកយើងបានវិនាសទៅហើយ ក្នុងកាលឥឡូវនេះ ។

[៥៩] បទថា អកដ្ឋបាកោ សេចក្តីថា កើតឡើងឯងលើដីដែលមិនបានភ្ជួររាស់ឡើយ ។ បទថា អកណោ ប្រែថា មិនមានកុន្ទក់លាយឡំ ។

បទថា អជុសោ ប្រែថា មិនមានអង្កាម ។ បទថា សុគន្ធោ សេចក្តីថា ក្លិនទិព្វ រមែងសាយកាយទៅ ។ បទថា តណ្ឌុលប្ផលោ សេចក្តីថា រមែងបញ្ចេញផលជាគ្រាប់អង្ករ.សបរិសុទ្ធិ ។ បទថា បក្កំ បដិវិរុឡ្ហំ សេចក្តីថា កន្លែងដែលគេបូតក្នុងវេលាល្ងាច ក្នុងពេលព្រឹកឡើងក៏ដុះល្អ តាមប្រក្រតីទៀត ទីដែលគេបូតមិនប្រាកដទេ ។ បទថា ឆាបឆានំ បញ្ញាយតិ សេចក្តីថា រមែងប្រាកដជាផ្ទៃ ដែលបូតមិនអស់ ហើយមិនចាំបាច់រក្សា បទថា ឥត្ថិយា ច សេចក្តីថា ភេទស្ត្រីរបស់ស្ត្រីក្នុងវេលាជាមនុស្ស ក្នុងជាតិមុនៗ ក៏ប្រាកដ ភេទប្រុសរបស់ប្រុសក្នុងកាលមុនៗ នោះក៏ប្រាកដ ។ សេចក្តីពិត មាតុគ្រាម កាលត្រូវការភាវៈជាបុរស ក៏ព្យាយាមបំពេញធម៌ ដែលជាបច្ច័យនៃភាពជាបុរសដោយលំដាប់ ក៏រមែងសម្រេចបាន ។ បុរស កាលត្រូវការភាពជាស្ត្រី ក៏ប្រព្រឹត្តកាមេសុមិច្ឆាចារ រមែងសម្រេចបាន ។ ក៏ក្នុងវេលានោះ តាមប្រក្រតី ភេទស្ត្រី រមែងប្រាកដឡើងដល់មាតុគ្រាម ភេទប្រុស ក៏ប្រាកដឡើងដល់បុរស ។

បទថា ឧបនិជ្ឈាយតំ សេចក្តីថា សម្លឹងមើល គឺ ក្រឡេកមើល ។ បទថា បរិឡាហោ បានដល់ សេចក្តីរោលរាលដោយអំណាចរាគៈ ។

បទថា សេដ្ឋី បានដល់ ផេះ ។ បទថា និត្ថុយ្ហមានាយ សេចក្តីថា នាំ
បេញទៅ ។

## ពោលអំពីការនាំយកស្រូវសាលីជាដើម

[៦០-៦១] បទថា អធម្មសម្មតំ សេចក្តីថា ការបោះអាចម៍ដីជាដើម នោះ សន្មតិគ្នាថា មិនមែនជាធម៌ ។ បទថា តទេតរហិ ធម្មសម្មតំ សេចក្តីថា តែក្នុងកាលឥឡូវនេះ ការបោះអាចម៍ជាដើមនេះ សន្មតិថា ជាធម៌ ។ ពួកព្រាហ្មណ៍ទាំងឡាយ នាំគ្នាកាន់យកការបោះអាចម៍ជាដើម នោះថា ជាធម៌ ត្រាប់ទៅ ។ ពិតយ៉ាងនោះ ក្នុងជនបទខ្លះ ពួកស្ត្រីទាំង ឡាយឈ្មោះគ្នា រមែងពោលថា ព្រោះហេតុអ្វី លោកទើបពោល លោក នឹងមិនបានអ្វីសូម្បីត្រឹមគោម័យស្រស់ ។ បទថា ចាតព្យំ បានដល់ ការ សេព ។ បទថា សន្និធិការកំ បានដល់ ធ្វើការសន្សំ ។ បទថា អចានានំ បញ្ញាយិត្ថ សេចក្តីថា កន្លែងដែលគេរក្សាទៅហើយ បានប្រាកដជារបស់ ខ្វះខាតទៅ ។ បទថា សណ្ឌសណ្ឌា សេចក្តីថា ដុះជាគុម្ពៗ ដូចចងទុកជា បាច់ក្នុងទីមួយៗ ។

*បទថា មរិយាទំ ឋបេយ្យាម សេចក្តីថា ពួកយើងនឹងបែងចែកដែនគ្នា ។*

## ការសន្មតសត្វម្នាក់ ការប្រគល់ចំណែកស្រូវសាលី

[៦២] *បទថា* យត្រ ហិ នាម *បានដល់* យោ ហិ នាម ( *ក៏ឈ្មោះថាសត្វណា ) ។ ពីរបទថា* ចាណិនា ចាហរឹសុ *សេចក្តីថា សត្វទាំងនោះ យកដៃវាយអ្នកដែលមិនជឿពាក្យខ្លួនដល់ ៣ ដង ។ បទថា* តនគ្គេ ខោ បន *ប្រែថា ព្រោះធ្វើហេតុនោះ ជាគ្រឿងសម្គាល់ ។*

*បទថា* ខីយិតព្វំ ខីយេយ្យ *អធិប្បាយថា គប្បីប្រកាសប្រាប់បុគ្គលដែលគួរប្រកាស គឺ តិះដៀលបុគ្គលដែលគួរតិះដៀល បណ្តេញអ្នកដែលគួរបណ្តេញ ។ បទថា* យោ នេសំ សត្តោ *សេចក្តីថា បណ្តាសត្វទាំងនោះសត្វពួកណា ។ សួរថា ក៏សត្វនោះជាអ្នកណា ។ ឆ្លើយថា គឺ ព្រះពោធិសត្វនៃយើងទាំងឡាយ ។ ច្រើនបទថា* សាលីនំ ភាគំ អនុប្បទស្សាម *សេចក្តីថា យើងនឹងនាំស្រូវសាលីមកពីចម្ការរបស់យើងម្នាក់ៗ មួយនាឡី ហើយនឹងឲ្យចំណែកស្រូវសាលីដល់លោក លោកមិនចាំបាច់ធ្វើការងារអ្វី*

សូមលោកតាំងនៅក្នុងឋានៈជាប្រមុខរបស់យើងទាំងឡាយចុះ ។

[៦៣] បទថា អក្ខរំ ឧបនិព្វត្តំ សេចក្តីថា កើតបញ្ញត្តិវោហារដែលយល់គ្នាបានដោយការរាប់ ។ ពាក្យថា ខត្តិយោ ខត្តិយោ ដូច្នេះ ជាពាក្យដែលកើតឡើងទីពីរ ។ បទថា អក្ខរំ សេចក្តីថា មិនមែនចំពោះអក្សរតែម្យ៉ាងប៉ុណ្ណោះ តែពួកសត្វទាំងនោះ នៅបានធ្វើការអភិសេកបុគ្គលនោះដោយការលើកតម្កើងដល់ ៣ ដងថា សូមឲ្យលោកជាធំក្នុងស្រែរបស់ពួកយើង ដូច្នេះ ។ បទថា រញ្ជេតិ ប្រែថា រមែងញុំាងអ្នកដទៃឲ្យមានសេចក្តីសុខស្កប់ស្កល់ ។ បទថា អគ្គញ្ញេន សេចក្តីថា ការកើតឡើងដោយអក្សរដែលកើតឡើងក្នុងសម័យនៃលោកកើតឡើង ដែលដឹងគ្នាថា ខ្ពង់ខ្ពស់ ឬស្គាល់គ្នាក្នុងចំណែកខ្ពង់ខ្ពស់ ។

## ពោលអំពីចាបធម៌ មានអទិន្នាទានជាដើម

[៦៤] បទថា វីតង្គារា វីតធូមា សេចក្តីថា ប្រាសចាកផ្សែង និងរងើកភ្លើង ព្រោះមិនមានអាហារ ដែលទឹងគប្បីចម្អិន ហើយស៊ី ។ បទថា បន្នមុសលា សេចក្តីថា ការមិនមាន មានការបុក ព្រោះមិនមានអាហារ

ដែលគប្បីបុក ហើយចម្អិន ។

បទថា ឃាសមេសនា សេចក្តីថា ស្វែងរកយាគូ និងភត្ត ដោយអំណាចភិក្ខាចារ ។ បទថា តមេនំ មនុស្សា ទិស្វា សេចក្តីថា ពួកមនុស្សទាំងនោះ បានឃើញបុគ្គលទាំងនោះ ។

បទថា អនភិសម្ភុនមានា ប្រែថា អត់ទ្រាំទុកមិនបាន គឺ មិនអាចនឹងអត់ទ្រាំទុកបាន ។ បទថា គន្ថេ ករោន្តា សេចក្តីថា តាក់តែង គឺ បង្រៀនត្រៃវេទ ។ បទថា អច្ឆន្តិ ប្រែថា រមែងអាស្រ័យនៅ ។ បាលីថា អច្ចេន្តិ ដូច្នេះខ្លះ ។ សេចក្តីដូចគ្នា ។ បទថា ហីនសម្មតំ សេចក្តីថា ម្នាលវាសេដ្ឋៈ ដោយសម័យនោះពាក្យថា ពួកព្រាហ្មណ៍ រមែងទ្រទ្រង់ចាំមន្ត្រ រមែងប្រាប់មន្ត្រដូច្នេះ ជាពាក្យសម្មតិថា ថោកទាប បទថា តទេ-តរហិ សេដ្ឋសម្មតំ សេចក្តីថា ឥឡូវនេះពាក្យថា ព្រាហ្មណ៍ទាំងឡាយ រមែងទ្រទ្រង់ចាំមន្ត្រ មានប្រមាណប៉ុណ្ណេះ រមែងពោលប្រាប់មន្ត្រ មានប្រមាណប៉ុណ្ណេះ ជាពាក្យសម្មតិថា **ប្រសើរ** ។ បទថា ព្រាហ្មណមណ្ឌលស្ស បាន ដល់ ពួកព្រាហ្មណ៍ ។

**[៦៥]** បទថា មេថុនំ ធម្មំ សមាទាយ ប្រែថា កាន់យកមេថុនធម្ម ។

ច្រើនបទថា វិសុំ កម្មន្តេ បយោជេសុំ សេចក្តីថា ពួកសត្វផ្សេងៗ នាំគ្នាប្រកបការងារ ដែលមានឈ្មោះបោះសម្ទេង គឺ បានទទួលការលើកតម្កើង មានការចិញ្ចឹមគោ និងការធ្វើជំនួញជាដើម ។ ពាក្យថា សុទ្ទា សុទ្ទា នេះ អធិប្បាយថា ពួកសូទ្រ ទៅយ៉ាងគួរស្អប់ខ្ពើម គឺ សាបសូន្យ រហ័សៗ ហៅថា សុទ្ទំ សុទ្ទំ ព្រោះការងារដែលប្រព្រឹត្តថោកទាប និងការងារដែលប្រព្រឹត្ត បន្តិចបន្តួចនោះ ។

[៦៦] បទថា អហុ ខោ បានដល់ ហោតិ ខោ ។ បទថា សកំ ធម្មំ គរហមានោ សេចក្តីថា ក្សត្រអង្គខ្លះ តិះដៀលខត្តិយធម៌របស់ខ្លួនឯង យ៉ាងនេះថា នរណាៗ ក៏មិនអាចនឹងបរិសុទ្ធិបាន ដោយត្រឹមតែឲ្យលើកស្វេតច្ឆត្រ ។ ក្នុងគ្រប់បទក៏ន័យនេះ ។ ដោយពាក្យនេះថា ឥមេហិ ខោ វាសេដ្ឋា ចតូហិ មណ្ឌលេហិ នេះ ព្រះមានព្រះភាគ ទ្រង់តែងតែសម្តែងពាក្យនេះថា ពួកសមណៈ រមែងមិនមានការបែងចែក ។ ពីព្រោះនរណាៗ ក៏មិនអាចនឹងបរិសុទ្ធិដោយជាតិបាន សេចក្តីបរិសុទ្ធិនឹងមានបាន ក៏ដោយការបដិបត្តិប្រពៃរបស់ខ្លួនឯង ដូច្នោះ ការកើតរបស់ព្រះសមណៈ ទើបកើតឡើងបាន ដោយពួកទាំង ៤ នេះ ពួកទាំងឡាយនេះ រមែងអនុវត្ត

តាមពួកសមណៈ និងពួកដែលអនុវត្តតាមទាំងនោះ ក៏រមែងអនុវត្តតាមធម៌ប៉ុណ្ណោះ មិនអនុវត្តតាមអធម៌ទេ សេចក្តីពិត ពួកសត្វទាំងឡាយអាស្រ័យពួកសមណៈ បំពេញសម្មាបដិបត្តិ រមែងដល់នូវសេចក្តីបរិសុទ្ធិបាន ដូច្នេះ ។

## ការប្រព្រឹត្តអាក្រក់ និងផលនៃការប្រព្រឹត្តអាក្រក់

**[៦៧-៦៨]** ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់ធ្វើសេចក្តីនោះថា នរណាៗ ក៏មិនអាចនឹងបរិសុទ្ធិបានតាមជាតិ តែពួកសត្វនឹងបរិសុទ្ធិបាន ក៏ដោយការប្រព្រឹត្តប្រពៃប៉ុណ្ណោះ ដូច្នេះ យ៉ាងច្បាស់លាស់ ទើបផ្តើមទេសនាថា ខត្តិយោបិ ខោ វាសេដ្ឋា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា មិច្ឆាទិដ្ឋិកម្មសមាទានហេតុ សេចក្តីថា ព្រោះហេតុ គឺ ការសមាទានកម្ម ដោយអំណាចមិច្ឆាទិដ្ឋិ ។ មយ៉ាងទៀត សេចក្តីថា ព្រោះហេតុដែលសមាទាននូវមិច្ឆាទិដ្ឋិកម្ម ។

## ការប្រព្រឹត្តល្អ ផលនៃការប្រព្រឹត្តល្អ

**[៦៩]** បទថា ទ្វយការី សេចក្តីថា រមែងធ្វើកម្មទាំងពីរចំណែក

យ៉ាងនេះ គឺ វេលាខ្លះធ្វើកុសលកម្ម វេលាខ្លះធ្វើអកុសលកម្ម ។ បទថា សុខទុក្ខប្បដិសំវេទី សេចក្តីថា ធម្មតាថា ស្ថានទីដែលឲ្យផលព្រមគ្នាទាំងពីរចំណែក ក្នុងពេលព្រមគ្នាមិនមាន ។ អ្នកណាបានធ្វើអកុសលកម្មទុកច្រើន ធ្វើកុសលកម្មទុកតិច គេអាស្រ័យកុសលកម្មនោះ ទៅកើតក្នុងត្រកូលក្សត្រ ឬត្រកូលព្រាហ្មណ៍ ។ ពេលនោះ អកុសលកម្មនោះ រមែងធ្វើឲ្យគេឲ្យជាបុគ្គលខ្វាក់ខ្លះ ពិការខ្លះ អាក្រាតខ្លះ គេរមែងមិនគួរដល់រាជសម្បត្តិ ឬគេនឹងជាយ៉ាងនេះ ក្នុងពេលដែលបានទទួលការអភិសេកហើយ ក៏មិនអាចនឹងប្រើប្រាស់ភោគសម្បត្តិបាន ។ តមក ក្នុងវេលាស្លាប់របស់គេ ទាំងកុសលកម្ម និងអកុសលកម្មទាំងពីរនោះ ក៏ប្រាកដដូចអ្នកប្រដាល់ ដែលមានកម្លាំងខ្លាំង ២ នាក់ ។ បណ្តាកម្មទាំងពីរនោះ អកុសលកម្មមានកម្លាំងច្រើនជាង ទើបហាមកុសលកម្មទុក ហើយឲ្យសត្វនោះកើតក្នុងកំណើតសត្វតិរច្ឆាន ។ ចំណែកកុសលកម្ម ជាកម្មដែលសត្វនឹងត្រូវសោយក្នុងបវត្តិកាល កុសលកម្មនោះ រមែងកសាង ( សត្វនោះឲ្យ ) ជាដំរីមង្គលខ្លះ សេះមង្គលខ្លះ គោមង្គលខ្លះ គេរមែងបានសោយសម្បត្តិនោះ ។ ព្រះមានព្រះភាគ ទ្រង់សំដៅយកកុសលកម្មនេះ ទើបត្រាស់ថា

សុខទុក្ខប្បដិសំវេទី ហោតិ ដូច្នេះ ។

**[៧០]** បទថា សត្តន្នំ ពោធិបក្ខិយានំ សេចក្តីថា ពោធិបក្ខិយធម៌ ៣៧ ប្រការ ដែលបែងចែកជា ៧ ពួក តាមលំដាប់ដោយចែកធម៌ប្រការដើមថា សតិប្បដ្ឋាន ៤ ។ បទថា ភាវនមន្វាយ សេចក្តីថា ទៅតាមភាវនា អធិប្បាយថា បដិបត្តិភាវនា ។ បទថា បរិនិព្វាតិ សេចក្តីថា រមែងរលត់ ដោយការរលត់កិលេស ។

ព្រះមានព្រះភាគ ទ្រង់សម្តែងវណ្ណៈ ៤ ដូចពណ៌នាមកដូច្នេះហើយ ទើបត្រឡប់មកសម្តែង លើកយកព្រះខីណាស្រពអ្នកសម្រេចសច្ចៈទាំង ៤ បានហើយថា ជាអ្នកប្រសើរក្នុងពួកទេវតា និងមនុស្ស ។

**[៧១]** ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងសេចក្តីនោះ ធ្វើឲ្យមុតមាំ តាមទំនងការសម្តែងពាក្យសួរបស់ព្រហ្មដែលលោកលើកតម្កើង ទើបត្រាស់ព្រះតម្រាស់ថា ឥមេសំ ហិ វាសេដ្ឋា ចតុន្នំ វណ្ណានំ ជាដើម ។ ពាក្យថា ព្រាហ្មណោ វេស្សោ ជាដើម បានអធិប្បាយពិស្តារក្នុងអម្ពដ្ឋសូត្រហើយ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងវាទៈដែលជាគ្រឿងទម្លាយភាពជាអ្នកប្រសើរដោយកថាមគ្គនេះ ត្រឹមតែប៉ុណ្ណេះ ដោយប្រការដូច្នេះ

*ហើយទ្រង់ត្រឡប់មកសម្តែងទេសនាឲ្យចប់ស្រេច ដោយធម៌ដែលជាកំពូល គឺ ព្រះអរហត្ត ។*

## គាថារបស់សនង្កុមារព្រហ្ម

**[៧២]** *បទថា អត្តមនា វាសេដ្ឋភារទ្វាជា សេចក្តីថា ក៏វាសេដ្ឋៈ និងភារទ្វាជៈសាមណេរនាំគ្នាលើកសរសើរ ត្រេកអរ បានសរសើរភាសិតរបស់ព្រះមានព្រះភាគថា សាធុ សាធុ ដូច្នេះ ។ សាមណេរទាំងពីរនោះកំពុងបង្អោនរលឹកដល់ ការដឹងតាមព្រះសូត្រនេះ នុ៎ះឯង ។ បានសម្រេចព្រះអរហត្ត ព្រមដោយបដិសម្ភិទាទាំងឡាយ ដូច្នេះឯង ។*

( ចប់ អដ្ឋកថាអគ្គញ្ញសូត្រទី ៤ )

# អដ្ឋកថា សម្បសាទនីយសូត្រ ទី ៥

[៧៣] *សម្បសាទនីយសូត្រ មានពាក្យផ្ដើមថា ឯវម្មេ សុតំ ដូច្នេះ ។*

*ក្នុងសម្បសាទនីយសូត្រនោះ មានការពណ៌នាបទ ដែលនៅមិនទាន់ច្បាស់ ដូចតទៅនេះ ៖*

*បទថា ឆាលន្ទាយំ សេចក្ដីថា ជិតព្រះនគរ ដែលបានឈ្មោះថា នាលន្ទា ព្រះមានព្រះភាគ ទ្រង់បានធ្វើក្រុងនាលន្ទានោះ ឲ្យជាទីគោចរគ្រាម ។ បទថា ចាវារិកម្ពវនេ សេចក្ដីថា ជាចម្ការស្វាយរបស់សេដ្ឋីអ្នកមានសំពត់រោមដ៏ទន់ល្មើយ ។*

*បានឮថា ចម្ការស្វាយនោះ ជាចម្ការរបស់សេដ្ឋីនោះ ។ គេបានស្ដាប់ព្រះធម៌ទេសនារបស់ព្រះមានព្រះភាគហើយ មានសេចក្ដីជ្រះថ្លាក្នុងព្រះមានព្រះភាគ បានកសាងវិហារដែលប្រដាប់ដោយកុដិ និងមណ្ឌបជាដើមក្នុងឧទ្យាននោះ បង្អោនថ្វាយព្រះមានព្រះភាគ វិហារនោះ បានដល់ ការរាប់ថា* ***បាវារិកម្ពវ័ន*** *ដូចជីវកម្ពវ័ន ដូច្នោះ ។ អធិប្បាយថា ព្រះមាន-ព្រះភាគ ប្រថាប់នៅត្រង់បាវារិកម្ពវ័ននោះ ។ ព្រះសារីបុត្រ បានក្រាប*

ទូលពាក្យនេះចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្ដីជ្រះថ្លាក្នុងព្រះមានព្រះភាគ យ៉ាងនេះ ។ សួរថា ព្រោះហេតុអ្វីព្រះថេរៈ ទើបទូលយ៉ាងនេះ ឆ្លើយថា ដើម្បីប្រកាសសេចក្ដីសោមនស្សដែលកើតដល់ខ្លួន ។

ក្នុងរឿងនេះ មានការពោលតាមលំដាប់ ដូចតទៅនេះ ។ ន័យថាក្នុងថ្ងៃនោះ ព្រះថេរៈជម្រះរាងកាយពីព្រឹកព្រលឹម ស្លៀកដណ្ដប់រៀបរយហើយ កាន់បាត្រ ចីវរ នាំសេចក្ដីជ្រះថ្លាមកឲ្យកើតដល់ពួកទេវតា និងមនុស្សដោយឥរិយាបថ មានការឈានទៅខាងមុខជាដើម ដែលគួរជ្រះថ្លា ប្រាថ្នាបំពេញប្រយោជន៍សុខដល់អ្នកក្រុងនាលន្ទា ទើបចូលទៅដើម្បីបិណ្ឌបាតក្នុងវេលាក្រោយភត្ត ក៏ត្រឡប់ពីបិណ្ឌបាតទៅវិហារវិញ ក៏សម្ដែងវត្តចំពោះព្រះសាស្ដា កាលព្រះសាស្ដាស្ដេចចូលព្រះគន្ធកុដិហើយ ថ្វាយបង្គំព្រះសាស្ដាត្រឡប់ទៅកាន់ទីសម្រាកពេលថ្ងៃរបស់ខ្លួន កាលសទ្ធិវិហារិក និងអន្តេវាសិកក្នុងទីនោះ នាំគ្នាសម្ដែងវត្តហើយចៀសទៅ ព្រះថេរៈបានបោសសម្អាតទីសម្រាកពេលថ្ងៃនោះ ហើយក្រាលបន្ទះស្បែក យកទឹកស្រលាបដៃ និងជើងឲ្យត្រជាក់ហើយ អង្គុយពែនភ្នែន ៣ ជាន់ ធ្វើការកំណត់វេលាហើយ

ទើបចូលផលសមាបត្តិ ។ លោកចេញចាកសមាបត្តិ តាមវេលាដែលបាន កំណត់ទុកហើយ ក៏ផ្តើមរឭកដល់គុណរបស់ខ្លួន ។ ពេលនោះ កាលលោក កំពុងរឭកដល់គុណ សីលក៏បានមកប្រាកដ តអំពីនោះ សមាធិ បញ្ញា វិមុត្តិ វិមុត្តិញ្ញាណទស្សនៈ បឋមជ្ឈាន ។ល។ ចតុត្ថជ្ឈាន អាកាសានញ្ចាយតនសមាបត្តិ ។ល។ នេវសញ្ញានាសញ្ញាយតនសមាបត្តិ ។ល។ វិបស្សនាញាណ ។ល។ ទិព្វចក្ខុញាណ ។ល។ សោតាបត្តិមគ្គ សោតាបត្តិផល ។ល។ អរហត្តមគ្គ អរហត្តផល អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា សាវកបារមីញាណ ក៏ប្រាកដ ឡើងតាមលំដាប់ ។ ចាប់ផ្តើមតាំងពីនោះ កាលលោកកំពុងរឭកគុណ របស់ខ្លួន ចាប់ផ្តើមតាំងពីអភិនីហារដែលបាន ( ធ្វើទុក ) ទៀបព្រះបាទមូល របស់ព្រះពុទ្ធទ្រង់ព្រះនាមថា **អនោមទស្សី** អស់អសង្ខេយ្យកំប្រែ សែនកប្ប ដរាបដល់វេលាដែលកំពុងអង្គុយពែនភ្នែន គុណទាំងឡាយ ក៏បានប្រាកដ ។ ព្រះថេរៈរឭកដល់គុណរបស់ខ្លួន ដ៏ច្រើនយ៉ាងនេះ ក៏មិន អាចប្រមាណ ឬកំណត់នូវគុណទាំងឡាយបានឡើយ ។

លោកគិតថា ប្រមាណ ឬកំណត់នូវគុណទាំងឡាយរបស់ព្រះសាវក

អ្នកតាំងនៅក្នុងញាណចំណែកខ្លះ រមែងមិនមានដល់យើង តែយើងប្តូសឧទ្ទិស ព្រះសាស្តាអង្គណា ព្រះសាស្តាព្រះអង្គនោះ មានព្រះគុណដូចម្តេចហ្ន៎ ដូច្នេះ ហើយ ទើបផ្តើមរឭកដល់ព្រះគុណរបស់ព្រះទសពល ។ លោកបានអាស្រ័យ សីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញ្ញាណទស្សនៈ សតិប្បដ្ឋាន ៤ របស់ ព្រះមានព្រះភាគ អាស្រ័យសម្មប្បធាន ៤ ឥទ្ធិបាទ ៤ មគ្គ ៤ ផល ៤ បដិសម្ភិទា ៤ យោនិបរិច្ឆេទកញ្ញាណ ៤ អរិយវង្ស ៤ របស់ព្រះទសពល ហើយផ្តើមរលឹកដល់ព្រះគុណរបស់ព្រះទសពល ។ មួយទៀត ព្រះថេរៈ អាស្រ័យអង្គរបស់បធាន ៥ សម្មាសមាធិមានអង្គ ៥ ឥន្ទ្រិយ ៥ ពលៈ ៥ និស្សរណីយធាតុ ៥ វិមុត្តាយតនៈ ៥ បញ្ញាគ្រឿងសន្សំវិមុត្តិ ៥ សារា-ណីយធម៌ ៦ អនុស្សតិកម្មដ្ឋាន ៦ គារវៈ ៦ និស្សរណីយធាតុ ៦ សត្ត-វិហារធម៌ ៦ អនុត្តរិយៈ ៦ បញ្ញាដែលជាចំណែកនៃការត្រាស់ដឹង ៦ អភិញ្ញា ៦ អសាធារណញ្ញាណ ៦ អបរិហានិយធម៌ ៧ អរិយទ្រព្យ ៧ ពោជ្ឈង្គ ៧ សប្បុរិសធម៌ ៧ និជ្ជរវត្ថុ ( រឿងរ៉ាវរបស់ទេវតា ) ៧ បញ្ញា ៧ ទក្ខិណេយ្យបុគ្គល ៧ ខីណាសវពលៈ ៧ បញ្ញាបដិលាភហេតុ ៨ សម្មត្តធម៌ ៨ ការឈានកន្លងលោកធម៌ ៨ អារព្ភវត្ថុ ៨ អក្ខណទេសនា

៨ មហាបុរិសវិតក្ក ៨ អភិភាយតនៈ ៨ វិមោក្ខ ៨ ធម៌ដែលជាមូលរបស់យោនិសោមនសិការ ៩ អង្គនៃសេចក្តីព្យាយាម ដ៏បរិសុទ្ធិ ៩ សត្តាវាសទេសនា ៩ អាឃាតបដិវិន័យ ៩ បញ្ញា ៩ នានត្តធម៌ ៩ អនុបុព្វវិហារ ៩ នាថករណធម៌ ១០ កសិណាយតនៈ ១០ កុសលកម្មបថ ១០ តថាគតពលៈ១០ សម្មត្តធម៌ ១០ អរិយវាសធម៌ ១០ អសេក្ខធម៌ ១០ អានិសង្សមេត្តា ១១ ធម្មចក្រមានអាការ ១២ ធុតង្គគុណ ១៣ ពុទ្ធញាណ ១៤ ធម៌គ្រឿងអប់រំវិមុត្តិ ១៥ អានាបានស្សតិ ១៦ ពុទ្ធធម៌ ១៨ បច្ចវេក្ខណញ្ញាណ ១៩ ញាណវត្ថុ ៤៤ កុសលធម៌ជាង ៥០ ញាណវត្ថុ ៧៧ សមាបត្តិ ២៤ សែនកោដិ សញ្ចារិតមហាវជិរញ្ញាណ ហើយ ផ្តើមរឭកដល់គុណរបស់ព្រះទសពល ។

ក៏ព្រះសារីបុត្រអង្គុយក្នុងទីសម្រាកពេលថ្ងៃនោះឯង អាស្រ័យធម៌ដែលជាក្រសែធម៌ដទៃទៀត ១៦ ប្រការ ដែលនឹងមានតទៅ ដោយព្រះបាលីថា អបរំ បន ភន្តេ ឯតទានុត្តរិយំ ទើបបានផ្តើមរឭកដល់ព្រះគុណរបស់ព្រះទសពល ។ ព្រះសារីបុត្រនោះរឭកដល់ព្រះគុណ របស់ព្រះទសពលយ៉ាងនេះថា ព្រះសាស្តារបស់យើង ទ្រង់ជាបុគ្គលកំពូលផ្តើម

ក្នុងកុសលប្បញ្ញត្តិ កំពូលឆ្នើមក្នុងអាយតនប្បញ្ញត្តិ កំពូលឆ្នើមក្នុងការឈានចុះកាន់ព្រះគភ៌ កំពូលឆ្នើមក្នុងវិធីសម្តែងធម៌ ស្គាល់ចិត្តអ្នកស្តាប់ កំពូលឆ្នើមក្នុងទស្សនសម្បត្តិ កំពូលឆ្នើមក្នុងបុគ្គលប្បញ្ញត្តិ កំពូលឆ្នើមក្នុងបធាន កំពូលឆ្នើមក្នុងបដិបទា កំពូលឆ្នើមក្នុងភស្សសមាចារ កំពូលឆ្នើមក្នុងបុរិសសីលសមាចារ ទ្រង់កំពូលឆ្នើមក្នុងអនុសាសនីវិធី កំពូលឆ្នើមក្នុងបរបុគ្គលវិមុត្តិញ្ញាណ កំពូលឆ្នើមក្នុងបុព្វេនិវាសញ្ញាណ កំពូលឆ្នើមក្នុងទិព្វចក្ខុញ្ញាណ កំពូលឆ្នើមក្នុងឥទ្ធិវិធី កំពូលឆ្នើមដោយធម៌នេះដូច្នេះ ក៏មិនឃើញទីបំផុត មិនឃើញប្រមាណនៃព្រះគុណទាំងឡាយរបស់ព្រះមានព្រះភាគបាន ។ ព្រះថេរៈមិនឃើញទីបំផុត មិនឃើញប្រមាណនៃគុណទាំងឡាយរបស់ខ្លួនមុន នឹងឃើញព្រះគុណទាំងឡាយរបស់ព្រះ-មានព្រះភាគបានយ៉ាងណា ។

ក៏អ្នកណាមានបញ្ញាច្រើន និងមានញាណចាស់ក្លា អ្នកនោះរមែងជឿពុទ្ធគុណយ៉ាងច្រើន ។ លោកិយមហាជន ក្សត្រិ កណ្តាស់ក្តី តាំងនៅក្នុងឧបនិស្ស័យរៀងៗ ខ្លួន រមែងរឭកដល់ព្រះគុណនៃព្រះពុទ្ធទាំងឡាយថា កិរិយានមស្ការ សូមមានចំពោះព្រះពុទ្ធទាំងឡាយ ។ ព្រះសោតាបន្ន

ម្នាក់ រមែងជឿព្រះពុទ្ធគុណច្រើនជាង លោកិយមហាជនទាំងអស់ ។ ព្រះសកទាគាមីម្នាក់ ជឿព្រះពុទ្ធគុណច្រើនជាង ព្រះសោតាបន្នទាំងរយ ទាំងពាន់ ។ ព្រះអនាគាមីម្នាក់ ជឿក្នុងព្រះពុទ្ធគុណច្រើនជាង ព្រះសកទាគាមីទាំងរយទាំងពាន់ ។ ព្រះអរហន្តតែមួយអង្គ ជឿព្រះពុទ្ធគុណច្រើនជាងព្រះអនាគាមីទាំងរយទាំងពាន់ ព្រះអសីតិមហាថេរៈ ជឿព្រះពុទ្ធគុណច្រើនជាងព្រះអរហន្តដ៏សេស ។ ព្រះមហាថេរៈ ៤ រូប ជឿព្រះពុទ្ធគុណច្រើនជាងព្រះអសីតិមហាថេរៈ ។ ព្រះអគ្គសាវកទាំងពីររូប ជឿព្រះពុទ្ធ-គុណច្រើនជាងព្រះមហាថេរៈទាំង ៤ រូប បណ្តាព្រះអគ្គសាវកទាំងពីរនោះ ព្រះសារីបុត្តត្ថេរ ជឿព្រះពុទ្ធគុណច្រើនជាងព្រះមោគ្គល្លាន ។ ព្រះបច្ចេកពុទ្ធតែមួយព្រះអង្គ ក៏ជឿព្រះពុទ្ធគុណច្រើនជាងព្រះសារីបុត្តត្ថេរ ក៏ប្រសិនបើព្រះបច្ចេកពុទ្ធទាំងឡាយ អង្គុយយកជាយសង្ឃាដីប៉ះនឹងជាយសង្ឃាដី ពេញកណ្តាប់ចក្រវាឡទាំងអស់ ហើយរឭកដល់ព្រះគុណរបស់ព្រះពុទ្ធ ព្រះសព្វញ្ញុពុទ្ធតែមួយព្រះអង្គប៉ុណ្ណោះ ជឿក្នុងព្រះពុទ្ធគុណច្រើនជាង ព្រះបច្ចេកពុទ្ធទាំងពួងនោះ ។

មហាជន វេញខ្សែទាំងឡាយ ដើម្បីត្រូវការដឹងថា មហាសមុទ្រ

ជ្រៅ-រាក់ប៉ុនណា ដូច្នេះ បណ្តាជនទាំងនោះ អ្នកខ្លះវេញបានមួយព្យាម អ្នកខ្លះវេញបាន ២ ព្យាម ។ល។ អ្នកខ្លះ ១០ ព្យាម អ្នកខ្លះ ២០ ព្យាម អ្នកខ្លះ ៣០ ព្យាម អ្នកខ្លះ ៤០ ព្យាម អ្នកខ្លះ ៥០ ព្យាម អ្នកខ្លះ ១០០ ព្យាម អ្នកខ្លះបាន ១០០០ ព្យាម អ្នកខ្លះបាន ៨៤,០០០ ព្យាម ជនទាំងនោះ នាំគ្នាចុះទូកហើយ តាំងនៅត្រង់កណ្តាល មហាសមុទ្រ ឬលើក្តីខ្ពស់ជាដើម ហើយទម្លាក់ខ្សែវៀងៗ ខ្លួនចុះទៅ បណ្តាជនទាំងនោះ អ្នកណាមានខ្សែប្រវែងមួយព្យាម គេក៏ដឹងជម្រៅទឹកបាន ក្នុងទីប្រមាណមួយព្យាមប៉ុណ្ណោះ ។ល។ អ្នកណាមានខ្សែប្រវែង ៨៤,០០០ ព្យាម អ្នកនោះរមែងដឹងទឹកបាន ក្នុងទីជម្រៅប្រមាណ ៨៤,០០០ ព្យាម ប៉ុណ្ណោះ តពីនោះទៅ រមែងមិនដឹងថា ទឹកក្នុងមហាសមុទ្រមានជម្រៅប៉ុនណា ដូច្នោះមួយទៀត ទឹកក្នុង មហាសមុទ្រ មិនមែនមានប្រមាណត្រឹមតែប៉ុណ្ណោះទេ សេចក្តីពិត រមែងមានច្រើនរកទីបំផុតប្រមាណមិនបាន ព្រោះមហាសមុទ្រមានជម្រៅដល់ ៨៤,០០០ យោជន៍ ប្រការនេះមានឧបមាយ៉ាងណា គប្បីជ្រាបព្រះពុទ្ធគុណ ដែលលោកិយមហាជនឃើញ ប្រៀបដូចទឹកដែលបុរសដឹងបានដោយខ្សែ គប្បីជ្រាបព្រះពុទ្ធគុណ មានឧបមេយ្យដូច្នោះ គឺ

តាំងពីមួយព្យាមដរាបដល់ ៩ ព្យាម គប្បីជ្រាបព្រះពុទ្ធគុណ ដែលលោកិយមហាជនឃើញ ប្រៀបដូចទឹក ដែលបុរសដឹងបានដោយខ្សែតាំងពីមួយព្យាមដរាបដល់ ៩ ព្យាម គប្បីជ្រាបព្រះពុទ្ធគុណ ដែលព្រះសោតាបន្នឃើញបាន ប្រៀបដូចទឹកដែលបុរសដឹងបានក្នុងទីប្រមាណ ១០ ព្យាម ដោយខ្សែប្រវែង ១០ ព្យាម គប្បីជ្រាបព្រះពុទ្ធគុណ ដែលព្រះសកទាគាមីឃើញបាន ប្រៀបដូចទឹកដែលបុរសដឹងបានក្នុងទីជម្រៅ ២០ ព្យាមដោយខ្សែប្រវែង ២០ ព្យាម គប្បីជ្រាបព្រះពុទ្ធគុណ ដែលព្រះអនាគាមីឃើញបាន ប្រៀបដូចទឹកដែលបុរសដឹងបានក្នុងទីជម្រៅ ៣០ ព្យាម ដោយខ្សែប្រវែង ៣០ ព្យាម គប្បីជ្រាបព្រះពុទ្ធគុណ ដែលព្រះអរហន្តឃើញបាន ប្រៀបដូចទឹកដែលបុរសឃើញបានក្នុងទីជម្រៅ ៤០ ព្យាម ដោយខ្សែប្រវែង ៤០ ព្យាម គប្បីជ្រាបព្រះពុទ្ធគុណ ដែលព្រះអសីតិមហាថេរៈឃើញបាន ប្រៀបដូចទឹក ដែលបុរសឃើញបានក្នុងទីជម្រៅ ៥០ ព្យាម ដោយខ្សែប្រវែង ៥០ ព្យាម គប្បីជ្រាបព្រះពុទ្ធគុណដែលព្រះមហាថេរៈ ៤ រូប ឃើញបាន ប្រៀបដូចទឹក ដែលបុរសឃើញបានក្នុងទីជម្រៅ ១០០ ព្យាម ដោយខ្សែប្រវែង ១០០ ព្យាម គប្បីជ្រាបព្រះពុទ្ធគុណ ដែលព្រះមហាមោគ្គល្លាន

ឃើញបាន ប្រៀបដូចទឹកដែលបុរសឃើញបានក្នុងទីជម្រៅ ១,០០០ ព្យាម ដោយ ខ្សែប្រវែង ១,០០០ ព្យាម គប្បីជ្រាបព្រះពុទ្ធគុណ ដែលព្រះធម្ម-សេនាបតីសារីបុត្រឃើញបាន ប្រៀបដូចទឹកដែលបុរសដឹងបានក្នុងទីជម្រៅ ប្រមាណ ៨៤,០០០ ព្យាម ដោយខ្សែប្រវែង ៨៤,០០០ ព្យាម ក្នុងបណ្ដាជនទាំងនោះ ជនណា កាន់យកថា ទឹកក្នុងមហាសមុទ្រមិនមានត្រឹមប៉ុណ្ណោះ រមែងរកទីបំផុត រកប្រមាណមិនបាន យ៉ាងណា ព្រះសារីបុត្រក៏ដូច្នោះដែរ តាំងនៅក្នុងសាវកបារមីញាណ រឭកដល់ព្រះគុណរបស់ព្រះទសពល ដោយគន្លងនៃធម៌ គឺ ដោយដឹងតាមគ្នាមក អនុមាន កាន់យកដោយន័យ ទើបជឿថា ព្រះពុទ្ធគុណមិនមានទីបំផុត មិនមានប្រមាណ ដូច្នេះ ។

សេចក្ដីពិត ចំពោះព្រះពុទ្ធគុណ ដែលបុគ្គលគប្បីកាន់យកដោយគន្លងធម៌ មានច្រើនជាងព្រះពុទ្ធគុណដែលព្រះថេរៈឃើញហើយ ។ លោកអធិប្បាយថា ដូចអ្វី ។ លោកអធិប្បាយទុកថា បុរសម្នាក់យកប្រហោងម្ជុល ជួសយកទឹកពីទន្លេឈ្មោះចន្ទ្រភាគា ដែលកំពុងហូរគួចស្ពានទីដល់ ១៨ យោជន៍ គឺ ខាងនេះ ៩ យោជន៍ ខាងនោះ ៩ យោជន៍ទៀត ទឹកដែលបុរសមិនបានជួសទៅ មានច្រើនជាងទឹកដែលបុរសជួសយកទៅ ឬ

ក៏បុរសគប្បីយកម្រាមដៃក្តិះយកធូលីពីផែនដីដ៏ធំ ធូលីដ៏សេសនោះឯង មានច្រើនជាងធូលី ដែលបុរសនោះយកម្រាមដៃក្តិះបានមក ឬក៏បុរសគប្បីយកចង្អុលដៃទៅជ្រលក់ក្នុងទឹកមហាសមុទ្រ ទឹកដ៏សេសនោះឯង មានច្រើនជាងទឹកជាប់នឹងចង្អុលដៃទៅ និងបុរសគប្បីចង្អុលទៅកាន់អាកាស ចំណែកអាកាសដ៏សេស មានច្រើនជាងអាកាសត្រង់ដែលបុរសចង្អុលនោះ ព្រះពុទ្ធគុណទាំងឡាយ ដែលព្រះថេរៈមិនឃើញនោះឯង គប្បីជ្រាបថាមានច្រើនជាង ព្រះពុទ្ធគុណដែលព្រះថេរៈបានឃើញហើយ ដូច្នោះ សមពិតដូចពាក្យដែលលោកពោលទុកថា ទោះបី ព្រះពុទ្ធមិនត្រាស់ពាក្យដទៃគប្បីពណ៌នាចំពោះព្រះពុទ្ធគុណរហូតដល់អស់កប្ប កប្បគប្បីអស់ទៅក្នុងកាលយូរអង្វែង តែគុណរបស់ព្រះតថាគតមិនអស់ទៅឡើយ ដូច្នេះ ។

កាលព្រះថេរៈរលឹកដល់គុណរបស់ខ្លួន និងព្រះគុណរបស់ព្រះសាស្តាយ៉ាងនេះ បីតិ និងសោមនស្សក៏ពោរពេញក្នុងខាងក្នុង ដូចអន្លង់ទឹកធំហូរលិចទន្លេធំពីរខ្សែ ញុំាងសរីរៈគ្រប់ចំណែកឲ្យពេញព្រៀប ដូចខ្យល់ធ្វើឲ្យថង់ខ្យល់ប៉ោងពេញ ( និង ) ដូចខ្សែទឹកដែលហូរបែក បាញ់ឡើងញុំាងអន្លង់ទឹកធំឲ្យពេញ ។ ដូច្នោះ លំដាប់នោះ ព្រះថេរៈគិតថា យើង

ដែលបានបួសក្នុងសម្នាក់របស់ព្រះសាស្ដាដូច្នេះ រាប់ថា បានតាំងសេចក្ដីប្រាថ្នាទុកល្អហើយ និងការបួសរបស់យើងបានល្អហើយ ។ បីតិ និងសោមនស្សដ៏មានកម្លាំងច្រើន បានកើតដល់ព្រះថេរៈដែលកំពុងគិតហើយយ៉ាងនេះ ។

ពេលនោះ ព្រះថេរៈគិតថា យើងគួរប្រាប់បីតិ និងសោមនស្សនេះ ដល់នរណាហ្ន៎ ដូច្នេះហើយ គិតទៀតថា សមណៈ ឬព្រាហ្មណ៍ ឬទេវតា ឬមារ ឬព្រហ្មខ្លះ មិនអាចនឹងទទួលយកសេចក្ដីជ្រះថ្លារបស់យើងនេះ ធ្វើឲ្យសមបាន យើងនឹងក្រាបទូលសេចក្ដីសោមនស្សនេះចំពោះព្រះសាស្ដាប៉ុណ្ណោះ ។

ព្រះសាស្ដាប៉ុណ្ណោះ ដែលនឹងអាចទទួលយកសេចក្ដីសោមនស្សរបស់យើងបាន បីតិសោមនស្សរបស់យើងនោះ សូមលើកទុកសិនចុះ កាលសមណៈដូចយើងមួយរយក្ដី មួយពាន់ក្ដី មួយសែនក្ដី ប្រកាសសេចក្ដីសោមនស្សហើយ ព្រះសាស្ដារបស់យើង នឹងគ្រប់គ្រងចិត្តជនទាំងពួងក៏ទ្រង់អាចនឹងទទួលបីតិសោមនស្សនោះបាន ដូចបឹង ឬជ្រលងភ្នំ មិនអាចនឹងទទួលទឹកទន្លេធំឈ្មោះចន្ទ្រភាគា ដែលកំពុងហូរជន់លិចទៅដល់

១៨ យោជន៍បាន មហាសមុទ្រប៉ុណ្ណោះ ដែលនឹងទទួលទឹកនោះបាន ទន្លេធំឈ្មោះចន្ទ្រភាគា សូមលើកទុកចុះ ទន្លេបែបនេះមួយរយក្តី មួយពាន់ក្តី មួយសែនក្តី មហាសមុទ្ររមែងទទួលបានទាំងអស់ ការខ្វះ ឬការពេញដោយទឹកនោះ របស់មហាសមុទ្រនោះ រកប្រាកដមិនបាន យ៉ាងណា ព្រះសាស្តារបស់យើងក៏ដូច្នោះដែរ កាលព្រះសមណៈដូចយើងមួយរយក្តី មួយពាន់ក្តី មួយសែនក្តី កំពុងប្រកាសបីតិសោមនស្ស ( ព្រះអង្គ ) ទ្រង់គ្រប់គ្រងចិត្តជនទាំងពួង អាចនឹងទទួលបាន សមណៈព្រាហ្មណ៍ដ៏សេស រមែងមិនអាចដើម្បីនឹងទទួលសោមនស្សរបស់យើងបាន ដូចបឹងនិងជ្រលងភ្នំ មិនអាចនឹងទទួលទឹកទន្លេធំ ឈ្មោះចន្ទ្រភាគាបាន ដូច្នោះ កុំដូច្នោះឡើយ យើងនឹងក្រាបទូលបីតិសោមនស្សរបស់យើង ដល់ព្រះសាស្តាប៉ុណ្ណោះ ដូច្នេះហើយ ទើបក្រោកឡើង រលាស់កម្រាលស្បែក កាន់ចូលទៅគាល់ព្រះសាស្តាក្នុងវេលាល្ងាច ដែលជាវេលាផ្កាឈើជ្រុះចាកទង កាលនឹងប្រកាសសោមនស្សរបស់ខ្លួន ទើបទូលថា ឯវំ បសន្នោ អហំ ភន្តេ ដូច្នេះ ជាដើម ។

បណ្តាបទទាំងនេះ បទថា ឯវំ បសន្នោ សេចក្តីថា មានការជឿ

កើតឡើងហើយយ៉ាងនេះ អធិប្បាយថា ខ្ញុំព្រះអង្គ ជឿយ៉ាងនេះ ។ បទថា ភិយ្យោភិញ្ញតរោ សេចក្ដីថា ដឹងក្រៃលែងជាង ឬអ្នកមានសេចក្ដីដឹងក្រៃលែងជាង ។ អធិប្បាយថា អ្នកមានញាណក្រៃលែងជាង ។ បទថា សម្ពោធិយំ សេចក្ដីថា ក្នុងសព្វញ្ញុតញ្ញាណ ឬក្នុងអរហត្តមគ្គញ្ញាណ ។ ព្រោះថា ព្រះពុទ្ធគុណទាំងឡាយ មិនមានចំណែកមួយផ្សេងដោយឡែក លោកកាន់យកដោយអរហត្តមគ្គនុ៎ះឯង ។ សេចក្ដីពិត ព្រះអគ្គសាវក ទាំងពីរ រមែងបានចំពោះសាវកបារមីញាណ ដោយអរហត្តមគ្គនុ៎ះឯង ។ ព្រះបច្ចេកពុទ្ធ រមែងបានបច្ចេកពោធិញ្ញាណ ព្រះពុទ្ធទាំងឡាយ រមែងបានទាំងព្រះសព្វញ្ញុតញ្ញាណ និងព្រះពុទ្ធគុណទាំងអស់ ។ សេចក្ដីពិត ព្រោះព្រះសព្វញ្ញុតញ្ញាណជាដើមនោះ រមែងសម្រេចដល់លោកទាំងនោះ ដោយអរហត្តមគ្គនោះឯង ។ ដូច្នោះ អរហត្តមគ្គញ្ញាណ ទើបឈ្មោះថា **សម្ពោធិ** ។ បុគ្គលដែលក្រៃលែងជាងព្រះមានព្រះភាគ ដោយអរហត្តមគ្គនោះមិនមានទេ ។ ដោយហេតុនោះ ព្រះសារីបុត្រ ទើបទូលថា ភគវតា ភិយ្យោភិញ្ញតរោ យទិទំ សម្ពោធិយំ ដូច្នេះ ។ បទថា ឧឡារា គឺ ប្រសើរ សេចក្ដីពិត ឧឡារ ស័ព្ទនេះ មកក្នុងអត្ថថា **ឆ្ងាញ់** ក្នុងប្រយោគជាដើម

ថា ៖

រមែងទំពាស៊ីរបស់ទំពាដ៏ឆ្ងាញ់ ។ មកក្នុងអត្ថថា **ប្រសើរ** ក្នុងប្រយោគថា ន័យថា លោកវច្ឆាយនៈ រមែងសរសើរព្រះសមណគោតមដោយពាក្យសរសើរដ៏ប្រសើរ ។ មកក្នុងអត្ថថា **រុពេចន៍** ក្នុងប្រយោគជាដើមថា រស្មីរុងរោចន៍ រកប្រមាណមិនបាន ដូច្នេះ ។ ក្នុងបាលីនេះ **ឧឡារ** ស័ព្ទនោះមកក្នុងអត្ថថា **ប្រសើរ** ។

ដោយហេតុនោះ លោកទើបពោលថា បទថា ឧឡារា ប្រែថាប្រសើរ ។

បទថា អាសភិ សេចក្ដីថា ជាវាចាមិនញាប់ញ័រ មិនរន្ធត់ ដូចជាវាចារបស់អ្នកអង់អាច ។ បទថា ឯកំសោ គហិតោ សេចក្ដីថា កាន់យកចំណែកតែមួយ ដូចរលឹកដឹងដោយញាណដោយប្រចក្ស មិនពោលព្រោះស្ដាប់តាមគ្នាមក ព្រោះជឿតាមអាចារ្យ ព្រោះជឿតាមការឮ ព្រោះអាងតម្រា ( ក្បួនច្បាប់ ) ព្រោះត្រិះរិះតាមអាការ ព្រោះត្រូវតាម ( ត្រូវហើយ ) ការឃើញរបស់ខ្លួន ព្រោះហេតុនៃការដៅយកខ្លួនឯង ឬព្រោះហេតុនៃការប៉ាន់ស្មាន ។ អធិប្បាយថា លោកកាន់យកសន្និដ្ឋានកថា តែ

ម្យ៉ាង ។ បទថា សីហនាទោ គឺ ការបន្លឺយ៉ាងប្រសើរ ។ អធិប្បាយថា បន្លឺសំឡេងខ្លាំង ដូចរាជសីហ៍ មិនមែនសំឡេងតិចៗ មិនមែនសំឡេងដូចស្អប់ ។

**[៧៤]** សួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគ ទើបទ្រង់ផ្ដើមទេសនាថា កិន្នុ តេ សារិបុត្ត ដូច្នេះ ។

ឆ្លើយថា ដើម្បីឲ្យលោកព្រមឲ្យសាកសួរបាន ព្រោះបុគ្គលខ្លះបន្លឺសីហនាទហើយ មិនអាចនឹងឆ្លើយពាក្យសាកសួរបាន ក្នុងការបន្លឺរបស់ខ្លួន ទាំងអត់ទ្រាំការបៀតបៀនមិនបាន រមែងដូចជាស្វាដែលជាប់ជ័រ ដូច្នោះ ។ ភ្លើងដែលឆេះសម្រាប់ជាងមាស ប្រើបញ្ចេះលោហៈដែលមិនបរិសុទ្ធ យ៉ាងណា បុគ្គលនោះ ក៏ដូចជាភ្លើងដែលឆេះ ដូច្នោះ ។ បុគ្គលបៀតបៀនខ្លះកាលត្រូវសួរនាំក្នុងសីហនាទ រមែងអាចនឹងឆ្លើយបាន ទាំងអត់ធន់ចំពោះការបៀតបៀនបាន រមែងប្រសើរក្រៃលែងដូចមាសសុទ្ធ ( បរិសុទ្ធិ ) របស់ជាងមាសដូច្នោះ ព្រះថេរៈក៏ដូច្នោះ ។ ដោយហេតុនោះ ព្រះមានព្រះភាគទ្រង់ជ្រាបព្រះថេរៈនោះថា សារីបុត្រនេះ គួរដល់ការសួរនាំបាន ទើបទ្រង់ផ្ដើមទេសនា ដើម្បីនឹងឲ្យលោកព្រម ឲ្យសួរនាំបានក្នុងការបន្លឺសីហនាទ ។

បណ្ដាបទទាំងនោះ បទថា សព្វេ តេ សេចក្ដីថា ព្រះពុទ្ធទាំងអស់នោះ ព្រះអង្គកំណត់ដឹងហើយ ។ ក្នុងពាក្យជាដើមថា ឯវំសីលា ដូច្នេះ ព្រះមានព្រះភាគ តែងត្រាស់សួរសីលជាដើម ដោយអំណាចសីល ទាំងដែលជាលោកិយៈ និងលោកុត្តរៈ ។

ពាក្យទាំងនោះ បានពោលពិស្ដារទុកហើយក្នុងមហាបទាន ។ ដោយពាក្យថា កឹ បន តេ សារីបុត្ត យេ តេ ភវិស្សន្តិ នេះ ព្រះមានព្រះភាគកាលនឹងត្រាស់សួរថា ក៏ព្រះពុទ្ធទាំងឡាយដែលមាន ក្នុងអតីតរលត់ទៅហើយ គឺ ដល់ភាពជាអ្នករកបញ្ញត្តិមិនបាន បានដល់ រលត់ទៅដូចអណ្ដាតប្រទីប ដូច្នោះ កាលព្រះពុទ្ធរលត់ទៅ គឺ ដល់ភាព ជាអ្នករកបញ្ញត្តិមិនបានយ៉ាងនេះ អ្នកនឹងដឹងបានយ៉ាងណា ក៏គុណរបស់ព្រះពុទ្ធក្នុងអនាគត អ្នកកំណត់ដឹងបានដោយចិត្តរបស់ខ្លួនយ៉ាងណា ដូច្នេះ ទើបត្រាស់យ៉ាងនេះ ។ ដោយពាក្យថា កឹ បន តេ សារីបុត្ត អហំ ឯតរហិ នេះ ព្រះមានព្រះភាគកាលនឹងទ្រង់ត្រាស់សួរថា ព្រះពុទ្ធទាំងឡាយ សូម្បីនៅមិនមក គឺ នៅមិនទាន់ប្រសូតិ នៅមិនទាន់កើត នៅមិនទាន់ឧប្បត្តិឡើង អ្នកនឹងដឹងព្រះពុទ្ធទាំងនោះបានយ៉ាងណា ព្រោះការដឹងដល់ព្រះពុទ្ធទាំងនោះ រមែងដូច

ជាការមើលស្នាមជើងក្នុងអាកាស ដែលមិនមានស្នាមជើងឡើយ ដូច្នោះ ។ ឥឡូវនេះ អ្នកនៅក្នុងវិហារជាមួយតថាគត ត្រាច់កិច្ចាចាររួមគ្នា ក្នុងវេលាសម្ដែងធម៌ អ្នកក៏អង្គុយនៅត្រង់ខាងស្ដាំ ( តថាគត ) ក៏គុណទាំងឡាយរបស់តថាគត អ្នកកំណត់ដឹងដោយចិត្តរបស់ខ្លួនហើយឬ ដូច្នេះហើយទើបត្រាស់សួរយ៉ាងនេះ ។ ក៏កាល ព្រះមានព្រះភាគត្រាស់សួរហើយ ព្រះថេរៈ ទើបក្រាបទូលបដិសេធថា ប្រការនោះមិនជាដូច្នោះទេ ព្រះអង្គដូច្នេះ ។

សួរថា ក៏រឿងដែលព្រះថេរៈដឹងក៏មានខ្លះ រឿងដែលព្រះថេរៈមិនដឹងក៏មានខ្លះ ព្រះថេរៈនោះ តែងធ្វើការជំទាស់ក្នុងទីដែលខ្លួនដឹង និងក្នុងទីដែលខ្លួនមិនដឹង យ៉ាងណា ។ ឆ្លើយថា ក្នុងរឿងដែលខ្លួនដឹង ព្រះថេរៈមិនបានជំទាស់ទេ ក្នុងរឿងដែលខ្លួនមិនដឹង ព្រះថេរៈទើបជំទាស់ ។ បានឮថា កាលផ្ដើមការសោកសួរនុ៎ះឯង ព្រះថេរៈបានដឹងថា នេះមិនមែនជាការសោកសួរក្នុងសាវកបារមីញាណ នេះជាការសួរក្នុងព្រះសព្វញ្ញុតញ្ញាណដូច្នេះ ។ ព្រះថេរៈ មិនធ្វើការជំទាស់ក្នុងសាវកបារមីញាណរបស់ខ្លួន រមែងធ្វើការជំទាស់ក្នុងព្រះសព្វញ្ញុតញ្ញាណ ក្នុងឋានៈដែលខ្លួនមិនដឹង ។

ដោយហេតុនេះ ព្រះសារីបុត្រ ទើបសម្តែងសេចក្តីនេះថា បពិត្រព្រះមាន-ព្រះភាគ ព្រះសព្វញ្ញុតញ្ញាណ ដែលអាចក្នុងការដឹងហេតុនៃសីល សមាធិ បញ្ញា និងវិមុត្តិ របស់ព្រះពុទ្ធទាំងឡាយ ក្នុងអតីត អនាគត និងបច្ចុប្បន្ន របស់ខ្ញុំព្រះអង្គ មិនមានទេ ដូច្នេះ ។ បទថា ឯត្ថ បានដល់ ក្នុងបណ្តា ព្រះពុទ្ធទាំងឡាយដែលផ្សេងគ្នា មានព្រះពុទ្ធក្នុងអតីតជាដើម ទាំងនោះ ។ ដោយបទថា អថ កិញ្ចរហិ ព្រះមានព្រះភាគត្រាស់ថា កាលញាណយ៉ាង នេះមិនមាន ដូច្នេះ ព្រោះហេតុអ្វីហ្ន៎ អ្នកទើបពោលពាក្យយ៉ាងនេះ ដូច្នេះ ។ បទថា ធម្មន្វយោ បានដល់ អនុមានញាណនៃធម៌ គឺ សេចក្តីដឹងដោយ ប្របក្សដល់ធម៌ដែលកើតឡើង ទន្ទឹមនឹងការសោកស្ងួរ គឺ ការកាន់យក ដោយន័យដែលខ្ញុំព្រះអង្គជ្រាបហើយ ។ ព្រោះតាំងនៅក្នុងសាវកបារមី-ញាណ ប៉ុណ្ណោះ ព្រះថេរៈទើបក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំ ព្រះអង្គជ្រាបដោយអាការនេះ ប៉ុណ្ណោះ ។ សេចក្តីពិត ការកាន់យកន័យ របស់ព្រះថេរៈរកប្រមាណមិនបាន និងរកទីបំផុតមិនបាន ។ ប្រមាណ ឬទី បំផុតនៃព្រះសព្វញ្ញុតញ្ញាណមិនមាន យ៉ាងណា ការកាន់យកន័យរបស់ ព្រះធម្មសេនាបតី ក៏មិនមានទីបំផុត ឬប្រមាណ ដូច្នោះ ។

ដោយហេតុនោះ ព្រះថេរៈរមែងដឹងថា ព្រះមានព្រះភាគ ទ្រង់ជាយ៉ាងនេះ ដោយវិថីនេះ ជាសាស្តាដ៏ធ្មេមដោយវិថីនេះ ។ ពិតណាស់ ការកាន់យកន័យរបស់ព្រះថេរៈ ក៏ប្រព្រឹត្តទៅតាមគន្លងនៃព្រះសព្វញ្ញុតញ្ញាណនោះឯង ។ ឥឡូវនេះ ព្រះថេរៈកាលនឹងសម្តែងសេចក្តីឧបមា ដើម្បីនឹងធ្វើការកាន់យកន័យនោះឲ្យប្រាកដច្បាស់ ទើបក្រាបទូលថា សេយ្យថាបិ ភន្តេ ដូច្នេះ ជាដើម ។

ក្នុងពាក្យថា សេយ្យថាបិ ភន្តេ នោះ មានវិនិច្ឆ័យថា ជើងកំពែងនិងកំពែងដ៏រឹងមាំជាដើម របស់ព្រះនគរក្នុងមជ្ឈិមប្រទេស នឹងជារបស់រឹងមាំក៏ដោយ មិនរឹងមាំក៏ដោយ ឬថា មិនមានដោយប្រការទាំងពួង ភាពរង្កៀសភ័យពីពួកចោរក៏មិនមាន ដូច្នោះ ព្រះថេរៈមិនកាន់យកមជ្ឈិមប្រទេសនោះ ទើបទូលថា បច្ចន្តិមំ ឆគរំ ដូច្នេះ ។ បទថា ឧឡ្ហាចាទ្ធាបំ បានដល់ មានជើងកំពែងរឹងមាំ ។

បទថា ឧឡ្ហាចាការតោរណំ គឺ មានកំពែងរឹងមាំ និងមានសសរខ្លោងទ្វារកំពែងរឹងមាំ ។ សួរថា ព្រោះហេតុអ្វី ព្រះថេរៈទើបពោលថា ឯកទ្វារំ ដូច្នេះ ។ ឆ្លើយថា ព្រោះក្នុងព្រះនគរ ដែលមានទ្វារច្រើន ត្រូវ

មានឆ្មាំទ្វារដែលឆ្លាតឈ្លាស ក្នុងព្រះនគរដែលមានទ្វារតែមួយ ក៏សមគួរឆ្មាំទ្វារត្រឹមតែម្នាក់ ។ មួយទៀត មិនមាននរណាជទែនឹងប្រៀបផ្ទឹមបញ្ញារបស់ព្រះថេរៈបាន ដូច្នោះ ដើម្បីនឹងសម្ដែងឆ្មាំទ្វារតែម្នាក់ប៉ុណ្ណោះ ដើម្បីប្រៀបធៀបភាពជាបណ្ឌិតរបស់ខ្លួន ព្រះថេរៈទើបពោលថា ឯកទ្វារំ ដូច្នេះ ។ បទថា បណ្ឌិតោ បានដល់ ប្រកប ដោយភាពជាបណ្ឌិត ។ បទថា ព្យត្តោ គឺ ប្រកបដោយសេចក្ដីវាងវៃ ឬជាអ្នកមានញាណចាស់ក្លា ។ បទថា មេធាវី គឺ ប្រកបដោយមេធា គឺ បញ្ញាដែលកើតឡើងតាមឋានៈ ។ បទថា អនុបរិយាយបថំ បានដល់ ផ្លូវកំពែង ដែលបាននាមថា អនុបរិយាយ ( វិលជុំវិញទៅមកបាន ) ។ បទថា ចាការសន្ធិំ បានដល់ ទីដែលមិនមានឥដ្ឋពីរជុំភ្ជាប់គ្នា ។ បទថា ចាការវិវរំ គឺ ស្នាមធ្លុះរបស់កំពែង ។

បទថា ចេតសោ ឧបក្កិលេសេ សេចក្ដីថា នីវរណៈទាំងប្រាំ រមែងញាំងចិត្តឲ្យសៅហ្មង គឺ រមែងធ្វើចិត្តឲ្យចូលទៅរកភាពសៅហ្មង ឲ្យក្ដៅក្រហាយ បានដល់ រមែងបៀតបៀនចិត្ត ដូច្នោះ នីវរណៈ ៥ នោះ លោកទើបហៅថា ភាពសៅហ្មងនៃចិត្ត ។

បទថា បញ្ញាយ ទុព្វលីករណេ សេចក្តីថា នីវរណៈទាំងឡាយ កាលកើតឡើង រមែងមិនឲ្យបញ្ញាដែលនៅមិនទាន់កើត ឲ្យកើតឡើងបាន ទាំងមិនព្រមឲ្យបញ្ញាដែលកើតឡើងហើយ ចម្រើនបាន ដូច្នោះ នីវរណៈទាំងនេះ លោកទើបហៅថា ជាគ្រឿងធ្វើបញ្ញាឲ្យខ្សោយកម្លាំង ។ បទថា សុបដ្ឋិតចិត្តា សេចក្តីថា ជាអ្នកមានចិត្តតាំងមាំទុកល្អ ក្នុងសតិប្បដ្ឋាន ៤ ។ បទថា សត្ត ពោជ្ឈង្គេ យថាភូតំ សេចក្តីថា ចម្រើនពោជ្ឈង្គៈទាំង ៧ តាមសភាព ។ ដោយបទថា អនុត្តរំ សម្មាសម្ពោធឹ ព្រះថេរៈសម្តែងថា ព្រះពុទ្ធទាំងឡាយ ទ្រង់ចាក់ធ្លុះព្រះអរហត្ត ឬព្រះសព្វញ្ញុតញ្ញាណ ។ ម្យ៉ាងទៀត ពាក្យថា សតិប្បដ្ឋានក្នុងទីនេះ បានដល់ វិបស្សនា , ពោជ្ឈង្គ បានដល់ មគ្គ , អនុត្តរសម្មាសម្ពោធិញ្ញាណ បានដល់ ព្រះអរហត្ត ។ ម្យ៉ាងទៀត ពាក្យថា សតិប្បដ្ឋាន បានដល់ វិបស្សនា , សម្មាសម្ពោធិញ្ញាណ ដែលលាយដោយពោជ្ឈង្គៈ បានដល់ ព្រះអរហត្តនោះឯង ។ ក៏ព្រះមហាសិវត្ថេរៈអ្នកពោលទីឃនិកាយ ពោលទុកថា កាលលោកកាន់យកសតិ-ប្បដ្ឋានថា ជាវិបស្សនា ហើយកាន់យកពោជ្ឈង្គៈថា ជាមគ្គ និងជាព្រះសព្វញ្ញុតញ្ញាណហើយ គប្បីមានបញ្ហាដែលល្អ តែប្រការនេះ លោក

មិនបានកាន់យកយ៉ាងនេះ ដូច្នេះ ។ ព្រះថេរៈ បានសម្ដែងសេចក្ដីផ្សេង គ្នាត្រង់កណ្ដាល ក្នុងការលះនីវរណៈ ក្នុងការចម្រើនសតិប្បដ្ឋាន និងក្នុង សម្ពោធិញ្ញាណរបស់ព្រះសព្វញ្ញុពុទ្ធទាំងឡាយ ដូចសម្ដែងមាស និងប្រាក់ ផ្សេងគ្នាដូច្នោះ ដោយប្រការដូច្នេះ ។ បណ្ឌិតតាំងនៅក្នុងទីនេះ គប្បី ប្រៀបធៀបឧបមា ។

សេចក្ដីពិត ព្រះសារីបុត្តត្ថេរ សម្ដែងបច្ចន្តនគរ ១ សម្ដែងកំពែង ១ ផ្លូវដើរជុំវិញកំពែង ១ សម្ដែងទ្វារ ១ សម្ដែងឆ្មាំទ្វារដ៏ឆ្លាត ១ សម្ដែង សត្វធំដែលចេញចូលក្នុងព្រះនគរ ១ សម្ដែងភាពប្រាកដនៃសត្វទាំងនោះ ដល់ឆ្មាំនោះ ១ ក្នុងសេចក្ដីឧបមានេះ បើមានពាក្យសួរថា អ្វីដូចគ្នានឹងអ្វី ដូច្នេះ ។ គប្បីឆ្លើយថា ក៏ព្រះនិព្វានដូចព្រះនគរ សីលដូចកំពែង ហិរិ ដូចផ្លូវដើរជុំវិញកំពែង អរិយមគ្គដូចទ្វារ ព្រះធម្មសេនាបតីដូចឆ្មាំទ្វារដ៏ ឆ្លាត ព្រះពុទ្ធទាំងឡាយ ដែលឧប្បត្តិឡើងក្នុងអតីត អនាគត និងបច្ចុប្បន្ន ដូចសត្វធំដែលចេញចូលក្នុងព្រះនគរ ភាពប្រាកដដោយសីល និងសមថៈ ជាដើម របស់ព្រះពុទ្ធទាំងឡាយ ទាំងក្នុងអតីត អនាគត និងបច្ចុប្បន្នដល់ ព្រះសារីបុត្រ ដូចគ្នានឹងភាពប្រាកដនៃសត្វទាំងឡាយនោះ ដល់ឆ្មាំទ្វារ

នោះឯង ។ ពាក្យមានប្រមាណប៉ុណ្ណេះ ជាពាក្យដែលព្រះថេរៈឆ្លើយតប ការសាកសួរនៃសីហនាទរបស់ខ្លួនថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ តាំងនៅក្នុងសាវកបារមីញាណយ៉ាងនេះ រមែងដឹងបានដោយអាការដែល ជាគន្លងឈម៌ ដោយការកាន់យកន័យ ដូច្នេះ ។

សួរថា ព្រោះហេតុអ្វី ព្រះថេរៈទើបផ្តើមធម៌ទេសនានេះថា ឥធាហំ ភន្តេ យេន ភគវា ដូច្នេះ ។ ឆ្លើយថា ដើម្បីសម្តែងភាពសម្រេចនៃសាវក បារមីញាណ ។ ក៏ក្នុងរឿងនេះ មានអធិប្បាយដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ កាលបានសាវកបារមីញាណ បានចូលទៅរកសមណៈ ឬព្រាហ្មណ៍ សូម្បីបុគ្គលខ្លះទៀត ក្នុងបណ្តាអ្នកបួសក្រៅសាសនាទាំង ៩៥ នាក់ហើយ នឹងបានសាវកបារមីញាណ ក៏រកមិនបាន ខ្ញុំព្រះអង្គ ចូលទៅរកព្រះអង្គ ប៉ុណ្ណោះ ចូលទៅអង្គុយជិតព្រះអង្គប៉ុណ្ណោះ ទើបបាន ។

ក្នុងបណ្តាបទទាំងនោះ ពាក្យថា ឥធ ត្រឹមតែជានិបាត ។ បទថា ឧបសង្កមឹ ធម្មស្សវនាយ សេចក្តីថា ម្យ៉ាងទៀត ខ្ញុំព្រះអង្គ កាលចូលទៅ គាល់ព្រះអង្គនោះ មិនបានចូលទៅគាល់ ព្រោះហេតុនៃបច្ច័យ មានចីវរ ជាដើម ប៉ុន្តែចូលទៅគាល់ដើម្បីស្តាប់ធម៌ ទៅគាល់យ៉ាងនេះហើយ ទើប

បានសាវកបារមីញាណ ។ សួរថា ព្រះថេរៈចូលទៅគាល់ដើម្បីស្តាប់ធម៌ក្នុងកាលណា ទើបបានសាវកបារមីញាណ ។ ឆ្លើយថា ព្រះថេរៈចូលទៅគាល់ក្នុងថ្ងៃដែលព្រះមានព្រះភាគទ្រង់សម្តែង **វេទនាបរិគ្គហសូត្រ** ដល់ទីឃនខបរិព្វាជក ជាក្មួយត្រង់ល្អាងសូករខាតា ទើបបានសាវកបារមីញាណក្នុងវេលានោះ ។ សេចក្តីពិត ក្នុងថ្ងៃនោះ ព្រះថេរៈកាន់ផ្លិតស្លឹកត្នោតបក់ថ្វាយព្រះមានព្រះភាគ បានស្តាប់ទេសនានោះហើយ បានញុំាងសាវកបារមីញាណឲ្យធ្លាក់នៅក្នុងកណ្តាប់ដៃក្នុងទីនោះឯង ។ បទថា ឧត្តរុត្តរំ បណីតបណីតំ សេចក្តីថា ព្រះអង្គទ្រង់សម្តែងយ៉ាងកំពូល និងយ៉ាងប្រណីតក្រៃលែងណាស់ ។ បទថា កណ្ហសុក្កំ សប្បដិភាគំ សេចក្តីថា ព្រះអង្គទ្រង់សម្តែងទាំងចំណែកខ្មៅ និងចំណែកស និងទ្រង់សម្តែងធម៌ចំណែកខ្មៅ និងចំណែកសនោះ ឲ្យជាបដិភាគចំពោះគ្នា គឺ ឲ្យជាបដិបក្ខចំពោះគ្នា ព្រះអង្គទ្រង់សម្តែងធម៌ចំណែកខ្មៅ និងចំណែកសឲ្យជាបដិភាគគ្នាយ៉ាងនេះ គឺ ទ្រង់ហាមធម៌ចំណែកខ្មៅ សម្តែងចំណែកស និងហាមចំណែកស សម្តែងចំណែកខ្មៅ ។ ម្យ៉ាងទៀត ព្រះអង្គកាលទ្រង់សម្តែងធម៌ចំណែកខ្មៅ ក៏ទ្រង់សម្តែងព្រមទាំងភាពឧសុព្រាហ៍ ព្រមគ្នានឹងវិបាក ។

កាលទ្រង់សម្តែងធម៌ចំណែកស ក៏ទ្រង់សម្តែងព្រមគ្នានឹងកាពឧស្សាហ៍ ព្រមគ្នានឹងវិបាក ។

ក្នុងប្រើនបទនេះថា តស្មឹំ ធម្មេ អភិញ្ញា ឥធេកច្ចំ ធម្មំ ធម្មេសុ និដ្ឋមគមំ សេចក្តីថា កាលព្រះអង្គទ្រង់សម្តែងធម៌នោះហើយ ខ្ញុំព្រះអង្គបានដឹងសាវកបារមីញាណ ដែលចាត់ជាធម៌ចំណែកខ្លះ បានដល់ ការសម្រេចក្នុងធម៌ទាំងឡាយ ។ សួរថា ក្នុងធម៌ពួកណា ។ ឆ្លើយថា ក្នុងសច្ចធម៌ ៤ ប្រការ ។ ក្នុងរឿងនេះ មានការសន្ទនារបស់ព្រះថេរៈដូចតទៅនេះ ៖

ព្រះសុមនត្ថេរៈអ្នកនៅក្នុងកាឡវល្លិវិហារ ពោលទុកមុនថា ឥឡូវនេះ មិនមានហេតុនៃការដល់សេចក្តីសម្រេចក្នុងសច្ចធម៌ ៤ ។ សេចក្តីពិត ក្នុងថ្ងៃដែលជួបព្រះអស្សជិមហាថេរៈនោះ ព្រះសារីបុត្រនោះ បានដល់នូវការសម្រេចក្នុងសច្ចធម៌ ៤ ដោយ មគ្គទី ១ ( សោតាបត្តិមគ្គ ) ក្នុងវេលាតមក បានដល់សេចក្តីសម្រេចក្នុងសច្ចធម៌ទាំង ៤ ដោយមគ្គ ៣ ខាងលើ ត្រង់ទ្វារល្អាងសូករខាតា តែក្នុងទីនេះ លោកបានដល់សេចក្តីសម្រេចក្នុងព្រះពុទ្ធគុណទាំងឡាយ ឈ្មោះថា សម្រេចក្នុងធម៌ទាំងឡាយ ។

ចំណែកព្រះចូឡសិវត្ថេរៈ អ្នកនៅក្នុងលោកន្តរវិហារ ពោលពាក្យទាំងអស់ដូចគ្នានោះឯង ហើយពោលទៀតថា ក៏ក្នុងទីនេះ ព្រះថេរៈ បានដល់សេចក្តីសម្រេចក្នុងព្រះអរហត្ត ឈ្មោះថា សម្រេចក្នុងធម៌ទាំងឡាយ ។ ចំណែកព្រះមហាសិវត្ថេរៈ អ្នកទ្រទ្រង់ព្រះត្រៃបិដក អ្នកពោលទីឃនិកាយ ពោលពាក្យខាងដើមដូចគ្នា ហើយពោលថា ក៏ក្នុងទីនេះ ព្រះថេរៈ បានដល់សេចក្តីសម្រេចក្នុងសាវកបារមីញាណ ឈ្មោះថា សម្រេចក្នុងធម៌ទាំងឡាយ ដូច្នេះហើយ ពោលទៀតថា ក៏ព្រះពុទ្ធគុណទាំងឡាយមកហើយដោយន័យ ដូច្នេះ ។

បទថា សត្ថរិ បសីទឹ សេចក្តីថា ខ្ញុំព្រះអង្គនោះ បានដល់សេចក្តីសម្រេចក្នុងធម៌ គឺ សាវកបារមីញាណយ៉ាងនេះហើយ មានសេចក្តីជ្រះថ្លាក្នុងព្រះសាស្តាដោយប្រមាណយ៉ាងក្រៃលែងថា ព្រះមានព្រះភាគនោះ ត្រាស់ដឹងដោយព្រះអង្គឯង ដោយប្រពៃហ្ន៎ ដូច្នេះ ។ បទថា ស្វាក្ខាតោ ភគវតា ធម្មោ គឺ មគ្គ ដែលជានិយ្យានិកធម៌ ដែលព្រះពុទ្ធត្រាស់ទុកល្អហើយ គឺ ទ្រង់ពោលទុកល្អហើយ រមែងនាំចេញទៅ ដើម្បីឲ្យសម្រេចអរិយផល អាចបន្ទោបង់ រាគៈ ទោសៈ និងមោហៈបាន ។ ពីរបទថា

សុបដិបន្នោ សង្ឃោ គឺ ព្រះថេរៈ រមែងសម្ដែងថា ខ្ញុំព្រះអង្គមានសេចក្ដីជ្រះថ្លាក្នុងព្រះមានព្រះភាគថា សូម្បីព្រះសង្ឃសាវ័ករបស់ព្រះមានព្រះភាគឈ្មោះថា បដិបត្តិល្អហើយ ព្រោះបដិបត្តិសម្មាបដិបទា ដែលវៀរចាកទោស មានសេចក្ដីវៀចវេរជាដើម ដូច្នេះ ។

## ពោធិបក្ខិយធម៌ញ៉ាំងបុគ្គលឱ្យស្គាល់អាយតនៈ

**[៧៥]** ឥឡូវនេះ ព្រះថេរៈអង្គុយក្នុងទីសម្រាកពេលថ្ងៃ ដើម្បីនឹងសម្ដែងធម៌ដែលជាប្រពៃណីប្រការដទៃទៀត ១៦ ប្រការ ដែលខ្លួនសម្រេចព្រមហើយ ទើបបានផ្ដើមទេសនានេះថា អបរំ បន ភន្តេ ឯតទានុត្តរិយំ ជាដើម ។

ក្នុងបណ្ដាពាក្យទាំងនោះ ភាពជាអ្នកកំពូល ឈ្មោះថា អនុត្តរិយ ។

ដោយពាក្យថា យថា ភគវា ធម្មំ ទេសេតិ នេះ ព្រះថេរៈរមែងទូលថា ព្រះមានព្រះភាគ ទ្រង់សម្ដែងធម៌ដោយប្រការណា គឺ ដោយអាការដូចម្ដី ដោយទេសនាយ៉ាងណា ទេសនារបស់ព្រះអង្គនោះ ចាត់ជាទេសនាដ៏កំពូល ។ ដោយពាក្យថា កុសលេសុ ធម្មេសុ ព្រះថេរៈ រមែង

សម្ដែងថា ព្រះមានព្រះភាគទ្រង់ជាអគ្គបុគ្គល សូម្បីក្នុងកុសលធម៌ទាំងឡាយ ដែលព្រះអង្គទ្រង់សម្ដែងហើយដោយទេសនានោះ ។

ម្យ៉ាងទៀត ព្រះថេរៈ សូម្បីកាលនឹងសម្ដែងភូមិរបស់ទេសនានោះ ទើបក្រាបទូលថា កុសលេសុ ធម្មេសុ ដូច្នេះ ។ បទ ថា តត្រិមេ កុសលា ធម្មា សេចក្ដីថា ក្នុងបទដែលពោលថា កុសលេសុ ធម្មេសុ នោះ គប្បីជ្រាបធម៌ដែលចាត់ជាកុសលធម៌ទាំងនេះ ។ ក្នុងពាក្យថា កុសលេសុ នោះ គប្បីយល់កុសលធម៌ដោយចំណែក ៥ គឺ ៖

ដោយអត្ថថា មិនមានរោគ ដោយអត្ថថា មិនមានទោស ដោយអត្ថថា ជាប្រភពកើតនៃភាពឈ្លាសវៃ ដោយអត្ថថា អស់សេចក្ដីខ្វល់ខ្វាយ និងដោយអត្ថថា មានសុខជាផល ។

ក្នុងអត្ថទាំងនោះ **កុសល** មានអត្ថថា មិនមានរោគ ព្រោះកាន់តាមគន្លងជាតក ។ **កុសល** មានអត្ថថា មិនមានទោស ព្រោះកាន់តាមគន្លងព្រះសូត្រ ។ **កុសល** មានអត្ថថា ជាប្រភពកើតនៃភាពឈ្លាសវៃ អស់សេចក្ដីខ្វល់ខ្វាយ និងមានសុខជាផល ព្រោះកាន់តាមគន្លងព្រះអភិធម្ម ។

តែក្នុងទីនេះគប្បីឃើញថា **កុសល** ដោយអត្ថថា មិនមានទោស តាមគន្លងនៃ **ពាហិតិយសូត្រ** ។

បទថា ចត្តារោ សតិប្បដ្ឋានា សេចក្តីថា ព្រះមានព្រះភាគ ទ្រង់ ចែកចេញដោយន័យផ្សេងៗ ហើយទ្រង់សម្តែងសតិប្បដ្ឋាន ៤ ប្រការ ដែលលាយឡំគ្នា ទាំងចំណែកលោកិយៈ និងលោកុត្តរៈ ដោយអំណាច នៃសមថៈ វិបស្សនា និងមគ្គយ៉ាងនេះថា កាយានុបស្សនាសតិប្បដ្ឋាន ដោយ ១៤ វិធី វេទនានុបស្សនាសតិប្បដ្ឋាន ៩ វិធី ចិត្តានុបស្សនា-សតិប្បដ្ឋាន ១៦ វិធី ធម្មានុបស្សនាសតិប្បដ្ឋាន ៥ វិធី ។ តែក្នុងទីនេះ មិនប្រាថ្នាយកសតិប្បដ្ឋានដែលជាចំណែកផល ។

បទថា ចត្តារោ សម្មប្បធានា សេចក្តីថា ព្រះមានព្រះភាគ ទ្រង់ សម្តែងសម្មប្បធានទុក ៤ ប្រការ ដែលមានលក្ខណៈតែម្យ៉ាង ដោយអត្ថ ថា ជាគ្រឿងផ្គងចិត្ត ផ្សេងគ្នាដោយអំណាចកិច្ច ដែលលាយឡំគ្នាទាំង ផ្នែកលោកិយៈ និងផ្នែកលោកុត្តរៈ ដោយអំណាចនៃសមថៈ វិបស្សនា និងមគ្គ ដោយន័យជាដើមថា ភិក្ខុក្នុងសាសនានេះ រមែងប្រារព្ធសេចក្តី ព្យាយាម ដើម្បីការមិនកើតនៃបាបអកុសលធម៌ ដែលមិនទាន់កើតឡើង ។

បទថា ចត្តារោ ឥទ្ធិបាទា សេចក្តីថា ព្រះមានព្រះភាគ ទ្រង់សម្តែងឥទ្ធិបាទ ៤ ជាពួកមួយ ដោយអត្ថថា ជាគ្រឿងសម្រេចមានសភាពផ្សេងគ្នា ដោយអំណាចសភាពមានការពេញចិត្តជាដើម ដែលលាយគ្នាទាំងផ្នែកលោកិយៈ និងផ្នែកលោកុត្តរៈ ដោយអំណាចនៃសមថៈ វិបស្សនា និងមគ្គ ដោយន័យជាដើមថា ភិក្ខុក្នុងសាសនានេះ រមែងចម្រើនឥទ្ធិបាទដែលប្រកបដោយសេចក្តីពេញចិត្ត សេចក្តីតាំងចិត្តមាំ សេចក្តីព្យាយាម និងការតាក់តែង ដូច្នេះ ។

បទថា បញ្ចិន្ទ្រិយានិ សេចក្តីថា ព្រះមានព្រះភាគ ទ្រង់សម្តែងឥន្ទ្រិយ ៥ មានសទ្ធិន្ទ្រិយជាដើម ដែលមានលក្ខណៈតែម្យ៉ាង ដោយអត្ថថា ជាធំ មានសភាពផ្សេងគ្នា ដោយអំណាចសភាពបង្អោនចិត្តជឿជាអាទិ៍ ដែលលាយគ្នាទាំងផ្នែកលោកិយៈ និងផ្នែកលោកុត្តរៈ ដោយអំណាចនៃសមថៈ វិបស្សនា និងមគ្គ ។

បទថា បញ្ច ពលានិ សេចក្តីថា ព្រះមានព្រះភាគ ទ្រង់សម្តែងពលៈទុក ៥ ប្រការ មានសទ្ធាជាដើម ជាមួយពួក ដោយអត្ថថា ជាគ្រឿងឧបត្ថម្ភ ឬដោយអត្ថថា មិនញាប់ញ័រ មានសភាពផ្សេងគ្នាតាមលក្ខណៈរបស់

ខ្លួន ដែលលាយគ្នាទាំងផ្នែកលោកិយៈ និងផ្នែកលោកុត្តរៈ ដោយអំណាចនៃសមថៈ វិបស្សនា និងមគ្គ ។

បទថា សត្ត ពោជ្ឈង្គា សេចក្ដីថា ព្រះមានព្រះភាគ ទ្រង់សម្ដែងពោជ្ឈង្គៈទុក ៧ ប្រការ ជាមួយពួក ដោយអត្ថថា ជាគ្រឿងនាំចេញមានសភាពផ្សេងគ្នាតាមលក្ខណៈរបស់ខ្លួន មានការប្រាកដជាដើម ដែលលាយគ្នាទាំងផ្នែកលោកិយៈ និងផ្នែកលោកុត្តរៈ ដោយអំណាចនៃសមថៈ វិបស្សនា និងមគ្គនោះឯង ។

បទថា អរិយោ អដ្ឋង្គិកោ មគ្គោ សេចក្ដីថា ព្រះមានព្រះភាគទ្រង់សម្ដែងមគ្គដែលប្រកបដោយអង្គ ៨ ដ៏ប្រសើរ ជាមួយពួក ដោយអត្ថថា ជាតួហេតុ និងមានសភាពផ្សេងៗ គ្នា តាមលក្ខណៈរបស់ខ្លួន មានការឃើញជាដើម លាយគ្នាទាំងផ្នែកលោកិយៈ និងផ្នែកលោកុត្តរៈ ដោយអំណាចនៃសមថៈ វិបស្សនា និងមគ្គនោះឯង ។

សួរថា ព្រោះហេតុអ្វី ព្រះថេរៈទើបផ្ដើមពាក្យនេះថា ឥធ ភន្តេ ភិក្ខុ អាសវានំ ខយា ដូច្នេះ ។ ឆ្លើយថា ដើម្បីសម្ដែងទីបំផុតនៃ ព្រះសាសនា សេចក្ដីពិត ទីបំផុតនៃព្រះសាសនាមិនមានដោយមគ្គតែម្យ៉ាង

ប៉ុណ្ណោះទេ រមែងមានសូម្បីដោយព្រះអរហត្តផល ដូច្នោះ គប្បីជ្រាបថា ព្រះថេរៈផ្តើមពាក្យនេះ ក៏ដើម្បីនឹងសម្តែងទីបំផុតនៃព្រះសាសនានោះ ។

ប្រើនបទថា ឯតទានុត្តរិយំ ភន្តេ កុសលេសុ ធម្មេសុ សេចក្តីថា បពិត្រព្រះអង្គដ៏ចម្រើន ការសម្តែងយ៉ាងនេះ ចាត់ជាធម៌ដ៏ប្រសើរ ក្នុងផ្នែកកុសលធម៌ទាំងឡាយ ។ បទថា តំ ភគវា គឺ ព្រះមានព្រះភាគ ទ្រង់រមែងជ្រាបច្បាស់ទេសនានោះទាំងអស់ មិនមាននៅសល់ ។ បទថា តំ ភគវតោ សេចក្តីថា កាលព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់ទេសនានោះដោយមិនសេសសល់ ។ បទថា ឧត្តរិ អភិញ្ញេយ្យំ នត្ថិ សេចក្តីថា ធម៌ដែលនឹងគប្បីដឹងក្រៃលែងឡើងជាងនេះ មិនមានទេ គឺ ពាក្យនេះថា ធម៌ ឬបុគ្គល ដែលព្រះមានព្រះភាគ ទ្រង់មិនជ្រាបក្រៅពីនេះ ឈ្មោះថា រមែងមិនមាន ។ បទថា យទភិជានំ អញ្ញោ សមណោ វា សេចក្តីថា សមណៈ ឬព្រាហ្មណ៍ដទៃ ដឹងធម៌ដែលព្រះអង្គ ទ្រង់មិនដឹង គប្បីជាអ្នកមានសេចក្តីដឹងក្រៃលែងជាង គឺ មានបញ្ញាក្រៃលែងជាងព្រះមានព្រះភាគ ។ ពាក្យថា យទិទំ ក្នុងបទថា យទិទំ កុសលេសុធម្មេសុ នេះ ត្រឹមតែជានិបាត ។ ក្នុងសេចក្តីនេះ មានពាក្យអធិប្បាយដូច្នេះថា សមណៈ ឬព្រាហ្មណ៍ដែល

ក្រៃលែងជាងព្រះមានព្រះភាគ ក្នុងចំណែកកុសលធម៌ រមែងមិនមាន ។ ព្រះសារីបុត្រ កាលនឹងសម្ដែងថា ព្រះមានព្រះភាគប៉ុណ្ណោះ ទ្រង់ជាអគ្គបុគ្គលក្នុងកុសលធម៌ទាំងឡាយ ដោយប្រការដូច្នេះហើយ រមែងសម្ដែងថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ មានសេចក្ដីជ្រះថ្លាក្នុងព្រះមាន-ព្រះភាគយ៉ាងនេះ ដោយហេតុនេះ ដូច្នេះ ។

[៧៦] ក្នុងពាក្យថា អបរំ បន ជាដើម ក្រៅពីនេះ ខ្ញុំនឹងពណ៌នាត្រឹមតែសេចក្ដីដែលផ្សេងគ្នាប៉ុណ្ណោះ ។ ចំណែកពាក្យដែលដូចគ្នានឹងវារៈខាងដើម គប្បីជ្រាបតាមន័យដែលពោលហើយនោះចុះ ។

បទថា អាយតនបណ្ណត្តីសុ គឺ ក្នុងការបញ្ញត្តិអាយតនៈ ។ ឥឡូវនេះ កាលនឹងសម្ដែងអាយតនបញ្ញត្តិទាំងឡាយនោះ ព្រះសារីបុត្តត្ថេរទើបទូលថា ឆយិមានិ ភន្តេ ដូច្នេះជាដើម ។ ក៏កថាពោលដោយអាយតនៈនេះ លោកពោលទុកយ៉ាងពិស្ដារក្នុងបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គ ។ ដូច្នោះ ខ្ញុំនឹងមិនពណ៌នាអាយតនៈនោះឲ្យពិស្ដារ ។ ព្រោះដូច្នោះ គប្បីជ្រាបអាយតនកថានោះយ៉ាងពិស្ដារ ដោយន័យបានពោលទុកហើយ ក្នុងវិសុទ្ធិមគ្គនោះចុះ ។ បទថា ឯតទានុត្តរិយំ ភន្តេ អាយតនបណ្ណត្តីសុ

គឺ ការសម្តែងយ៉ាងនេះ ដោយអំណាចការកំណត់ជាអាយតនៈខាងក្នុង និងខាងក្រៅជាដើមនេះ ចាត់ជាធម៌ដ៏ឧត្តមក្នុងអាយតនបញ្ញត្តិនេះ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

**[៧៧]** បទថា គព្ភាវក្កន្តីសុ គឺ ក្នុងការឈានចុះកាន់គភ៌ ។ ព្រះសារីបុត្តត្ថេរ កាលនឹងសម្តែងការឈានចុះកាន់គភ៌ទាំងនោះ ទើបក្រាបទូលថា ចតស្សោ ឥមា ភន្តេ ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា អសម្បជានោ គឺ មិនដឹង បានដល់វង្វេងព្រម ។ បទថា មាតុ កុច្ឆឹ ឱក្កមតិ គឺ រមែងចូលទៅកាន់គភ៌ដោយអំណាចបដិសន្ធិ ។ បទថា ឋាតិ ប្រែថា រមែងនៅ ។ បទថា និក្ខមតិ គឺ សូម្បីកាលប្រសូតក៏មិនដឹង គឺ វង្វេងព្រមចេញទៅ (ចាកគភ៌) ។ បទថា អយំ បឋមា ១ គឺ នេះចាត់ជាការឈានចុះកាន់គភ៌របស់ពួកមនុស្សលោក តាមប្រក្រតីប្រការទី ១ ។

បទថា សម្បជានោ ហិ ខោ គឺ សត្វកាលនឹងឈានចុះ ក៏ជាអ្នកដឹង មិនវង្វេងក្នុងការឈានចុះកាន់គភ៌ ។ បទថា អយំ ទុតិយា គឺ នេះចាត់ជាការឈានចុះកាន់គភ៌ប្រការទី ២ របស់អសីតិមហាសាវកទាំងឡាយ ។

សេចក្ដីពិត ព្រះមហាសាវកទាំងនោះ កាលនឹងចូលទៅកាន់គភ៌ប៉ុណ្ណោះ រមែងដឹង កាលតាំងនៅ និងកាលប្រសូត រមែងមិនដឹង ។

បទថា អយំ តតិយា សេចក្ដីថា នេះចាត់ជាការឈានចុះកាន់គភ៌ ប្រការទី ៣ នៃព្រះអគ្គសាវកទាំងពីរ និងនៃព្រះបច្ចេកពោធិសត្វទាំងឡាយ ។ ន័យថា លោកទាំងនោះ ត្រូវខ្យល់កម្មជវាតបក់ឲ្យត្រឡប់សីសៈចុះទៅខាងក្រោម ឲ្យជើងឡើងលើ មកនៅត្រង់មាត់ទ្វារប្រសូត ដូចនៅក្នុងជ្រោះដ៏ជ្រៅច្រើនរយជួរបុរស ចេញចាកទ្វារប្រសូតដ៏ចង្អៀត ក៏រមែងជួបទុក្ខដ៏ច្រើន ប្រៀបដូចដំរីដែលចេញចាករន្ធដើមត្នោត រមែងប្រសព្វសេចក្ដីទុក្ខ ដូច្នោះ ។ ដោយហេតុនោះ សត្វទាំងនោះរមែងមិនមានសេចក្ដីដឹងថា យើងប្រសូត្រហើយ ដូច្នេះ ។ សេចក្ដីទុក្ខយ៉ាងខ្លាំងក្លា ក្នុងឋានៈបែបនេះ រមែងកើតឡើងដល់ពួកសត្វ សូម្បីអ្នកបំពេញបារមីមកហើយ ពិតយ៉ាងនេះ ដូច្នោះ គួរនឹងនឿយណាយ គួរនឹងលះបង់តម្រេក ក្នុងការនៅក្នុងគភ៌ ។

បទថា អយំ ចតុត្ថា គឺ នេះជាការឈានចុះកាន់គភ៌ប្រការទី ៤ ដោយអំណាចនៃព្រះសព្វញ្ញូពោធិសត្វទាំងឡាយ ។ ពិតហើយ ព្រះសព្វញ្ញូ-ពោធិសត្វទាំងឡាយ សូម្បីកាលចុះកាន់បដិសន្ធិក្នុងគភ៌របស់មាតា រមែង

ដឹងទាំងកាលតាំងនៅក្នុងគភ៌ ។ ក្នុងវេលាប្រសូតចាកព្រះគភ៌ ខ្យល់កម្មជវាតទាំងឡាយ រមែងមិនអាចនឹងបក់នាំ ឲ្យព្រះសព្វញ្ញូពោធិសត្វទាំងនោះឲ្យត្រឡប់ជើងទៅខាងលើ និងសីសៈមកខាងក្រោមបាន ។ ព្រះសព្វញ្ញូពោធិសត្វទាំងនោះ សណ្ដូកព្រះហស្ដទាំងពីរ ហើយបើកព្រះនេត្រ ប្រថាប់ឈរ ស្ដេចប្រសូតចេញមក ។ វៀរតែព្រះសព្វញ្ញូពោធិសត្វចេញ សត្វដទៃក្នុងចន្លោះអវិចី ដរាបដល់ភវគ្គព្រហ្ម ដែលឈ្មោះថា ដឹងក្នុងពេលទាំងបី រមែងមិនមានឡើយ ។ ដោយហេតុនោះនោះឯង ក្នុងវេលាដែលព្រះសព្វញ្ញូពោធិសត្វទាំងឡាយនោះ ឈានចុះកាន់ព្រះគភ៌មាតា និងក្នុងវេលាប្រសូត ម៉ឺនលោកធាតុ ទើបបានញាប់ញ័រ ។ ពាក្យដ៏សេសក្នុងរឿងឈានចុះកាន់គភ៌នេះ គប្បីជ្រាប តាមន័យដែលពោលហើយនោះចុះ ។

## អាទេសនាវិធី

**[៧៨]** បទថា អាទេសនវិធាសុ គឺ ក្នុងចំណែកនៃការសម្ដែងធម៌ ។ ឥឡូវនេះ ព្រះសារីបុត្រ កាលនឹងសម្ដែងវិធីការសម្ដែងធម៌ទាក់ចិត្តមនុស្សទាំងនោះ ទើបក្រាបទូលថា ចតស្សោ ឥមា ដូច្នេះជាដើម ។ ដោយ

ពាក្យថា និមិត្តេន អាទិសតិ នេះ ព្រះសារីបុត្ររម៉ែងសម្តែងថា ឈ្មោះថា ការសម្តែងធម៌ទាក់ចិត្តមនុស្សនេះនឹងមាន ដោយអនាគតនិមិត្តខ្លះ ដោយ គតិនិមិត្តខ្លះ ដោយឋិតិនិមិត្តខ្លះ ។

ក្នុងសេចក្តីនោះ មានរឿងនេះជាឧទាហរណ៍ ។ ព្រះរាជាមួយអង្គ ទ្រង់កាន់យកកែវមុក្តា ៣ ដួង ហើយត្រាស់សួរបុរោហិតថា អាចារ្យ អ្វីនៅក្នុងដៃរបស់យើងនេះ ។ បុរោហិតនោះ ទើបសម្លឹងមើលទៅខាង នោះ និងខាងនេះ ។ ក៏ដោយសម័យនោះ សត្វតុកកែមួយរត់ចេញទៅ ដោយបំណងថា " យើងនឹងចាប់រុយស៊ី " ដូច្នេះ ។ ក្នុងវេលាដែលនឹង ចាប់ សត្វរុយហើរចៀសចេញទៅ ។ បុរោហិតនោះទូលថា បពិត្រមហារាជ កែវមុក្តា ! ព្រះអង្គ ដូច្នេះ ព្រោះហេតុរុយហើរចៀសចេញផុតទៅបាន ។ ព្រះរាជា ទើបត្រាស់សួរទៀតថា កែវមុក្តាចូរលើកទុកចុះ ( តែ ) កែវមុក្តា មានប៉ុន្មានដួង ។ បុរោហិតនោះ ទើបសម្លឹងមើលនិមិត្តនោះទៀត ។ លំដាប់នោះ មាន់រងាវឡើង ៣ ដង ក្នុងទីមិនឆ្ងាយ ។ ព្រាហ្មណ៍ ទើប ក្រាបទូលថា ៣ ដួង ព្រះអង្គ ដូច្នេះ ។ អ្នកខ្លះ រម៉ែងនិយាយដោយ និមិត្តដែលមកប្រាកដ យ៉ាងនេះ ។ គប្បីជ្រាបការពោលសួម្បីដោយគតិនិមិត្ត

និងឋិតិនិមិត្ត ដោយឧបាយនោះ ។

បទថា អមនុស្សានំ គឺ ពួកយក្ខ និងបិសាចជាដើម ។ បទថា ទេវតានំ គឺ ពួកទេវតាអ្នកតាំងនៅក្នុងជាន់ចាតុម្មហារាជ ជាដើម ។

បទថា សទ្ទំ សុត្វា សេចក្ដីថា ឮសំឡេងរបស់ពួកទេវតា និងអមនុស្ស អ្នកដែលដឹងចិត្តរបស់អ្នកដទៃហើយពោល ។

បទថា វិតក្កវិប្ផារសទ្ទំ បានដល់ សំឡេងរបស់ពួកជនអ្នកដេកលក់ និងប្រមាទហើយជាដើម អ្នករវើរវាយ ដែលកើតឡើងមកដោយការផ្សាយជ្រួតជ្រាបទៅនៃវិតក្កៈ ។ បទថា សុត្វា គឺ បានឮសំឡេងនោះ ។ សំឡេងនោះ កើតឡើងដល់បុគ្គលនោះអ្នកត្រិះរិះរឿងណា គេរមែងដាក់ចិត្តបានថា ចិត្តរបស់លោកជាយ៉ាងនេះ ដោយអំណាចនៃការត្រិះរិះនោះ ។

បទថា មនោសង្ខារា បណិហិតា គឺ ចិត្តសង្ខារតាំងមាំដោយល្អហើយ ។ បទថា វិតក្កេស្សតិ គឺ គេរមែងដឹងថា អ្នកនេះនឹងត្រិះរិះ គឺ នឹងឲ្យ (ចិត្តសង្ខារ) ប្រព្រឹត្តទៅ ។ មួយទៀត គេកាលដឹង រមែងដឹងដោយការមករបស់និមិត្ត រមែងដឹងដោយនិមិត្ត ដែលជាចំណែកខាងដើម ពិចារណាមើលចិត្តក្នុងខាងក្នុងសមាបត្តិ រមែងដឹងបាន ។ បុគ្គល

រមែងដឹងថា ក្នុងវេលាបរិកម្មកសិណនោះឯង បុគ្គលនេះ ផ្តើមការនា កសិណ ដោយអាការណា នឹងញុំាងបឋមជ្ឈាន ។ល។ ឬចតុត្ថជ្ឈាន ឬសមាបត្តិ ៨ ឲ្យកើតបាន បុគ្គលនេះឈ្មោះថា រមែងដឹង ដោយការមក ប្រាកដរបស់និមិត្ត ។ បុគ្គលខ្លះ រមែងដឹងកាលផ្តើមបំពេញសមថៈ វិបស្សនា គឺ ដឹងថា បុគ្គលនេះ ផ្តើមបំពេញវិបស្សនា ដោយអាការណា នឹងញុំាង សោតាបត្តិមគ្គឲ្យកើត ។ល។ ឬញុំាងអរហត្តមគ្គឲ្យកើត អ្នកនេះឈ្មោះ ថា រមែងដឹងបានដោយនិមិត្តដែលជាចំណែកខាងដើម ។ បុគ្គលខ្លះ រមែង ដឹងថា មនោសង្ខាររបស់បុគ្គលនេះតាំងមាំដោយល្អ ដោយអាការណា គេ នឹងត្រិះរិះដល់វិតក្កៈឈ្មោះនេះ ជាលំដាប់នៃចិត្តឈ្មោះនេះ កាលបុគ្គល នោះចេញចាកវិតក្កៈនេះ សមាធិដែលជាចំណែកវិនាស ឬជាចំណែកតាំង នៅ ឬជាចំណែកនៃភាពវិសេសឡើង ឬជាចំណែកទម្លាយកិលេសនឹងមាន ឬនឹងញុំាងអភិញ្ញាឲ្យកើតឡើង បុគ្គលនេះឈ្មោះថា ពិចារណាមើលចិត្ត ក្នុងខាងក្នុងសមាបត្តិហើយ ទើបដឹងបាន ។ ក្នុងបណ្តាជនទាំងនោះ បុថុជ្ជន អ្នកបានចេតោបរិយញ្ញាណ រមែងដឹងចិត្តរបស់បុថុជ្ជនប៉ុណ្ណោះ មិនដឹង ចិត្តរបស់ព្រះអរិយៈទាំងឡាយ ។ សូម្បីក្នុងព្រះអរិយៈទាំងឡាយ ព្រះ

អរិយបុគ្គល ដែលតាំងនៅក្នុងមគ្គខាងក្រោម រមែងមិនដឹងចិត្តរបស់ព្រះអរិយបុគ្គលដែលតាំងនៅក្នុងមគ្គខាងលើបាន ។ ចំណែកព្រះអរិយបុគ្គលដែលតាំងនៅក្នុងមគ្គខាងលើ រមែងដឹងចិត្តរបស់ព្រះអរិយបុគ្គល ដែលតាំងនៅក្នុងមគ្គខាងក្រោមបាន ។ ក៏ក្នុងបណ្តាលោកទាំងនោះ ព្រះសោតាបន្ន រមែងចូលសោតាបត្តិផលសមាបត្តិ ព្រះសកទាគាមី រមែងចូលសកទាគាមីផលសមាបត្តិ ព្រះអនាគាមី រមែងចូលអនាគាមីផលសមាបត្តិ ព្រះអរហន្ត ក៏រមែងចូលអរហត្តផលសមាបត្តិ ព្រះអរិយបុគ្គលដែលតាំងនៅក្នុងផលខាងលើ រមែងមិនចូលសមាបត្តិ ដែលតាំងនៅក្នុងខាងក្រោម ។ សេចក្តីពិត សមាបត្តិខាងក្រោមរបស់លោកទាំងនោះ ក៏មានការប្រព្រឹត្តទៅក្នុងសមាបត្តិនោះដូចគ្នា ។ បទថា ឯតទេវ ឯតំ ហោតិ សេចក្តីថា រឿងនេះ រមែងយ៉ាងនោះឯង ដោយចំណែកតែមួយ ។ សេចក្តីពិត ឈ្មោះថាភាពជាប្រការដទៃ ដែលដឹងដោយអំណាចចេតោបរិយញ្ញាណ រមែងមិនមាន ។ ពាក្យដ៏សេស គប្បីប្រកបចូលដោយន័យមុននោះឯង ។

## ទស្សនសមាបត្តិ ៤

[៧៩] ពាក្យជាដើមថា អាតប្បមន្វាយ ព្រះមានព្រះភាគ ត្រាស់ឲ្យពិស្តារហើយក្នុងព្រហ្មជាលសូត្រ ។ ចំណែកសេចក្ដីសង្ខេបក្នុងទីនេះ មានដូចតទៅនេះ ។

សេចក្ដីព្យាយាម ឈ្មោះថា **អាតប្បៈ** ។ សេចក្ដីព្យាយាមនោះឯង ឈ្មោះថា **បធាន** ព្រោះជារបស់ដែលបុគ្គលគប្បីតាំងទុក ឈ្មោះថា **អនុយោគ** ព្រោះជារបស់ដែលបុគ្គលគប្បីប្រកបទុក ។ បទថា អប្បមាទំ គឺ ការមិនប្រាសចាកសតិ ។ បទថា សម្មា មនសិការំ គឺ ការធ្វើមនសិការដោយឧបាយ ដែលប្រព្រឹត្តទៅដោយអំណាចការពិចារណាក្នុងធម៌ដែលមិនទៀង ថាមិនទៀងជាដើម ។ បទថា ចេតោសមាធឹ បានដល់សមាធិក្នុងបឋមជ្ឈាន ។ ច្រើនបទថា អយំ បឋមា ទស្សនសម្បត្តិ សេចក្ដីថា បឋមជ្ឈានសមាបត្តិ ដែលព្រះយោគាវចរពិចារណាអាការ ៣២ ដោយជារបស់បដិកូលហើយ ឲ្យកើតឡើង ដោយអំណាចការឃើញ ថាជារបស់បដិកូលនេះ ឈ្មោះថា ទស្សនសមាបត្តិទី ១ តែបើព្រះយោគាវចរធ្វើឈាននោះឲ្យជាបាទ ហើយជាព្រះសោតាបន្ន នេះចាត់ជាទស្សន-

សមាបត្តិទី ១ ដោយត្រង់នោះឯង ។ បទថា អតិក្កម្ម ច គឺ ឈានកន្លង ។ បទថា ឆវិមំសលោហិតំ គឺ សម្បុរស្បែក សាច់ និងឈាម ។ បទថា អដ្ឋឹ បច្ចវេក្ខតិ គឺ រមែងពិចារណាថា ឆ្អឹង ឆ្អឹង ដូច្នេះ ។ បទថា អដ្ឋិ អដ្ឋិ សេចក្ដីថា ឈានសមាបត្តិ ដែលមានទិព្វចក្ខុជាបាទ មានឆ្អឹងជាអារម្មណ៍ ដែលព្រះយោគាវចរពិចារណាហើយ ឲ្យកើតឡើង ឈ្មោះថា ទស្សនសមាបត្តិ ទី ២ ។ តែបើព្រះយោគាវចរ ធ្វើឈាននោះឲ្យជាបាទហើយ រមែងឲ្យសកទាគាមិមគ្គកើតឡើងបាន ។ ប្រការនេះ ក៏ចាត់ថា ជាទស្សនសមាបត្តិ ទី ២ ដោយត្រង់ ។ ចំណែកព្រះសុមនត្ថេរដែលនៅក្នុងកាឡវល្លិវិហារ ពោលថា រមែងគួរតាំងពីមគ្គទី ៣ ។

វិញ្ញាណនោះឯង ឈ្មោះ វិញ្ញាណសោតៈ ។ បទថា ឧភយតោ អព្វោច្ឆិន្នំ សេចក្ដីថា ក្រសែវិញ្ញាណនោះ លោកកាត់ផ្ដាច់បានហើយ ដោយចំណែកទាំងពីរ ។

បទថា ឥធ លោកេ បតិដ្ឋិតញ្ច គឺ ដែលតាំងនៅហើយក្នុងលោកនេះ ដោយអំណាចឆន្ទរាគៈ ។ សូម្បីក្នុងបទទី ២ ក៏ន័យនេះដូចគ្នា ។ មួយយ៉ាងទៀត ក្រសែវិញ្ញាណ កាលចូលដល់កម្មដោយកម្ម ឈ្មោះថា តាំង

ទៅចំពោះហើយក្នុងលោកនេះ ។ ក្រសែវិញ្ញាណ កាលទាញមកបាននូវកម្មភព ឈ្មោះថា តាំងទៅចំពោះក្នុងបរលោក ។ សួរថា ដោយបទនេះលោកពោលអ្វីទុក ។ ឆ្លើយថា លោកពោលចេតោបរិយញ្ញាណ របស់សេក្ខបុថុជ្ជនទាំងឡាយទុក ។ សេចក្តីពិត ចេតោបរិយញ្ញាណរបស់សេក្ខបុថុជ្ជនទាំងឡាយ ឈ្មោះថា ទស្សនសមាបត្តិប្រការទី ៣ ។

បទថា ឥធ លោកេ អប្បតិដ្ឋិតញ្ច គឺ តាំងនៅមិនបានក្នុងលោកនេះ ព្រោះមានតម្រេក ដោយអំណាចលះសេចក្តីពេញចិត្តចេញហើយ ។ សូម្បីក្នុងបទទី ២ ក៏ន័យនេះ ។ ម្យ៉ាងទៀត ក្រសែវិញ្ញាណមិនចូលដល់កម្មដោយកម្ម ឈ្មោះថា តាំងនៅក្នុងលោកនេះមិនបាន ។ កាលទាញកម្មភពមកមិនបាន ឈ្មោះថា តាំងនៅក្នុងបរលោកមិនបាន ។ សួរថា ដោយបទនេះ លោកពោលអ្វីទុក ។ ឆ្លើយថា លោកពោលចេតោបរិយញ្ញាណរបស់ព្រះខីណាស្រពទុក ។ សេចក្តីពិត ចេតោបរិយញ្ញាណរបស់ព្រះខីណាស្រព ឈ្មោះថា ក្នុងទស្សនសមាបត្តិប្រការទី ៤ ។

ម្យ៉ាងទៀត សូម្បីវិបស្សនាដែលព្រះយោគាវចរប្រារព្ធអាការ ៣២ ក៏ចាត់ជាទស្សនសមាបត្តិប្រការទី ១ ។ វិបស្សនាដែលព្រះយោគាវចរ

ប្រារព្ធកម្មដ្ឋាន ដែលមានឆ្អឹងជាអារម្មណ៍ ចាត់ជាទស្សនសមាបត្តិប្រការទី ២ ។ បទទាំងពីរនេះថា ចេតោបរិយញ្ញាណរបស់សេក្ខបុថុជ្ជន ចេតោបរិយញ្ញាណរបស់ព្រះខីណាស្រព ដូច្នេះ មិនញាប់ញ័រឡើយ ។

ន័យមួយទៀត ។ បឋមជ្ឈាន ឈ្មោះថា ទស្សនសមាបត្តិប្រការទី ១ ។ ទុតិយជ្ឈាន ឈ្មោះថា ទស្សនសមាបត្តិប្រការទី ២ ។ តតិយជ្ឈាន ឈ្មោះថា ទស្សនសមាបត្តិប្រការទី ៣ ។ ចតុត្ថជ្ឈាន ឈ្មោះថា ទស្សនសមាបត្តិប្រការទី ៤ ។ មួយទៀត បឋមមគ្គ ឈ្មោះថា ទស្សនសមាបត្តិប្រការទី ១ ។ មគ្គទី ២ ឈ្មោះថា ទស្សនសមាបត្តិប្រការ ទី ២ ។ មគ្គទី ៣ ឈ្មោះថា ទស្សនសមាបត្តិប្រការទី ៣ ។ មគ្គទី ៤ ឈ្មោះថា ទស្សនសមាបត្តិប្រការទី ៤ ។ ពាក្យដ៏សេសក្នុងបទនេះ គប្បីប្រកបចូល ដោយន័យមុននោះឯង ។

## បុគ្គល ៧ ពួក

[៨០] បទថា បុគ្គលបណ្ណត្តីសុ គឺ ក្នុងលោកបញ្ញត្តិ ដែលបុគ្គលគប្បីបញ្ញត្តិយ៉ាងនេះថា សត្តៈ បុគ្គលៈ នរៈ បោសៈ ដូច្នេះ តាម

វោហារផ្លូវលោក ។ សេចក្ដីពិត កថាទាំងពីរ គឺ សម្មតិកថា បរមត្ថកថា របស់ព្រះពុទ្ធទាំងឡាយ ទ្រង់ធ្វើឲ្យពិស្ដារហើយ **ក្នុងបោដ្ឋបាទសូត្រ** ក្នុងបណ្ដាកថាទាំងពីរនោះ កថានេះថា ក្នុងបុគ្គលប្បញ្ញត្តិទាំងឡាយ ដូច្នេះឈ្មោះ សម្មតិកថា ។ ព្រះមានព្រះភាគ កាលទ្រង់បញ្ញត្តិបុគ្គលពួកណាទ្រង់ជាអគ្គបុគ្គល ក្នុងបុគ្គលប្បញ្ញត្តិទាំងឡាយ ឥឡូវនេះ ព្រះសារីបុត្តត្ថេរកាលនឹងសម្ដែងបុគ្គលទាំងនោះ ទើបទូលពាក្យជាដើមថា សត្តីមេ ភន្តេបុគ្គលា ឧភតោភាគវិមុត្តោ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា ឧភតោភាគវិមុត្តោ សេចក្ដីថា បុគ្គលដែលរួចផុតហើយ ដោយចំណែកពីរ គឺ អ្នករួចផុតចាករូបកាយ ដោយអរូបសមាបត្តិ រួចផុតចាកនាមកាយ ដោយមគ្គ ។ បុគ្គលនោះចេញចាកបណ្ដាអរូបសមាបត្តិទាំង ៤ យ៉ាងណាមួយ ហើយពិចារណាសង្ខារ រមែងជាបុគ្គលពួក ៥ ដោយអំណាចនៃបុគ្គល គឺ ព្រះអរិយបុគ្គល ៤ អ្នកសម្រេចព្រះអរហត្ត និងព្រះអនាគាមី ចេញចាកនិរោធហើយ សម្រេចព្រះអរហត្ត ។ ក៏ព្រះបាលីក្នុងទីនេះថា បុគ្គលដែលរួចផុតដោយចំណែកទាំងពីរ តើដូចម្ដេច គឺ បុគ្គលខ្លះក្នុងលោកនេះ ពាល់ត្រូវវិមោក្ខទាំង ៨

ដោយកាយហើយ អាសវៈរបស់លោកក៏អស់ទៅ ព្រោះឃើញដោយបញ្ញា បុគ្គលនេះ លោកហៅថា អ្នករួចផុតហើយដោយចំណែកទាំងពីរ ។ ព្រះបាលីនេះ មកហើយដោយអំណាចនៃលោកអ្នកបានវិមោក្ខ ៨ យ៉ាងនេះ ។

បទថា បញ្ញាវិមុត្តោ ប្រែថា រួចផុតហើយដោយបញ្ញា ។ បុគ្គលដែលរួចផុតបានដោយបញ្ញានោះមាន ៥ ពួក ដោយអំណាចនៃបុគ្គលទាំងនេះ គឺ សុក្ខវិបស្សកបុគ្គល ១ និងបុគ្គលដែលចេញចាកឈាន ទាំង ៤ ហើយសម្រេចព្រះអរហត្ត ៤ ពួក ១ ។ ក៏ព្រះបាលីក្នុងទីនេះ មកហើយដោយអំណាចធម៌ដែលជាបដិបក្ខចំពោះវិមោក្ខ ៨ សមដូចដែលព្រះមានព្រះភាគត្រាស់ទុកថា បុគ្គលមិនបានពាល់ត្រូវវិមោក្ខ ៨ ដោយកាយឡើយ និងព្រោះឃើញដោយបញ្ញា អាសវៈរបស់បុគ្គលនោះក៏អស់ទៅ បុគ្គលនេះហៅថា អ្នករួចផុតដោយបញ្ញា ។

បុគ្គល រមែងធ្វើឲ្យច្បាស់នូវកាយ ដែលពាល់ត្រូវ ដូច្នោះ ទើបឈ្មោះថា **កាយសក្ខី** ។ បុគ្គលនោះ រមែងពាល់ត្រូវឈានជាមុន ទើបធ្វើឲ្យច្បាស់នូវនិរោធ គឺ និព្វានក្នុងខាងក្រោយ ។ កាយសក្ខីនោះ គប្បីជ្រាបថា មាន ៦ ពួក ផ្តើមតាំងពីលោកអ្នកតាំងនៅក្នុងសោតាបត្តិផល ដរាប

ដល់លោកអ្នកតាំងនៅក្នុងអរហត្តមគ្គ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ទុកថា បុគ្គលខ្លះក្នុងលោកនេះ ពាល់ត្រូវវិមោក្ខទាំង ៨ ដោយកាយ និងព្រោះឃើញដោយបញ្ញា អាសវៈពួកខ្លះរបស់គេនោះក៏អស់ទៅ បុគ្គលនេះហៅថា **កាយសក្ខី** ។

បុគ្គលសម្រេចដល់ទីបំផុតនៃទិដ្ឋិ ដូច្នោះទើបឈ្មោះថា អ្នកសម្រេចទិដ្ឋិ ។ ក្នុងសេចក្តីនោះ មានលក្ខណៈដោយសង្ខេបដូចតទៅនេះ រីបុគ្គលណាបានដឹង បានឃើញ បានជ្រាប បានធ្វើឲ្យច្បាស់ ពាល់ត្រូវដោយបញ្ញាថា សង្ខារទាំងឡាយជាទុក្ខ ការរលត់នៃសង្ខារទាំងឡាយទាំងនោះ ជាសុខដូច្នេះ ដូច្នោះបុគ្គលនោះ ឈ្មោះថា អ្នកសម្រេចទិដ្ឋិ ។ ក៏បុគ្គលដែលសម្រេចទិដ្ឋិសូម្បីនេះ មាន ៦ ពួក ដោយពិស្តារ ដូចកាយសក្ខីបុគ្គល ។ ដោយហេតុនោះនុ៎ះឯង ព្រះមានព្រះភាគ ទើបត្រាស់ថា បុគ្គលខ្លះក្នុងលោកនេះ រមែងដឹងច្បាស់តាមសេចក្តីពិតថា ធម៌នេះទុក្ខ ។ល។ រមែងដឹងច្បាស់ថា នេះជាប្រការបដិបត្តិឲ្យដល់សេចក្តីរំលត់ទុក្ខ ធម៌ទាំងឡាយ ដែលព្រះតថាគតប្រកាសហើយ ជាធម៌ដែលអ្នកគប្បីឃើញហើយដោយបញ្ញាប្រព្រឹត្តហើយដោយបញ្ញា បុគ្គលនេះ ហៅថា អ្នកសម្រេចទិដ្ឋិ ដូច្នេះ ។

បទថា សទ្ធាវិមុត្តោ គឺ បុគ្គលដែលរួចផុតហើយ ដោយសទ្ធា ។ សូម្បីបុគ្គលដែលរួចផុតដោយសទ្ធានោះ មាន ៦ ពួក ដូចន័យមុននោះឯង ។ ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា បុគ្គលខ្លះក្នុងលោកនេះ រមែងដឹងច្បាស់តាមពិតថា ធម៌នេះជាទុក្ខ ។ល។ នេះ គឺ ប្រការបដិបត្តិឲ្យដល់សេចក្ដីរំលត់ទុក្ខ និងធម៌ទាំងឡាយដែលព្រះតថាគតប្រកាស ហើយ ជាធម៌ដែលអ្នកគប្បីឃើញច្បាស់ហើយដោយបញ្ញា និងប្រព្រឹត្តហើយដោយបញ្ញា បុគ្គលនេះឈ្មោះថា អ្នករួចផុតហើយ ដោយសទ្ធា ពុំមែនថា រមែងដឹងច្បាស់តាមសេចក្ដីពិត ដូចការដឹងច្បាស់របស់បុគ្គលដែលសម្រេចទិដ្ឋិទេ ។ ក៏ក្នុងបុគ្គលពីរប្រភេទនេះ ការអស់កិលេសរបស់បុគ្គលដែលរួចផុតដោយសទ្ធា ដូចគ្នានឹងការជឿ ដាក់ចិត្តជឿ និងបង្អោនចិត្តជឿ ក្នុងខណៈនៃមគ្គ ដែលជាចំណែកខាងដើម ។ ញាណដែលជាគ្រឿងកាត់កិលេសរបស់បុគ្គលដែលសម្រេចទិដ្ឋិ ជាញាណមិនស្ទាក់ស្ទើរ ជាញាណដែលមុតស្រួច និងក្លៀវក្លា រមែងនាំទៅក្នុងខណៈនៃមគ្គ ដែលជាចំណែកខាងដើម ព្រោះដូច្នោះ ទើបដូចកាលបុគ្គលយកដាវដែលមិនមុតកាប់ដើមចេក កន្លែងដែលបុគ្គលកាប់ ក៏មិនរលោង ទាំងដាវ

ក៏មិនកន្ទេងទៅបានដោយរហ័ស បុគ្គលរមែងបានព្រួសំឡេង បុគ្គលត្រូវធ្វើសេចក្ដីព្យាយាមដោយកម្លាំងច្រើនជាង យ៉ាងណា មគ្គការទៅដែលជាចំណែកខាងដើម របស់បុគ្គលដែលរួចផុតដោយសទ្ធាបែបនោះ ក៏គប្បីជ្រាបដូច្នោះ ។ មួយទៀត ដូចកាលបុគ្គលយកដាវដែលមុតល្អ ហើយកាប់ដើមចេកត្រង់កន្លែងដែលគេកាប់ ក៏រលោង ទាំងដាវក៏កន្ទេងទៅបានរហ័ស បុគ្គលក៏មិនបានព្រួសំឡេង កិច្ច គឺ សេចក្ដីព្យាយាម ដោយកម្លាំងច្រើនក៏មិនមាន យ៉ាងណា មគ្គការទៅដែលជាចំណែកខាងដើម របស់បុគ្គលដែលរួចផុតដោយបញ្ញាក៏យ៉ាងនោះ គប្បីជ្រាបដូច្នោះ ។

បុគ្គល រមែងតាមរលឹកដល់ធម៌ ដូច្នោះ ទើបឈ្មោះថា **ធម្មានុសារី** ។ **បញ្ញា** ឈ្មោះថា **ធម៌** អធិប្បាយថា បុគ្គលរមែងចម្រើនមគ្គ ដែលមានបញ្ញាជាខាងដើម ។ សូម្បីក្នុងសទ្ធានុសារីបុគ្គល ក៏ន័យនេះដូចគ្នា ។ បុគ្គលទាំងពីរ សូម្បីទាំងនោះ គឺ បុគ្គលដែលតាំងនៅក្នុងសោតាបត្តិមគ្គនុ៎ះឯង ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកថា បញ្ញិន្រ្ទិយ បុគ្គលអ្នកបដិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់សោតាបត្តិផល ជាបញ្ញាដែលមានប្រមាណដ៏ក្រៃលែង បុគ្គលអ្នកខ្វល់ខ្វាយដើម្បីបានមកនូវសទ្ធា រមែង

ចម្រើនអរិយមគ្គដែលមានសទ្ធាជាខាងដើម បុគ្គលនេះហៅថា សទ្ធានុសារី ។ មួយទៀត សទ្ធិន្ទ្រិយរបស់បុគ្គលអ្នកបដិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល រមែងមានប្រមាណច្រើនក្រៃលែងណាស់ បុគ្គលអ្នកខ្វល់ខ្វាយដើម្បីបានមកនូវសទ្ធា រមែងចម្រើនអរិយមគ្គ ដែលមានសទ្ធាជាខាងដើម បុគ្គលនេះហៅថា សទ្ធានុសារីបុគ្គល ។ សេចក្ដីសង្ខេបក្នុងរឿងនេះ ត្រឹមប៉ុណ្ណេះ ។ ចំណែកកថា ពោលដោយឧភតោភាគវិមុត្តិជាដើមនេះ លោកពោលទុកហើយក្នុងអធិការនៃបញ្ញាភាវនា ក្នុងបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គដោយពិស្ដារ ។ ដូច្នោះ គប្បីជ្រាបវិត្ថារកថា ដោយន័យដែលលោកពោលទុកក្នុងវិសុទ្ធិមគ្គនោះចុះ ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីប្រកបចូលដោយន័យមុននោះឯង ។

[៨១] ពោជ្ឈង្គៈ ៧ ព្រះមានព្រះភាគត្រាស់ថា បធាន ដោយអំណាចការផ្ដើមតាំងសេចក្ដីព្យាយាម ក្នុងបទនេះថា បធានេសុ ដូច្នេះ ។ កថាដោយពិស្ដាររបស់ពោជ្ឈង្គៈ ៧ ទាំងនោះ គប្បីជ្រាបដោយន័យដែលព្រះមានព្រះភាគ ត្រាស់ទុកក្នុងមហាសតិប្បដ្ឋាន ។ ពាក្យដ៏សេសសូម្បីក្នុងទីនេះ គប្បីប្រកបចូលដោយន័យមុននោះចុះ ។

## បដិបទា ៤ យ៉ាង

[៨២] ក្នុងពាក្យថា ទុក្ខាបដិបទា ជាដើម មានន័យដោយពិស្តារ ដូចតទៅនេះ ៖

ក្នុងបាលីប្រទេសនោះ បញ្ញាទាំងប្រតិបត្តិលំបាក ទាំងត្រាស់ដឹងយឺតយូរ តើដូចម្តេច គឺ បញ្ញា សេចក្តីត្រាស់ដឹងច្បាស់ ។ល។ ការមិនវង្វេងធម្មវិចយៈ សម្មាទិដ្ឋិណា របស់បុគ្គលដែលឲ្យសមាធិកើតឡើងបានដោយលំបាក ទាំងត្រាស់ដឹងឋានៈនោះយឺតយូរ នេះហៅថា បញ្ញា ដែលជាការបដិបត្តិលំបាក ទាំងត្រាស់ដឹងយឺតយូរ ។

ក្នុងបាលីប្រទេសនោះ បញ្ញាដែលបដិបត្តិលំបាក តែត្រាស់ដឹងបានឆាប់រហ័ស តើដូចម្តេច គឺ បញ្ញា ការត្រាស់ច្បាស់ ។ល។ សម្មាទិដ្ឋិណារបស់បុគ្គលដែលឲ្យសមាធិកើតឡើងបានដោយលំបាក តែត្រាស់ដឹងឋានៈនោះបានដោយឆាប់រហ័ស នេះហៅថា បញ្ញាដែលជាការបដិបត្តិលំបាក តែត្រាស់ដឹងបានឆាប់រហ័ស ។

ក្នុងបាលីប្រទេសនោះ បញ្ញា ដែលបដិបត្តិងាយ តែត្រាស់ដឹងបានយឺតយូរ តើដូចម្តេច គឺ បញ្ញា ការដឹងច្បាស់ ។ល។ សម្មាទិដ្ឋិណា

របស់បុគ្គល ដែលឲ្យសមាធិកើតឡើងដោយមិនលំបាក ត្រាស់ដឹងឋានៈនោះដោយយឺតយូរ នេះហៅថា បញ្ញា ដែលមានការបដិបត្តិងាយស្រួល តែត្រាស់ដឹងយឺតយូរ ។

ក្នុងបាលីប្រទេសនោះ បញ្ញា ដែលប្រតិបត្តិងាយ ទាំងត្រាស់ដឹងឆាប់រហ័ស តើដូចម្តេច គឺ បញ្ញា ការដឹងច្បាស់ ។ល។ សម្មាទិដ្ឋិណា របស់បុគ្គលដែលឲ្យសមាធិកើតឡើងដោយមិនលំបាក ទាំងត្រាស់ដឹងឋានៈនោះយ៉ាងឆាប់រហ័ស នេះហៅថា បញ្ញា ដែលជាការបដិបត្តិងាយស្រួល ទាំងមានការត្រាស់ឆាប់រហ័ស ។ សេចក្តីសង្ខេបក្នុងទីនេះ ប៉ុណ្ណេះ ។ ចំណែកសេចក្តីពិស្តារ លោកពោលទុកហើយ ក្នុងវិសុទ្ធិមគ្គ ។ ពាក្យដ៏សេសសូម្បីក្នុងទីនេះ គប្បីប្រកបដោយន័យដូចពោលហើយនោះឯង ។

[៨៣] បទថា ន ចេវ មុសាវាទូបសញ្ហិតំ សេចក្តីថា ភិក្ខុរូបខ្លះ ក្នុងសាសនានេះ តាំងនៅក្នុងកស្សសមាចារ ( មារយាទជាប់ទាក់ទងនឹងការនិយាយ ) ខ្លះ មិនចូលទៅកាត់កថាមគ្គខ្លះ រមែងមិនពោលវាចាដែលប្រកបដោយមុសាវាទឡើយ វៀរវោហារដែលមិនប្រសើរ ៨ យ៉ាង ចេញពោលវាចាដែលប្រកបដោយវោហារដ៏ប្រសើរ ៨ យ៉ាងប៉ុណ្ណោះ ។ បទថា

ឆ ច វេភូតិយំ សេចក្ដីថា ភិក្ខុរូបខ្លះក្នុងសាសនានេះ សូម្បីតាំងនៅក្នុងកសិរស្រមាចារ រមែងមិនពោលវាចាដែលធ្វើឲ្យបែកបាក់គ្នា ។ ពាក្យថា បេសុណិយំ នោះ ជាវេវចនៈរបស់ពាក្យថា វេភូតិយំ នោះ ។ សេចក្ដីពិត វាចាដែលធ្វើឲ្យបែកបាក់គ្នា លោកហៅថា **បេសុណិយំ** ព្រោះញុាំងភាពជាទីស្រឡាញ់គ្នាឲ្យវិនាស ។ ព្រះមហាសិវត្ថេរៈពោលថា ពាក្យថា **បេសុណិយំ** នោះ ជាឈ្មោះរបស់វាចានោះ ។ បទថា ឆ ច សារម្ភជំ សេចក្ដីថា វាចាណាកើត ព្រោះការប្រណាំងប្រជែង ភិក្ខុរមែងមិនពោលវាចានោះ កាលគេពោលថា លោកទ្រុស្តសីល ឬថា លោកទ្រុស្តសីល អាចារ្យរបស់លោកក៏ទ្រុស្តសីល ឬកាលគេពោលថា លោកត្រូវអាបត្តិ រមែងមិនពោលវាចា ដែលប្រព្រឹត្តទៅដោយការពោល បាចសាចទៅខាងក្រៅ ឬវាចាដែលក្រៃលែងជាង ការធ្វើដោយន័យជាដើមថា យើងត្រាច់បិណ្ឌបាតរហូតដល់ក្រុងបាដលីបុត្ត ដូច្នេះ ។ បទថា ជយាបេក្ខោ គឺជាអ្នកប្រាថ្នាចំពោះជ័យជម្នះ ។ អធិប្បាយថា ភិក្ខុដែលសម្លឹងដល់ជ័យជម្នះ គឺ ប្រាថ្នាជ័យជំនះជាប្រមុខ រមែងមិនពោល ដូចហត្ថកសក្យបុត្រ ពោលវាចាពិត និងវាចឡេះឡោះយ៉ាងណានីមួយថា ធម្មតាពួកតិរ្ថិយ បុគ្គល

គប្បីឈ្មោះដោយធម៌ខ្លះ ដោយអធម៌ខ្លះ ដូច្នេះ ។ បញ្ញាលោកហៅថា **មន្តា** ក្នុងពាក្យថា មន្តា មន្តា ច វាចំ ភាសតិ នេះ ។ ពោលវាចាដោយបញ្ញា ឈ្មោះថា **មន្តា** ។ ម្យ៉ាងទៀត បទថា មន្តា គឺ ពិចារណាហើយ ។ មានពាក្យអធិប្បាយ ដែលព្រះមានព្រះភាគត្រាស់ទុកថា ភិក្ខុក្នុងសាសនានេះ តាំងនៅក្នុងកសុស្រមាចារ កាលពោលរហូតដល់អស់ទាំងថ្ងៃ ក៏ពិចារណាដោយបញ្ញា ពោលចំពោះពាក្យដែលសមគួរប៉ុណ្ណោះ ។ បទថា និធានវតី គឺ គួរដើម្បីនឹងយកដាក់ទុកក្នុងចិត្ត ។ បទថា កាលេន គឺ តាមកាលដ៏គួរហើយ និងដល់ហើយ ។ សេចក្តីពិត វាចា ដែលបុគ្គលពោលហើយយ៉ាងនេះ រមែងជាវាចាដែលមិនកុហក មិនញុះញង់ មិនបោកទាប មិនអួតអាង មិនផ្តេសផ្តាស ។ ក៏វាចាបែបនេះ នេះហៅថា វាចាពឹងអាស្រ័យសច្ចៈ ៤ ខ្លះ វាចាពឹងអាស្រ័យត្រៃសិក្ខាខ្លះ វាចាពឹងអាស្រ័យកថាវត្ថុ ១០ ខ្លះ វាចាពឹងអាស្រ័យធុតង្គគុណ ១៣ ខ្លះ វាចាពឹងអាស្រ័យពោធិបក្ខិយធម៌ ៣៧ ប្រការខ្លះ វាចាពឹងអាស្រ័យមគ្គខ្លះ ។ ដោយហេតុនោះ ព្រះសារីបុត្រទើបពោលថា ឯតទានុត្តរិយំ ភន្តេ ភស្ស-សមាចារេ ដូច្នេះ ។ ពាក្យនោះ គប្បីប្រកបចូលដោយន័យមុននោះចុះ ។

[៨៤] ប្រើនបទថា សច្ចោ ចស្ស សទ្ធោ ច សេចក្តីថា ភិក្ខុក្នុង ព្រះសាសនានេះ ជាអ្នកតាំងនៅក្នុងសីលាចារ គប្បីជាអ្នកពិតត្រង់ ពោលវាចាពិត គប្បីជាអ្នកមានសទ្ធា និងជល់ព្រមដោយសទ្ធា ។ សួរថា សច្ចៈ ព្រះមានព្រះភាគ ត្រាស់ទុកក្នុងកាលក្រោយហើយមិនមែនឬ ព្រោះហេតុអ្វី ក្នុងទីនេះព្រះអង្គ ទើបត្រាស់ទុកទៀត ដូច្នោះ ។

ឆ្លើយថា សច្ចវាចា ព្រះអង្គត្រាស់ទុកហើយក្នុងខាងក្រោយ ។ ក្នុងទីនេះ ព្រះអង្គត្រាស់ទុកដើម្បីទ្រង់សម្តែងថា ក៏ភិក្ខុតាំងនៅក្នុងសីលាចារហើយ រមែងមិនពោលមុសាវាទ ដោយទីបំផុតសូម្បីដោយការពោលឲ្យសើច ។ ឥឡូវនេះ ព្រះថេរៈដើម្បីនឹងសម្តែងថា ភិក្ខុនោះរមែងសម្រេចការរស់នៅដោយធម៌ស្មើ ដូច្នេះ ទើបពោលពាក្យជាដើមថា ន ច កុហកោ ដូច្នេះជាដើម ។ បណ្តាពាក្យទាំងនោះ ពាក្យថា **កុហកោ** ជាដើម ព្រះមានព្រះភាគទ្រង់អធិប្បាយពិស្តារហើយក្នុង **ព្រហ្មជាលសូត្រ** ។ ប្រើនបទថា ឥន្ទ្រិយេសុ គុត្តទ្វារោ ភោជនេ មត្តញ្ញូ សេចក្តីថា ជាអ្នកឃុំគ្រងទ្វារល្អហើយក្នុងឥន្ទ្រិយទាំង ៦ ទាំងជាអ្នកស្គាល់ប្រមាណក្នុងភោជន ។ បទថា សមការី គឺ អ្នកមានប្រក្រតីប្រព្រឹត្តស្មើ ។ អធិប្បាយថា ភិក្ខុក្នុង

ព្រះសាសនានេះ វៀរចាកហេតុ មានការវៀចវៀរផ្លូវកាយជាដើម ប្រព្រឹត្ត ស្មើក្នុងផ្លូវកាយ វាចា និងចិត្ត ។

បទថា ជាគរិយានុយោគមនុយុត្តោ សេចក្តីថា ភិក្ខុរមែងខ្វល់ខ្វាយ ប្រកបដោយភាពជាអ្នកភ្ញាក់ហើយ ដោយន័យដែលព្រះមានព្រះភាគត្រាស់ទុកថា ភិក្ខុគប្បីបែងចែកពេលថ្ងៃ និងពេលយប់ ចេញជា ៦ ចំណែក ហើយគប្បីប្រកបសេចក្តីព្យាយាមក្នុងពេលថ្ងៃ ដោយការចង្ក្រម និងអង្គុយ ។ បទថា អតន្ទិតោ គឺ បានដល់ មិនខ្ជិលច្រអូស គឺ វៀរចាកការខ្ជិលច្រអូសផ្លូវកាយ ។ បទថា អារទ្ធវីរិយោ សេចក្តីថា ជាអ្នកផ្តើមសេចក្តីព្យាយាម សូម្បីដោយសេចក្តីព្យាយាមផ្លូវកាយ បន្ទោបង់ការជាប់ជំពាក់ដោយពួកចេញ ហើយនៅម្នាក់ឯង ដោយអំណាចអារព្ភវត្ថុ ៨ ក្នុងឥរិយាបថទាំង ៤ ។ ជាអ្នកផ្តើមសេចក្តីព្យាយាម សូម្បីដោយសេចក្តីព្យាយាមផ្លូវចិត្ត បន្ទោបង់ការជាប់ជំពាក់ដោយកិលេសចេញ នៅម្នាក់ឯង ដោយអំណាចសមាបត្តិ ៨ ។ មួយ៉ាងទៀត ហាមការកើតឡើងនៃ កិលេស ដោយប្រការណាមួយ ក៏ចាត់ថា ជាអ្នកផ្តើមសេចក្តីព្យាយាម ដោយសេចក្តីព្យាយាមផ្លូវចិត្តដូចគ្នា ។ បទថា ឈាយី គឺ ជាអ្នកសម្លឹង ដោយ

អារម្មណូបនិជ្ឈាន និងលក្ខណូបនិជ្ឈាន ។ បទថា **សតិមា** គឺ ប្រកប ដោយសតិដែលអាចរឭកដល់កិច្ច ដែលធ្វើទុកយូរហើយបានជាដើម ។ បទថា កល្យាណបដិភាណោ គឺ សម្បូរណ៍ដោយការនិយាយល្អ និងសម្បូរណ៍ ដោយបដិភាណ ។ ក៏បុគ្គលនោះ ជាអ្នកប្រកបដោយបដិភាណ មិនមែន ជាអ្នកខ្វះបដិភាណ ។ ពិតហើយ ភិក្ខុដែលតាំងនៅក្នុងសីលសមាចារ មិនមែនខ្វះបដិភាណទេ ។ មួយទៀត ភិក្ខុដែលប្រកបដោយបដិភាណ រមែងដូចជាព្រះវង្គីសត្ថេរៈ ដូច្នោះ ។ បទថា គតិមា គឺ ប្រកបដោយ បញ្ញា ដែលអាចក្នុងការដើរទៅ ។ បទថា ធិតិមា គឺ ប្រកបដោយបញ្ញា ដែលអាចក្នុងការទ្រទ្រង់ចាំទុក ។ ក៏ពាក្យថា **មតិ** ក្នុងពាក្យថា មតិមា នេះ ជាឈ្មោះរបស់បញ្ញា ។ ដូច្នោះ អធិប្បាយថា អ្នកមានបញ្ញា ។ បញ្ញានោះឯង លោកពោលទុកដោយបទសូម្បីទាំង ៣ នេះ ដូចពណ៌នា មក ដូច្នេះ ។ ក្នុងបាលីប្រទេសនោះ សេចក្តីព្យាយាម ជាគ្រឿងសមណធម៌ លោកពោលទុកក្នុងកាលក្រោយ ។ ក្នុងទីនេះ លោកពោលសេចក្តីព្យាយាម ជាគ្រឿងរៀនសូត្រព្រះពុទ្ធវចនៈ ។ មួយទៀត វិបស្សនាបញ្ញា លោក ពោលទុកហើយក្នុងខាងក្រោយ ។ ក្នុងទីនេះ លោកពោលដល់បញ្ញាដែល

ជាគ្រឿងរៀនសូត្រព្រះពុទ្ធវចនៈ ។ ត្រង់បទថា ន ច កាមេសុ គិទ្ធោ គឺ ជាអ្នកមិនជាប់ក្នុងវត្ថុកាម និងកិលេសកាម ។ ត្រង់បទថា សតោ ច និបកោ ចរេ សេចក្ដីថា ភិក្ខុគប្បីជាអ្នកប្រកប ដោយសតិ និងដោយញាណ ក្នុងឋានៈទាំង ៧ មានការឈានទៅខាងមុខជាដើម ត្រាសប់ទៅ ។ បញ្ញា ឈ្មោះ នេបក្ក ភិក្ខុ លោកពោលថា មានបញ្ញា ដូច្នេះ ព្រោះប្រកប ដោយបញ្ញានោះ ពាក្យដ៏សេសក្នុងទីនេះ គប្បីប្រកបចូលដោយន័យមុន នោះចុះ ។

## អនុសាសនវិធា ៤ យ៉ាង

[៨៥] បទថា បច្ចត្តំ យោនិសោមនសិការា គឺ ដោយការធ្វើទុក ក្នុងព្រះហឫទ័យ ដោយឧបាយរបស់ព្រះអង្គ ។ បទថា យថានុសិដ្ឋំ តថាបដិបជ្ជមានោ គឺ ជាអ្នកបដិបត្តិតាមដែលតថាគតបានឲ្យអនុសាសន៍ ទុក ។ ពាក្យជាដើមថា តិណ្ណំ សញ្ញោជនានំ បរិក្ខយា មានសេចក្ដីដូច ពោលហើយ ។ ពាក្យដ៏សេសសូម្បីក្នុងទីនេះ គប្បីប្រកបចូលដោយន័យ មុននោះឯង ។

[៨៦] បទថា បរបុគ្គលវិមុត្តិញ្ញាណោ គឺ ក្នុងញាណជាគ្រឿងរួចផុតចាកកិលេសដោយមគ្គនោះៗ របស់បុគ្គលដទៃ មានព្រះសោតាបន្នជាដើម ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីប្រកបចូលដោយន័យមុននោះឯង ។

## សស្សតវាទ ៣ ប្រការ

[៨៧] បទថា អមុត្រាសឹ ឯវំ នាមោ សេចក្តីថា បុគ្គលម្នាក់កាលរឭកបុព្វេនិវាស រមែងកំណត់ឈ្មោះ និងគោត្រទៅបាន ។ បុគ្គលម្នាក់ទៀត រឭកបានតែខន្ធសុទ្ធៗ ប៉ុណ្ណោះ ។ បុគ្គលពួកមួយ អាចរឭកបាន បុគ្គលពួកមួយមិនអាច ។ ក្នុងទីនោះ មិនបានកាន់យកដោយអំណាចនៃអ្នកអាច ។ បានកាន់យក ដោយអំណាចនៃអ្នកមិនអាច ក៏អ្នកមិនអាចនឹងធ្វើអ្វីបាន ។ បុគ្គលនោះ រឭកចំពោះតែខន្ធសុទ្ធៗ ទៅតាំងនៅក្នុងទីបំផុតច្រើនសែនជាតិ ញុំាងញាណចុះកាន់នាម និងគោត្រ ។ ព្រះសារីបុត្តត្ថេរ កាលនឹងសម្តែងនាម និងគោត្រនោះ ទើបពោលពាក្យជាដើមថា ឯវំ នាមោ ដូច្នេះ ។ បទថា សោ ឯវមាហ គឺ បុគ្គលដែលប្រកាន់ដោយទិដ្ឋិនោះ បានពោលយ៉ាងនេះ ។ ក្នុងបាលីប្រទេសនោះ កាលបុគ្គលនោះ

ពោលថា ទៀង ហើយពោលថា សត្វទាំងនោះរមែងអន្ទោលទៅ ដូច្នេះ ពាក្យនិយាយរមែងមានខាងដើម និងខាងចុងខ្វាស់គ្នាក៏ពិត ។ តែបុគ្គលនោះ កំណត់ពាក្យនោះមិនបាន ព្រោះជាអ្នកប្រកាន់ទិដ្ឋិ ។ សេចក្ដីពិតឋានៈ ឬការកំណត់របស់អ្នកប្រកាន់ទិដ្ឋិ រមែងមិនមាន ។ ពាក្យនោះ លោកឲ្យពិស្ដារហើយក្នុង **ព្រហ្មជាលសូត្រ** ថា បុគ្គលនោះ ប្រកាន់យកវត្ថុនេះហើយ ក៏ប្រលែងវត្ថុនោះ លុះប្រលែងវត្ថុនោះហើយ ក៏ប្រកាន់យកវត្ថុនេះ ដូច្នេះ ។ ដោយពាក្យថា អយំ តតិយោ សស្សតវាទោ[1] នេះ ព្រះថេរៈពោលបុគ្គលដែលជាសស្សតវាទៈទុក ៣ ប្រភេទ ដោយអំណាចនៃ ញាណលាភីបុគ្គលប៉ុណ្ណោះ ។ ប៉ុន្តែព្រះមានព្រះភាគ បានត្រាស់បុគ្គល ៤ ប្រភេទទុកក្នុង **ព្រហ្មជាលសូត្រ** ព្រោះរួមយកសូម្បីបុគ្គលដែលជាតក្កីវាទៈចូលទុកផង ។ ក៏ពាក្យពោលពិស្ដាររបស់បុគ្គលដែលមានវាទៈ ៣ ប្រភេទនោះ គប្បីជ្រាបដោយន័យដែលលោកពោលទុកហើយក្នុងព្រហ្មជាលសូត្រ ។ ពាក្យដ៏សេសសូម្បីក្នុងទីនេះ គប្បីឲ្យពិស្ដារដោយន័យដែលពោលហើយក្នុងកាលមុន ។

---

១ បិដកខ្មែរ ទំព័រ ២២៤ បន្ទាត់ទី ៨ ថា អយំ ភន្តេ តតិយា សស្សតវាទោ ។

## បុព្វេនិវាសានុស្សតិញ្ញាណ

[៨៨] បទថា គណនាយ វា គឺ ដោយការរាប់ជាពួក ។ បទថា សង្ខានេន គឺ ដោយការរាប់ដោយចិត្ត ដោយមិនឲ្យដាច់ខ្សែដោយពីរវិធីនោះ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងចំពោះការរាប់ជាពួក មានពាក្យអធិប្បាយ ដែលព្រះសារីបុត្រពោលទុកថា នរណាមិនអាចនឹងធ្វើជាពួកដោយអំណាចរយ ពាន់ សែន កោដិនៃឆ្នាំទាំងឡាយ ហើយរាប់ថា មួយរយឆ្នាំប៉ុណ្ណោះ ដូច្នេះ ឬថា ។ល។ កោដិឆ្នាំប៉ុណ្ណេះ ។ ព្រះថេរៈរមែងសម្តែងថា ព្រោះព្រះអង្គទ្រង់បំពេញបារមី ១០ ប្រការ ព្រោះព្រះអង្គទ្រង់សម្រេចសព្វញ្ញុតញ្ញាណ ព្រោះព្រះអនាវរណញ្ញាណរបស់ព្រះអង្គប្រព្រឹត្តទៅចាស់ក្លា ព្រះអង្គទើបទ្រង់ឆ្លាតក្នុងទេសនាញាណជាប្រមុខ ធ្វើឲ្យមានទីបំផុតដោយការរាប់ឆ្នាំ សូម្បីដោយការរាប់កប្ប ក៏កំណត់សម្តែងថា មានប្រមាណប៉ុណ្ណេះបាន ។ សេចក្តីក្នុងបាលី មានន័យពោលហើយក្នុងបាលីនេះ ។ ពាក្យដ៏សេសសូម្បីក្នុងទីនេះ ក៏គប្បីប្រកបចូលដោយន័យមុននោះចុះ ។

[៨៩] ដោយប្រើនបទថា ឯតទានុត្តរិយំ ភន្តេ សត្តានំ ចុត្ូបបា-

តញ្ញាណោ ព្រះថេរៈ រមែងសម្តែងថា បពិត្រព្រះអង្គដ៏ចម្រើន ញាណទេសនា ដោយអំណាចចុតិ និងបដិសន្ធិនៃសត្វទាំងឡាយនេះណា មានហើយ ញាណ-ទេសនានោះ ចាត់ជាកំពូលរបស់ព្រះអង្គ សូម្បីព្រះពុទ្ធក្នុងអតីតទាំងឡាយ ក៏ទ្រង់សម្តែងយ៉ាងនេះ ដូចគ្នា ។ សូម្បីព្រះពុទ្ធក្នុងអនាគត ក៏នឹងទ្រង់សម្តែងយ៉ាងនេះ ដូចគ្នា ។ ព្រះអង្គ ទ្រង់ប្រៀបធៀបដោយព្រះញាណរបស់ព្រះពុទ្ធទាំងក្នុងអតីត និងក្នុងអនាគតទាំងនោះ ហើយទ្រង់សម្តែង បពិត្រព្រះអង្គដ៏ចម្រើន ដោយហេតុសូម្បីនេះ ខ្ញុំព្រះអង្គមានសេចក្តីជ្រះថ្លាក្នុងព្រះមានព្រះភាគ យ៉ាងនេះ ។ ក៏សេចក្តីរបស់ព្រះបាលីក្នុងទីនេះ លោកឲ្យពិស្តារហើយ ដូចគ្នា ។

## ឥទ្ធិវិធា ២ យ៉ាង

**[៩០]** ពីរបទថា សាសវា សឧបធិកា គឺ ឫទ្ធិដែលមានទោស គឺមានការតិះដៀល ។ ច្រើនបទថា នោ អរិយាតិ វុច្ចតិ សេចក្តីថា ឫទ្ធិដូច្នោះ មិនហៅថា ឫទ្ធិដែលជាអរិយៈ ។ ពីរបទថា អនាសវា អនុបធិកា គឺ មិនមានទោស បានដល់ មិនមានប្រការគួរតិះដៀល ។ ពីរបទថា អរិយាតិ វុច្ចតិ គឺ ឫទ្ធិដូច្នេះ ហៅថា ឫទ្ធិដែលជាអរិយៈ ។

ប្រើនបទថា អប្បដិក្កូលសញ្ញី តត្ថ វិហរតិ សេចក្តីថា ភិក្ខុរមែងមានការសម្គាល់ក្នុងវត្ថុបដិកូលថា មិនបដិកូល យ៉ាងណា ។ គឺ លោករមែងផ្សាយមេត្តាទៅ ក្នុងសត្វដែលបដិកូល គឺ រួមសេចក្តីសម្គាល់ថា ជាធាតុចុះ ក្នុងសង្ខារ ។ ដូចដែលលោកពោលទុកថា ភិក្ខុជាអ្នកមានសេចក្តីសម្គាល់ក្នុងវត្ថុបដិកូលថា មិនគួរខ្ពើមនោះ យ៉ាងណា គឺ លោករមែងផ្សាយមេត្តាទៅក្នុងវត្ថុដែលមិនគួរប្រាថ្នា ឬរួមចុះដោយជាធាតុ ដូច្នេះ ។ ប្រើនបទថា បដិក្កូលសញ្ញី តត្ថ វិហរតិ សេចក្តីថា ភិក្ខុរមែងផ្សាយអសុភសញ្ញាទៅក្នុងសត្វដែលមិនបដិកូល គឺ រួមអនិច្ចសញ្ញាចុះក្នុងសង្ខារ ។ ដូចដែលលោកពោលទុកថា ភិក្ខុជាអ្នកមានការសម្គាល់ក្នុងវត្ថុ មិនបដិកូលថា បដិកូលយ៉ាងណា គឺ លោករមែងផ្សាយទៅដោយអសុភសញ្ញា ក្នុងវត្ថុដែលគួរប្រាថ្នា ឬរួមចុះ ដោយជារបស់មិនទៀង ដូច្នេះ ។ គប្បីជ្រាបសេចក្តី សូម្បីក្នុងបទដ៏សេសយ៉ាងនេះ ។ ប្រើនបទថា ឧបេក្ខកោ តត្ថ វិហរតិ សេចក្តីថា ភិក្ខុមិនត្រេកត្រអាលក្នុងអារម្មណ៍ដែលគួរប្រាថ្នា និងមិនថ្នាំងថ្នាក់ក្នុងអារម្មណ៍ដែលមិនគួរប្រាថ្នា ទាំងមិនឲ្យមោហៈកើតឡើងដូចជនពួកដទៃឲ្យមោហៈកើតឡើង ដោយការសម្លឹងអារម្មណ៍ដែលមិនមាន

ចំណែកស្មើ ជាអ្នកព្រងើយក្នុងអារម្មណ៍ទាំង ៦ ដោយឧបេក្ខាមានអង្គ ៦ ។ ប្រើនបទថា ឯតទានុត្តរិយំ ភន្តេ ឥទ្ធិវិធាសុ សេចក្តីថា បពិត្រព្រះអង្គដ៏ចម្រើន នេះចាត់ថា ជាទេសនាដ៏កំពូលឆ្នើមយ៉ាងនេះ ក្នុងចំណែកឫទ្ធិទាំងពីរ ។

បទថា តំ ភគវា សេចក្តីថា ព្រះមានព្រះភាគ រមែងដឹងក្រៃលែងនូវទេសនានោះទាំងអស់ មិនមានសល់ឡើយ ។ ពីរបទថា តំ ភគវតោ សេចក្តីថា កាលព្រះមានព្រះភាគទ្រង់ដឹងក្រៃលែង នូវទេសនានោះ ដោយមិនមានសល់ ។ ប្រើនបទថា ឧត្តរិ អភិញ្ញេយ្យំ នត្ថិ សេចក្តីថា ធម៌ដែលនឹងគប្បីដឹងក្រៃលែងឡើងទៅជាងនេះ រមែងមិនមាន គឺ ពាក្យនេះថា ធម៌ ឬបុគ្គលដទៃអំពីនេះ ដែលព្រះមានព្រះភាគ ទ្រង់មិនជ្រាប ដូច្នេះ រមែងមិនមានឡើយ ។ ប្រើនបទថា យទភិជានំ អញ្ញោ សមណោ វា សេចក្តីថា វត្ថុណាដែលព្រះអង្គមិនដឹង សមណៈ ឬព្រាហ្មណ៍ ដទៃនឹងដឹងវត្ថុនោះ ជាអ្នកមានសេចក្តីដឹងក្រៃលែងជាង គឺ មានបញ្ញាច្រើនជាងព្រះមានព្រះភាគ ។ ពាក្យថា យទិទំ ក្នុងពាក្យថា យទិទំ ឥទ្ធិវិធាសុ ត្រឹមតែជានិបាត ។ បុគ្គលដែលក្រៃលែងជាងព្រះមានព្រះភាគ ក្នុងចំណែក

ឥទ្ធិវិធី រមែងមិនមានឡើយ ។ សេចក្ដីពិត សព្វព្រះពុទ្ធក្នុងអតីតទាំង ឡាយ ក៏ទ្រង់សម្ដែងឫទ្ធិ ២ យ៉ាងទាំងនេះ ។ សព្វព្រះពុទ្ធក្នុងអនាគត ក៏នឹងសម្ដែងឫទ្ធិទាំង ២ នេះ ។ សព្វព្រះអង្គទ្រង់ប្រៀបផ្ទឹមដោយញាណ របស់ព្រះពុទ្ធទាំងនោះហើយ ក៏ទ្រង់សម្ដែងឫទ្ធិទាំងនេះ ។ ព្រះថេរៈកាល នឹងសម្ដែងថា ព្រះមានព្រះភាគប៉ុណ្ណោះ ទ្រង់ជាដ៏កំពូលធ្មើមក្នុងចំណែក ឥទ្ធិវិធីដូចពណ៌នាមកដូច្នេះ ដូច្នេះ ទើបសម្ដែងថា បពិត្រព្រះអង្គដ៏ចម្រើន ដោយហេតុនេះ ខ្ញុំព្រះអង្គ ទើបមានសេចក្ដីជ្រះថ្លាក្នុងព្រះមានព្រះភាគ ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះ ព្រះធម្មសេនាបតី អង្គុយក្នុងទីសម្រាកពេលថ្ងៃ ហើយពិចារណាធម៌ដទៃតទៅ ១៦ យ៉ាង ពួកណា ធម៌ពួកនោះ ជាធម៌ដែលលោកសម្ដែងហើយ ។

## ព្រះសារីបុត្រទូលសួរ ព្រះសាស្ដាទ្រង់ព្យាករ

**[៩១]** ឥឡូវនេះ ព្រះថេរៈកាលនឹងសម្ដែងគុណរបស់ព្រះមាន-ព្រះភាគ ដោយអាការសព្វដទៃទៀត ទើបទូលពាក្យជាដើមថា យន្តំ ភន្តេ ដូច្នេះ ។

បណ្ដាបទទាំងនោះ ពីរបទថា សទ្ធេន កុលបុត្តេន សេចក្ដីថា ព្រះពោធិសត្វដែលមានក្នុងអតីត អនាគត និងបច្ចុប្បន្ន ឈ្មោះថា កុលបុត្រអ្នកមានសទ្ធា ។ ព្រោះដូច្នោះ ទើបមានពាក្យអធិប្បាយថា ធម៌ណាដែលព្រះសព្វញ្ញូពោធិសត្វគប្បីសម្រេច ។ សួរថា អ្វីដែលព្រះសព្វញ្ញូពោធិសត្វគប្បីសម្រេច ។ ឆ្លើយថា លោកុត្តរធម៌ ៩ ដែលព្រះសព្វញ្ញូពោធិសត្វនោះ គប្បីសម្រេច ។ ពាក្យទាំងអស់ មានជាដើមថា វីរិយំ ថាមោ ក្នុងបទថា អារទ្ធវិរិយេន ជាដើមនេះ ជាវេវចនៈរបស់សេចក្ដីព្យាយាម ។ បណ្ដាបទទាំងនោះ បទថា អារទ្ធវិរិយេន គឺ អ្នកផ្គងសេចក្ដីព្យាយាម ។ បទថា ថាមវតា គឺ សម្បូរណ៍ដោយកម្លាំង គឺមានសេចក្ដីព្យាយាមខ្ជាប់ខ្ជួន ។ បទថា បុរិសថាមេន អធិប្បាយថា វត្ថុណាដែលព្រះសព្វញ្ញូពោធិសត្វអ្នកមានកម្លាំងនោះ គប្បីសម្រេចដោយកម្លាំងរបស់បុរស ។ ក្នុងពីរបទបន្ទាប់ទៅ ក៏មានន័យដូច្នេះ ដូចគ្នា បទថា បុរិសធោរេយ្យេន គឺ មហាបុរសអ្នកអាចដើម្បីនឹងនាំធុរៈ ដែលព្រះពុទ្ធទាំងឡាយអ្នកមានធុរៈ រកបុគ្គលស្មើមិនបាន គប្បីនាំទៅ ។ ដោយពីរបទថា អនុប្បត្តំ តំ ភគវតា ព្រះថេរៈ រមែងសម្ដែងថា ធម៌ទាំងអស់នោះ

ដែលព្រះពុទ្ធទាំងក្នុងអតីត ទាំងក្នុងអនាគតគប្បីសម្រេច ធម៌ទាំងអស់នោះ ព្រះមានព្រះភាគទ្រង់តាមសម្រេចបានហើយ សូម្បីគុណណាមួយនឹងខ្វះទៅ ក៏មិនមាន ដូច្នេះ ។

ពីរបទថា កាមេសុ កាមសុខល្លិកានុយោគំ គឺ ព្រះមានព្រះភាគទ្រង់មិនតាមប្រកបកាមសុខក្នុងចំណែកវត្ថុកាម ។ ព្រះថេរៈ រមែងសម្តែងថា សមណព្រាហ្មណ៍ពួកដទៃ មានកេណិយជដិលជាដើម គិតគ្នាថា នរណានឹងដឹងបរលោក ការដែលនាងបរិព្វាជិកានេះ យកដៃដែលមានរោមទន់ល្មើមកសម្ផស្សជាសុខ ដូច្នេះ ទើបបំពាក់បំប៉នដោយពួកនាងបរិព្វាជិកាដែលចងផ្នួងសក់ជា ៣ កញ្ចុំ ពួកគេនាំគ្នាសោយអារម្មណ៍ មានរូបជាដើមដែលបរិបូរណ៍យ៉ាងក្រៃលែង តាមប្រកបសេចក្តីសុខក្នុងកាម យ៉ាងណា ព្រះមានព្រះភាគ ទ្រង់មិនប្រកបដូច្នោះ ។ បទថា ហីនំ គឺ ថោកទាប ។

បទថា គម្មំ គឺ ជាធម៌របស់អ្នកស្រុក ។

បទថា ចោថុជ្ជនិកំ គឺ ដែលបុថុជ្ជនគួរសេព ។ បទថា អនរិយំ គឺ នឹងមិនមានទោស ក៏មិនមែន ឬដែលព្រះអរិយៈទាំងឡាយមិនគួរសេព ។ បទថា អនត្ថសញ្ហិតំ គឺ មិនប្រកបដោយប្រយោជន៍ ។ បទថា អត្ថ-

កិលមថានុយោគំ គឺ ការតាមប្រកបសេចក្តីព្យាយាម ដែលធ្វើខ្លួនឲ្យក្តៅក្រហាយ និងអន្ទះអន្ទែង ។ បទថា ទុក្ខំ គឺ ប្រកបដោយទុក្ខ ឬទ្រាំបានដោយលំបាក ។ សមណព្រាហ្មណ៍ពួកខ្លះ គិតគ្នាថា ពួកយើងនឹងលះបង់នូវការប្រកបសេចក្តីសុខផ្លូវកាម ដូច្នេះ ទើបនាំគ្នាត្រាច់ទៅកាន់សេចក្តីលំបាកផ្លូវកាយ តអំពីនោះ ក៏គិតថា យើងនឹងផុតពីសេចក្តីលំបាកនោះ ដូច្នេះ ទើបនាំគ្នាត្រាច់ទៅកាន់សេចក្តីសុខផ្លូវកាយ យ៉ាងណា ព្រះមានព្រះភាគ មិនដូច្នោះឡើយ ។ តែព្រះមានព្រះភាគទ្រង់វៀរទីបំផុត ២ យ៉ាង ទាំងនោះហើយ ទ្រង់បដិបត្តិបដិបទាប្រពៃ ដែលព្រះអង្គត្រាស់ទុកយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ មជ្ឈិមាបដិបទា ដែលព្រះតថាគតដឹងក្រៃលែងហើយ ធ្វើឲ្យច្បាស់ដោយចក្ខុហើយ ដូច្នេះ ដូច្នោះ ព្រះអង្គទើបត្រាស់ថា ន ច អត្តកិលមថានុយោគំ ដូច្នេះ ជាដើម ។

បទថា អភិចេតសិកានំ គឺ កើតឡើងក្នុងអភិចិត្ត អធិប្បាយថាកន្លងកាមាវចរចិត្ត ហើយតាំងនៅ ។ បទថា ទិដ្ឋធម្មសុខវិហារានំ គឺ ដែលឲ្យនៅយ៉ាងសប្បាយក្នុងអត្តភាពនេះ នោះឯង ។ សេចក្តីពិតទុតិយជ្ឈានផលសមាបត្តិព្រមដោយបីតិ ព្រះមានព្រះភាគ ត្រាស់ទុកក្នុង

**បោដ្ឋបាទសូត្រ** ។ ឈានដែលជាបាទនៃវិបស្សនា ព្រមដោយមគ្គ ព្រះមានព្រះភាគត្រាស់ទុកក្នុង **បាសាទិកសូត្រ** ។ ផលសមាបត្តិដែលរាប់ជាប់ក្នុងចតុត្ថជ្ឈាន ព្រះអង្គត្រាស់ទុកក្នុង **ទសុត្តរសូត្រ** ។ ក្នុង **សម្បសាទនីយសូត្រ** នេះ បានត្រាស់ ឈានដែលជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ។ បទថា និក្កាមលាភី គឺ ព្រះមានព្រះភាគ ទ្រង់បានឈានតាមសេចក្តីប្រាថ្នា ។ បទថា អកិច្ឆលាភី គឺ ទ្រង់បានដោយមិនលំបាក ។ បទថា អកសិរលាភី គឺ ទ្រង់បានយ៉ាងបរិបូណ៌ ។

បទថា ឯកិស្សា លោកធាតុយា គឺ ក្នុងមួយលោកធាតុ ។ សេចក្តីពិត ព្រំប្រទល់មាន ៣ យ៉ាង គឺ **ជាតិខេត្ត អាណាខេត្ត វិសយខេត្ត** ក្នុងបណ្តាខេត្តទាំង ៣ នោះ ម៉ឺនលោកធាតុ ឈ្មោះ ជាតិខេត្ត ។ ក៏ក្នុងវេលាដែលព្រះតថាគត ស្តេចឈានចុះកាន់ព្រះគភ៌នៃព្រះមាតា , ក្នុងវេលាស្តេចចេញចាកព្រះគភ៌ , ក្នុងវេលាត្រាស់ដឹង , ក្នុងវេលាប្រកាសព្រះធម្មចក្រ , ក្នុងវេលាដាក់ព្រះជន្មាយុសង្ខារ និងក្នុងគ្រាបរិនិព្វាន លោកធាតុនោះរមែងញាប់ញ័រ ។ ចំណែក សែនកោដិចក្រវាឡ ឈ្មោះថា **អាណាខេត្ត** ។ ពិតណាស់ អាណា នៃអាដានា-

ជិយបរិត្ត មោរបរិត្ត ធជគ្គបរិត្ត និងរតនបរិត្តជាដើម រមែងប្រព្រឹត្តទៅក្នុងសែនកោដិចក្រវាឡ ។ ចំណែក **វិស័យខេត្ត** មិនមានប្រមាណឡើយ ។ សេចក្តីពិត ឈ្មោះថា ធម៌ដែលមិនមែនវិស័យរបស់ព្រះពុទ្ធទាំងឡាយ រមែងមិនមាន ព្រោះព្រះបាលីថា ញាណមានប៉ុនណា ធម៌ដែលព្រះអង្គគប្បីត្រាស់ដឹងក៏មានត្រឹមនោះ , ធម៌ដែលព្រះអង្គគប្បីត្រាស់ដឹង ញាណក៏មានត្រឹមនោះ ធម៌ដែលព្រះអង្គគប្បីត្រាស់ដឹង មានញាណជាទីបំផុត ញាណក៏មានធម៌ដែលព្រះអង្គគប្បីត្រាស់ជាទីបំផុត ដូច្នេះ ។ ព្រះសូត្រថា ក៏ក្នុងខេត្តទាំង ៣ នេះ ព្រះពុទ្ធទាំងឡាយ ទ្រង់រមែងឧប្បត្តិឡើងក្នុងចក្រវាឡដទៃ វៀរចក្រវាឡនេះ ដូច្នេះ រមែងមិនមាន តែព្រះសូត្រថា ព្រះពុទ្ធទាំងឡាយ រមែងទ្រង់មិនឧប្បត្តិឡើង ដូច្នេះមាន ។

បិដកមាន ៣ គឺ វិន័យបិដក សុត្តន្តបិដក អភិធម្មបិដក ។ ការសង្គាយនាមាន ៣ លើក គឺ ការសង្គាយនាដែលព្រះមហាកស្សបៈធ្វើ ១ សង្គាយនាដែលព្រះយសត្ថេរៈធ្វើ ១ សង្គាយនាដែលព្រះមោគ្គលីបុត្តត្ថេរៈធ្វើ ១ ក្នុងព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ដែលព្រះធម្មសង្គាហកាចារ្យលើកឡើងកាន់សង្គាយនាទាំង ៣ លើកនេះ ក៏មិនមានព្រះសូត្រ

សម្ដែងថា ព្រះពុទ្ធទាំងឡាយ រមែងឧប្បត្តិក្នុងចក្រវាឡដទៃក្រៅពីចក្រវាឡនេះទេ តែព្រះសូត្រសម្ដែងថា ព្រះពុទ្ធទាំងឡាយ ទ្រង់រមែងមិនឧប្បត្តិឡើងដូច្នេះមាន ។

បទថា អបុព្វំ អចរិមំ សេចក្ដីថា ព្រះពុទ្ធទាំងឡាយ ទ្រង់រមែងមិនឧប្បត្តិឡើងព្រមគ្នា មិនមុនមិនក្រោយ មានពាក្យអធិប្បាយថា រមែងទ្រង់ឧប្បត្តិឡើងក្នុងកាលមុន ឬក្នុងខាងក្រោយ ។ រយៈវេលា រាប់តាំងពីព្រះពុទ្ធប្រថាប់គង់នៅត្រង់ពោធិបល្ល័ង្កនោះ ដោយតាំងចិត្តថា យើងមិនបានសម្រេចព្រះពោធិញាណហើយ នឹងមិនក្រោកចេញ ដរាបដល់ចុះកាន់បដិសន្ធិក្នុងព្រះគភ៌របស់ព្រះមាតា មិនគួរយល់ថា ជាវេលាមុន ។ ព្រោះបានធ្វើការកំណត់ខេត្តទុកហើយ ដោយការញាប់ញ័រនៃម៉ឺនចក្រវាឡក្នុងខណៈដែលព្រះពោធិសត្វចុះកាន់បដិសន្ធិ សូម្បីការឧប្បត្តិឡើងនៃព្រះពុទ្ធអង្គដទៃ ជាការហាមឃាត់ហើយ ។ មួយទៀត រយៈវេលារាប់ពីបរិនិព្វាន ដរាបដល់ព្រះធាតុទាំងឡាយ សូម្បីប៉ុនគ្រាប់ស្ពៃតាំងនៅ ក៏មិនគប្បីយល់ថា ជាវេលាខាងក្រោយ ។ ព្រោះកាលព្រះធាតុទាំងឡាយតាំងនៅ ព្រះពុទ្ធទាំងឡាយ ក៏ឈ្មោះថា តាំងនៅតែម្យ៉ាង ។ ព្រោះដូច្នោះ

ការឧប្បត្តិឡើងរបស់ព្រះពុទ្ធអង្គនោះ ព្រះអង្គដទៃក្នុងចន្លោះនេះ ទើបជាការហាមឃាត់ហើយ ។ តែកាលការបរិនិព្វានរបស់ព្រះធាតុកើតឡើង ការឧប្បត្តិឡើងរបស់ព្រះពុទ្ធ ព្រះអង្គដទៃជាការមិនហាមឃាត់ឡើយ ។

ពិតណាស់ អន្តរធាន មាន ៣ យ៉ាង គឺ បរិយត្តិអន្តរធាន ១ បដិវេធអន្តរធាន ១ បដិបត្តិអន្តរធាន ១ ។ ក្នុងអន្តរធានទាំងនោះ ព្រះត្រៃបិដក ឈ្មោះថា **បរិយត្តិ** ។ ការចាក់ធ្លុះ រហូតដល់អស់សច្ចៈ ឈ្មោះថា **បដិវេធ** ។ ការបដិបត្តិឈ្មោះថា **បដិបត្តិ** ។ ក្នុង ៣ យ៉ាងនោះ បដិវេធ និងបដិបត្តិ រមែងមានខ្លះ រមែងមិនមានខ្លះ ។ ក៏ក្នុងកាលណា ពួកភិក្ខុដែលទ្រទ្រង់បដិវេធមានច្រើន ។ ភិក្ខុនោះគប្បី ត្រូវលើកដៃចង្អុលប្រាប់ថា ភិក្ខុរូបនេះជាបុថុជ្ជន ។ ក្នុងទ្វីបមួយប៉ុណ្ណោះ ដែលឈ្មោះថា ភិក្ខុដែលជាបុថុជ្ជនគ្រាតែមួយជាមួយគ្នា មិនមានទេ ។ ពួកភិក្ខុ សូម្បីបំពេញបដិបទាក្នុងកាលខ្លះមានច្រើន ក្នុងកាលខ្លះមានតិច ។ បដិវេធ និងការបដិបត្តិ រមែងមានខ្លះ រមែងមិនមានខ្លះដោយប្រការដូច្នេះ ។ ប៉ុន្តែថា បរិយត្តិ រមែងជាប្រមាណនៃការតាំងនៅបានរបស់ព្រះសាសនា ។ ព្រោះបណ្ឌិតទាំងឡាយបានស្តាប់ព្រះត្រៃបិដកហើយ រមែងបំពេញបានទាំងបដិបត្តិ

និងបដិវេធទាំងពីរ ។ ព្រះពោធិសត្វរបស់យើងទាំងឡាយ ឲ្យអភិញ្ញា ៥ និងសមាបត្តិ ៨ កើតឡើងក្នុងសម្នាក់របស់អាឡារតាបសហើយ ត្រាស់សួរបរិកម្មរបស់នេវសញ្ញានាសញ្ញាយតនសមាបត្តិ អាឡារតាបសទូលថា ខ្ញុំព្រះអង្គមិនជ្រាប ដូច្នេះ តអំពីនោះ ព្រះពោធិសត្វនោះ ទើបសំដៅទៅកាន់សម្នាក់របស់ឧទកតាបស ហើយទ្រង់ប្រៀបផ្ទឹមគុណវិសេស ដែលព្រះអង្គសម្រេចហើយ ត្រាស់សួរការបរិកម្មនៃនេវសញ្ញានាសញ្ញាយតន-សមាបត្តិ ឧទកតាបសនោះ ក៏ទូលឲ្យទ្រង់ជ្រាប ព្រះមហាសត្វក៏ទ្រង់ញុាំងឈាននោះឲ្យកើតឡើង ក្នុងលំដាប់នៃពាក្យរបស់ឧទកតាបសនោះ យ៉ាងណា ភិក្ខុដែលមានបញ្ញា ក៏ដូច្នោះដូចគ្នា បានស្តាប់បរិយត្តិធម៌ហើយ ក៏រមែងបំពេញទាំងបដិបត្តិ និងបដិវេធទាំងពីរបាន ។ ព្រោះដូច្នោះ កាលព្រះបរិយត្តិតាំងនៅបាន សាសនាក៏ជាការតាំងនៅបាន ។ តែក្នុងកាលណាបរិយត្តិនោះអន្តរធានទៅ ក្នុងកាលនោះ អភិធម្មបិដក រមែងសាបសូន្យទៅមុន ។ ក្នុងអភិធម្មនោះ ព្រះបដ្ឋាន រមែងអន្តរធានទៅមុន ។ ធម៌-សង្គហៈ រមែងសាបសូន្យទៅតាមក្រោយ តាមលំដាប់ ។ កាលអភិធម្ម-បិដកនោះ សាបសូន្យទៅ សូម្បីកាលបិដកទាំងពីរក្រៅពីនេះតាំងនៅ

ព្រះសាសនា ក៏រមែងជាការតាំងនៅបានដែរ ។ ក្នុងបិដកទាំងនោះ កាល ព្រះសុត្តន្តបិដកអន្តរធាន អង្គុត្តរនិកាយ រមែងសាបសូន្យទៅមុន តាំងពី ពួកទី ១១ ចុះមកដល់ពួក ១ ។ ក្នុងលំដាប់នោះ សំយុត្តនិកាយ ក៏សាបសូន្យទៅ ផ្តើមពីចក្កបេយ្យាល ចុះមកដល់ ឱឃតរណសូត្រ ។ ក្នុងលំដាប់នោះ មជ្ឈិមនិកាយ ក៏អន្តរធាន ផ្តើមតាំងពីឥន្ទ្រិយភាវនា ចុះមកដល់មូលបរិយាយសូត្រ ។ ក្នុងលំដាប់នោះ ទីឃនិកាយ ក៏អន្តរធាន តាំងពីទសុត្តរសូត្រ ចុះមកដល់ព្រហ្មជាលសូត្រ ។ ពាក្យសួររបស់មួយ គាថាក្តី ពីរគាថាក្តី រមែងមាននៅយូរ រមែងមិនអាចតាំងសាសនាទុក បាន ដូចសភិយបុច្ឆា និងអាឡវកបុច្ឆា ។ បានឮថា មួយចន្លោះកាលនៃ ព្រះកស្សបៈសម្ពុទ្ធ មិនអាចនឹងតាំងសាសនាទុកបាន ។ ក៏កាលបិដក ទាំងពីរដល់នូវភាពអន្តរធានទៅ កាលវិន័យបិដកតាំងនៅ សាសនាក៏តាំង នៅបាន ។ កាលបរិវារខន្ធកៈអន្តរធានទៅ កាលឧភតោវិភង្គតាំងនៅ សាសនាក៏ជាការតាំងនៅបាន ។ កាលឧភតោវិភង្គអន្តរធានទៅ សូម្បី កាលមាតិកាតាំងនៅ សាសនាក៏ជាការតាំងនៅបាន ។ កាលមាតិកា អន្តរធានទៅ កាលបាដិមោក្ខ បព្វជ្ជា និងឧបសម្បទាតាំងនៅ សាសនា

ក៏រមែងតាំងនៅបាន ។ គេទក៏ប្រព្រឹត្តទៅនៅបានយូរ ។ តែវង្សរបស់សមណៈអ្នកស្លៀកសំពត់ស មិនអាចនឹងទ្រទ្រង់សាសនាទុកបាន តាំងពីកាលរបស់ព្រះពុទ្ធទ្រង់ព្រះនាមថា កស្សបៈ ។ សាសនាតាំងនៅបានរហូតដល់អស់ពាន់ឆ្នាំ ដោយភិក្ខុដែលសម្រេចបដិសម្ភិទា តាំងនៅបានពាន់ឆ្នាំ ដោយភិក្ខុដែលទ្រទ្រង់អភិញ្ញា ៦ តាំងនៅបានពាន់ឆ្នាំ ដោយភិក្ខុដែលទ្រទ្រង់វិជ្ជា ៣ តាំងនៅបានពាន់ឆ្នាំ ដោយភិក្ខុដែលជាសុក្ខ-វិបស្សកៈ តាំងនៅបានពាន់ឆ្នាំ ដោយពួកភិក្ខុដែលទ្រទ្រង់បាតិមោក្ខ ។ ក៏សាសនា រមែងមានការស្រុតចុះ តាំងពីការចាក់ធ្លុះសច្ចៈរបស់ភិក្ខុអង្គក្រោយៗ និងចាកការទម្លាយសីលរបស់ភិក្ខុអង្គក្រោយៗ ។ ចាប់ផ្តើមតាំងពីនោះទៅ ការឧប្បត្តិឡើងរបស់ព្រះពុទ្ធព្រះអង្គដទៃ លោកមិនបានហាមទុក ។

ឈ្មោះថា បរិនិព្វានមាន ៣ យ៉ាង គឺ កិលេសបរិនិព្វាន ១ ខន្ធបរិនិព្វាន ១ ធាតុបរិនិព្វាន ១ ។ ក្នុងបរិនិព្វានទាំង ៣ យ៉ាងនោះ ការរំលត់មិនមានសល់នៃកិលេសបានមានហើយត្រង់ពោធិបល្ល័ង្ក ការរំលត់មិនមានសល់នៃខន្ធបានមានត្រង់ក្រុងកុសិនារា ការរំលត់នៃធាតុនឹងមាន

ក្នុងអនាគត ។ បានឮថា ក្នុងវេលាដែលសាសនាថយចុះ ព្រះធាតុទាំងឡាយ ក៏នឹងទៅរួមគ្នានៅត្រង់មហាចេតិយក្នុងកោះតម្ពបណ្ណិទ្វីប តអំពីមហាចេតិយ ក៏នឹងទៅរួមគ្នាត្រង់រាជាយតនចេតិយក្នុងនាគទ្វីប តអំពីនោះ ក៏នឹងទៅកាន់មហាពោធិបល្ល័ង្ក ។ ព្រះធាតុទាំងឡាយមកពីពិភពនៃនាគក្តី មកពីព្រហ្មលោកក្តី នឹងទៅកាន់មហាពោធិបល្ល័ង្កតែម្យ៉ាង ។ ព្រះធាតុ សូម្បីមានប្រមាណប៉ុនគ្រាប់ស្ពៃ ក៏នឹងមិនអន្តរធានទៅឡើយ ។ ព្រះធាតុទាំងអស់ ក៏នឹងរួមគ្នាជាគំនរនៅត្រង់មហាពោធិបល្ល័ង្ក រួមគ្នាប្រៀបដូចគំនរមាសដូច្នោះ បញ្ចេញឆព្វណ្ណរង្សីចេញមក ។ ព្រះធាតុទាំងនោះ នឹងផ្សាយទៅរហូតដល់អស់ម៉ឺនលោកធាតុ ។ តអំពីនោះ ទេវតាក្នុងម៉ឺនចក្រវាឡក៏ប្រជុំព្រមគ្នា ហើយនាំគ្នាពោលថា ព្រះសាស្តានឹងបរិនិព្វានទៅក្នុងថ្ងៃនេះ សាសនាក៏រមែងទ្រុឌទ្រោមទៅក្នុងថ្ងៃនេះ នេះជាការបានឃើញគ្រាចុងក្រោយបង្អស់របស់យើងទាំងឡាយក្នុងកាលឥឡូវនេះ ដូច្នេះហើយ យើងនឹងនាំគ្នាធ្វើសេចក្តីករុណាដ៏ធំក្រៃលែង ជាងថ្ងៃដែលព្រះទសពលបរិនិព្វាន ។ វៀរព្រះអនាគាមី និងព្រះខីណាស្រពចេញ ភិក្ខុដ៏សេសក៏នឹងមិនអាចតាំងនៅបានដោយភាវៈរបស់ខ្លួន ។ តេជោធាតុ ក្នុង

បណ្ដាធាតុទាំងឡាយ ក៏នឹងចេះត្របាញ់ឡើងទៅដរាបដល់ព្រហ្មលោក កាលមានព្រះធាតុ សូម្បីប៉ុនគ្រាប់ស្ពៃនៅសល់ ក៏នឹងចេះជាអណ្ដាតភ្លើងតែម្យ៉ាង កាលធាតុទាំងឡាយ ដល់នូវការអស់ហើយ តេជោធាតុក៏នឹងរលត់បាត់ទៅ ។ កាលព្រះធាតុទាំងឡាយ បានសម្ដែងអានុភាពដ៏ធំយ៉ាងនេះហើយបាត់ទៅ សាសនាក៏បានឈ្មោះថា អន្តរធានទៅ ។ សាសនានៅមិនទាន់អន្តរធានយ៉ាងនេះ ដរាបណា សាសនាចាត់ថា នៅមិនទាន់អស់ដរាបនោះ ។ ប្រការដែលព្រះសាស្ដា គប្បីកើតឡើងមិនមុនមិនក្រោយយ៉ាងនេះ រមែងជាឋានៈដែលនឹងមានមិនបាន ។

សួរថា ក៏ព្រោះហេតុអ្វី ព្រះពុទ្ធទាំងឡាយ រមែងទ្រង់មិនឧប្បត្តិឡើងមិនមុនមិនក្រោយ ដូច្នេះ ។ ឆ្លើយថា ព្រោះជាវត្ថុដែលមិនគួរអស្ចារ្យ ។ សេចក្ដីពិត ព្រះពុទ្ធទាំងឡាយជាមនុស្សដែលអស្ចារ្យ ។ ដូចដែលព្រះអង្គត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ បុគ្គលឯក កាលកើតឡើងក្នុងលោក ក៏រមែងកើតឡើងជាមនុស្សអស្ចារ្យ បុគ្គលឯក តើដូចម្ដេច គឺ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ។ ក៏ប្រសិនបើព្រះពុទ្ធទាំងឡាយ ស្ដេចគប្បីឧប្បត្តិឡើងក្នុងគ្រាតែមួយជាមួយគ្នា ២ ព្រះអង្គខ្លះ ៤ ព្រះអង្គខ្លះ ៨ ព្រះអង្គខ្លះ

១៦ ព្រះអង្គខ្ពះសោត ព្រះពុទ្ធទាំងឡាយ ក៏គប្បីជាបុគ្គលដែលមិនគួរអស្ចារ្យ ។ សូម្បីព្រះចេតិយពីរកន្លែង ក្នុងវត្តតែមួយជាមួយគ្នា លាភសក្ការៈក៏មិនច្រើន ទាំងភិក្ខុទាំងឡាយក៏មិនគួរអស្ចារ្យ ព្រោះប្រការដែលមានច្រើន យ៉ាងណា សូម្បីព្រះពុទ្ធទាំងឡាយ ក៏គប្បីជាដូច្នោះដែរ ព្រោះដូច្នោះ ព្រះពុទ្ធទាំងឡាយ ទើបទ្រង់ស្តេចមិនឧប្បត្តិឡើងយ៉ាងនេះ ។

មួយទៀត ព្រះពុទ្ធទាំងឡាយទ្រង់មិនឧប្បត្តិឡើងព្រមគ្នា ក៏ព្រោះការទេសនាមិនផ្សេងគ្នា ។ ពិតណាស់ ព្រះពុទ្ធមួយអង្គ ទ្រង់សម្តែងធម៌ផ្សេងគ្នា មានសតិប្បដ្ឋានជាដើម យ៉ាងណា ព្រះធម៌នោះទុំះឯងព្រះពុទ្ធព្រះអង្គដទៃ ដែលទ្រង់ឧប្បត្តិឡើងហើយ ក៏គប្បីសម្តែងដូច្នោះ ព្រះពុទ្ធ ក៏នឹងជាបុគ្គលមិនគួរអស្ចារ្យ ។ តែកាលព្រះពុទ្ធមួយព្រះអង្គសម្តែងធម៌ សូម្បីព្រះទេសនា ក៏ជារបស់ដែលគួរអស្ចារ្យ ។ មួយទៀត ព្រះពុទ្ធទាំងឡាយ ទ្រង់មិនឧប្បត្តិឡើងព្រមគ្នា ព្រោះមិនមានការវិវាទគ្នា ។ សេចក្តីពិត កាលព្រះពុទ្ធជាច្រើនព្រះអង្គ ស្តេចឧប្បត្តិឡើង ភិក្ខុទាំងឡាយគប្បីវិវាទគ្នាថា ព្រះពុទ្ធរបស់យើងទាំងឡាយគួរជ្រះថ្លា ព្រះពុទ្ធរបស់ពួកយើង មានព្រះសូរសេងពីរោះ មានលាភ និងមានបុណ្យ ដូច្នេះ

ដូចអន្តេវាសិករបស់អាចារ្យច្រើនអង្គ ។ ព្រោះដូច្នោះ ព្រះពុទ្ធទាំងឡាយ ទើបទ្រង់មិនឧប្បត្តិឡើងយ៉ាងនេះ ។

ម្យ៉ាងទៀត ប្រការនេះ ព្រះនាគសេនត្ថេរ ត្រូវស្តេចមិលិន្ទត្រាស់សួរ ក៏បានឆ្លើយទុកយ៉ាងពិស្តារ ។ សេចក្តីពិត ក្នុងមិលិន្ទបញ្ហានោះ ស្តេចមិលិន្ទត្រាស់ទុកថា ព្រះនាគសេនដ៏ចម្រើន ក៏ព្រះមានព្រះភាគទ្រង់បានសម្តែងទុកថា ម្នាលភិក្ខុទាំងឡាយ ប្រការនោះមិនមែនជាឋានៈមិនមែនឱកាស គឺ ប្រការដែលព្រះអរហន្តសម្មាសម្ពុទ្ធ ២ ព្រះអង្គ គប្បីឧប្បត្តិឡើងមិនមុនមិនក្រោយ ក្នុងលោកធាតុនេះ នោះជាឋានៈដែលនឹងមានមិនបាន ដូច្នេះ ព្រះនាគសេនដ៏ចម្រើន ព្រះតថាគតទាំងអស់ កាលនឹងទ្រង់សម្តែងធម៌ រមែងទ្រង់សម្តែងពោធិបក្ខិយធម៌ ៣៧ ប្រការ និងកាលនឹងត្រាស់ក៏រមែងត្រាស់អរិយសច្ចធម៌ ៤ និងកាលនឹងទ្រង់ឲ្យសិក្សារមែងទ្រង់ឲ្យសិក្សាក្នុងត្រៃសិក្ខា កាលនឹងទ្រង់ទូន្មាន ក៏ទ្រង់ទូន្មានប្រការបដិបត្តិ គឺ សេចក្តីមិនប្រមាទ ព្រះនាគសេនដ៏ចម្រើន បើព្រះតថាគតទាំងអស់ មានឧទ្ទេសតែម្យ៉ាង មានកថាតែម្យ៉ាង មានសិក្ខាបទតែម្យ៉ាង មានអនុសន្ធិតែម្យ៉ាង ព្រោះហេតុអ្វី ព្រះតថាគត ២ ព្រះអង្គ ទើបទ្រង់

មិនឧប្បត្តិឡើងក្នុងខណៈតែមួយ លោកនេះកើតមានពន្លឺដោយការឧប្បត្តិឡើងរបស់ព្រះពុទ្ធមួយព្រះអង្គ បើព្រះពុទ្ធអង្គទីពីរគប្បីមានឡើង លោកនេះគប្បីមានពន្លឺឡើងមក មានប្រមាណក្រៃលែងដោយព្រះរស្មីរបស់ព្រះពុទ្ធ ២ ព្រះអង្គ និងព្រះតថាគតទាំងពីរព្រះអង្គ កាលនឹងទ្រង់ប្រទានឱវាទ ក៏គប្បីប្រទានឱវាទយ៉ាងសប្បាយ កាលនឹងទ្រង់ទូន្មាន ក៏គប្បីទូន្មានយ៉ាងសប្បាយ សូមលោកចូរសម្តែងហេតុក្នុងសេចក្តីនោះ ឲ្យញោមអស់សេចក្តីសង្ស័យផង ។ ព្រះនាគសេនត្ថេរថ្វាយព្រះពរថា មហាបពិត្រ មុឺនលោក-ធាតុនេះ ធានាទុកបាននូវព្រះពុទ្ធត្រឹមតែមួយព្រះអង្គ ធានាទុកបាននូវព្រះគុណរបស់ព្រះតថាគតមួយអង្គដូចគ្នា បើអង្គទីពីរគប្បីស្តេចឧប្បត្តិឡើងមុឺនលោកធាតុនេះ ក៏គប្បីធានាទុកមិនបាន គប្បីញាប់ញ័រ កម្រើកទៅបង្អោនទៅ ឱនទៅ ទោរទៅ រាត់រាយ ខ្ចាត់ខ្ចាយ វិនាសទៅ មិនគប្បីចូលដល់ការតាំងនៅបាន មហាបពិត្រ ប្រៀបដូចទូកដែលផ្ទុកបុរសទុកបានតែម្នាក់ កាលបុរសម្នាក់ឡើងទៅ ទូកគប្បីតាំងនៅបានល្មម ប្រសិនបើបុរសទីពីរ ដែលដូចជាគ្នាដោយអាយុ ដោយពណ៌ ដោយវ័យ ដោយប្រមាណ ដោយធាត់ និងស្គម ដោយអវយវៈតូចធំប៉ុនគ្នា និងបុរសនោះ

គប្បីឡើងកាន់ទូកនោះ មហាបពិត្រ ទូកនោះនឹងគប្បីធានាបុរសទាំងពីរនោះ ទុកបានឬទេ ។ ស្តេចមិលិន្ទត្រាស់ឆ្លើយថា លោកម្ចាស់ដ៏ចម្រើន ទូកនោះ គប្បីធានាទុកមិនបាន គប្បីញាប់ញ័រ កម្រើក បង្អោនទៅឱនទៅ រាត់រាយ ខ្ចាត់ខ្ចាយទៅ វិនាសទៅ មិនគប្បីចូលដល់ការតាំងនៅបានឡើយ ទូកនោះ គប្បីលិចចុះទៅក្នុងទឹកដោយពិត ដូច្នេះ ។ ព្រះនាគសេនថ្វាយព្រះពរថា មហាបពិត្រ ប្រការនេះ ក៏មានឧបមាដូច្នោះដែរ មុឺនលោកធាតុនេះ ទ្រទ្រង់ព្រះពុទ្ធទុកបានតែមួយព្រះអង្គ ទាំងទ្រទ្រង់គុណរបស់ព្រះតថាគតទុកបានតែមួយព្រះអង្គប៉ុណ្ណោះ បើព្រះពុទ្ធអង្គទីពីរគប្បីឧប្បត្តិឡើង មុឺនលោកធាតុនេះ ក៏ទ្រទ្រង់ទុកមិនបាន ។ល។ មិនគប្បីចូលដល់សេចក្តីតាំងនៅបាន មហាបពិត្រ ន័យមួយទៀត ប្រៀបដូចបុរសអ្នកមានសេចក្តីសុខ គប្បីបរិភោគភោជនតាមសេចក្តីត្រូវការ គឺ កាលឃ្លានក៏បរិភោគរហូតដល់.ក លំបាក ហល់ ឱនមិនចុះ កាលបរិភោគនោះ ក្នុងថ្ងៃស្អែក ក៏បរិភោគភោជនត្រឹមប៉ុណ្ណោះ មហាបពិត្រ បុរសនោះ ចាត់ថាជាអ្នកមានសេចក្តីសុខ បាន ឬមិនបាន ដូច្នេះ ។ ស្តេចមិលិន្ទ ត្រាស់ឆ្លើយថា លោកម្ចាស់ដ៏ចម្រើន បុរសនោះ បរិភោគគ្រាតែមួយមិនគប្បី

ស្តាប់បាន ដូច្នេះ ។ ព្រះនាគសេនថ្វាយព្រះពរថា មហាបពិត្រ ប្រការនេះ ក៏ដូច្នោះដែរ ម៉ឺនលោកធាតុនេះ ទ្រទ្រង់ព្រះពុទ្ធទុកបានតែមួយព្រះអង្គ ។ល។ មិនគប្បីចូលដល់សេចក្តីតាំងនៅបានឡើយ ដូច្នេះ ។ ស្តេចមិលិន្ទត្រាស់ថា ព្រះនាគសេនដ៏ចម្រើន ផែនដីរមែងញ័រដោយធម៌ដែលធ្ងន់ក្រៃលែងយ៉ាងណាហ្ន៎ ។ ព្រះនាគសេនថ្វាយព្រះពរថា មហាបពិត្រ ក្នុងលោកនេះ រទេះ ២ គ្រឿងផ្ទុកដោយរតនៈដរាបពេញទ្រុង អ្នកទាំងឡាយ ក៏នាំគ្នាជញ្ជូនយករតនៈ ពីរទេះមួយមកចាក់ទុកក្នុងរទេះមួយទៀត មហាបពិត្រ រទេះនោះ នឹងគប្បីធានារតនៈរបស់រទេះទាំងពីរគ្រឿងនោះ ទុកបានឬទេ ដូច្នេះ ។ ស្តេចមិលិន្ទត្រាស់ថា លោកម្ចាស់ដ៏ចម្រើន រទេះនោះ រមែងធានាទុកមិនបានទេ ដុំរបស់រទេះនោះគប្បីញ័រខ្លះ កាំរបស់រទេះនោះ គប្បីបាក់ទៅខ្លះ ភ្លៅរបស់រទេះនោះ គប្បីទៅខ្លះ ដូច្នេះ ។ ព្រះនាគសេនទូលសួរថា រទេះរមែងបាក់ទៅ ព្រោះការផ្ទុករតនៈដែលច្រើនពេកទៅ មែនឬមិនមែន ។ ស្តេចមិលិន្ទ ត្រាស់ឆ្លើយថា មែនហើយ លោកម្ចាស់ដ៏ចម្រើន ដូច្នេះ ។ ព្រះនាគសេនថ្វាយព្រះពរថា មហាបពិត្រ ប្រការនេះ ក៏មានឧបមេយ្យដូច្នោះ ដូចគ្នា ផែនដីរមែងញាប់ញ័រ ដោយធម៌ដ៏ធ្ងន់ក្រៃលែង ។

មយ៉ាងទៀត មហាបពិត្រ ហេតុនេះ ជាការរួមចុះក្នុងការសម្តែងព្រះកម្លាំង នៃព្រះពុទ្ធ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ហេតុដែលសមគួរយ៉ាងដទៃ ក្នុងការសម្តែងកម្លាំងរបស់ព្រះពុទ្ធនោះ ព្រោះហេតុយ៉ាងណា ព្រះសម្មាសម្ពុទ្ធ ២ ព្រះអង្គ ទ្រង់ទើបមិនឧប្បត្តិឡើងក្នុងខណៈតែមួយ បើព្រះសម្មាសម្ពុទ្ធ ពីរព្រះអង្គ ស្តេចឧប្បត្តិឡើងក្នុងខណៈជាមួយគ្នាសោត ការឈ្លោះវិវាទ របស់បរិស័ទគប្បីកើតឡើង មនុស្សទាំងឡាយ ក៏នឹងមានជាពីរចំណែក ដោយពោលថា ព្រះពុទ្ធរបស់ពួកលោក ព្រះពុទ្ធរបស់ពួកយើង ដូច្នេះ មហាបពិត្រ ប្រៀបដូចបរិស័ទនៃអាមាត្យអ្នកមានកម្លាំងពីរនាក់ គប្បីកើតការវិវាទគ្នា អ្នកទាំងនោះក៏នឹងជាពីរចំណែក ដោយពោលថា អាមាត្យរបស់ពួកលោក អាមាត្យរបស់ពួកយើង ដូច្នេះ យ៉ាងណា មហាបពិត្រ ប្រការនេះកដូច្នោះដូចគ្នាដែរ ប្រសិនបើថា ព្រះសម្មាសម្ពុទ្ធ ២ ព្រះអង្គ គប្បីស្តេចឧប្បត្តិឡើងក្នុងខណៈជាមួយគ្នាសោត ការវិវាទរបស់បរិស័ទ គប្បីកើតឡើងបាន និងមនុស្សទាំងឡាយ ក៏នឹងទៅជាពីរចំណែក ដោយពោលថា ព្រះពុទ្ធរបស់ពួកលោក ព្រះពុទ្ធរបស់ពួកយើង ដូច្នេះ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ហេតុទី ១ នេះ ដោយហេតុណា ព្រះសម្មា-

សម្ពុទ្ធ ២ ព្រះអង្គ ទ្រង់ទើបមិនឧប្បត្តិឡើងក្នុងខណៈជាមួយគ្នា សូមព្រះអង្គទ្រង់ព្រះសណ្ដាប់ហេតុដែលក្រៅលែងសូម្បីយ៉ាងដទៃ ដោយហេតុណា ព្រះសម្មាសម្ពុទ្ធពីរព្រះអង្គ ទ្រង់មិនឧប្បត្តិឡើងក្នុងខណៈជាមួយគ្នា មហាបពិត្រ បើព្រះសម្មាសម្ពុទ្ធ ២ ព្រះអង្គគប្បីឧប្បត្តិឡើងក្នុងខណៈជាមួយគ្នា ពាក្យថា ព្រះពុទ្ធជាបុគ្គលខ្ពង់ខ្ពស់ ក៏រមែងជាពាក្យខុស ពាក្យថា ព្រះពុទ្ធជាបុគ្គលចម្រើនជាទីបំផុត ពាក្យថា ព្រះពុទ្ធជាបុគ្គលប្រសើរបំផុត ពាក្យថា ព្រះពុទ្ធជាបុគ្គលវិសេសបំផុត ពាក្យថា ព្រះពុទ្ធជាបុគ្គលខ្ពង់ខ្ពស់បំផុត ពាក្យថា ព្រះពុទ្ធជាបុគ្គលប្រសើរ ពាក្យថា ព្រះពុទ្ធមិនមានអ្នកស្មើ ពាក្យថា ព្រះពុទ្ធរកអ្នកស្មើដូចមិនបាន ពាក្យថា ព្រះពុទ្ធមិនមានអ្នកស្មើដូច ពាក្យថា ព្រះពុទ្ធរកបុគ្គលប្រៀបមិនបាន ពាក្យថា ព្រះពុទ្ធមិនមានបុគ្គលប្រៀប ដូច្នេះ គប្បីជាពាក្យខុស មហាបពិត្រ សូមព្រះអង្គមេត្តាទ្រង់ព្រមទទួល ហេតុដែលព្រះសម្មាសម្ពុទ្ធពីរព្រះអង្គ ទ្រង់មិនឧប្បត្តិក្នុងខណៈតែមួយ ដោយន័យ ( ដែលនាំមកថ្វាយវិសជ្ជនាហើយ ) ម្យ៉ាងទៀត មហាបពិត្រ ប្រការដែលព្រះពុទ្ធតែមួយព្រះអង្គ ទ្រង់រមែងឧប្បត្តិឡើងក្នុងលោកនេះ ជាសភាពតាមប្រក្រតីរបស់ព្រះពុទ្ធទាំងឡាយ ។ សួរថា

ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះគុណរបស់ព្រះសព្វញ្ញុពុទ្ធទាំងឡាយ មានហេតុក្រៃលែង មហាបពិត្រ គុណដ៏ប្រសើរដ៏ធំក្រៃលែងដទៃនោះ ក៏មានប្រការតែមួយប៉ុណ្ណោះ មហាបពិត្រ ផែនដីធំនោះមានផ្ទាំងតែមួយ សាគរធំមានខ្សែតែមួយ ភ្នំសិនេរុជាភ្នំធំក្រៃលែងមានតែមួយ អាកាសធំមានតែមួយ ស្តេចសក្កៈជាធំមានតែមួយអង្គ ព្រះព្រហ្មជាធំមានតែមួយអង្គ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធជាធំ ក៏មានតែមួយព្រះអង្គប៉ុណ្ណោះ ព្រះអង្គស្តេចឧប្បត្តិឡើងក្នុងទីណា ក្នុងទីនោះ ក៏មិនមានឱកាសដល់ព្រះពុទ្ធទាំងឡាយអង្គដទៃ ដូច្នោះ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធតែមួយព្រះអង្គប៉ុណ្ណោះ រមែងឧប្បត្តិឡើងក្នុងលោក ដូច្នេះ ។ ស្តេចមិលិន្ទបានត្រាស់ថា បពិត្រព្រះនាគសេនដ៏ចម្រើន លោកម្ចាស់បានពោលដោះស្រាយបញ្ហាជាក់ច្បាស់ល្អហើយ ដោយឧបមា ឧបមេយ្យទាំងឡាយ ។

**[៩២-៩៣]** ពីរបទថា ធម្មស្ស ច អនុធម្មំ សេចក្តីថា បដិបទាដែលជាចំណែកខាងដើម ដែលជាធម៌សមគួរដល់លោកុត្តរធម៌ ៩ យ៉ាង បទថា សហធម្មិកោ គឺ ការឆ្លើយឆ្លងដែលមានហេតុ ។

បទថា អាយស្មា ឧទាយិ សេចក្តីថា ព្រះថេរៈឈ្មោះឧទាយី មាន

៣ អង្គ គឺ ព្រះលោឡុទាយី ១ កាឡុទាយី ១ មហាឧទាយី ១ ក្នុងទីនេះ បំណងយកមហាឧទាយី ។ បានឮថា កាលព្រះមហាឧទាយីនោះ ស្តាប់ព្រះសូត្រនេះ តាំងពីដើមដល់ចប់ បីតិ ( មានវណ្ណៈ ៥ ) កើតឡើងក្នុងខាងក្នុង រមែងផ្សាយទៅតាំងពីបាតជើងឡើងទៅដល់ក្បាល តាំងពីក្បាលផ្សាយចុះមកកាន់ដល់បាតជើង ទាំងពីរខាងរួមចុះត្រង់កណ្តាល តាំងពីកណ្តាលផ្សាយទៅទាំងពីរខាង ។ ព្រះមហាឧទាយីនោះ កាលបីតិពាល់ត្រូវទូទៅសរីរៈ ក៏ពោលគុណរបស់ព្រះទសពល ដោយសោមនស្សដ៏មានកម្លាំង ទើបពោលពាក្យជាដើមថា អច្ឆរិយំ ភន្តេ ដូច្នេះជាដើម ។ ភាពជាអ្នកអស់តណ្ហា ឈ្មោះថា ភាពជាអ្នកប្រាថ្នាតិច ។ សេចក្តីគាប់ចិត្តដោយអាការ ៣ យ៉ាង ក្នុងបច្ច័យ ៤ ឈ្មោះថា ភាពជាអ្នកសន្តោស ។ ការជុសខាត់កិលេសគ្រប់យ៉ាង ឈ្មោះថា ភាពជាអ្នកជុសខាត់ ។ បទថា យត្រ ហិ នាម គឺ យោ ហិ នាម ។ បទថា ន អត្តានំ ចាតុករិស្សតិ សេចក្តីថា ទ្រង់មិនធ្វើគុណរបស់ព្រះអង្គឲ្យប្រាកដ ។ បទថា បដាកំ បរិហរេយ្យុំ សេចក្តីថា ពួកអន្យតិរ្ថិយបរិព្វាជកទាំងឡាយ កាលនឹងពោលថា នរណា ជាអ្នកដូចគ្នានឹងយើងមានទេ ដូច្នេះ ក៏លើកទង់សំពត់ឡើង

ត្រាច់ទៅកាន់ក្រុងនាលន្ទា ។ ដោយប្រើនបទថា បស្ស ខោ ត្វំ ឧទាយិ តថាគតស្ស អបរិច្ចតា នេះ ព្រះមានព្រះភាគ ត្រាស់ទទួលពាក្យរបស់ព្រះថេរៈថា ម្នាលឧទាយី អ្នកចូរមើល តថាគតមានសេចក្ដីប្រាថ្នាតិចយ៉ាងណា ។ សួម្បីមិនមានពាក្យសួរថា ព្រោះហេតុអ្វី ព្រះតថាគត ទើបទ្រង់មិនធ្វើព្រះអង្គឲ្យប្រាកដ ទាំងមិនត្រាស់គុណរបស់ព្រះអង្គ ។ គប្បីឆ្លើយថា មិនត្រាស់ក៏ទេ ព្រះអង្គ មិនត្រាស់ពាក្យដែលគួរត្រាស់ដោយគុណមានភាពជាអ្នកប្រាថ្នាតិចជាដើម ព្រោះហេតុនៃលាភ មានចីវរជាដើម ។ ដោយហេតុនោះ ព្រះអង្គទើបត្រាស់ពាក្យជាដើមថា ម្នាលឧទាយី អ្នកចូរមើលការប្រាថ្នាតិចរបស់តថាគត ។ ក៏ព្រះមានព្រះភាគ ទ្រង់អាស្រ័យសត្វអ្នកដែលនឹងត្រាស់ដឹង ទើបត្រាស់ទុកដោយអំណាចវេនេយ្យសត្វ ។ ដូចដែលព្រះអង្គត្រាស់ទុកថា ៖

**អាចារ្យរបស់តថាគតមិនមាន បុគ្គលដូចនឹងតថាគតមិនមាន**

**បុគ្គលអ្នកប្រៀបដោយតថាគត រមែងមិនមាន ក្នុងលោក**

**ព្រមទាំងទេវលោក ។**

គាថាក្ដី ព្រះសូត្រក្ដី ជាច្រើន ដែលជាគ្រឿងសម្ដែងព្រះគុណរបស់

ព្រះតថាគត ក៏គួរឲ្យពិស្តារយ៉ាងនេះ ។

បទថា អភិក្ខណំ ភាសេយ្យាសិ គឺ លោកគប្បីពោលរឿយៗ ។ អធិប្បាយថា កុំពោលក្នុងថ្ងៃត្រង់ជាដើម ព្រោះគិតថា យើងបានពោលក្នុងវេលាព្រឹកហើយ ឬកុំបានពោល ក្នុងថ្ងៃស្អែកនេះជាដើម ព្រោះគិតថា យើងបានពោលក្នុងថ្ងៃនេះហើយ ។

បទថា បវេទេសិ គឺ ពោលហើយ ។ ពីរបទថា ឥមស្ស វេយ្យាករណស្ស សេចក្តីថា ព្រះសូត្រនេះលោកពោលថា វេយ្យាករណ៍ ព្រោះមិនមានគាថា ។ ពាក្យថា អធិវចនំ គឺ ឈ្មោះ ។ ក៏ពាក្យនេះ ព្រះសង្គីតិកាចារ្យ ផ្តើមបទទុកតាំងពីពាក្យថា ឥតិ ហិទំ ។ ពាក្យដ៏សេសក្នុងគ្រប់ៗ បទ មានសេចក្តីច្បាស់លាស់ហើយ ដូច្នេះឯង ។

( ចប់ អដ្ឋកថាសម្បសាទនីយសូត្រ ទី ៥ )

## អដ្ឋកថា បាសាទិកសូត្រ ទី ៦

[៩៨] បាសាទិកសូត្រ មានបទចាប់ផ្តើមថា **ខ្ញុំបានស្តាប់មកយ៉ាងនេះ** នឹងអធិប្បាយនូវបទដែលលំបាកក្នុងបាសាទិកសូត្រនោះ ។ បទថា **ពួកសក្យៈ មានឈ្មោះថា វេធញ្ញា** នោះ សំដៅដល់ ពួកសក្យៈមួយពួក ឈ្មោះ **វេធញ្ញា** សិក្សាការហាត់បាញ់ធ្នូ ។ បទថា **ក្នុងប្រាសាទនាសួនអម្ពវ័នរបស់ពួកសក្យៈទាំងនោះ** អធិប្បាយថា មានប្រាសាទវែង ដែលសាងទុកដើម្បីរៀនសិល្បៈ នាអម្ពវ័នរបស់ពួកសក្យៈទាំងនោះ ព្រះមានព្រះភាគ ប្រថាប់នៅក្នុងសួនអម្ពវ័ននោះ ។

បទថា អធុនា កាលកតោ បានដល់ និគណ្ឋនាដបុត្រធ្វើកាលកិរិយាមួយរំពេច ។ បទថា **កើតការបែកគ្នាជាពីរពួក** គឺ បែកគ្នាជាពីរចំណែក ។ ក្នុងបណ្តាការទាស់ទែងជាដើម ការឈ្លោះគ្នាក្នុងពេលដំបូងជាសេចក្តីទាស់ទែង ការទាស់ទែងនោះបានចម្រើនឡើង ដោយអំណាចការកាន់ដំបងជាដើម និងដោយអំណាចការកន្ទងបញ្ញត្តិ ជាការឈ្លោះ ពាក្យទម្លាយគ្នាដោយន័យ ជាដើមថា លោកមិនដឹងទូទៅដល់ធម្មវិន័យនេះ ជា

វិវាទ ។ បទថា វិគ្គហោ គឺ ចាក់រុក ។ បទថា **ពាក្យរបស់ខ្ញុំមានប្រយោជន៍** គឺ ពាក្យរបស់ខ្ញុំប្រកបដោយអត្ថ ។ បទថា **វត្ថុដែលលោកធ្លាប់ជំនាញ បានប្រែប្រួលទៅហើយ** អធិប្បាយថា យ៉ាងណា ដែលលោកជំនាញមកហើយ គឺ របស់របរប្លន ដោយអំណាចសេវនៈមកអស់កាលជាយូរអង្វែងយ៉ាងនោះ បានប្រែប្រួលទៅហើយ ព្រោះអាស្រ័យវាទៈរបស់ខ្ញុំ ។ បទថា **ខ្ញុំចាប់កំហុសរបស់លោកបានហើយ** គឺ ខ្ញុំបានដាក់កំហុសទុកលើលោក ។ បទថា **លោកចូរត្រាច់ទៅដើម្បីដោះវាទៈ** អធិប្បាយថា លោកចូរកាន់កញ្ចប់បាយ ចូលទៅកាន់ប្រជុំជននោះៗ ហើយ នៅស្វែងរកឲ្យក្រៃលែងៗ ឡើងដើម្បីឲ្យផុតវាទៈ ។ បទថា **ឬលោកចូរកែខ្លួនចេញ** អធិប្បាយថា ម្យ៉ាងទៀត លោកចូរដោះខ្លួនពីទោសដែលយើងលើកឡើង ។ បទថា សចេ បហោសិ ប្រែថា បើអ្នកអាច ។ បទថា វធោយេវ គឺ សម្លាប់នុ៎ះឯង ។ បទថា **ក្នុងពួកនាដបុត្រ** គឺ អន្តេវាសិករបស់នាដបុត្រ ។ បទថា **មានអាការនឿយណាយ** គឺ សាវករបស់និគណ្ឋនាដបុត្រ មានការធុញទ្រាន់ជាសភាព រមែងមិនធ្វើសូម្បីការអភិវាទជាដើម ។

បទថា **លះបង់សេចក្តីស្រឡាញ់** គឺ ប្រាសចាកសេចក្តីស្រឡាញ់ ។

បទថា **ការនឿយណាយ** គឺ មានសេចក្ដីរាថយចាកការធ្វើសេចក្ដីគោរព នៃពួកសាវ័ក របស់និគណ្ឋនាដបុត្រ ។

បទថា ***ដោយហេតុធម្មវិន័យរបស់និគណ្ឋនាដបុត្រ ពោលទុកមិនល្អ*** អធិប្បាយថា បានកើតឡើង ដោយហេតុដែលសាវ័កទាំងនោះ គប្បីជាអ្នកមានសេចក្ដីធុញទ្រាន់ ប្រាសចាកសេចក្ដីស្រឡាញ់ ធុញទ្រាន់ក្នុងធម្មវិន័យ ដែលនិគណ្ឋនាដបុត្រពោលទុកមិនល្អជាដើម ។ បទថា ទុរាក្ខាតេ គឺ ពោលទុកមិនល្អ ។ បទថា ទុប្បវេទិតេ គឺ ទូន្មានមិនល្អ ។ បទថា អនុបសមសំវត្តនិកេ គឺ មិនអាចនឹងធ្វើរាគៈជាដើមឲ្យស្ងប់បាន ។ បទថា ភិន្នថូបេ គឺ មានទីពំនាក់ដែលបែកធ្លាយហើយ ។ ក៏ក្នុងបទនេះ និគណ្ឋនាដបុត្រ ឈ្មោះថា ជាទីពំនាក់ ព្រោះអត្ថថា ជាទីពឹងរបស់សាវ័កទាំងនោះ ។ តែគេបានបែកធ្លាយ គឺ ស្លាប់ហើយ ។ ព្រោះដូច្នោះ លោកទើបពោលថា ជាធម្មវិន័យមានទីពំនាក់ ដែលទម្លាយចេញហើយ ។ បទថា **ជាធម្មវិន័យមិនមានទីពឹងអាស្រ័យ** គឺ ខ្វះទីពឹងអាស្រ័យ ព្រោះមិនមាននិគណ្ឋនាដបុត្រនោះឯង ។

ក៏នាដបុត្រនេះ អាស្រ័យនៅក្នុងក្រុងនាលន្ទាមិនមែនឬ ហេតុអ្វី

គេទើបស្លាប់នៅក្រុងបាវា ។ បានឮថា នាដបុត្រនោះ ស្តាប់ពុទ្ធគុណ ដែលឧបាលីគហបតីអ្នកដឹងច្បាស់សច្ចធម៌ ពោលដោយគាថា ១០ គាថា ទើបក្អួតឈាមចេញមកក្តៅៗ គ្រានោះ សាវកទាំងឡាយ ទើបបាននាំនាដបុត្រ ដែលមិនមានសេចក្តីសប្បាយទៅក្រុងបាវា គេទើបបានស្លាប់ក្នុងទីនោះ មួយទៀត កាលនាដបុត្រ ជិតនឹងស្លាប់ ក៏គិតថា លទ្ធិរបស់យើង ជា លទ្ធិដែលមិននាំចេញទៅបាន ជាលទ្ធិដែលមិនមានសារៈ យើងវិនាសទៅចុះ ដើម្បីកុំឲ្យជនដ៏សេសបានទៅពេញក្នុងអបាយ ក៏ប្រសិនបើយើងនឹង ពោលថា ពាក្យទូន្មានរបស់យើង ជាពាក្យទូន្មានដែលមិននាំចេញទៅបាន ជនទាំងឡាយនឹងមិនជឿ ទោះបីជាយ៉ាងណា យើងមិនគួរឲ្យជនសូម្បីពីរ នាក់ កាន់បែបតែមួយ កាលយើងស្លាប់ទៅ ជនទាំងនោះ នឹងវិវាទគ្នា និងគ្នា ព្រះសាស្តានឹងត្រាស់ធម្មកថា មួយបទអាស្រ័យការវិវាទនោះ បន្ទាប់ពីនោះ ជនទាំងឡាយនឹងដឹងសេចក្តីដែលព្រះសាសនា ជាសាសនា ដែលមានគុណធំ ដូច្នេះ ។ គ្រានោះ អន្តេវាសិកម្នាក់ចូលទៅរកនាដបុត្រ នោះ ហើយពោលថា លោកម្ចាស់ លោកទុព្វលភាពហើយ សូមប្រាប់សារៈ ដែលជាអាចរិយៈប្រមាណក្នុងធម៌នេះ ដល់ខ្ញុំខ្លះចុះ ដូច្នេះ ។ នាដបុត្រ

ពោលថា ម្នាលអ្នកមានអាយុ កាលបើយើងស្លាប់ទៅ អ្នកគប្បីកាន់យកថា " **ទៀង** " ដូច្នេះ ។ អន្តេវាសិកម្នាក់ទៀត ចូលទៅរក ។ នាដបុត្រឲ្យអន្តេវាសិកនោះកាន់ថា " **សូន្យ** " ។

នាដបុត្រ មិនធ្វើឲ្យជនសូម្បីទាំងពីរនាក់ មានលទ្ធិតែម្យ៉ាងដូចគ្នាយ៉ាងនេះហើយ ឲ្យជនជាច្រើនកាន់បែបផ្សេងៗ គ្នា លុះស្លាប់ហើយ ជនទាំងឡាយធ្វើឈាបនកិច្ចនាដបុត្រនោះរួចស្រេច ទើបប្រជុំសួរគ្នាថា ម្នាលអ្នកមានអាយុ អាចារ្យប្រាប់ធម៌ដែលជាសារៈឲ្យដល់អ្នកណា ។ ម្នាក់ក្រោកឡើងពោលថា ដល់យើង ដូច្នេះ ។ប្រាប់ទុកយ៉ាងណា ។ ប្រាប់ថា " **ទៀង** " ម្នាក់ទៀតជំទាស់ ហើយពោលថា អាចារ្យបានប្រាប់ធម៌ដែលជាសារៈដល់យើង ដោយអាការយ៉ាងនេះ ជនទាំងអស់គ្នា ក៏វិវាទគ្នាខ្លាំងក្លាឡើងថា អាចារ្យប្រាប់ធម៌ដែលជាសារៈដល់យើង យើងជាធំ ហើយក៏ដល់ការជេរប្រទេចគ្នា និងធ្វើអាក្រក់ដោយដៃ និងជើងជាដើម មិនរួមផ្លូវគ្នាតែមួយបែកគ្នាទៅផ្លូវម្នាក់មួយ ។

**[៩៤]** បទថា **គ្រានោះឯង ព្រះចុន្ទសមណុទ្ទេស** មានអធិប្បាយថា ព្រះថេរៈរូបនេះ ជាប្អូនរបស់ព្រះធម្មសេនាបតីសារីបុត្រ ភិក្ខុទាំងឡាយ

ហៅលោកថា ព្រះចុន្ទសមណុទ្ទេស ក្នុងកាលជាអនុបសម្បន្ន សូម្បីកាលជាថេរៈ ក៏នៅតែហៅយ៉ាងនោះដូចគ្នា ។ ព្រោះដូច្នោះ ទើបពោលថា ព្រះចុន្ទសមណុទ្ទេស ដូច្នេះ ។ ក្នុងបទទាំងឡាយថា **ព្រះចុន្ទសម-ណុទ្ទេស** នៅចាំវស្សាក្នុងក្រុងបាវា បានចូលទៅរកព្រះអានន្ទដែលនៅក្នុងសាមគ្រាម ដូច្នេះ ព្រោះហេតុអ្វីទើបចូលទៅរក ។ បានឮថា កាលនាដបុត្រស្លាប់ហើយ ពួកមនុស្សក្នុងជម្ពូទ្វីបម្នាក់ៗ នាំគ្នានិយាយតៗ គ្នាក្នុងទីនោះៗ ថា និគណ្ឋនាដបុត្រប្រកាសជាសាស្តាម្នាក់ កាលគេស្លាប់ពួកសាវ័កកើតវិវាទគ្នាដល់បែបនេះ ក៏ព្រះសមណគោតម ប្រាកដហើយក្នុងជម្ពូទ្វីប ដូចព្រះចន្ទ និងព្រះអាទិត្យ សូម្បីព្រះសាវ័ករបស់ព្រះអង្គក៏ប្រាកដហើយដូចគ្នា កាលព្រះសមណគោតមបរិនិព្វានហើយ ពួកសាវ័កនឹងវិវាទគ្នា យ៉ាងណាហ្ន៎ ដូច្នេះ ។ ព្រះថេរៈស្តាប់ពាក្យនោះហើយ គិតថាយើងនឹងនាំពាក្យនេះទៅទូលចំពោះព្រះទសពល ព្រះសាស្តា នឹងធ្វើពាក្យនោះឲ្យជាហេតុកើតរឿងរ៉ាវ ហើយនឹងទ្រង់ទេសនា ១ កណ្ឌ ព្រះថេរៈនោះ ទើបចេញទៅរកព្រះអានន្ទក្នុងសាមគ្រាម ។ បទថា **សាមគាម** ជាឈ្មោះរបស់ស្រុកនោះ ព្រោះមានស្រូវ និងស្រងែច្រើន ។ បទថា **ចូល**

**ទៅរកព្រះអានន្ទ** អធិប្បាយថា ព្រះចុន្ទត្ថេរមិនទៅគាល់ព្រះមានព្រះភាគ ត្រង់តែម្តង ប៉ុន្តែចូលទៅរកព្រះអានន្ទដែលជាឧបជ្ឈាយ៍ ។

បានឮថា ក្នុងសម័យពុទ្ធកាល ព្រះសារីបុត្តត្ថេរ និងព្រះអានន្ទ រាប់អានគ្នាណាស់ ព្រះសារីបុត្តត្ថេររាប់អានព្រះអានន្ទថា ព្រះអានន្ទធ្វើ ឧបដ្ឋាកព្រះសាស្តាដែលយើងគួរធ្វើ ព្រះអានន្ទរាប់អានព្រះសារីបុត្រថា ព្រះសារីបុត្រជាអ្នកប្រសើរជាងសាវ័កទាំងឡាយនៃព្រះមានព្រះភាគ ព្រះ អានន្ទឲ្យក្មេងក្នុងត្រកូលបព្វជ្ជា ហើយឲ្យទទួលការថែរក្សាក្នុងសម្នាក់របស់ ព្រះសារីបុត្រ សូម្បីព្រះសារីបុត្រ ក៏បានធ្វើយ៉ាងនោះដូចគ្នា មានភិក្ខុ ប្រមាណ ១,០០០ រូប មួយរូបៗ បានឲ្យបាត្រ និងចីវររៀងៗ ខ្លួន ហើយ ឲ្យបព្វជ្ជា ឲ្យទទួលការថែរក្សា ។ ព្រះអានន្ទបានសូម្បីចីវរជាដើម ដ៏ ប្រណីតក៏ថ្វាយព្រះថេរៈ ។

បានឮថា ព្រាហ្មណ៍ម្នាក់គិតថា ការបូជាព្រះពុទ្ធរតនៈ និងព្រះ- សង្ឃរតនៈ រមែងប្រាកដច្បាស់ យ៉ាងណាហ្ន៎ ទើបឈ្មោះថា ជាការបូជា ព្រះធម្មរតនៈ ព្រាហ្មណ៍នោះទើបចូលទៅគាល់ព្រះមានព្រះភាគ ទូលសួរ សេចក្តីនោះ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលព្រាហ្មណ៍ ប្រសិនបើ

អ្នកប្រាថ្នានឹងបូជាព្រះធម្មរតនៈ ក៏ចូរបូជាភិក្ខុដែលជាពហុស្សូតមួយរូប ដូច្នេះ ។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់បង្ហាញភិក្ខុដែលជាពហុស្សូតផង ។ អ្នកចូរសួរភិក្ខុសង្ឃចុះ ។ ព្រាហ្មណ៍នោះ ចូលទៅរកភិក្ខុទាំងឡាយ ហើយពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ប្រាប់ភិក្ខុដែលជាពហុស្សូតឲ្យទាន ។ ម្នាលព្រាហ្មណ៍ ព្រះអានន្ទជាពហុស្សូត ព្រាហ្មណ៍ទើបបូជាព្រះថេរៈ ដោយត្រៃចីវរមានតម្លៃមួយពាន់ ព្រះថេរៈបាននាំព្រាហ្មណ៍នោះ ទៅគាល់ព្រះមានព្រះភាគ ព្រះមានព្រះភាគត្រាស់សួរថា អានន្ទអ្នកបានត្រៃចីវរមកពីណា ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រាហ្មណ៍ម្នាក់ប្រគេន តែខ្ញុំព្រះអង្គប្រាថ្នានឹងប្រគេនត្រៃចីវរនេះ ដល់ព្រះសារីបុត្តត្ថេរ ។ ចូរឲ្យចុះអានន្ទ ។ ព្រះសារីបុត្តត្ថេរចេញចារិក ។ អ្នកចូរឲ្យក្នុងវេលាដែលសារីបុត្រត្រឡប់មកវិញ ។ ព្រះអង្គបានបញ្ញត្តិសិក្ខាបទទុកហើយ ។ ក៏សារីបុត្រនឹងមកពេលណា ។ ប្រមាណ ១០ ថ្ងៃទៀត ។ អានន្ទ តថាគតអនុញ្ញាតដើម្បីរក្សាអតិរេកចីវរបាន ១០ ថ្ងៃ យ៉ាងច្រើន ដោយប្រការដូច្នេះ ។ តថាគតបញ្ញត្តិសិក្ខាបទហើយ សូម្បីព្រះសារីបុត្តត្ថេរ បានវត្ថុដែលពេញចិត្តណាមួយ ក៏ប្រគេនវត្ថុនោះ ដល់ព្រះអានន្ទយ៉ាងនោះដូចគ្នា ។

ព្រះសារីបុត្តត្ថេរនោះ បានឲ្យព្រះចុន្ទសមណុទ្ទេស ដែលជាប្អូនរបស់ខ្លួន ជាសទ្ធិវិហារិករបស់ព្រះថេរៈ ព្រោះដូច្នោះ លោកទើបពោលថា ព្រះចុន្ទ-សមណុទ្ទេស ចូលទៅរកព្រះអានន្ទត្ថេរដែលជាព្រះឧបជ្ឈាយ៍ ដូច្នេះ ។ ន័យថា ព្រះចុន្ទសមណុទ្ទេស មានសេចក្ដីគិតយ៉ាងនេះថា ព្រះឧបជ្ឈាយ៍របស់យើងមានបញ្ញាច្រើន លោកនឹងក្រាបទូលពាក្យនេះ ចំពោះព្រះសាស្ដាពេលនោះ ព្រះសាស្ដា នឹងទ្រង់សម្ដែងធម៌អនុរូបដល់កថានោះ ដូច្នេះ បទថា កថាបាភតំ ប្រែថា មូលនៃពាក្យ ។ ពិតហើយ ពាក្យថា **មូល** លោកថា បាភតំ ( ដើមហេតុ ) សមដូចព្រះមានព្រះភាគត្រាស់ទុកថា ៖

អប្បកេនាបិ មេធាវី ចាភដេន វិចក្ខណោ

សមុដ្ឋាបេតិ អត្តានំ អណុំ អគ្គឹវ សន្ធមំ

**អ្នកមានបញ្ញា មានការឃើញច្បាស់លាស់ ញុំាងខ្លួន**

**ឲ្យតាំងនៅបានស្មើដោយទ្រព្យធន សូម្បីមានប្រមាណតិច**

**ដូចបង្កាត់ភ្លើងតិច ដូច្នោះ ។**

បទថា ភគវន្តំ ទស្សនាយ ប្រែថា ដើម្បីឃើញព្រះមានព្រះភាគ ។ មានពាក្យសួរថា ក៏ព្រះអានន្ទត្ថេរនោះ មិនធ្លាប់ឃើញព្រះមានព្រះភាគ

ឬ ។ មិនធ្លាប់ឃើញ ក៏មិនមែន ។ ព្រោះព្រះអានន្ទត្ថេរនេះ ទៅគាល់ព្រះមានព្រះភាគមួយថ្ងៃ ១៨ ដង គឺ ពេលថ្ងៃ ៩ ដង ពេលយប់ ៩ ដង សូម្បីប្រាថ្នានឹងទៅ ១០០ ដង ១.០០០ ដង ចំពោះថ្ងៃក៏មិនទៅ ព្រោះមិនមានហេតុ លោកចាប់លើកបញ្ហាប្រការណាមួយឡើង ហើយទើបទៅគាល់ ក្នុងថ្ងៃនោះ ព្រះអានន្ទត្ថេរនោះ ប្រាថ្នានឹងទៅដោយមូលហេតុនៃកថានោះ ទើបពោលហើយយ៉ាងនេះ ។

## ធម្មវិន័យដែលសាស្តាពោលទុកមិនល្អ

[៩៦] បទថា **ម្នាលចុន្ទ សេចក្តីនេះរមែងមានយ៉ាងនោះ** សេចក្តីថា សូម្បីព្រះអានន្ទត្ថេរ ក្រាបទូលសេចក្តីនោះចំពោះព្រះមានព្រះភាគ ព្រោះព្រះអានន្ទត្ថេរមិនមែនជាម្ចាស់នៃកថានេះ តែព្រះចុន្ទត្ថេរជាម្ចាស់នៃកថាមួយទៀតព្រះចុន្ទត្ថេរនោះ រមែងដឹងខាងដើម កណ្តាល ខាងចុងរបស់កថានោះ ដូច្នោះ ព្រះមានព្រះភាគ កាលនឹងត្រាស់នឹងព្រះចុន្ទត្ថេរនោះ ទើបត្រាស់ពាក្យជាអាទិ៍ថា ឯវញ្ហេតំ ចុន្ទ ហោតិ ដូច្នេះ ។ អធិប្បាយសេចក្តីតទៅថា ម្នាលចុន្ទៈ ការណ៍នេះ រមែងមានយ៉ាងនេះ សាវ័កក្នុង

ធម្មវិន័យ ដែលមានសភាពជាដើមថា ពោលទុកមិនល្អ កើតការបែក
គ្នាជាពីរពួក ធ្វើការទាស់ទែងគ្នាជាដើម ចាក់រុកគ្នាដោយលំពែង គឺ
មាត់ ព្រោះពាក្យទូន្មានដែលនឹងនាំអ្នកបដិបត្តិឲ្យចេញចាកទុក្ខបាន ជាការ
ប្រាកដដោយពាក្យទូន្មាន ដែលមិននាំអ្នកបដិបត្តិឲ្យចេញចាកទុក្ខបាន ក្នុង
កាលឥឡូវនេះ ដូច្នោះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងពាក្យទូន្មាន
ដែលនឹងមិននាំអ្នកបដិបត្តិឲ្យចេញចាកទុក្ខបានអំពីដើម ទើបត្រាស់ពាក្យជា
អាទិ៍ថា **ម្នាលចុន្ទៈ សាស្តាក្នុងលោកនេះ មិនជាសម្មាសម្ពុទ្ធ ដូច្នេះ** ។
ក្នុងបទថា **ប្រព្រឹត្តឃ្លៀងឃ្លាតចាកឈម៌នោះ** គឺ មិនបំពេញជាប់តគ្នា ។
អធិប្បាយថា ប្រព្រឹត្តឃ្លៀងឃ្លាត គឺ ធ្វើឲ្យមានចន្លោះប្រហោង ។ បទថា
**ម្នាលអ្នកមានអាយុ ជាលាភរបស់លោកនោះ** គឺ ការបដិបត្តិធម៌សមគួរ
ដល់ធម៌ជាដើម ទាំងនេះជាលាភរបស់លោកនោះ ។ បទថា **លោកបាន
ល្អហើយ** គឺ លោកបានភាពជាមនុស្សល្អហើយ ។ ក្នុងបទថា **ធម៌ដែល
សាស្តាបេស់លោកសម្តែងហើយ** យ៉ាងណា ។ សាស្តារបស់លោក សម្តែង
ធម៌ទុក ដោយអាការណា ។ បទថា **អ្នកណាបបួល** គឺ អាចារ្យណាបបួល ។
បទថា **បបួលអ្នកណា** គឺ បបួលអន្តេវាសិកណា ។ បទថា **អ្នកណាត្រូវ**

**បបួល** គឺ អន្តេវាសិក ត្រូវបបួលដោយទីបដិបត្តិ ដែលអាចារ្យបបួល ដើម្បីភាពជាយ៉ាងនោះ ។ បទថា **មនុស្សទាំងអស់នោះ** គឺ មនុស្សទាំងបី ពួកនោះ អធិប្បាយថា ក្នុងបុគ្គលទាំង ៣ នេះ អាចារ្យ រមែងជួបធម៌ដែល មិនមែនបុណ្យ ព្រោះជាអ្នកបបួល អន្តេវាសិកអ្នកត្រូវបបួល រមែងជួប ធម៌ដែលមិនមែនបុណ្យ ព្រោះជាអ្នកត្រូវបបួល អ្នកបដិបត្តិរមែងជួបធម៌ ដែលមិនមែនបុណ្យ ព្រោះជាអ្នកបដិបត្តិ ព្រោះដូច្នោះ លោកទើបពោល ថា **បុគ្គលទាំងអស់នោះ** រមែងជួបធម៌ដែលមិនមែនបុណ្យជាច្រើន ។ គប្បីជ្រាបសេចក្តីក្នុងវារៈទាំងអស់ ដោយទំនងនេះ ។

**[៨៧]** មួយទៀត ក្នុងបទនេះថា **បដិបត្តិដើម្បីធម៌ដែលគួរដឹង** គឺ បដិបត្តិតាមហេតុ ។ បទថា **នឹងញុំាងធម៌ដែលគួរដឹងឲ្យសម្រេច** គឺ នឹងញុំាងហេតុឲ្យសម្រេច ។ បទថា **ប្រារព្ធសេចក្តីព្យាយាម** គឺ ធ្វើ សេចក្តីព្យាយាមដែលនឹងឲ្យកើតទុក្ខដល់ខ្លួន ដូចដែលព្រះមានព្រះភាគ ត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ អ្នកណាប្រារព្ធនូវសេចក្តីព្យាយាម ក្នុង
ធម្មវិន័យដែលសាស្តាពោលទុកមិនល្អ អ្នកនោះរមែងនៅជា

ទុក្ខ អ្នកណាខ្ជិលច្រអូស អ្នកនោះរមែងនៅជាសុខ ដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់សម្តែងពាក្យទូន្មាន ដែលមិននាំអ្នកបដិបត្តិឲ្យចេញចាកទុក្ខបាន យ៉ាងនេះហើយ កាលនឹងទ្រង់សម្តែងពាក្យទូន្មានដែលនឹងនាំអ្នកបដិបត្តិឲ្យចេញចាកទុក្ខបានក្នុងកាលឥឡូវនេះ ទើបត្រាស់ពាក្យជាអាទិ៍ថា ម្នាលចុន្ទៈ មួយទៀត សាស្តាក្នុងលោកនេះ រមែងជាព្រះសម្មាសម្ពុទ្ធ ដូច្នេះ ។

[៩៨-៩៩] ក្នុងបទទាំងនោះ បទថា **ជាធម៌ដែលនាំអ្នកបដិបត្តិឲ្យចេញទៅបាន** គឺ នាំទៅដើម្បីប្រយោជន៍នៃមគ្គ និងដើម្បីប្រយោជន៍នៃផល ។ បទថា **ប្រារព្ធសេចក្តីព្យាយាម** គឺ ប្រារព្ធសេចក្តីព្យាយាម ដែលនឹងឲ្យសម្រេចសុខដល់ខ្លួន ដូចព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ អ្នកណាខ្ជិលច្រអូស ក្នុងធម្មវិន័យដែលតថាគតពោលទុកល្អហើយ អ្នកនោះរមែងនៅជាទុក្ខ អ្នកណាមានសេចក្តីព្យាយាមដែលប្រារព្ធហើយ អ្នកនោះរមែងនៅជាសុខ ដូច្នេះ ។

## ពួកសាវកមិនបានដឹងសេចក្តីច្បាស់ក្នុងព្រះសទ្ធម្ម

[១០០] ដោយប្រការដូច្នេះ ព្រះមានព្រះភាគទ្រង់សម្តែងអានិសង្ស

នៃកុលបុត្រអ្នកបដិបត្តិប្រពៃក្នុងពាក្យទូន្មាន ដែលនឹងធ្វើអ្នកបដិបត្តិឲ្យចេញចាកទុក្ខបាន កាលនឹងទ្រង់អធិប្បាយព្រះធម៌ទេសនាទៀត ទើបត្រាស់ពាក្យជាអាទិ៍ថា ម្នាលចុន្ទៈ ក៏ព្រះសាស្ដាឧប្បត្តិឡើងហើយក្នុងលោកនេះដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សាវ័កទាំងឡាយ ជាអ្នកមិនដឹងច្បាស់អត្ថ** គឺ មិនមានបញ្ញាដែលនឹងត្រាស់ដឹងបាន ។

បទថា **ធ្វើឲ្យមានបទដែលរួបរួមទុកព្រមហើយ** គឺ ធ្វើដោយបទដែលរួបរួមទុកទាំងអស់ អធិប្បាយថា មិនមែនរួបរួមទុកតែម្យ៉ាង ។ បាឋៈថា សព្វសង្គាហបទកតំ ដូច្នេះខ្លះ គឺ មិនទៅក្នុងបទដែលរួបរួមទុកទាំងអស់ អធិប្បាយថា មិនសង្គ្រោះចូលជាមួយគ្នា ។ បទថា **ធ្វើឲ្យមានបាដិហារិយ** គឺ ជាធម៌ដែលនាំអ្នកបដិបត្តិឲ្យចេញចាកទុក្ខបាន ។ បទថា **ហេតុដល់ទេវតា និងមនុស្សទាំងឡាយ** គឺ ប្រកាសទុកដោយល្អហើយតាំងពីមនុស្សលោកដរាបដល់ទេវលោក ។ បទថា **រមែងជាហេតុឲ្យក្ដៅក្រហាយ** គឺ ជាអ្នកធ្វើសេចក្ដីក្ដៅក្រហាយក្នុងកាលជាខាងក្រោយ ។

បទថា **សាស្ដារបស់យើងទាំងឡាយ កើតឡើងហើយក្នុងលោកនេះ**

ព្រះមានព្រះភាគត្រាស់ ដើម្បីសម្តែងដល់អាការដែលធ្វើឲ្យក្តៅក្រហាយរបស់សាវកទាំងនោះ ។

[១០១] បទថា **រមែងមិនជាហេតុក្តៅក្រហាយ ក្នុងកាលជាខាងក្រោយ** អធិប្បាយថា ឈ្មោះថា រមែងមិនធ្វើសេចក្តីក្តៅក្រហាយ ក្នុងកាលជាខាងក្រោយ ព្រោះកិច្ចដែលសាវកទាំងឡាយអាស្រ័យព្រះសាស្តា គប្បីសម្រេច បានសម្រេចហើយ ។

[១០២] បទថា ថេរោ បានដល់ អ្នករឹងមាំ គឺ ប្រកបដោយធម៌ដែលធ្វើឲ្យជាអ្នករឹងមាំ ។ ពាក្យថា រត្តញ្ញូ ជាដើម មានសេចក្តីពោលទុកហើយ ។

[១០៣] បទថា ឯតេហិ ចេបិ គឺ ដោយពាក្យទាំងនេះ លោកពោលទុកផ្នែកខាងដើម ។ បទថា **ជាអ្នកសម្រេចធម៌ដ៏ក្សេមចាកយោគៈ** សេចក្តីថា ព្រះអរហត្ត ឈ្មោះថា ជាដែនក្សេមចាកយោគៈក្នុងធម្មវិន័យនេះ ព្រោះព្រះអរហត្តជាដែនក្សេមចាកយោគៈ ៤ សាវកទាំងឡាយសម្រេចព្រះអរហត្តនោះ ។ បទថា **គួរដែលនឹងពោលព្រះសទ្ធម្មបានដោយប្រពៃ** អធិប្បាយថា គប្បីជាអ្នកអាចនឹងពោលព្រះសទ្ធម្មបានដោយប្រពៃ ព្រោះ

រៀនសូត្រមកចំពោះមុខ ។

[១០៤-១០៨] បទថា **ជាអ្នកប្រព្រឹត្តព្រហ្មចារ្យ** គឺ ព្រះអរិយសាវកទាំងឡាយ ជាអ្នកប្រព្រឹត្តព្រហ្មចារ្យហើយ ។ បទថា **ជាអ្នកបរិភោគកាម** គឺ គ្រហស្ថដែលជាព្រះសោតាបន្ន ។ បទទាំងឡាយជាដើមថា ព្រហ្មចារ្យសម្រេចផលនោះ ពិស្តារហើយក្នុងមហាបរិនិព្វានសូត្រនុ៎ះឯង ។

បទថា លាភគ្គយសគ្គប្បត្តំ ប្រែថា ដល់ភាពក្រៃលែងដោយលាភនិងយស ។ បទទាំងឡាយថា ម្នាលចុន្ទៈ ភិក្ខុទាំងឡាយដែលជាថេរៈជាសាវករបស់តថាគតក្នុងកាលឥឡូវនេះមាន ដូច្នេះ អ្នកជាថេរៈក្នុងបទនេះ បានដល់ ព្រះថេរៈមានព្រះសារីបុត្រ និងព្រះមោគ្គល្លានជាដើម ។ បទថា **ភិក្ខុនីទាំងឡាយ** បានដល់ ខេមាថេរី និងឧប្បលវណ្ណាថេរីជាដើម ។ បទទាំងឡាយថា **ឧបាសកទាំងឡាយដែលជាសាវក** ជាគ្រហស្ថស្លៀកពាក់ស ប្រព្រឹត្តព្រហ្មចារ្យ ដូច្នេះ ។ ឧបាសកក្នុងទីនេះ បានដល់ចិត្តគហបតី និងហត្ថកអាឡវកៈ ជាដើម ។ បទថា **អ្នកបរិភោគកាម** បានដល់ ចុល្លអនាថបិណ្ឌិកៈ និងមហាអនាថបិណ្ឌិកៈជាដើម ។ បទថា **ស្ត្រីដែលជាព្រហ្មចារិនី** បានដល់ ស្ត្រីទាំងឡាយ មាននន្ទមាតាជាដើម ។

បទថា **ស្ត្រីដែលបរិភោគកាម** បានដល់ ស្ត្រីទាំងឡាយ មាននាងខុជ្ជុត្តរា ជាដើម បទថា សព្វាការសម្បន្នំ បានដល់ អ្នកដល់ព្រមដោយការណ៍ទាំងពួង ។ បទថា ឥធមេវ តំ សេចក្តីថា បុគ្គលកាលនឹងពោលដល់ព្រហ្មចរិយៈនេះ គឺ ធម៌នេះ គប្បីពោលដោយហេតុ ដោយន័យដ៏ប្រពៃ ។ បទថា ឧទ្ទកស្សុទំ កាត់បទជា ឧទ្ទកោ សុទំ ។

បទថា បស្សំ ន បស្សតិ គឺ បុគ្គលកាលឃើញ ក៏ឈ្មោះថា រមែងមិនឃើញ ។ បានឮថា ឧទ្ទករាមបុត្រនោះ សួរបញ្ហានេះចំពោះមហាជន ។ មហាជនពោលថា លោកអាចារ្យពួកយើងមិនដឹង សូមលោកអាចារ្យមេត្តាប្រាប់ដល់ពួកយើងផង ឧទ្ទករាមបុត្រ ទើបពោលថា បញ្ហានេះជ្រាលជ្រៅ កាលមានអាហារសប្បាយ អាចគិតបានភ្លាម ឆ្លើយភ្លាមតពីនោះមក មហាជនទាំងឡាយនោះ ក៏នាំគ្នាធ្វើសក្ការៈធំរហូតដល់អស់ ៤ ខែ ឧទ្ទករាមបុត្រ កាលនឹងពោលបញ្ហានោះ បានពោលពាក្យជាអាទិ៍ថា បុគ្គលឃើញនូវអ្វី ទើបឈ្មោះថា រមែងមិនឃើញ ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា កាំបិតកោរសំលៀងល្អហើយ គឺ សំលៀងយ៉ាងមុត ក្នុងសេចក្តីនេះ មានអធិប្បាយថា កាំបិតកោរសំលៀងល្អហើយ រមែងប្រាកដ

តែការមុតរបស់កាំបិតកោរមិនប្រាកដ ។

បទថា សន្តម្ម សមាគម្ម គឺ រូបរួម ត្រួតត្រាអត្ថដោយអត្ថ ព្យញ្ជនៈដោយព្យញ្ជនៈនោះ អធិប្បាយថា នាំមកប្រៀបធៀបអត្ថនិងអត្ថ ព្យញ្ជនៈនិងព្យញ្ជនៈ បទថា **គប្បីរូបរួម** គឺ គប្បីប្រាប់បាន គប្បីសូត្របាន ។ បទថា យថយិទំ ព្រហ្មចរិយំ សេចក្តីថា សាសនព្រហ្មចរិយៈទាំងអស់នេះ ។

## ធម្មភាសិតរបស់សង្ឃជាសព្រហ្មចារី

**[១០៩-១១១]** បទថា តត្រ ចេ គឺ ត្រង់កណ្តាលជំនុំសង្ឃនោះ ឬក្នុងភាសិតរបស់សព្រហ្មចារីនោះ ។ ក្នុងបទទាំងឡាយថា លោកអ្នកមានអាយុកាន់យកអត្ថខុស និងលើកព្យញ្ជនៈទាំងឡាយខុស ដូច្នេះ អធិប្បាយថា ក្នុងបទនេះថា សតិប្បដ្ឋាន ៤ រមែងកាន់យកអត្ថថា អារម្មណ៍ គឺ សតិប្បដ្ឋាន លើកព្យញ្ជនៈឡើងថា សតិប្បដ្ឋានានិ ។ បទថា ឥមស្ស គឺ នុ ខោ អាវុសោ អត្ថស្ស សេចក្តីថា ព្យញ្ជនៈទាំងឡាយនេះ គឺ ចត្តារោ សតិប្បដ្ឋានា ឬ ឬថាព្យញ្ជនៈទាំងឡាយនោះ គឺ ចត្តារិ

សតិបដ្ឋានានិ របស់អត្ថថា សតិទាំងឯង គឺ សតិប្បដ្ឋាន ។ បទថា **យ៉ាងណា ទីងសមគួរជាងគ្នា** គឺ ព្យញ្ជនៈទាំងឡាយរបស់អត្ថនេះយ៉ាងណា បទថា **ចូលដល់ជាង** គឺ ណែនជាង ។ បទថា **នៃព្យញ្ជនៈទាំងឡាយនេះ** គឺ អត្ថនេះថា សតិទាំងឯង គឺ សតិប្បដ្ឋានឬ ឬថា អត្ថនោះថា អារម្មណ៍ គឺ សតិប្បដ្ឋាននៃព្យញ្ជនៈទាំងឡាយថា ចត្តារោ សតិប្បដ្ឋានា ។ បទថា **ម្នាលអ្នកមានអាយុ របស់អត្ថនេះ** គឺ របស់អត្ថនេះថា អារម្មណ៍ ជា សតិប្បដ្ឋាន បទថា យានិ ចេវ ឯតានិ សេចក្តីថា ព្យញ្ជនៈទាំងនេះណា ដែលខ្ញុំពោលហើយ ។ បទថា យោ ចេវ ឯសោ សេចក្តីថា សេចក្តីនេះ ណាដែលខ្ញុំពោលហើយ ។ បទថា សោ នេវ ឧស្សាទេតព្វោ សេចក្តីថា ពួកលោកគួរតាំងនៅក្នុងអត្ថ និងក្នុងព្យញ្ជនៈដោយត្រូវសិន តែសព្រហ្មចារី នោះ ពួកលោកមិនគួរត្រេកអរ មិនគួររុកកួន បទថា សញ្ញាបេតព្វោ ប្រែថា គួរឲ្យដឹង ។ បទថា តស្ស ច អត្ថស្ស គឺ នៃអត្ថថា សតិទាំងឯង គឺ សតិប្បដ្ឋាន ។ បទថា តេសញ្ច ព្យញ្ជនានំ គឺ នៃព្យញ្ជនៈថា សតិប្បដ្ឋានា ។ បទថា និសន្តិយា គឺ ដើម្បីពិចារណា ដើម្បីទ្រទ្រង់ទុក ។

**[១១២]** គប្បីជ្រាបសេចក្តីក្នុងវារៈទាំងអស់ ដោយន័យនេះ ។

បទថា នាធិសំ ប្រែថា ដូចនឹងលោក បទថា អត្ថុបេតំ បានដល់ ចូលដល់ដោយអត្ថ គឺ ដឹងនូវអត្ថ បទថា ព្យញ្ជនូបេតំ បានដល់ ចូលដល់ដោយព្យញ្ជនៈ គឺ ដឹងនូវព្យញ្ជនៈ ពួកលោកសរសើរភិក្ខុនោះយ៉ាងនេះពិតហើយ ភិក្ខុនោះមិនឈ្មោះថា ជាសាវ័ករបស់ពួកលោក ម្នាលចុន្ទៈ ភិក្ខុនោះ ឈ្មោះថា ជាព្រះពុទ្ធដោយប្រការដូច្នេះ ព្រះមានព្រះភាគទ្រង់តែងតាំងភិក្ខុពហុស្សុតក្នុងតំណែងរបស់ខ្លួន ។

**[១១៣]** ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្ដែងព្រះធម៌ទេសនាឲ្យក្រៃលែងឡើងៗ ជាងនោះ ទើបត្រាស់ពាក្យជាអាទិ៍ថា ***ម្នាលចុន្ទៈ តថាគតមិនសម្ដែងធម៌ដល់ពួកអ្នក ដើម្បីរារាំងនូវអាសវៈទាំងឡាយដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នប៉ុណ្ណោះទេ*** ដូច្នេះ ។

ក្នុងបទនោះ អាសវៈទាំងឡាយដែលកើតឡើង ព្រោះមានបច្ច័យជាហេតុ ក្នុងលោកនេះ ឈ្មោះអាសវៈប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន អាសវៈទាំងឡាយដែលកើតឡើង ព្រោះមានការទាស់ទែងគ្នាជាហេតុ ក្នុងបរលោក ឈ្មោះថា អាសវៈប្រព្រឹត្តទៅក្នុងកពខាងមុខ ។ បទថា **សង្វរម** គឺ ដើម្បីបិទនូវអាសវៈទាំងនោះ ចូលទៅមិនបាន បទថា បដិឃាតាយ គឺ ដើម្បី

កម្មាត់ ដោយការទម្លាយឫស ។ ក្នុងបទទាំងឡាយថា **តថាគតអនុញ្ញាតចីវរដល់ពួកអ្នក ដើម្បីជាគ្រឿងកម្ចាត់ត្រជាក់** ដូច្នេះ អធិប្បាយថា ចីវរនោះអាចដើម្បីកម្ចាត់ត្រជាក់ដល់ពួកអ្នក សេចក្ដីនេះ ព្រះមានព្រះភាគត្រាស់ទុកថា ចីវរណា ដែលតថាគតអនុញ្ញាតដល់ពួកអ្នក ពួកអ្នកនឹងដណ្ដប់ចីវរនោះ ហើយធ្វើសេចក្ដីសប្បាយក្ដី ប្រកាន់ខ្លួនក្ដី ដូច្នេះ តថាគតមិនអនុញ្ញាត , តែពួកអ្នកដណ្ដប់ចីវរនោះហើយ ធ្វើការកម្ចាត់ត្រជាក់ជាដើម ហើយធ្វើយោនិសោមនសិការសមណធម៌ងាយ ដូច្នេះ តថាគតអនុញ្ញាត , សូម្បីបិណ្ឌបាតជាដើម ក៏មានន័យដូចចីវរ ក៏ការពណ៌នាអនុបទក្នុងទីនេះ គប្បីជ្រាបដោយន័យដែលពោលហើយក្នុងវិសុទ្ធិមគ្គនោះចុះ ។

**[១១៤-១១៦]** បទថា សុខល្លិកានុយោគំ ប្រែថា ប្រកបសេចក្ដីព្យាយាមក្នុងសេចក្ដីសុខ អធិប្បាយថា ភាពជាអ្នកពេញចិត្តក្នុងការសោយសុខ ។ បទថា សុខេ គឺ ធ្វើឲ្យតាំងនៅក្នុងសេចក្ដីសុខ ។ បទថា បីនេតិ គឺ ធ្វើឲ្យឆ្អែតស្កប់ស្កល់ គឺ ឲ្យធាត់ ។

## ការឈប់ប្រព្រឹត្តកន្លងហេតុទាំង ៩ យ៉ាង

**[១១៧]** បទថា អដ្ឋិតធម្មា គឺ ជាបុគ្គលមានសភាព មិនយឺនយូរ ។

បទថា ឋិត្វា នោ អត្ថិ អធិប្បាយថា ប្រាថ្នារឿងណាៗ កាលពោល ដល់រឿងនោះៗ គ្រាខ្លះពោលដល់មគ្គ គ្រាខ្លះពោលដល់ផល គ្រាខ្លះពោល ដល់និព្វាន ។ បទថា ជានតា គឺ ដឹងដោយសព្វញ្ញុតញ្ញាណ ។ បទថា បស្សតា គឺ ឃើញដោយចក្ខុ ៥ ។ បទថា គម្ភីរនេមោ គឺ កប់ជ្រៅទៅ ក្នុងដី ។ បទថា សុនិខាតោ គឺ កប់ណែន ។ បទថា ឯវមេវ ខោ អាវុសោ សេចក្ដីថា ព្រះខីណាស្រពជាអ្នកមិនគួរប្រព្រឹត្តកន្លងឋានៈ ៩ ជាអ្នកមិនញាប់ញ័រ មិនកម្រើកក្នុងការប្រព្រឹត្តកន្លងនោះ ។ ក្នុងការ ប្រព្រឹត្តកន្លងនោះ សូម្បីព្រះអរិយៈទាំងឡាយ មានព្រះសោតាបន្នជាដើម ក៏មិនគួរក្នុងការក្លែងធ្វើសត្វឲ្យដាច់ជីវិតជាដើម ។ បទថា សន្និធិការកំ កាមេ បរិភុញ្ជិតុំ សេចក្ដីថា ដើម្បីធ្វើការសន្សំវត្ថុកាម និងកិលេសកាម ហើយបរិភោគ ។ បទថា **ដូចដែលខ្លួនជាអ្នកគ្រប់គ្រងផ្ទះក្នុងកាលមុន** សេចក្ដីថា មិនគួរបរិភោគដូចដែលខ្លួននៅជាគ្រហស្ថ បរិភោគក្នុងកាល មុន ពិតហើយ ព្រះអរិយៈ មានព្រះសោតាបន្នជាដើម នៅត្រង់កណ្ដាល

ផុះ រមែងតាំងនៅដោយនិមិត្តរបស់គ្រហស្ថរហូតដល់អស់ជីវិត ។ តែព្រះ ទីណាស្រេព សម្រេចព្រះអរហត្តហើយ ជាមនុស្សរមែងបរិនិព្វាន ឬបួស ព្រះទីណាស្រេព មិនតាំងនៅក្នុងកាមាវចរទេវលោកទាំងឡាយ មានចាតុ-ម្មហារាជិកាជាដើមសូម្បីត្រឹមតែមួយក្អែត ព្រោះហេតុអ្វី ព្រោះមិនមាន វិវេក ក៏ប៉ុន្តែថា ព្រះទីណាស្រេពតាំងនៅក្នុងអត្តភាពនៃកុម្មទេវតា សូម្បី សម្រេចព្រះអរហត្តហើយ ក៏តាំងនៅ ក៏បញ្ហានេះមកដល់ដោយអំណាចនៃ ព្រះទីណាស្រេពនោះ គប្បីជ្រាបកិក្ខុការៈរបស់ព្រះទីណាស្រេពនោះ ព្រោះ ទម្លាយទោសៈបានហើយ ។

**[១១៨]** បទថា ***រកត្រើយមិនបាន*** គឺ មិនមានត្រើយ មិនមាន កំណត់ ធំល្ហល្ហេវ បទថា ***ព្រះសមណគោតមមិនបានប្រារព្ធកាលយូរអង្វែង ដែលជាអនាគតទេ*** អធិប្បាយថា ក៏ព្រះសមណគោតម ទ្រង់មិនបានបញ្ញត្តិ យ៉ាងនេះ ព្រោះប្រារព្ធកាលយូរអង្វែង ដែលជាអនាគតទេ ព្រះសមណ-គោតមទ្រង់ជ្រាបតែអតីតប៉ុណ្ណោះ ទ្រង់មិនជ្រាបអនាគតទេ ការពិតនោះ ការរឭកដល់កំណើត ៥៥០ ជាតិ ក្នុងអតីត រមែងប្រាកដដល់ព្រះសមណ-គោតមនោះ ការរឭកដល់ច្រើនយ៉ាងនេះ រមែងមិនប្រាកដក្នុងអនាគត

ពួកបរិព្វាជកអន្យតិរ្ថិយ៍សម្គាល់សេចក្តីនោះដូច្នេះ គប្បីពោលយ៉ាងនោះ ។ បទថា តយិទំ កឹសុ គឺ មិនដឹងអនាគតជាយ៉ាងណា បទថា កថំសុ គឺ ដោយហេតុអ្វីហ្ន៎ ។ អធិប្បាយថា ព្រះសមណគោតម ទ្រង់មិនជ្រាបទេឬអ្វី ទើបទ្រង់មិនរឭកដល់អនាគត គឺថា ព្រោះទ្រង់ប្រាជ្ញានឹងមិនរឭកដល់ ទើបមិនរឭកដល់ ។ បទថា អញ្ញាវិហិតកេន ញាណទស្សនេន សេចក្តីថា ពួកបរិព្វាជកអន្យតិរ្ថិយ៍ រមែងសម្គាល់វត្ថុដែលគប្បីកាន់យក វត្ថុដែលគប្បីបញ្ញត្តិ ជាញាណទស្សនៈដែលប្រព្រឹត្តទៅ ព្រោះប្រារព្ធញាណ-ទស្សនៈដទៃ ដែលជាយ៉ាងដទៃ ដោយញាណដែលជាទស្សនៈ ព្រោះភាពជាអ្នកអាចឃើញ ដូចធ្វើឲ្យប្រចក្ស ដែលជាប្រការដទៃ គឺ ប្រារព្ធញាណទស្សនៈដទៃប្រព្រឹត្តទៅ ពិតហើយ ពួកបរិព្វាជកអន្យតិរ្ថិយ៍ទាំងនោះ រមែងសម្គាល់ញាណទស្សនៈដែលស្ថិតតាំងឡើងហើយ ចំពោះមុខរឿយៗ ដល់អ្នកដើរទៅ ឈរ ដេកលក់ និងភ្ញាក់ ។ ក៏ឈ្មោះថា ញាណ ដូច្នោះ រមែងមិនមាន ព្រោះដូច្នោះ គប្បីជ្រាបបរិព្វាជកអន្យតិរ្ថិយ៍ថា ពួកគេរមែងសម្គាល់ ដូចជាអ្នកល្ងង់មិនឆ្លាត ដូច្នោះ ។

បទថា សតានុសារី បានដល់ ញាណដែលសម្បយុត្តដោយបុព្វេ-

និវាសានុស្សតិ បទថា យាវតកំ អាកង្ខតិ សេចក្តីថា ព្រះតថាគត រមែងបញ្ជូនព្រះញាណទៅថា តថាគតនឹងដឹងស្មើ ដែលប្រាថ្នានឹងដឹង ញាណរបស់ព្រះតថាគតនោះគ្មានអ្វីបិទបាំង គ្មានអ្វីរាំង រមែងស៊ុះទៅដូចកូនសរ ដែលគេបាញ់ទៅក្នុងគំនរស្លឹកឈើពុក ដូច្នោះ ព្រោះដូច្នោះ ព្រះតថាគត រមែងទ្រង់រឭកបានស្មើតាមដែលទ្រង់ប្រាថ្នា ។ បទថា ពោធិជំ ប្រែថា កើតក្បែរគល់ពោធិព្រឹក្ស បទថា ញាណំ ឧប្បជ្ជតិ បានដល់ ចតុមគ្គ-ញាណ រមែងកើត ។ បទថា **ជាតិនេះ ជាជាតិចុងក្រោយ** អធិប្បាយថា ជាតិនេះមានក្នុងទីបំផុត ព្រោះលះហេតុដែលនឹងធ្វើឲ្យមានជាតិ បានដោយញាណនោះ ។ បទថា **ឥឡូវនេះ ភពថ្មីរមែងមិនមាន** អធិប្បាយថា សូម្បីញាណដទៃទៀត ក៏រមែងកើតឡើង ។

## ប្រស្នាដែលព្រះតថាគតទ្រង់ព្យាករ និងមិនព្យាករ

[១១៩] បទថា **មិនប្រកបដោយប្រយោជន៍** សេចក្តីថា មិនអាស្រ័យប្រយោជន៍ក្នុងលោកនេះ ឬប្រយោជន៍ក្នុងលោកមុខ ។ បទថា **ព្រះតថាគតទ្រង់ព្យាករពាក្យនោះ** អធិប្បាយថា ព្រះតថាគត ទ្រង់រមែងមិនពោលដល់

កថាដែលមិននាំអ្នកបដិបត្តិឲ្យចេញចាកទុក្ខបាន ដូចការតយុទ្ធ និងការលួចនាំនាងសេតា ។ បទថា **ពាក្យជារបស់ពិត ជារបស់ប្រាកដ តែមិនប្រកបដោយប្រយោជន៍** សំដៅដល់ តិរច្ឆានកថា មានរាជកថាជាដើម ។ បទថា **ព្រះតថាគតទ្រង់ជាអ្នកជ្រាបកាល** អធិប្បាយថា ព្រះតថាគតទ្រង់រមែងដឹងកាល គឺ ធ្វើឲ្យមានហេតុការណ៍ហើយ ទ្រង់ទើបសម្ដែងក្នុងកាលដល់សេចក្ដីសមគួរ ព្រោះដូច្នោះ ទើបហៅថា **តថាគត** ។ អធិប្បាយថា ធ្វើ ឧ អក្សរឲ្យជា ត អក្សរ ព្រោះត្រាស់ ដោយប្រការដែលគួរត្រាស់ លោកទើបពោលថា **តថាគត** ។

**[១២០]** បទថា ទិដ្ឋំបានដល់ រូបាយតនៈ ។ បទថា សុតំ បានដល់ សទ្ទាយតនៈ ។ បទថា មុតំ បានដល់ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ របស់វត្ថុដែលខ្លួនដឹងហើយ គឺ ដល់ហើយគប្បីកាន់យក ។ បទថា វិញ្ញាតំ បានដល់ ធម្មាយតនៈ មានសុខ និងទុក្ខជាដើម បទថា បត្តំ បានដល់ ស្វែងរកក្ដី មិនស្វែងរកក្ដី សម្រេចហើយ ។ បទថា បរិយេសិតំ បានដល់ ស្វែងរកវត្ថុដែលសម្រេចហើយក្ដី វត្ថុដែលនៅមិនទាន់សម្រេចក្ដី បទថា អនុវិចរិតំ មនសា គឺ ត្រាច់ទៅដោយចិត្ត ។

ទ្រង់សម្តែងបទនេះ ដោយពាក្យនេះថា តថាគតេន អភិសម្ពុទ្ធំ ដូច្នេះ ត្រង់គល់ពោធិ៍ បទថា **តថាគតត្រាស់ដឹងក្រៃលែងហើយ** អធិប្បាយថា ក៏រូបារម្មណ៍ មានពណ៌ខៀវ ពណ៌លឿងជាដើម របស់លោកព្រមដោយទេវលោកនេះ ក្នុងលោកធាតុទាំងឡាយរកប្រមាណមិនបាន យ៉ាងណា រមែងមកកាន់គន្លងនៃចក្ខុទ្វារ សត្វនេះឃើញរូបារម្មណ៍នេះ ក្នុងខណៈនេះ ជាអ្នកពេញចិត្ត ទាស់ចិត្ត ឬមានខ្លួនជាកណ្តាល ដូច្នេះ រូបារម្មណ៍នោះទាំងអស់ ដែលព្រះតថាគតត្រាស់ដឹងក្រៃលែងហើយ ដោយអាការយ៉ាងនេះ ៗ ដូចគ្នា សទ្ទារម្មណ៍ណា មានសំឡេងស្គរ សំឡេងសម្ភោរជាដើម របស់លោកព្រមដោយទេវលោក ក្នុងលោកធាតុទាំងឡាយ ដែលរកប្រមាណមិនបាន រមែងមកកាន់គន្លងនៃសោតទ្វារ គន្ធារម្មណ៍ណា មានក្លិនត្រង់ឫស មានក្លិនត្រង់សំបកជាដើម រមែងមកកាន់គន្លងនៃឃានទ្វារ រសារម្មណ៍ណា មានរសត្រង់ឫស រសត្រង់ដើមជាដើម រមែងមកកាន់គន្លងនៃជិវ្ហាទ្វារ ផោដ្ឋព្វារម្មណ៍ណា ដែលផ្សេងដោយបឋវីធាតុ តេជោធាតុ វាយោធាតុ មានរឹង មានទន់ជាដើម រមែងមកកាន់គន្លងនៃកាយទ្វារ សត្វនេះពាល់ត្រូវផោដ្ឋព្វារម្មណ៍នេះ ក្នុងខណៈនេះ ជាអ្នកពេញចិត្ត ជាអ្នកទាស់ចិត្ត

ឬមានខ្លួនជាកណ្តាល អារម្មណ៍ទាំងអស់នោះ ព្រះតថាគតត្រាស់ដឹងក្រៃលែងហើយ ដោយប្រការដូច្នេះ ។ ដូចគ្នា ធម្មារម្មណ៍ណា ដែលផ្សេងដោយសុខ និងទុក្ខជាដើម របស់លោកព្រមដោយទេវលោកនេះ ក្នុងលោក-ធាតុទាំងឡាយ ដែលរកប្រមាណមិនបាន រមែងមកកាន់គន្លងនៃមនោទ្វារសត្វនេះដឹងច្បាស់ធម្មារម្មណ៍នេះ ក្នុងខណៈនេះ ជាអ្នកពេញចិត្ត ជាអ្នកទាស់ចិត្ត ឬជាអ្នកមានខ្លួនជាកណ្តាល ធម្មារម្មណ៍ទាំងអស់នោះ ដែលព្រះតថាគតត្រាស់ដឹងក្រៃលែងហើយ ដោយប្រការដូច្នេះ ។

ម្នាលចុន្ទៈ តថាគតមិនឃើញ មិនឮ មិនដឹង ឬមិនដឹងច្បាស់ក្នុងវត្ថុដែលមនុស្សទាំងឡាយនេះ ឃើញហើយ ឮហើយ ដឹងហើយ ឬដឹងច្បាស់ហើយរមែងមិនមាន វត្ថុដែលមហាជននេះស្វែងរកហើយសម្រេចក៏មាន វត្ថុដែលមហាជននេះស្វែងរកហើយ មិនសម្រេចក៏មាន វត្ថុដែលមហាជនមិនស្វែងរកហើយសម្រេចក៏មាន វត្ថុដែលមហាជនមិនស្វែងរកហើយមិនសម្រេចក៏មាន សព្វវីទាំងអស់នោះ ឈ្មោះថា ព្រះតថាគតមិនសម្រេចហើយ ទ្រង់មិនធ្វើឲ្យច្បាស់ដោយញាណ រមែងមិនមាន ព្រោះដូច្នោះទើបហៅថា **តថាគត** ដូច្នេះ ដែលហៅថា **តថាគត** ព្រោះកន្លែងដែល

ស្ដេចមិនយាងទៅក្នុងលោក មិនមាន ។ តែក្នុងបាលីពោលថា **អភិសម្ពុទ្ធ** ពាក្យនោះ មានសេចក្ដីស្មើគ្នានឹង **គត** ស័ព្ទ គប្បីជ្រាបសេចក្ដីនៃបទសរុបថា តថាគតោ ក្នុងវារៈទាំងអស់ ដោយន័យនេះ ការពាល់ត្រូវរបស់អត្ថនោះ លោកពោលសេចក្ដីពិស្ដារនៃ **តថាគត** ស័ព្ទ ទុកក្នុងព្រហ្មជាលសូត្រ ។

**[១២១]** ព្រះមានព្រះភាគកាលនឹងទ្រង់បន្លឺព្រះសីហនាទថា តថាគតពោលដល់ភាពជាអ្នករកបុគ្គលស្មើមិនបាន ភាពជាអ្នករកបុគ្គលក្រៃលែងជាង មិនបាន ភាពជាអ្នកដឹងធម៌ទាំងពួង ភាពជាធម្មរាជារបស់ព្រះអង្គយ៉ាងនេះហើយ ឈ្មោះថា មិនដឹង មិនឃើញក្នុងលទ្ធិទាំងឡាយ របស់ពួកសមណព្រាហ្មណ៍ជាច្រើនក្នុងកាលឥឡូវនេះ រមែងមិនមាន ទាំងអស់រមែងប្រព្រឹត្តទៅក្នុងខាងក្នុងញាណរបស់តថាគតតែម្យ៉ាង ដូច្នេះ ទើបត្រាស់ពាក្យជាអាទិ៍ថា **ម្នាលចុន្ទៈ ប្រការនោះជាឋានៈដែលនឹងមានបាន** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា តថាគតោ សំដៅដល់សត្វ ។

**[១២២]** បទថា **ម្នាលអ្នកមានអាយុ ព្រោះថា ប្រការនេះមិនប្រកបដោយអត្ថ** គឺ មិនប្រកបដោយប្រយោជន៍ក្នុងលោកនេះ និងប្រយោជន៍

ក្នុងលោកខាងមុខ ។ បទថា **មិនប្រកបដោយធម៌** គឺ មិនអាស្រ័យនូវលោកុត្តរធម៌ ។ បទថា **មិនជាខាងដើមនៃព្រហ្មចារ្យ** គឺ មិនជាខាងដើមនៃសាសនព្រហ្មចារ្យទាំងអស់ ដែលសង្គ្រោះដោយត្រៃសិក្ខា ក្នុងបទទាំងឡាយថា **នេះជាទុក្ខ** ជាដើម មានអធិប្បាយថា ធម៌ទាំងឡាយប្រព្រឹត្តទៅក្នុងភូមិ ៣ ដ៏សេស វៀរតណ្ហា ព្រះមានព្រះភាគ ទ្រង់ព្យាករណ៍ថា **នេះជាទុក្ខ** , តណ្ហា ជាហេតុចម្រើន ជាហេតុកើតនៃទុក្ខនោះឯង ព្រះមាន-ព្រះភាគទ្រង់ព្យាករណ៍ថា **ជាទុក្ខសមុទ័យ** , ការមិនប្រព្រឹត្តទៅនៃធម៌ទាំងពីរនោះ គឺ ទុក្ខ និងទុក្ខសមុទ័យ ព្រះមានព្រះភាគ ទ្រង់ព្យាករណ៍ថា **ជាទុក្ខនិរោធ** , អរិយមគ្គ គឺ ការដឹងជុំវិញទុក្ខ ការលះសមុទ័យ ការធ្វើឲ្យជាក់ច្បាស់នូវនិរោធ ព្រះមានព្រះភាគទ្រង់ព្យាករណ៍ថា **ជាទុក្ខនិរោធ-គាមិនីបដិបទា** ក្នុងបទទាំងឡាយថា **ម្នាលអ្នកមានអាយុ ប្រការនេះប្រកបដោយប្រយោជន៍** ជាដើម មានអធិប្បាយថា ប្រការនេះអាស្រ័យប្រយោជន៍ក្នុងលោកនេះ និងប្រយោជន៍ក្នុងលោកខាងមុខ អាស្រ័យនូវលោកុត្តរធម៌ជាខាងដើម គឺ ជាប្រធាន គឺ ជាប្រមុខ នៃសាសនព្រហ្មចរិយៈទាំងអស់ ។

[១២៣] ព្រះមានព្រះភាគ កាលទ្រង់បន្ទឹព្រះសីហនាទថា ឥឡូវ

នេះ ពួកបរិព្វាជកអន្យតិរ្ថិយ៍ទាំងឡាយ កុំគប្បីយល់យ៉ាងនេះថា ពាក្យណា ដែលតថាគតមិនព្យាករណ៍ទុក ពាក្យនោះ តថាគតមិនដឹង , ទើបមិនព្យាករណ៍ទុកដូច្នេះ តថាគតដឹងច្បាស់ តែមិនព្យាករណ៍ ព្រោះសូម្បីកាលតថាគតព្យាករណ៍ពាក្យនេះទៅ ក៏មិនមានប្រយោជន៍ ក៏ពាក្យណាដែលតថាគតគួរព្យាករណ៍យ៉ាងណា ពាក្យនោះ តថាគតក៏បានព្យាករណ៍ទុកហើយនុ៎ះឯង ដូច្នេះ ទើបត្រាស់ទៀតថា **ម្នាលចុន្ទៈ ទិដ្ឋិនិស្ស័យសូម្បីពួកណា** ជាអាទិ៍ ។

ទិដ្ឋិទាំងឡាយក្នុងបទនោះ អធិប្បាយថា បានដល់ ទិដ្ឋិនិស្ស័យ ទិដ្ឋិនិស្សិត ទិដ្ឋិគតិ ។ បទថា **ពាក្យនេះឯងពិត** គឺ ពាក្យនេះឯង ជាទស្សនៈដែលពិត ។ បទថា **ពាក្យដទៃជាមោឃៈ** បានដល់ ពាក្យរបស់បុគ្គលដទៃ ជាពាក្យសោះសូន្យទទេ បទថា អសយំការោ ប្រែថា មិនបានធ្វើដោយខ្លួនឯង ។

## អធិប្បញ្ញត្តិនៃសមណព្រាហ្មណ៍ទាំងឡាយ

**[១២៤-១២៧]** បទថា តត្រ បានដល់ សមណៈ និងព្រាហ្មណ៍ទាំង

នោះ បទថា **ម្នាលអ្នកមានអាយុ មានឬហ្ន៎ ដែលអ្នកទាំងឡាយពោលពាក្យនេះ** ដូច្នេះ អធិប្បាយថា តថាគត សួរពួកអ្នកយ៉ាងនេះថា ម្នាលអ្នកមានអាយុ ពាក្យណា ដែលពួកអ្នកពោលហើយថា ខ្លួន និងលោកទៀង ដូច្នេះ ពាក្យនេះមាន ឬមិនមាន ។ បទថា **សមណព្រាហ្មណ៍ទាំងនោះ ពោលពាក្យណា** យ៉ាងនេះ សេចក្តីថា ក៏សមណព្រាហ្មណ៍ទាំងនោះ ពោលពាក្យណាថា ពាក្យនេះឯងពិត ពាក្យដទៃទទេ តថាគតមិនអនុញ្ញាត ពាក្យនោះដល់សមណព្រាហ្មណ៍ទាំងនោះ ។ បទថា **ដោយបញ្ញត្តិ** គឺ ដោយទិដ្ឋិប្បញ្ញត្តិ ។ បទថា **សមល្មម** គឺ សមរម្យដោយញាណដ៏ស្មើ ។ បទថា យទិទំ អធិបញ្ញត្តិ គឺ នេះឈ្មោះ អធិប្បញ្ញត្តិ ។ ក្នុងអធិប្បញ្ញត្តិនេះ តថាគតនុ៎ះឯង ក្រៃលែងជាង មិនមានអ្នកស្មើដោយតថាគត ពាក្យដែលអ្នកពោលដោយបញ្ញត្តិ និងអធិប្បញ្ញត្តិ ទាំងពីរពាក្យនេះ ដូចគ្នាដោយអត្ថ ដោយប្រភេទ មានពីរ គឺ ជាបញ្ញត្តិ អធិប្បញ្ញត្តិ ក្នុងបញ្ញត្តិទាំងពីរនោះ ទិដ្ឋិប្បញ្ញត្តិ ហៅ **បញ្ញត្តិ** , បញ្ញត្តិ ៦ ដែលលោកពោលទុកយ៉ាងនេះ គឺ ខន្ធប្បញ្ញត្តិ ធាតុប្បញ្ញត្តិ អាយតនប្បញ្ញត្តិ ឥន្ទ្រិយប្បញ្ញត្តិ សច្ចបញ្ញត្តិ បុគ្គលប្បញ្ញត្តិ ឈ្មោះ **អធិប្បញ្ញត្តិ** តែក្នុងទីនេះ ពាក្យពោល

ដោយបញ្ញត្តិ សំដៅយកទាំងបញ្ញត្តិ និងអធិបញ្ញត្តិ ពិតណាស់ ព្រះមាន-ព្រះភាគ ទ្រង់ជាអគ្គបុគ្គល រកបុគ្គលដទៃក្រៃលែងជាងគ្មាន ទាំងដោយបញ្ញត្តិ ទាំងដោយអធិប្បញ្ញត្តិ ក្នុងបទថា **អធិប្បញ្ញត្តិ** នេះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា តថាគតតែម្នាក់ ជាបុគ្គលក្រៃលែងក្នុងបញ្ញត្តិ និងអធិប្បញ្ញត្តិ ដូច្នេះ ។

## សតិប្បដ្ឋានទាំង ៤

[១២៨] បទថា បហានាយ គឺ ដើម្បីលះបង់ ។ បទថា សមតិក្កមាយ ជាវេវចនៈរបស់បទនោះ ។ បទថា ទេសិតា ប្រែថា ពោលហើយ ។ បទថា បញ្ញត្តា គឺ តាំងទុកហើយ អធិប្បាយថា កាលធ្វើការចែកវត្ថុដែលជាជុំចេញ ដើម្បីចម្រើនសតិប្បដ្ឋាន បានឃើញវត្ថុទាំងពួងដោយសេចក្តីពិតប្រាកដ ជាការលះទិដ្ឋិនិស្ស័យទាំងអស់ ដោយបង្អានការឃើញថា រមែងមិនចូលទៅទទួលដឹងភាពជាសត្វ ក្នុងគំនរសង្ខារសុទ្ធ ដូច្នេះ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា សតិប្បដ្ឋាន ៤ ដែលតថាគតសម្តែងហើយ បញ្ញត្តិហើយ ដើម្បីលះ ដើម្បីឈានកន្លង

នូវទិដ្ឋិនិស្ស័យ ដូច្នេះ ចំណែកដ៏សេស មានសេចក្តីងាយក្នុងទីទាំងពួង ហើយ ។

" ចប់ អដ្ឋកថា ចាសានិកសូត្រទី ៦ "

ការពណ៌នាសេចក្តីនៃចាជិកវគ្គ

ដែលមាន ៦ សូត្រ ក៏ចប់ស្រេចហើយដែរ ។

សុមង្គលវិលាសិនី អដ្ឋកថា ទីឃនិកាយ ចាជិកវគ្គ បញ្ចមភាគ

" ភាគ ១៨ "

រួមព្រះសូត្រដែលមានក្នុងវគ្គនេះ គឺ

ចាជិកសូត្រ ១ ឧទុម្ពរិកសូត្រ ១ ចក្កវត្តិសូត្រ ១ អគ្គញ្ញសូត្រ ១

សម្បសាទនីយសូត្រ ១ ចាសានិកសូត្រ ១

រួមជា ៦ សូត្រ ។


ខេមរ សន្តិ បរំ ទិព្វំ
ព្រះរាជាណាចក្រកម្ពុជា